# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ  ទុតិយភាគ
# សីលក្ខន្ធវគ្គ
# ១៥



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## DĪGHANIKĀYA DUTIYABHĀGA

## SĪLAKKHANDHAVAGGA

## 15

KŪṬADANTASUTTA MAHĀLISUTTA

JĀLIYASUTTA MAHĀSĪHANĀDASUTTA

POṬṬHAPĀDASUTTA SUBHASUTTA

KEVAṬṬASUTTA LOHICCASUTTA

& TEVIJJASUTTA

សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្ដេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្ដេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្ដីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្ដីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប្ចួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
**This book is strictly for free distribution, it is not for sale.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្ដីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្+ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្+ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ទឹកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ទីឃនិកាយ  ទុតិយភាគ

## សីលក្ខន្ធវគ្គ

១៥

កូដទន្តសូត្រ  មហាលិសូត្រ  ជាលិយសូត្រ

មហាសីហនាទសូត្រ  ពោដ្ឋបាទសូត្រ

សុភសូត្រ  កេវដ្ដសូត្រ

លោហិច្ចសូត្រ

និង  តេវិជ្ជសូត្រ

ព. ស. ២៥០១

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## ទុតិយោ ភាគោ

## សីលក្ខន្ធវគ្គោ

## កូដទន្តសុត្តំ បញ្ចមំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ច-មត្តេហិ ភិក្ខុសតេហិ យេន ខាណុមត្តំ នាម មគធានំ ព្រាហ្មណគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា ខាណុ-មត្តេ វិហរតិ អម្ពលដ្ឋិកាយំ ។ តេន ខោ បន សម-យេន កូដទន្តោ ព្រាហ្មណោ ខាណុមត្តំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។

# សុត្តន្តបិដក ទីឃនិកាយ

# ទុតិយភាគ

# សីលក្ខន្ធវគ្គ

## កូដទន្តសូត្រ ទី ៥

[១] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងមគធជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប ទ្រង់ពុទ្ធដំណើរទៅកាន់ស្រុកព្រាហ្មណ៍ឈ្មោះខានុមត្តៈរបស់មគធជនបទ ។ ឮថា ព្រះមានព្រះភាគទ្រង់នៅក្នុងឧទ្យានឈ្មោះអម្ពលដ្ឋិកា ទៀបខានុមត្តគ្រាមនោះ ។ ក៏ក្នុងសម័យនោះ កូដទន្តព្រាហ្មណ៍អ្នកគ្រប់គ្រងខានុមត្តគ្រាម ដែលជាស្រុកកុះករដោយមនុស្សសត្វ បរិបូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយធញ្ញាហារជាស្រុកព្រះរាជទ្រព្យ ដែលព្រះរាជាមាគធសេនិយពិម្ពិសារ ទ្រង់ព្រះរាជទានជាព្រះរាជអំណោយដ៏ប្រសើរ គឺទ្រង់ប្រទានដោយដាច់ខាត ។

[២] តេន ខោ បន សមយេន កូដទន្តស្ស ព្រាហ្មណស្ស មហាយញ្ញោ ឧបក្ខដោ ហោតិ ។ សត្ត ច ឧសភសតានិ សត្ត ច វច្ឆតរសតានិ សត្ត ច វច្ឆតរិសតានិ សត្ត ច អជសតានិ សត្ត ច ឧរព្ភសតានិ ថូណូបនីតានិ ហោន្តិ យញ្ញត្ថាយ ។ អស្សោសុំ ខោ ខាណុមត្តកា ព្រាហ្មណគហបតិកា ស-មណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ មគធេសុ ចារិកញ្ចរមានោ មហតា ភិក្ខុ-សង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ខាណុមត្តំ អនុប្បត្តោ ខាណុមត្តេ វិហរតិ អម្ពលដ្ឋិកាយំ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្ត-រោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ

[២] សម័យនោះឯង កូដទន្តព្រាហ្មណ៍ កំពុងចាត់ចែងមហាយ័ញ្ញ (ការបូជាធំ) ។ ព្រាហ្មណ៍នោះបានយកគោឈ្មោល ៧០០ កូនគោឈ្មោល ៧០០ កូនគោញី ៧០០ ពពែ ៧០០ កែះ ៧០០ ទៅចងទុកនឹងបង្គោល សម្រាប់យញ្ញពិធី ។ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកខានុមត្ត: បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ទ្រង់ពុទ្ធដំណើរមកកាន់ចារិក ក្នុងមគធជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប បានមកដល់ខានុមត្តគ្រាម គង់នៅក្នុងអម្ពលដ្ឋិកាឧទ្យាន ទៀបខានុមត្តគ្រាម ក៏កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ឮពីរោះខ្ចរខ្ចាយសុះសាយមកយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត ជាសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ព្រះអង្គជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាំងលោកនេះព្រមទាំងទេវលោក មារលោក

សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យា-ណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-ចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ ខានុមត្តកា ព្រាហ្មណ-គហបតិកា ខានុមត្តា និក្ខមិត្វា សង្ឃាសង្ឃីគណី-ភូតា យេន អម្ពលដ្ឋិកា តេនុបសង្កមន្តិ ។

[៣] តេន ខោ បន សមយេន កូដទន្តោ ព្រាហ្ម-ណោ ឧបរិប្បាសាទេ ទិវាសេយ្យំ ឧបគតោ ហោតិ ។ អទ្ទសា ខោ សោ[១] កូដទន្តោ ព្រាហ្មណោ ខានុ-មត្តេ[២] ព្រាហ្មណគហបតិកេ ខានុមត្តា និក្ខមិត្វា សង្ឃាសង្ឃីគណីភូតេ យេន អម្ពលដ្ឋិកា តេនុបសង្ក-មន្តេ ទិស្វា ខត្តំ អាមន្តេសិ កិន្នុ ខោ ភោ ខត្តេ ខានុមត្តកា ព្រាហ្មណគហបតិកា ខានុមត្តា និក្ខមិ-

១ ឱ. ម. សោតិសទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. ខានុមត្តកេ ។

ព្រហ្មលោក ញុំាងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹងផង ព្រះអង្គទ្រង់សំដែងធម៌មានលំអបទដើម លំអបទកណ្តាល លំអបទចុង ព្រះអង្គទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំង-អស់ ការបានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពដូច្នោះ រមែងឲ្យសម្រេចប្រយោជន៍ ។ គ្រានោះ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកខានុមត្តៈ ចេញពីខានុមត្តគ្រាម ជាក្រុម ជាពួក ជាគណៈ ចូលសំដៅទៅកាន់អម្ពលដ្ឋិកាឱទ្យាន ។

[៣] សម័យនោះឯង កូដទន្តព្រាហ្មណ៍ ចូលទៅកាន់ដំណេកវេលាថ្ងៃ ឰដ៏ប្រាសាទជាន់ខាងលើ ។ កូដទន្តព្រាហ្មណ៍នោះបានឃើញពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកខានុមត្តៈ នាំគ្នាចេញពីខានុមត្តគ្រាមជាក្រុម ជាពួក ជាគណៈ ដើរត្រេសង់ចូលទៅកាន់អម្ពលដ្ឋិកាឱទ្យាន លុះបានឃើញហើយ ទើបហៅខត្តាមាត្យមកសួរថា នែខត្តៈដ៏ចម្រើន មានហេតុដូចម្តេច បានជាពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកខានុមត្តៈ នាំគ្នាចេញ

ត្វា សង្ឃាសង្ឃីគណីភូតា យេន អម្ពលដ្ឋិកា តេនុប-
សង្កមន្តីតិ ។ អត្ថិ ខោ ភោ សមណោ គោតមោ
សក្យបុត្តោ សក្យកុលា បព្វជិតោ មគធេសុ ចារិ-
កញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ
ភិក្ខុសតេហិ ខានុមត្តំ អនុប្បត្តោ ខានុមត្តេ វិហរតិ
អម្ពលដ្ឋិកាយំ តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យា-
ណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ
សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ
អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ
ភគវាតិ តមេតេ ភវន្តំ គោតមំ ទស្សនាយ ឧប-
សង្កមន្តីតិ ។ អថខោ កូដទន្តស្ស ព្រាហ្មណស្ស ឯត-
ទហោសិ សុតំ ខោ បន មេតំ សមណោ គោតមោ
តិវិធំ យញ្ញសម្បទំ សោឡសបរិក្ខារំ ជានាតីតិ ន
ខោ បនាហំ ជានាមិ តិវិធំ យញ្ញសម្បទំ សោឡស-
បរិក្ខារំ ឥច្ឆាមិ ចាហំ មហាយញ្ញំ យជិតុំ យន្នូនាហំ

ពីខានុមត្តគ្រាម ជាក្រុម ជាពួក ជាគណៈ ដើរត្រសង់ចូលទៅកាន់អម្ពលដ្ឋិកា-ឱទ្យាន ។ ខត្តាមាត្យជម្រាបថា បពិត្រលោកដ៏ចម្រើន មានសមណៈឈ្មោះគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលមកបួស មានដំណើរមកកាន់ចារិកក្នុងដែនមគធៈព្រមដោយភិក្ខុសង្ឃច្រើនប្រមាណ ៥០០ រូប បានមកដល់ខានុមត្តគ្រាមហើយ នៅក្នុងអម្ពលដ្ឋិកាឱទ្យាន ជិតខានុមត្តគ្រាម កិត្តិ-សព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ឮពីរោះខ្ចរខ្ចាយសុះសាយមកយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំង-ឡាយ ជាព្រះពុទ្ធលែងវិលមកកាន់ភពថ្មីទៀត បពិត្រលោកដ៏ចម្រើនពួកព្រាហ្មណ៍និងគហបតីទាំងនុ៎ះ នាំគ្នាចូលទៅរកព្រះគោតមដ៏ចម្រើននោះ ។ លំដាប់នោះ កូដទន្តព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា អញបានឮពាក្យនេះមកថា ព្រះសមណគោតមទ្រង់ជ្រាបយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ ចំណែកអាត្មាអញមិនបានដឹងយញ្ញសម្បទា ៣ ប្រការដែលមានបរិក្ខារ ១៦ ទេ ប៉ុន្តែអញបម្រុងនឹងបូជានូវមហាយ័ញ្ញ

សមណំ គោតមំ ឧបសង្កមិត្វា តិវិធំ យញ្ញសម្បទំ សោឡសបរិក្ខារំ បុច្ឆេយ្យន្តិ ។ អថខោ កូដទន្តោ ព្រាហ្មណោ ខត្តំ[១] អាមន្តេសិ តេនហិ ភោ ខត្តេ យេន ខាណុមត្តកា ព្រាហ្មណគហបតិកា តេនុបសង្កម ឧបសង្កមិត្វា ខាណុមត្តកេ ព្រាហ្មណគហបតិកេ ឯវំ វទេហិ កូដទន្តោ ភោ ព្រាហ្មណោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ កូដទន្តោបិ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ ឯវំ ភោតិ ខោ សោ[២] ខត្តា កូដទន្តស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ខាណុមត្តកា ព្រាហ្មណគហបតិកា តេនុបសង្កមិ ឧបសង្កមិត្វា ខាណុមត្តកេ ព្រាហ្មណគហបតិកេ ឯតទវោច កូដទន្តោ ភោ ព្រាហ្មណោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ កូដទន្តោបិ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

---

១ ឱ. តំ ខត្តុំ ។ ២ សាតិបិ ។

កូដទន្តសូត្រ រឿងកូដទន្តព្រាហ្មណ៍

បើដូច្នោះ មានតែអាត្មាអញចូលទៅរកព្រះសមណគោតម ហើយសួរនូវយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ ។ ទើបកូដទន្តព្រាហ្មណ៍និយាយនឹងខត្តាមាត្យថា នែខត្តៈដ៏ចម្រើន បើដូច្នោះចូរអ្នកទៅរកពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកខានុមត្តៈ លុះចូលទៅដល់ហើយ ចូរនិយាយនឹងពួកព្រាហ្មណ៍គហបតី អ្នកស្រុកខានុមត្តៈយ៉ាងនេះថា នែអ្នកទាំងឡាយដ៏ចម្រើន កូដទន្តព្រាហ្មណ៍ ផ្តាំមកយ៉ាងនេះថា សូមឲ្យអ្នកដ៏ចម្រើនទាំងឡាយ រង់ចាំផង ដ្បិតកូដទន្តព្រាហ្មណ៍នឹងចូលទៅរកព្រះសមណគោតមដែរ ។ ខត្តាមាត្យនោះ ទទួលពាក្យកូដទន្តព្រាហ្មណ៍ថា បពិត្រលោកដ៏ចម្រើន យ៉ាងនេះឯង ហើយក៏ចូលទៅរកពួកព្រាហ្មណ៍គហបតីអ្នកស្រុកខានុមត្តៈ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងពួកព្រាហ្មណ៍គហបតីអ្នកស្រុកខានុមត្តៈថា នែអ្នកទាំងឡាយដ៏ចម្រើន កូដទន្តព្រាហ្មណ៍ផ្តាំមកយ៉ាងនេះថា សូមឲ្យអ្នកដ៏ចម្រើនទាំងឡាយរង់ចាំផង ដ្បិតកូដទន្តព្រាហ្មណ៍នឹងចូលទៅរកព្រះសមណគោតមដែរ ។

[៤] តេន ខោ បន សមយេន អនេកានិ ព្រាហ្ម-ណសតានិ ខានុមត្តេ បដិវសន្តិ កូដទន្តស្ស ព្រាហ្ម-ណស្ស មហាយញ្ញំ អនុភវិស្សាមាតិ ។ អស្សោសុំ ខោ តេ ព្រាហ្មណា កូដទន្តោ កិរ ព្រាហ្មណោ ស-មណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ អថខោ តេ ព្រាហ្មណា យេន កូដទន្តោ ព្រាហ្មណោ តេនុប-សង្កមឹសុ ឧបសង្កមិត្វា កូដទន្តំ ព្រាហ្មណំ ឯតទវោចុំ សច្ចំ កិរ ភវំ កូដទន្តោ សមណំ គោតមំ ទស្ស-នាយ ឧបសង្កមិស្សតីតិ ។ ឯវំ ខោ មេ ភោ ហោតិ អហំបិ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សាមី-តិ ។ មា ភវំ កូដទន្តោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិ ន អរហតិ ភវំ កូដទន្តោ សមណំ គោត-មំ ទស្សនាយ ឧបសង្កមិតុំ សចេ ភវំ កូដទន្តោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតិ ភោ-តោ កូដទន្តស្ស យសោ ហាយិស្សតិ សមណស្ស គោតមស្ស យសោ អភិវឌ្ឍិស្សតិ យម្បិ ភោតោ កូដទន្តស្ស យសោ ហាយិស្សតិ សមណស្ស គោ-

[៤] សម័យនោះឯង ពួកព្រាហ្មណ៍ច្រើនរយ ដែលនៅអាស្រ័យក្នុងខានុមត្តគ្រាម គិតគ្នាថា យើងនឹងបរិភោគនូវមហាយ័ញ្ញរបស់កូដទន្តព្រាហ្មណ៍ ។ លុះពួកព្រាហ្មណ៍ទាំងនោះបានឮដំណឹងថា កូដទន្តព្រាហ្មណ៍នឹងចូលទៅរកព្រះសមណគោតមដែរ ។ ទើបពួកព្រាហ្មណ៍ទាំងអម្បាលនោះ នាំគ្នាចូលទៅរកកូដទន្តព្រាហ្មណ៍ លុះចូលទៅដល់ហើយក៏និយាយពាក្យនេះនឹងកូដទន្តព្រាហ្មណ៍ថា បានឮថា លោកកូដទន្តៈនឹងចូលទៅរកព្រះសមណគោតម ពិតមែនឬ ។ កូដទន្តព្រាហ្មណ៍ឆ្លើយថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំនិយាយយ៉ាងនេះមែនថា ខ្ញុំឯងនឹងចូលទៅរកព្រះសមណគោតម ។ ព្រាហ្មណ៍ទាំងនោះនិយាយថា លោកកូដទន្តៈកុំចូលទៅរកព្រះសមណគោតមឡើយ លោកកូដទន្តៈ មិនគួរនឹងចូលទៅរកព្រះសមណគោតមទេ បើលោកកូដទន្តៈខំចូលទៅរកព្រះសមណគោតម យសរបស់លោកកូដទន្តៈនឹងសាបសូន្យ យសព្រះសមណគោតមនឹងចម្រើន ប្រសិនបើយសរបស់លោកកូដទន្តៈនឹងសាបសូន្យ យសរបស់ព្រះ

## ៧

### កូដទន្តសុត្តេ  កូដទន្តព្រាហ្មណគុណកថា

តមស្ស យសោ អភិវឌ្ឍិស្សតិ ឥមិនា ចង្គេន[១] ន អរហតិ ភវំ កូដទន្តោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ កូដទន្តំ ទស្សនាយ ឧបសង្កមិតុំ ភវំ ហិ កូដទន្តោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គ-ហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន យម្បិ ភវំ កូដទន្តោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនា ចង្គេន[២] ន អរហតិ ភវំ កូដទន្តោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ កូដទន្តំ ទស្សនាយ ឧបសង្កមិតុំ ភវំ ហិ កូដទន្តោ អឌ្ឍោ មហទ្ធនោ មហាភោគោ បហូតវិត្តូបករណោ បហូតជាតរូបរជតោ

---

១-២ ឱ. ម. បង្គេន ។

កូដទន្តសូត្រ ការពោលអំពីគុណនៃកូដទន្តព្រាហ្មណ៍

សមណគោតមនឹងចម្រើនឡើង ដោយហេតុណា ហេតុនេះបានជាថា លោកកូដទន្តៈ មិនគួរនឹងចូលទៅរកព្រះសមណគោតមទេ គួរតែព្រះសម-ណគោតមទេតើ ទើបគួរចូលមករកលោកកូដទន្តៈវិញ ដ្បិតលោកកូដទន្តៈ មានកំណើតបរិសុទ្ធទាំងពីរចំណែក គឺខាងមាតានិងខាងបិតា ប្រសូតចាក គត៌ដ៏បរិសុទ្ធតាំងអំពីតំណ នៃជីដូនជីតាជាគម្រប់ ៧ មក មិនមានអ្នកណា រិះគន់តិះដៀលបាន ដោយពោលដល់ជាតិកំណើតឡើយ លោកកូដទន្តៈ មានកំណើតបរិសុទ្ធទាំងពីរចំណែក គឺខាងមាតានិងខាងបិតា ប្រសូតចាក គត៌បរិសុទ្ធ តាំងអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មក មិនមានអ្នកណា រិះគន់តិះដៀលបាន ដោយពោលដល់ជាតិកំណើតឡើយ ដោយហេតុ ណា ហេតុនេះបានជាថាលោកកូដទន្តៈ មិនគួរនឹងចូលទៅជួបនឹងព្រះ សមណគោតមទេ គួរតែព្រះសមណគោតមទេតើ ចូលមករកលោក កូដទន្តៈវិញ ដ្បិតថាលោកកូដទន្តៈ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានរបស់ប្រើប្រាស់ច្រើន មានសម្បត្តិច្រើន មានមាសប្រាក់ច្រើន

៨



ភវញ្ហិ កូដទន្តោ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ ភវញ្ហិ កូដទន្តោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អក្ខុទ្ទាវកាសោ ទស្សនាយ ភវញ្ហិ កូដទន្តោ សីលវា វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ ភវញ្ហិ កូដទន្តោ កល្យាណវាចោ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគលាយ អត្ថស្ស វិញ្ញាបនិយា ភវញ្ហិ កូដទន្តោ ពហូនំ អាចរិយបាចរិយោ តីណិ មាណវកសតានិ មន្តេ វាចេសិ ពហូ ខោ បន នានាទិសា នានាជនបទា មាណវកា អាគច្ឆន្តិ ភោតោ កូដទន្តស្ស សន្តិកេ មន្តត្ថិកា មន្តេ អធិយិតុកាមា ភវញ្ហិ កូដទន្តោ ជិណ្ណោ វុឌ្ឍោ មហល្លកោ

ម្យ៉ាងទៀត លោកកូដទន្តៈជាអ្នករាយមន្ត ចេះចាំនូវមន្ត ចេះចប់ត្រៃ-វេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេតុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់៥ ជាអ្នកស្គាល់នូវបទនិងវេយ្យាករណ៍ ជាអ្នកមិនឱនថយគឺស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណាព្យាករណសាស្ត្រ លោកកូដទន្តៈមានរូបល្អ គួររមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរៈស្រដៀងនឹងព្រហ្ម មានសណ្ឋានកាយគួរឲ្យចង់មើលមិនលែង លោកកូដទន្តៈជាអ្នកមានសីល មានសីលដ៏ចម្រើន ប្រកបដោយសីលដ៏ចម្រើន លោកកូដទន្តៈមានសំដីពីរោះ និយាយពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុំាងអ្នកស្តាប់ ឲ្យចូលចិត្តសេចក្តីជាក់លាក់បាន លោកកូដទន្តៈជាអាចារ្យ ជាប្រធានលើអាចារ្យនៃជនច្រើន បានបង្រៀនមន្តមាណព ៣ រយនាក់ មិនតែប៉ុណ្ណោះ ពួកមាណពច្រើននាក់តែងមកអំពីទិសផ្សេង ៗ អំពីជនបទផ្សេង ៗ ជាអ្នកត្រូវការដោយមន្ត ចង់រៀនមន្តក្នុងសំណាក់លោកកូដទន្តៈ លោកកូដទន្តៈជាមនុស្សចាស់ព្រឹទ្ធាចារ្យ មានអាយុច្រើន

៩



អទ្ធគតោ វយោអនុប្បត្តោ សមណោ គោតមោ តរុណោ ចេវ តរុណបព្វជិតោ ច ភវញ្ហិ កូដទន្តោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ ភវញ្ហិ កូដទន្តោ ព្រាហ្មណស្ស បោក្ខរសាតិស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ ភវញ្ហិ កូដទន្តោ ខាណុមតំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ យម្បិ ភវំ កូដទន្តោ ខាណុមតំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ឥមិនា ចង្គេន ន អរហតិ ភវំ កូដទន្តោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ កូដទន្តំ ទស្សនាយ ឧបសង្កមិតុន្តិ ។

រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ឯព្រះសមណគោតម ជាមនុស្សក្មេងផង ទើបនឹងបួសផង មួយទៀត លោកកូដទន្តៈ ព្រះបាទមាគធសេនិយពិម្ពិសារ តែងធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទាំងបោក្ខរសាតិព្រាហ្មណ៍ក៏តែងធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងលោកកូដទន្តៈដែរ មួយវិញទៀត លោកកូដទន្តៈ នៅគ្រប់គ្រងខានុមត្តគ្រាម ដែលជាស្រុកកុះករដោយមនុស្ស សត្វ សម្បូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយធញ្ញាហារ ជាស្រុកព្រះរាជទ្រព្យ ដែលព្រះបាទមាគធសេនិយពិម្ពិសារទ្រង់ប្រទាន ជាព្រះរាជអំណោយដ៏ប្រសើរ លោកកូដទន្តៈនៅគ្រប់គ្រងខានុមត្តគ្រាម ដែលជាស្រុកកុះករដោយមនុស្សសត្វ សម្បូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយធញ្ញាហារ ជាស្រុកព្រះរាជទ្រព្យដែលព្រះបាទមាគធសេនិយពិម្ពិសារប្រទាន ជាព្រះរាជអំណោយដ៏ប្រសើរ ដោយហេតុណា ហេតុនេះបានជាថាលោកកូដទន្តៈ មិនគួរចូលទៅរកព្រះសមណគោតមឡើយ គួរតែព្រះសមណគោតមទេតើ ចូលមករកលោកកូដទន្តៈវិញ ។

[៥] ឯវំ វុត្តេ កូដទន្តោ ព្រាហ្មណោ តេ ព្រាហ្មណេ ឯតទវោច តេនហិ ភោ មមបិ សុណាថ យថា មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ន ត្វេវ អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន យម្បិ ភោ សមណោ គោតមោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនា ចង្គេន ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ មហន្តំ ញាតិសង្ឃំ ឱហាយ បព្វជិតោ សមណោ ខលុ ភោ គោតមោ

[៥] កាលបើពួកព្រាហ្មណ៍ និយាយយ៉ាងនេះហើយ កូដទន្ត-ព្រាហ្មណ៍ ក៏និយាយនឹងព្រាហ្មណ៍ទាំងនោះយ៉ាងនេះថា នៃអ្នកដ៏ចម្រើន បើដូច្នោះអ្នកទាំងឡាយ ចូរស្តាប់ពាក្យខ្ញុំសិន គួរតែយើងចូលទៅរកព្រះគោតមដ៏ចម្រើននោះវិញ មិនគួរព្រះគោតមដ៏ចម្រើននោះ ចូលមករកយើងទេ នៃអ្នកទាំងឡាយដ៏ចម្រើន ឮថាព្រះសមណគោតម មានជាតិបរិសុទ្ធទាំងពីរចំណែក គឺខាងព្រះមាតានិងខាងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធ តាំងពីតំណនៃព្រះអយ្យកោអយ្យិកាជាគម្រប់ ៧ មក មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ នៃអ្នកទាំងឡាយដ៏ចម្រើន ព្រះសមណគោតម មានជាតិបរិសុទ្ធទាំងពីរចំណែក គឺខាងព្រះមាតានិងខាងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធ តាំងពីតំណនៃព្រះអយ្យកោអយ្យិកាជាគម្រប់ ៧ មក មិនមានអ្នកណារិះគន់តិះ-ដៀលដោយពោលដល់ជាតិកំណើតបានឡើយ ដោយហេតុណា ហេតុនេះ មិនគួរឲ្យព្រះគោតមដ៏ចម្រើននេះ ចូលមករកយើងទេ គួរតែយើងរាល់គ្នាចូលទៅរកព្រះគោតមដ៏ចម្រើននោះ ដោយពិត នៃអ្នកទាំងឡាយដ៏ចម្រើន ឮថា ព្រះសមណគោតមព្រះអង្គលះបង់ នូវពពួកញាតិជាច្រើន ចេញទៅទ្រង់ព្រះផ្នួស នៃអ្នកទាំងឡាយដ៏ចម្រើន ឮថា ព្រះសមណគោតម

១១

កូដទន្តសុត្តេ ពុទ្ធគុណកថា

បហូតំ ហិរញ្ញសុវណ្ណំ ឱហាយ បព្វជិតោ ភូមិគតញ្ច[១] វេហាសដ្ឋញ្ច សមណោ ខលុ ភោ គោតមោ ទហរោ វ សមានោ សុសូ[២] កាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អគារ-ស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អកាមកានំ មាតាបិតូនំ អស្សុមុខានំ រុទន្តានំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អភិរូបោ ទស្សនីយោ បាសា-ទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អក្ខុទ្ទាវកាសោ ទស្សនាយ សមណោ ខលុ ភោ គោតមោ សីលវា អរិយ-សីលី កុសលសីលី កុសលសីលេន សមន្នាគតោ សមណោ ខលុ ភោ គោតមោ កល្យាណវាចោ

១ ភូមិគតញ្ចេវាតិបិ ។ ២ ឱ. សុសុ ។ ម. យុវា សុសុ ។

ទ្រង់លះបង់នូវមាសប្រាក់មានប្រមាណច្រើន ដែលឋិតនៅក្នុងផែនដីនិងឋិតនៅក្នុងវេហាស៍ គឺក្នុងប្រាសាទជាន់លើ ចេញទៅទ្រង់ព្រះផ្នួសនៃគ្នាយើង ឮថាព្រះសមណគោតម ព្រះអង្គនៅកំឡោះនៅឡើយ មានព្រះកេសាខ្មៅស្រស់ ប្រកបដោយវ័យដ៏ចម្រើន ឋិតនៅក្នុងបឋមវ័យចេញចាកគេហដ្ឋានទៅបួស ក្នុងភេទជាបុគ្គលមិនមានប្រយោជន៍ ដោយការផ្ទះក្នុងផ្ទះ នៃគ្នាយើង ឮថាព្រះសមណគោតម កាលព្រះវរមាតាបិតាមិនពេញព្រះហឫទ័យ (នឹងការទ្រង់ព្រះផ្នួស) កំពុងមានព្រះភក្ត្រដោកដោយទឹកព្រះនេត្រទ្រង់ព្រះកន្សែងសោយសោក ព្រះអង្គទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់ព្រះកាសាវពស្ត្រ ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួសក្នុងភេទជាបុគ្គលមិនមានប្រយោជន៍ ដោយការផ្ទះក្នុងផ្ទះ នៃគ្នាយើង ឮថាព្រះសមណគោតមមានព្រះរូបល្អ គួរឲ្យរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយព្រះវណ្ណៈដ៏ល្អក្រៃលែង មានព្រះវណ្ណៈស្រដៀងនឹងព្រហ្ម មានព្រះសរីរៈស្រដៀងនឹងព្រហ្ម មានព្រះសណ្ឋានកាយគួរឲ្យចង់មើលមិនលែង នៃគ្នាយើង ឮថាព្រះសមណគោតមទ្រង់មានសីល មានសីលដ៏ប្រសើរ មានសីលជាកុសល ប្រកបដោយសីលជាកុសល នៃគ្នាយើង ឮថាព្រះសមណគោតមមានព្រះវាចាដ៏ពីរោះ មានព្រះពុទ្ធដីកា

កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគលាយ អត្ថស្ស វិញ្ញាបនិយា សមណោ ខលុ ភោ គោតមោ ពហូនំ អាចរិយបាចរិយោ[១] សមណោ ខលុ ភោ គោតមោ ខីណកាមរាគោ វិគតចាបល្លោ សមណោ ខលុ ភោ គោតមោ កម្មវាទី កិរិយវាទី អបាបបុរេក្ខារោ ព្រហ្មញ្ញាយ បជាយ សមណោ ខលុ ភោ គោតមោ ឧច្ចា កុលា បព្វជិតោ អភិន្នខត្តិយកុលា[២] សមណោ ខលុ ភោ គោតមោ អឌ្ឍា កុលា បព្វជិតោ មហទ្ធនា មហាភោគា សមណំ ខលុ ភោ គោតមំ តិរោរដ្ឋា តិរោជនបទា សំបុច្ឆិតុំ អាគច្ឆន្តិ សមណំ ខលុ ភោ គោតមំ អនេកានិ ទេវតាសហស្សានិ បាណេហិ សរណង្គតានិ សមណំ ខលុ ភោ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ

១ ឱ. ពហុន្នំ អាចរិយបាចរិយកោ ។ ២ ម. អសម្ភិន្នក្ខត្តិយកុលា ។

ដ៏ពីរោះ ប្រកបដោយព្រះវាចាជារបស់អ្នកក្រុង ជាព្រះវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុាំងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីច្បាស់លាស់បាន នៃគ្នាយើង ឮថាព្រះសមណគោតម ជាអាចារ្យជាប្រធានលើអាចារ្យរបស់ពួកជនច្រើន នៃគ្នាយើង ឮថាព្រះសមណគោតម អស់កាមរាគហើយ ប្រាសចាកសេចក្តីស្រើបស្រាលហើយ នៃគ្នាយើង ឮថាព្រះសមណ-គោតមជាកម្មវាទី ជាកិរិយវាទី ព្រះអង្គទ្រង់ធ្វើធម៌ដែលគ្មានបាបទុកជាខាងមុខ ក្នុងពួកព្រាហ្មណ៍និងពួកសត្វ នៃគ្នាយើង ឮថាព្រះសមណគោតម ចេញចាកត្រកូលដ៏ខ្ពង់ខ្ពស់ ជាត្រកូលក្សត្រិយ៍ មិនលាយច្រឡំ មកទ្រង់ព្រះផ្នួស នៃគ្នាយើង ឮថាព្រះសមណគោតម ចេញចាកត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន ភោគៈច្រើន មកទ្រង់ព្រះផ្នួស នៃគ្នាយើង ឮថាពួកមនុស្សអ្នកនៅដែនក្រៅ អ្នកនៅជនបទក្រៅ តែងនាំគ្នាមកសាកសួរព្រះសមណគោតម នៃគ្នាយើង ឮថាទេវតាមានពាន់ដ៏ច្រើន បានដល់នូវព្រះសមណគោតម ជាសរណៈស្មើដោយជីវិត នៃគ្នាយើង ឮថាកិត្តិសព្ទសរ-សើរព្រះសមណគោតម ឮពីរោះខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ

១៣

## កូដទន្តសុត្តេ ពុទ្ធគុណកថា

សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សមណោ ខលុ ភោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នាគតោ សមណោ ខលុ ភោ គោតមោ ឯហិស្វាគតវាទី សខិ-លោ សម្មោទកោ អព្ភាកុដិកោ ឧត្តានមុខោ បុព្វ-ភាសី សមណោ ខលុ ភោ គោតមោ ចតុន្នំ បរិសានំ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ សម-ណំ ខលុ ភោ គោតមំ ពហូ ទេវា ច មនុស្សា ច អភិប្បសន្នា សមណោ ខលុ ភោ គោតមោ យស្មឹ គាមេ វា និគមេ វា បដិវសតិ ន តស្មឹ គាមេ វា និគមេ វា អមនុស្សា មនុស្សេ វិហេឋេន្តិ សមណោ ខលុ ភោ គោតមោ សង្ឃីគណីគណាចរិយោ បុថុ-តិត្ថករានំ អគ្គមក្ខាយតិ យថា ខោ បន ភោ ឯ-តេសំ សមណព្រាហ្មណានំ យថា វា តថា វា យ-សោ សមុទាគច្ឆតិ ន ហេវំ សមណស្ស គោតមស្ស

ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ បានត្រាស់ដឹងនូវចតុរារិយសច្ចធម៌លែងវិលមកកាន់ភពថ្មីទៀត នៃគ្នាយើងឮថាព្រះសមណ-គោតមប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ នៃគ្នាយើង ឮថាព្រះសមណគោតម តែងពោលថា អ្នកមកចុះល្អហើយ ព្រះអង្គមានព្រះវាចាដ៏ពីរោះ ព្រះអង្គទ្រង់ឈ្លាសក្នុងការសំណេះសំណាល មានព្រះកត្រ្គីកពាយស្រស់ស្រាយ ព្រះអង្គតែងមានព្រះវាចា រាក់ទាក់ជាមុន នៃគ្នាយើង ឮថាព្រះសមណគោតម តែងមានពួកបរិសទ្យទាំង ៤ ធ្វើសក្ការៈគោរព រាប់អាន បូជា កោតក្រែង នៃគ្នាយើង ឮថាពួកទេវតានិងមនុស្សជាច្រើននាំគ្នាជ្រះថ្លាខ្លាំងចំពោះព្រះសមណគោតម នៃគ្នាយើង ឮថាព្រះសមណគោតមគង់អាស្រ័យក្នុងស្រុកណា ឬក្នុងនិគមណា ពួកអមនុស្សក្នុងស្រុកឬក្នុងនិគមនោះ មិនហ៊ានបៀតបៀនមនុស្សឡើយ នៃគ្នាយើង ឮថាព្រះសមណគោតម ជាគណាចារ្យរបស់ពួកក្រុម ព្រះអង្គប្រាកដជាចម្បងជាងពួកមេលទ្ធិទាំងឡាយដ៏ច្រើន នៃគ្នាយើង យសបរិវាររបស់សមណព្រាហ្មណ៍ទុំះ តែងចម្រើនរុងរឿងឡើង ដោយហេតុតាមតែបាន (មានមិនស្មៀកសំពត់ជាដើម) យ៉ាងណា ឯយសបរិវារ របស់ព្រះសម-

យសោ សមុគ្គតោ អជ្ជេ អនុត្តរាយ វិជ្ជាចរណ-សម្បន្នាយ សមណស្ស គោតមស្ស យសោ សមុ-គ្គតោ សមណំ ខលុ ភោ គោតមំ រាជា មាគធោ សេនិយោ ពិម្ពិសារោ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ បាណេហិ សរណាគ្គតោ សមណំ ខលុ ភោ គោតមំ រាជា បសេនទិកោសលោ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ បាណេហិ សរណាគ្គតោ សមណំ ខលុ ភោ គោតមំ ព្រាហ្មណោ បោក្ខរសាតិ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ បាណេហិ សរណាគ្គតោ សមណោ ខលុ ភោ គោតមោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស សក្កតោ គរុក-តោ មានិតោ បូជិតោ អបចិតោ សមណោ ខលុ ភោ គោតមោ រញ្ញោ បសេនទិកោសលស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ សមណោ ខលុ ភោ គោតមោ ព្រាហ្មណស្ស បោក្ខរសាតិស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ សមណោ ខលុ ភោ គោតមោ ខាណុមត្តំ អនុប្បត្តោ

ណាគោតមមិនមែនចម្រើនរុងរឿងឡើងដោយហេតុយ៉ាងនោះទេ តាមដែលពិត យសបរិវាររបស់ព្រះសមណគោតម ចម្រើនរុងរឿងឡើងដោយការបរិបូណ៌ដោយវិជ្ជានិងចរណៈ នៃគ្នាយើង ឮថាព្រះបាទមាគធសេនិយ-ពិម្ពិសារ ព្រមទាំងព្រះរាជបុត្រទាំងអគ្គមហេសី ទាំងបរិសទ្យនិងអមាត្យបានដល់នូវព្រះសមណគោតមជាសរណៈ ស្មើដោយជីវិត នៃគ្នាយើង ឮថាព្រះបាទបសេនទិកោសល ព្រមទាំងព្រះរាជបុត្រនិងអគ្គមហេសីព្រមទាំងបរិសទ្យនិងអមាត្យ បានដល់នូវព្រះសមណគោតមជាសរណៈស្មើដោយជីវិត នៃគ្នាយើង ឮថាព្រាហ្មណ៍បោក្ខរសាតិ ព្រមទាំងបុត្រភរិយា ទាំងបរិសទ្យនិងអមាត្យ បានដល់នូវព្រះសមណគោតម ជាសរណៈស្មើដោយជីវិត នៃគ្នាយើងឮថាព្រះបាទមាគធសេនិយពិម្ពិសារបានធ្វើសក្ការៈគោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតមហើយ នៃគ្នាយើងឮថាព្រះបាទបសេនទិកោសល បានធ្វើសក្ការៈ គោរព រាប់អាន បូជាកោតក្រែងព្រះសមណគោតមហើយ នៃគ្នាយើង ឮថាព្រាហ្មណ៍បោក្ខ-រសាតិ បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោ-តមហើយ នៃគ្នាយើង ឮថាព្រះសមណគោតមបានដល់ខានុមត្តគ្រាម

ខាណុមត្តេ វិហរតិ អម្ពលដ្ឋិកាយំ យេ ខោ បន កេចិ សមណា វា ព្រាហ្មណា វា អម្ហាកំ គាមក្ខេត្តំ អាគច្ឆន្តិ អតិថី នោ តេ ហោន្តិ អតិថី ខោ បនម្ហេហិ សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វា អបចេតព្វា អយំ(១) ខោ សមណោ គោតមោ ខាណុមត្តំ អនុប្បត្តោ ខាណុមត្តេ វិហរតិ អម្ពលដ្ឋិកាយំ អតិថិ អម្ហាកំ សមណោ គោតមោ អតិថិ ខោ បនម្ហេហិ សក្កាតព្វោ គរុកាតព្វោ មានេតព្វោ បូជេតព្វោ អបចេតព្វោ ឥមិនា ចង្គេន ន អរហតិ សោ ភវំ សមណោ(២) គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ឯត្តកេ ខោ អហំ ភោតោ គោតមស្ស វណ្ណេ បរិយាបុណាមិ នោ ច ខោ សោ ភវំ គោតមោ ឯត្តកវណ្ណោ អបរិមាណវណ្ណោ ហិ សោ ភវំ គោតមោតិ ។

១ ឱ. យម្បិភោ ។ ម. យំបិខោ ។ ២ ឱ. ម. សមណោតិ ន ទិស្សតិ ។

ហើយ ឥឡូវនេះគង់ក្នុងអម្ពលដ្ឋិកាឱទ្យានទៀបខានុមត្តគ្រាម ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមកដល់គាមក្ខេត្ររបស់យើងហើយ ពួកសមណព្រាហ្មណ៍ទាំងនោះ សុទ្ធតែជាភ្ញៀវរបស់យើង ភ្ញៀវហ្នឹងឯងត្រូវយើងធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រះសមណគោតមនេះឯង បានមកដល់ខានុមត្តគ្រាមហើយ ឥឡូវគង់នៅក្នុងអម្ពលដ្ឋិកាឱទ្យានទៀបខានុមត្តគ្រាម ព្រះសមណគោតម ជាភ្ញៀវរបស់យើង ភ្ញៀវហ្នឹងឯងត្រូវតែយើងធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ដោយហេតុនេះហើយ បានជាមិនគួរ ឲ្យព្រះសមណគោតមដ៏ចម្រើននោះចូលមករកយើងទេ ពួកយើងទេតើ ទើបគួរនឹងចូលទៅរកព្រះគោតមដ៏ចម្រើននោះវិញ ខ្ញុំដឹងគុណ (ដែលគួរសរសើរ) របស់ព្រះសមណគោតមត្រឹមតែប៉ុណ្ណេះឯង តែព្រះគោតមដ៏ចម្រើននោះ មិនមែនមានគុណដែលគួរសរសើរត្រឹមតែប៉ុណ្ណេះទេ ព្រោះព្រះគោតមដ៏ចម្រើននោះមានគុណនឹងរាប់នឹងប្រមាណពុំបានឡើយ ។

[៦] ឯវំ វុត្តេ តេ ព្រាហ្មណា កូដទន្តំ ព្រាហ្មណំ ឯតទវោចុំ យថា ខោ ភវំ កូដទន្តោ សមណស្ស គោតមស្ស វណ្ណំ ភាសតិ ឥតោ ចេបិ សោ ភវំ គោត-មោ យោជនសតេ វិហរតិ អលមេវ សទ្ធេន កុលបុត្តេន ទស្សនាយ ឧបសង្កមិតុំ អបិ បុដ្ដោសេនាតិ[១] ។ តេន-ហិ ភោ សព្វេ វ មយំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សាមាតិ ។ អថខោ កូដទន្តោ ព្រាហ្មណោ មហតា ព្រាហ្មណគណេន សទ្ធឹ យេន អម្ពលដ្ឋិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ បន ខានុមត្តកា[២] ព្រាហ្មណគហបតិកា អប្បេកច្ចេ ភគ-វន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ

---

១ ឱ. បុដំសេនាបិ ។ ម. ផុដោសេនាបិ ។ ២ ឱ. ម. ឯកមន្តំ និសិន្នា ខោ បនាតិ ឥមេ បាឋា ន ទិស្សន្តិ ។ ខានុមត្តកាបិ ខោតិ ទិស្សតិ ។

[៦] លុះកូដទន្តព្រាហ្មណ៍និយាយយ៉ាងនេះហើយ ពួកព្រាហ្មណ៍ទាំងនោះ ក៏និយាយពាក្យនុ៎ះនឹងកូដទន្តព្រាហ្មណ៍ថា អម្បាលយ៉ាងលោកកូដទន្តៈម្តេចគង់ពោលសរសើរគុណព្រះសមណគោតម ទោះបីព្រះសមណគោតមដ៏ចម្រើន គង់នៅក្នុងទីប្រមាណ ១០០ យោជន៍អំពីទីនេះក្តី គួរណាស់តែកុលបុត្រដែលមានសទ្ធា រកស្បៀងយកទៅតាមផ្លូវ ដើម្បីនឹងទៅគាល់ឲ្យបាន ។ ព្រាហ្មណ៍ទាំងនោះក៏និយាយគ្នាថា នៃគ្នាយើង បើដូច្នោះ យើងទាំងអស់គ្នានឹងចូលទៅគាល់ព្រះសមណគោតម ។ គ្រានោះកូដទន្តព្រាហ្មណ៍ ព្រមដោយពួកព្រាហ្មណ៍ច្រើននាក់ ក៏ចូលទៅកាន់អម្ពលដ្ឋិកាឱទ្យាន សំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះពួកព្រាហ្មណ៍គហបតីអ្នកស្រុកខានុមត្តៈអង្គុយក្នុងទីដ៏សមគួរស៊ប់ហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលពាក្យសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹក

វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ កូដទន្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតំ មេតំ ភោ គោតម សមណោ គោតមោ តិវិធំ យញ្ញ-សម្បទំ សោឡសបរិក្ខារំ ជានាតីតិ ន ខោ បនាហំ ជានាមិ តិវិធំ យញ្ញសម្បទំ សោឡសបរិក្ខារំ ឥច្ឆាម-ហំ[១] មហាយញ្ញំ យជិតុំ សាធុ មេ ភវំ គោតមោ តិវិធំ យញ្ញសម្បទំ សោឡសបរិក្ខារំ ទេសេតូតិ ។

[៧] តេនហិ ព្រាហ្មណ សុណាហិ[២] សាធុ-កំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ កូដទន្តោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ភូតបុព្វំ ព្រាហ្មណ រាជា មហា-វិជិតោ នាម អហោសិ អឌ្ឍោ មហទ្ធនោ មហា-ភោគោ បហូតជាតរូបរជតោ បហូតវិត្តូបករណោ

---

១ ឱ. ម. ឥច្ឆាមិ ចាហំ ។ ២ ឱ. សុណោហិ ។

ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ផ្គងអញ្ជលីសំដៅទៅរកព្រះមានព្រះភាគអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ប្រកាសនាមនិងគោត្រហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ លុះកូដទន្តព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរស៊ប់ហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណគោតម ចេះយញ្ញសម្បទា ៣ ប្រការ មានបរិក្ខារ ១៦ មែនឬ ខ្ញុំព្រះអង្គមិនចេះយញ្ញសម្បទា ៣ ប្រការ មានបរិក្ខារ ១៦ទេ តែខ្ញុំព្រះអង្គប្រាថ្នាដើម្បីនឹងបូជាមហាយ័ញ្ញ សូមព្រះគោតមដ៏ចម្រើន មេត្តាប្រោសសំដែងយញ្ញសម្បទា ៣ ប្រការ មានបរិក្ខារ ១៦ ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[៧] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះចូរអ្នកចាំស្តាប់ចូរអ្នកធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ កូដទន្តព្រាហ្មណ៍ក៏ទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលពីព្រេងនាយ មានមហាក្សត្រិយ៍មួយព្រះអង្គព្រះនាមមហាវិជិត ជាស្តេចស្តុកស្តម្ភ មានព្រះរាជទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានទ្រព្យនិងគ្រឿងឧបករណ៍ច្រើន

បហូតធនធញ្ញោ បរិបុណ្ណកោសកោដ្ឋាគារោ ។ អថខោ ព្រាហ្មណ រញ្ញោ មហាវិជិតស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អធិគតា ខោ មេ វិបុលា មានុសកា ភោគា មហន្តំ បឋវីមណ្ឌលំ អភិវិជិយ អជ្ឈាវសាមិ យន្នូនាហំ មហាយញ្ញំ យជេយ្យំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ ព្រាហ្មណ រាជា មហាវិជិតោ បុរោហិតំ ព្រាហ្មណំ អាមន្តេត្វា ឯតទវោច ឥធ មយ្ហំ ព្រាហ្មណ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អធិគតា ខោ មេ វិបុលា មានុសកា ភោគា មហន្តំ បឋវីមណ្ឌលំ អភិវិជិយ អជ្ឈាវសាមិ យន្នូនាហំ មហាយញ្ញំ យជេយ្យំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ឥច្ឆាមហំ ព្រាហ្មណ មហាយញ្ញំ យជិតុំ អនុសាសតុ មំ ភវំ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

មានធញ្ញជាតិ ជាទ្រព្យច្រើន មានជង្រុកនិងឃ្លាំងក៏បរិបូណ៌ ។ ម្នាលព្រាហ្មណ៍ គ្រានោះ ព្រះបាទមហាវិជិត ស្តេចចូលទៅក្នុងទីរហោស្ថាន ជាទីចេញចាកពួក ហើយពួនសម្ងំ មានសេចក្តីត្រិះរិះ កើតឡើងក្នុងព្រះហឫទ័យ យ៉ាងនេះថា ភោគសម្បត្តិទាំងឡាយជារបស់មនុស្សដ៏ពេញបរិបូណ៌ អាត្មាអញបានហើយ ប្រឹថពីមណ្ឌលដ៏ធំទូលាយ អាត្មាអញបានប្រាបប្រាមរួចហើយនៅគ្រប់គ្រង បើដូច្នោះមានតែអាត្មាអញបូជាមហាយ័ញ្ញដែលអាចប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ខ្លួនអញអស់កាលដ៏យូរអង្វែង ។ ម្នាលព្រាហ្មណ៍ លំដាប់នោះ ព្រះបាទមហាវិជិត ត្រាស់ឲ្យហៅព្រាហ្មណ៍បុរោហិតមកហើយ ទ្រង់មានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ យើងបានចូលទៅទីរហោស្ថាន ជាទីចេញចាកពួក ហើយពួនសម្ងំមានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្តយ៉ាងនេះថា ភោគសម្បត្តិទាំងឡាយជារបស់មនុស្សដ៏ពេញបរិបូណ៌ អាត្មាអញបានហើយ ប្រឹថពីមណ្ឌលដ៏ធំទូលាយ អាត្មាអញបានប្រាបប្រាមរួចហើយនៅគ្រប់គ្រង បើដូច្នោះមានតែអាត្មាអញបូជាមហាយ័ញ្ញ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ខ្លួនអញអស់កាលជាយូរអង្វែង ម្នាលព្រាហ្មណ៍ យើងប្រាថ្នាដើម្បីបូជាមហាយ័ញ្ញ ចូរអ្នកដ៏ចម្រើនជួយពន្យល់យើងផង ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់យើងអស់កាលដ៏យូរអង្វែង ។

[៨] ឯវំ វុត្តេ ព្រាហ្មណ បុរោហិតោ ព្រាហ្មណោ រាជានំ មហាវិជិតំ ឯតទវោច ភោតោ ខោ រញ្ញោ ជនបទោ សកណ្ដកោ សឧប្បីឡោ គាមឃាតាបិ ទិស្សន្តិ និគមឃាតាបិ ទិស្សន្តិ នគរឃាតាបិ ទិស្សន្តិ បន្ថទុហនាបិ[១] ទិស្សន្តិ ភវំ ខោ បន[២] រាជា ឯវំ សកណ្ដកេ ជនបទេ សឧប្បីឡេ វលឹ ឧទ្ធរេយ្យ[៣] អកិច្ចការី អស្ស តេន ភវំ រាជា សិយា ខោ បន ភោតោ រញ្ញោ ឯវមស្ស អហមេតំ ទស្សុខិលំ[៤] វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា សមូហនិស្សាមីតិ ន ខោ បនេតស្ស ទស្សុខិលស្ស ឯវំ សម្មា សមុគ្ឃាតោ ហោតិ យេ តេ ហតាវសេសកា ភវិស្សន្តិ តេ បច្ឆា រញ្ញោ ជនបទេ[៥] វិហេឋេស្សន្តិ អបិច ខោ ឥទំ សំវិធានំ អាគម្ម ឯវមេតស្ស ទស្សុខិលស្ស សម្មា សមុគ្ឃាតោ ហោតិ

---

១ ម. បន្ថទូសនាបិ ។ ២ ឱ. ភវញ្ចេ ខោ បន ។ ៣ ឱ. ម. ពលិមុទ្ធរេយ្យ ។ ៤ ឱ. ទស្សុខីលំ ។ ម. ទស្សុខិលំ ។ ៥ ឱ. ម. ជនបទំ ។

[៨] ម្នាលព្រាហ្មណ៍ កាលបើព្រះរាជា ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍បុរោហិត ក៏ក្រាបទូលព្រះបាទមហាវិជិតដូច្នេះថា ជនបទរបស់ព្រះរាជាដ៏ចម្រើន ប្រកបដោយចំរូងគឺចោរ ប្រកបដោចោរបៀតបៀន ពួកចោរសម្លាប់អ្នកស្រុកក៏មាន សម្លាប់អ្នកនិគមក៏មាន សម្លាប់អ្នកនគរក៏មាន ចាំស្កាត់សម្លាប់តាមផ្លូវក៏មាន បើព្រះរាជាដ៏ចម្រើនលើកលែងយកសួយ ក្នុងជនបទដែលប្រកបដោយចម្រូងគឺចោរ ប្រកបដោយចោរបៀតបៀនយ៉ាងនេះ ព្រោះហេតុនោះ ព្រះរាជាដ៏ចម្រើនឈ្មោះថាធ្វើមិនត្រូវតាមទំនៀមទេ មួយទៀត ព្រះរាជាដ៏ចម្រើន តែងទ្រង់ត្រិះរិះយ៉ាងនេះថា អញនឹងដកដង្គត់គឺចោរកំណាចនុ៎ះចេញ ដោយការសម្លាប់ចោលខ្លះ ដោយការឃុំខាំងខ្លះ ដោយរឹបជាន់ឲ្យវិនាសខ្លះ ដោយធ្វើទោសផ្កាល់ខ្លះ ដោយបំបរបង់ខ្លះ យ៉ាងនេះមិនឈ្មោះថា ការដកឡើងនូវដង្គត់គឺចោរនុ៎ះដោយប្រពៃឡើយ (ព្រោះថា) ចោរទាំងឡាយណាដែលនៅសល់អំពីគេសម្លាប់ ចោរទាំងនោះមុខជានឹងបៀតបៀនពួកមនុស្សអ្នកជនបទរបស់ស្តេច ក្នុងកាលជាខាងក្រោយ លុះតែអាស្រ័យការចាត់ចែងដូចតទៅនេះ ទើបឈ្មោះថា ដកដង្គត់គឺចោរនុ៎ះបាន ដោយប្រពៃយ៉ាងនេះ

តេនហិ ភវំ រាជា សិយា ខោ បន[១] យេ ភោតោ រញ្ញោ ជនបទេ ឧស្សហន្តិ កសិគោរក្ខេ តេសំ ភវំ រាជា ពីជភត្តំ អនុប្បទេតុ យេ ភោតោ រញ្ញោ ជនបទេ ឧស្សហន្តិ វណិជ្ជាយ តេសំ ភវំ រាជា ឋាភតំ អនុប្បទេតុ យេ ភោតោ រញ្ញោ ជនបទេ ឧស្សហន្តិ រាជឋោរិសេ តេសំ ភវំ រាជា ភត្តវេតនំ បកប្បេតុ តេ ច មនុស្សា សកម្មបសុតា រញ្ញោ ជនបទំ ន វិហេ-បេស្សន្តិ មហា ច រញ្ញោ រាសិកោ ភវិស្សតិ ខេមដ្ឋិតា ជនបទា អកណ្ដកា អនុប្បីឡា មនុស្សា ច មុទា មោទមានា ឧរេ បុត្តេ នច្ចន្តា អឋារុតឃរា មញ្ញេ វិហរិស្សន្តីតិ ។ ឯវំ ភោតិ ខោ ព្រាហ្មណ រាជា មហាវិជិតោ បុរោហិតស្ស ព្រាហ្មណស្ស បដិស្សុត្វា យេ បន រញ្ញោ ជនបទេ ឧស្សហឹសុ កសិគោរក្ខេ តេសំ រាជា មហាវិជិតោ ពីជភត្តំ អនុប្បទាសិ យេ

១ ឱ. ម. សិយា ខោ បនាតិ ន ទិស្សតិ ។

សូមព្រះរាជាដ៏ចម្រើន (ប្រកបការដូច្នេះ) ពួកជនណាអាចធ្វើស្រែរក្សាគោ ក្នុងជនបទរបស់ព្រះរាជាដ៏ចម្រើន សូមព្រះរាជាដ៏ចម្រើន ប្រទានពូជធារនិង ភត្តាហារដល់ពួកជននោះ ពួកជនណាអាចខ្មីឃ្មាតក្នុងការជួញក្នុងជនបទ របស់ព្រះរាជាដ៏ចម្រើន សូមព្រះរាជាដ៏ចម្រើនប្រទានព្រះរាជទ្រព្យជាដើមទុន ដល់ជនទាំងនោះ ពួករាជបុរសណា ដែលប្រឹងប្រែងធ្វើរាជការក្នុងជន-បទរបស់ព្រះរាជាដ៏ចម្រើន សូមព្រះរាជាដ៏ចម្រើនកំណត់នូវបៀវត្សរ៍ដល់រាជ-បុរសទាំងនោះ ទើបមនុស្សទាំងនោះនឹងខំខ្វល់ខ្វាយ ក្នុងមុខការរបស់ខ្លួន នឹងមិនបៀតបៀននូវជនបទរបស់ព្រះរាជាឡើយ ឯគំនរនៃព្រះរាជទ្រព្យក៏ នឹងមានច្រើនឡើង ពួកអ្នកជនបទក៏តាំងនៅដោយក្សេមក្សាន្ត មិនមាន ចំរូងគឺចោរ មិនមានមនុស្សបៀតបៀនគ្នាឡើយ មនុស្សទាំងឡាយក៏នឹង ពេញចិត្តត្រេកអររីករាយបញ្ចើចកូនឲ្យរាំរែកលើទ្រូង ប្រហែលជានឹងមិន ចាំបាច់បិទទ្វារផ្ទះក៏បាន (ព្រោះមិនមានចោរ) ។ ម្នាលព្រាហ្មណ៍ ព្រះបាទ មហាវិជិតរាជ ទទួលពាក្យព្រាហ្មណ៍បុរោហិតថា យ៉ាងនឹងល្អហើយ ពួក ជនណាខ្មីឃ្មាតក្នុងការភ្ជួរស្រែនិងរក្សាគោ ក្នុងជនបទរបស់ព្រះរាជា ព្រះ បាទមហាវិជិតរាជ ក៏បានប្រទានពូជធារនិងភត្តាហារដល់ជនទាំងនោះ ពួក

កូដទន្តសុត្តេ មហាវិជិតរាជមហាយញ្ញកថា

រញ្ញោ ជនបទេ ឧស្សហឹសុ វណិជ្ជាយ តេសំ រាជា មហាវិជិតោ បាភតំ អនុប្បទាសិ យេ រញ្ញោ ជនបទេ ឧស្សហឹសុ រាជបោរិសា តេសំ រាជា មហាវិជិតោ ភត្តវេត្តនំ កប្បេសិ តេ ច មនុស្សា សកម្មបសុតា រញ្ញោ ជនបទំ ន វិហេឋេសុំ ។ មហា ច[១] រញ្ញោ រាសិកោ អហោសិ ខេមដ្ឋិតា ជនបទា អកណ្ដកា អនុប្បីឡា មនុស្សា មុទា មោទមានា ឧរេ បុត្តេ នច្ចេន្តា អបារុតឃរា មញ្ញេ វិហរឹសុ ។

[៩] អថខោ ព្រាហ្មណ រាជា មហាវិជិតោ បុរោហិតំ ព្រាហ្មណំ អាមន្តាបេត្វា ឯតទវោច សមូហ-តោ ខោ មេ ភោ សោ ទុស្សុខិលោ ភោតោ សំវិជានំ អាគម្ម មហា ច មេ រាសិកោ ខេមដ្ឋិតា ជនបទា អកណ្ដកា អនុប្បីឡា មនុស្សា មុទា មោទមានា ឧរេ បុត្តេ នច្ចេន្តា អបារុតឃរា មញ្ញេ វិហរន្តិ ឥច្ឆាមហំ ព្រាហ្មណ មហាយញ្ញំ យជិតុំ អនុសាសតុ មំ ភវំ

១ កត្ថចិ បោត្ថកេ វាតិ ទិស្សតិ ។

ជនណាខ្មីឃ្មាតក្នុងការជួញក្នុងជនបទរបស់ព្រះរាជា ព្រះបាទមហាវិជិតរាជក៏បានប្រទានព្រះរាជទ្រព្យជាដើមទុនដល់ជនទាំងនោះ ពួករាជបុរសណាដែលប្រឹងប្រែងធ្វើរាជការ ក្នុងជនបទរបស់ព្រះរាជា ព្រះបាទមហាវិជិតរាជបានកំណត់នូវបៀវត្សរ៍ដល់ជនទាំងនោះ មនុស្សទាំងនោះក៏ខំខ្វល់ខ្វាយក្នុងមុខការរបស់ខ្លួន មិនបានបៀតបៀនជនបទ របស់ព្រះរាជាឡើយ ។ ឯគំនរនៃព្រះរាជទ្រព្យក៏មានច្រើនឡើង ជនអ្នកនៅក្នុងជនបទក៏តាំងនៅដោយក្សេមក្សាន្ត មិនមានចំរូងគឺចោរ មិនមានមនុស្សបៀតបៀនគ្នាឡើយ មនុស្សទាំងឡាយ ក៏ពេញចិត្តត្រេកអររីករាយបញ្ចើចកូនឲ្យរាំរែកលើទ្រូង មិនចាំបាច់បិទទ្វារផ្ទះក៏បាន ។

[៩] ម្នាលព្រាហ្មណ៍ លំដាប់នោះ ព្រះបាទមហាវិជិតរាជមានព្រះតម្រាស់ ឲ្យហៅព្រាហ្មណ៍បុរោហិតមកហើយ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ដង្គត់ចោរនុ៎ះយើងបានដកចោលហើយ ព្រោះអាស្រ័យនូវការចាត់ចែងរបស់អ្នកដ៏ចម្រើន ទ្រព្យរបស់យើងក៏បានជាគំនរច្រើនឡើងហើយ អ្នកជនបទទាំងឡាយ ក៏នៅដោយក្សេមក្សាន្ត ឥតមានចំរូងគឺចោរ ឥតមានមនុស្សបៀតបៀនឡើយ មនុស្សទាំងឡាយ ក៏ពេញចិត្តត្រេកអររីករាយ បញ្ចើចកូនឲ្យរាំរែកលើទ្រូង មិនចាំបាច់បិទទ្វារផ្ទះក៏បាន ម្នាលព្រាហ្មណ៍ យើងចង់បូជាមហាយ័ញ្ញ ដែលប្រព្រឹត្តទៅ

យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ តេនហិ ភវំ[១] យេ ភោតោ រញ្ញោ ជនបទេ ខត្តិយា អនុយន្តា នេគមា ចេវ ជានបទា ច តេ ភវំ រាជា អាមន្តយតំ ឥច្ឆាមហំ ភោ មហាយញ្ញំ យជិតុំ អនុជានន្តុ មេ ភវន្តោ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ យេ ភោតោ រញ្ញោ ជនបទេ អមច្ចា បារិសជ្ជា នេគមា ចេវ ជានបទា ច ។ បេ ។ ព្រាហ្មណមហាសាលា នេគមា ចេវ ជានបទា ច ។ បេ ។ គហបតិកា នេចយិកា[២] នេគមា ចេវ ជានបទា ច តេ ភវំ រាជា អាមន្តយតំ ឥច្ឆាមហំ ភោ មហាយញ្ញំ យជិតុំ អនុជានន្តុ មេ ភវន្តោ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភោតិ ខោ ព្រាហ្មណ រាជា មហាវិជិតោ បុរោហិតស្ស ព្រាហ្មណស្ស បដិស្សុត្វា យេ រញ្ញោ ជនបទេ ខត្តិយា អនុយន្តា នេគមា ចេវ ជានបទា ច តេ រាជា មហាវិជិតោ អាមន្តេសិ ឥច្ឆាមហំ

១ ឱ. ម. ភវំ រាជា ។ ២ ឱ. ម. គហបតិនេចយិកា ។

ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់យើងអស់កាលជាយូរអង្វែង ចូរអ្នកដ៏ចម្រើនជួយណែនាំយើងផង ។ ព្រាហ្មណ៍បុរោហិតក៏ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នោះ ពួកជនណាទោះជាក្សត្រិយ៍ដែលនៅក្នុងនិគមក្ដី ដែលនៅក្នុងជនបទក្ដី ដែលចុះចូលក្នុងជនបទរបស់ព្រះរាជាដ៏ចម្រើន សូមព្រះរាជាដ៏ចម្រើនទ្រង់ហៅជនទាំងនោះមកប្រាប់ថា ម្នាលគ្នាយើង យើងចង់បូជាមហាយ័ញ្ញដែលប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់យើង អស់កាលជាយូរអង្វែង ចូរអ្នកដ៏ចម្រើនរាល់គ្នាយល់តាមយើង ពួកជនណាជាអមាត្យ រាជបរិសទ្យក្នុងជនបទរបស់ព្រះរាជាដ៏ចម្រើន ទោះនៅក្នុងនិគមក្ដី នៅក្នុងជនបទក្ដី ។ បេ ។ ពួកព្រាហ្មណ៍មហាសាលជាអ្នកនិគមក្ដី ជាអ្នកជនបទក្ដី ។ បេ ។ ពួកគហបតីអ្នកសន្សំទ្រព្យជានិច្ចជាអ្នកនិគមក្ដី ជាអ្នកជនបទក្ដី សូមព្រះរាជាដ៏ចម្រើនទ្រង់ហៅជនទាំងនោះមកហើយទ្រង់ប្រាប់ថា នៃអ្នករាល់គ្នា យើងចង់បូជាមហាយ័ញ្ញដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់យើងអស់កាលជាយូរអង្វែង ចូរអ្នកដ៏ចម្រើនទាំងឡាយយល់ព្រមតាមយើង ។ ម្នាលព្រាហ្មណ៍ ព្រះបាទមហាវិជិតរាជ ក៏ទទួលពាក្យព្រាហ្មណ៍បុរោហិតថា យ៉ាងហ្នឹងហើយ ជនទាំងឡាយណា ជាក្សត្រិយ៍នៅក្នុងនិគមក្ដី នៅក្នុងជនបទក្ដី ដែលចុះចូលមកក្នុងជនបទរបស់ព្រះរាជា ព្រះបាទមហាវិជិតរាជក៏ទ្រង់

២៣

កូដទន្តសុត្តេ មហាវិជិតរាជមហាយញ្ញកថា

កោ មហាយញ្ញំ យជិតុំ អនុជានន្តុ មេ ភវន្តោ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ យជតំ ភវំ រាជា យញ្ញំ យញ្ញកាលោ មហារាជាតិ ។ យេ រញ្ញោ ជនបទេ អមច្ចា បារិសជ្ជា នេគមា ចេវ ជាន-បទា ច ។ បេ ។ ព្រាហ្មណមហាសាលា នេគមា ចេវ ជានបទា ច ។ បេ ។ គហបតិកា នេចយិកា នេគមា ចេវ ជានបទា ច តេ រាជា មហាវិជិតោ អាមន្តេសិ ឥច្ឆាមហំ ភោ មហាយញ្ញំ យជិតុំ អនុជា-នន្តុ មេ ភវន្តោ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ យជតំ ភវំ រាជា យញ្ញំ យញ្ញកាលោ មហារាជាតិ ។ ឥតិ ឥមេ[១] ចត្តារោ អនុមតិបក្ខា តស្សេវ យញ្ញស្ស បរិក្ខារា ភវន្តិ ។

---

១ ឱ. ម. ឥតីមេ ។

ត្រាស់ហៅជនទាំងនោះមក ទ្រង់ត្រាស់ថា នែអ្នកពល់គ្នា យើងចង់បូជាមហាយ័ញ្ញ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់យើងអស់កាលជាយូរអង្វែង ចូរអ្នកទាំងឡាយដ៏ចម្រើនយល់ព្រមតាមយើង ។ ពួកជននោះក៏ក្រាបបង្គំទូលថា បពិត្រ មហារាជ កាលនេះជាកាលគួរនឹងបូជាយ័ញ្ញហើយ សូមព្រះរាជាដ៏ចម្រើន ទ្រង់បូជាយ័ញ្ញចុះ ។ ជនទាំងឡាយណា ជាអមាត្យ រាជបរិសទ្យក្នុងជនបទ របស់ព្រះរាជាទោះជាអ្នកនិគមក្តី ជាអ្នកជនបទក្តី ។ បេ ។ ពួកព្រាហ្មណ៍មហាសាលជាអ្នកនិគមក្តី ជាអ្នកជនបទក្តី ។ បេ ។ ពួកគហបតីអ្នកសន្សំទ្រព្យជានិច្ច ជាអ្នកនិគមក្តី ជាអ្នកជនបទក្តី ព្រះបាទមហាវិជិតរាជ ក៏ទ្រង់ត្រាស់ហៅជនទាំងឡាយនោះមក ទ្រង់មានព្រះរាជឱង្ការថា នែអ្នកពល់គ្នា យើងចង់បូជាមហាយ័ញ្ញ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់យើងអស់កាលជាយូរអង្វែង ចូរអ្នកដ៏ចម្រើនទាំងឡាយយល់ព្រមតាមយើង ។ ជនទាំងនោះក៏ក្រាបទូលថា បពិត្រមហារាជ កាលនេះ ជាកាលគួរនឹងបូជាយ័ញ្ញហើយ សូមព្រះរាជាដ៏ចម្រើន បូជាយ័ញ្ញចុះ ។ ពួកជនទាំង ៤ ពួកនេះ ជាអ្នករួមសេចក្តីយល់ព្រម ជាបរិក្ខារនៃយ័ញ្ញនោះដោយប្រការដូច្នេះ ។

[១០] រាជា មហាវិជិតោ អដ្ឋហិ អង្គេហិ ស-
មន្នាគតោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ
ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា
អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អភិរូបោ ទស្សនី-
យោ ។ បេ ។ អក្ខុទ្ទាវកាសោ ទស្សនាយ អឌ្ឍោ
មហទ្ធនោ មហាភោគោ បហូតជាតរូបរជតោ បហូត-
វិត្តូបករណោ បហូតធនធញ្ញោ បរិបុណ្ណកោសកោដ្ឋា-
គារោ ពលវា ចតុរង្គិនិយា សេនាយ សមន្នាគតោ
អស្សវាយ ឱវាទប្បដិករាយ តបតិ មញ្ញេ បច្ចត្ថិកេ
យសសា សទ្ធោ ទាយកោ ទានបតិ អនា-
វដទ្វារោ សមណព្រាហ្មណកបណទ្ធិកវណិព្វកយា-
ចកានំ ឱបានភូតោ បុញ្ញានិ ករោតិ ពហុស្សុតោ

[១០] ព្រះបាទមហាវិជិតរាជប្រកបដោយអង្គ ៨ ប្រការ គឺព្រះអង្គមានព្រះជាតិល្អ ទាំងពីរចំណែក គឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធអំពីតំណា នៃអយ្យកោអយ្យិកាជាគម្រប់ ៧ មិនមានអ្នករិះគន់តិះដៀល ដោយពោលដល់ជាតិបាន ១ ព្រះអង្គមានព្រះរូបល្អគួររមិលមើល ។ បេ ។ ព្រះសរីរាង្គរាងកាយគួរឲ្យចង់មើលមិនលែង ១ ព្រះអង្គជាស្តេចស្តុកស្តម្ភមានព្រះរាជទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ ជាទីគាប់ចិត្តច្រើន មានធនធាននិងធញ្ញាហារច្រើន មានឃ្លាំងនិងជង្រុកដ៏បរិបូណ៌ ១ ព្រះអង្គមានវេហ៍ពលប្រកបដោយចតុរង្គសេនា ដែលស្តាប់បង្គាប់ធ្វើតាមព្រះរាជឱវាទ (ទ្រង់ទូន្មានមនុស្សទាំងឡាយ) ព្រះអង្គមានតេជានុភាព ហាក់ដូចជាដុតបំផ្លាញនូវពួកសត្រូវ ដោយរាជឥស្សរិយយស ១ ព្រះអង្គមានព្រះរាជសទ្ធា ជាទាយក ជាទានបតិ មិនបានបិទទ្វារ ព្រះអង្គដូចជាអណ្តូងទឹកសម្រាប់ផឹករបស់សមណព្រាហ្មណ៍និងមនុស្សកំព្រា អ្នកដំណើរ មនុស្សអ្នកពណ៌នា (គុណរបស់ទាន) ហើយសូម និងយាចកទាំងឡាយ រមែងទ្រង់ធ្វើនូវបុណ្យ ១ ព្រះអង្គជាពហុស្សូត គឺទ្រង់បានរៀនសូត្រស្តាប់

តស្ស តស្ស សុតជាតស្ស តស្ស តស្សេវ ខោ បន ភាសិតស្ស អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ បណ្ឌិតោ វិយត្តោ មេធាវី បដិពលោ អតីតានាគតប្បច្ចុប្បន្នេ អត្ថេ ចិន្តេតុំ ។ រាជា មហាវិជិតោ ឥមេហិ អដ្ឋហិ អង្គេហិ សមន្នាគតោ ។ ឥតិ ឥមានិបិ អដ្ឋង្គានិ តស្សេវ យញ្ញស្ស បរិក្ខារា ភវន្តិ ។

[១១] បុរោហិតោ[១] ព្រាហ្មណោ ចតូហង្គេហិ សមន្នាគតោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ សីលវា វុឌ្ឍសីលី វុឌ្ឍសីលេន[២] សមន្នាគតោ បណ្ឌិតោ ព្យត្តោ មេធាវី

---

១ ម. បុរោហិតោបិ ។ ២ ម. ពុទ្ធសីលី ពុទ្ធសីលេន ។

ច្រើន ១ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីអធិប្បាយនៃសុតៈ គឺវិជ្ជាចំណេះនោះ ៗ នៃភាសិតនោះ ៗ ដោយន័យច្បាស់លាស់ថា នេះជាសេចក្ដីអធិប្បាយនៃភាសិតនេះ ៗ ១ ព្រះអង្គជាអ្នកប្រាជ្ញវាងវៃមានប្រាជ្ញាអង់អាចនឹងទ្រង់ព្រះរាជតម្រិះនូវប្រយោជន៍ទាំងឡាយ ដែលជាអតីត អនាគត និង បច្ចុប្បន្ន ១ ។ ព្រះបាទមហាវិជិតរាជ ទ្រង់ប្រកបដោយអង្គទាំង ៨ នេះឯង ។ អង្គ ៨ នេះ ជាបរិក្ខាររបស់យញ្ញនោះ ដោយប្រការដូច្នេះ ។

[១១] ព្រាហ្មណ៍បុរោហិត ប្រកបដោយអង្គ ៤ គឺជាអ្នកមានកំណើតស្អាតទាំងពីរចំណែក គឺខាងមាតានិងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណា រិះគន់តិះដៀលដោយពោលដល់ជាតិកំណើតបាន ១ ជាអ្នករាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេតុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនថយថោក គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ ជាអ្នកមានសីល មានសីលដ៏ចម្រើន ប្រកបដោយសីលដ៏ចម្រើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញាឈ្លាសវៃ

បឋមោ វា ទុតិយោ វា ឞុជម្បគ្គណ្ហន្តានំ[១] ។ បុរោហិតោ ព្រាហ្មណោ ឥមេហិ ចតូហង្គេហិ សមន្នាគតោ ។ ឥតិ ឥមានិបិ ចត្តារិ អង្គានិ តស្សេវ យញ្ញស្ស បរិក្ខារា ភវន្តិ ។

[១២] អថខោ ព្រាហ្មណ បុរោហិតោ ព្រាហ្មណោ រញ្ញោ មហាវិជិតស្ស បុព្វេ វ យញ្ញា តិស្សោ វិធា ទេសេសិ សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វិប្បដិសារោ មហា វត មេ ភោគក្ខន្ធោ វិគច្ឆិស្សតីតិ សោ ភោតា រញ្ញោ វិប្បដិសារោ ន ករណីយោ ។ សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វិប្បដិសារោ មហា វត មេ ភោគក្ខន្ធោ វិគច្ឆតីតិ សោ ភោតា រញ្ញោ វិប្បដិសារោ ន ករណីយោ ។ សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វិប្បដិសារោ

១ ឱ. ម. សុជំ បគ្គណ្ហន្តានំ ។

ជាបុគ្គលទី ១ ឬទី ២ របស់ព្រាហ្មណ៍អ្នកទទួលនូវការបូជា ។ ព្រាហ្មណ៍បុរោហិតប្រកបដោយអង្គទាំង ៤ នេះឯង ។ អង្គទាំង ៤ នេះជាបរិក្ខាររបស់យ័ញ្ញនោះដោយប្រការដូច្នេះ ។

[១២] ម្នាលព្រាហ្មណ៍ លំដាប់នោះ ព្រាហ្មណ៍បុរោហិតបានសំដែងវិធីតម្កល់ចិត្ត ៣ យ៉ាងដល់ព្រះបាទមហាវិជិតរាជ ក្នុងកាលមុនយញ្ញពិធីថា កាលបើព្រះរាជាដ៏ចម្រើន នឹងបូជាមហាយ័ញ្ញ គង់នឹងមានសេចក្តីក្តៅក្រហាយណាមួយមិនខានថា ឱហ្ន៎ គំនរភោគៈយ៉ាងច្រើនរបស់អញនឹងវិនាសទៅ ព្រះរាជាដ៏ចម្រើន កុំគប្បីធ្វើសេចក្តីក្តៅក្រហាយនោះឡើយ ។ កាលបើព្រះរាជាដ៏ចម្រើន នឹងបូជាមហាយ័ញ្ញ នឹងមានសេចក្តីក្តៅក្រហាយណាមួយមិនខានថា ឱហ្ន៎ គំនរភោគៈយ៉ាងច្រើនរបស់អញវិនាសទៅ ព្រះរាជាដ៏ចម្រើន កុំគប្បីធ្វើសេចក្តីក្តៅក្រហាយនោះឡើយ ។ កាលបើព្រះរាជាដ៏ចម្រើន នឹងបូជាយ័ញ្ញ នឹងមានសេចក្តីក្តៅក្រហាយណាមួយ

កូដទន្តសុត្តេ មហាវិជិតរាជមហាយញ្ញកថា

មហា វត មេ ភោគក្ខន្ធោ វិគតោតិ សោ ភោតា រញ្ញា វិប្បដិសារោ ន ករណីយោ ។ ឥមេ(១) ព្រាហ្មណា បុរោហិតោ ព្រាហ្មណោ រញ្ញោ មហាវិជិតស្ស បុព្វេ វ យញ្ញា តិស្សោ វិធា ទេសេសិ ។

[១៣] អថខោ ព្រាហ្មណ បុរោហិតោ ព្រាហ្មណោ រញ្ញោ មហាវិជិតស្ស បុព្វេ វ យញ្ញា ទសហាការេហិ បដិគ្គាហកេសុ វិប្បដិសារំ បដិវិនេសិ(២) ។ អាគមិស្សន្តិ ខោ ភោតោ យញ្ញំ បាណាតិបាតិនោបិ បាណាតិបាតាបិ បដិវិរតា យេ តត្ថ បាណាតិបាតិនោ តេសំ-យេវ តេន យេ តត្ថ បាណាតិបាតា បដិវិរតា តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

---

១ ឥមា ខោតិ បាឋេន ភវិតព្វំ ។ ២ បដិវិនេតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

មិនខានថា ឱហ្ន៎ គំនរភោគៈយ៉ាងច្រើនរបស់អញវិនាសទៅហើយ ព្រះរាជាដ៏ចម្រើន កុំគប្បីធ្វើសេចក្តីក្តៅក្រហាយនោះឡើយ ។ ម្នាលព្រាហ្មណ៍ ព្រាហ្មណ៍បុរោហិតបានសំដែងវិធីតម្កល់ចិត្ត ៣ យ៉ាងនេះ ដល់ព្រះបាទមហាវិជិតរាជ ក្នុងកាលមុនយញ្ញពិធី ។

[១៣] ម្នាលព្រាហ្មណ៍ លំដាប់នោះ ព្រាហ្មណ៍បុរោហិតបានបន្ទោបង់នូវសេចក្តីក្តៅក្រហាយ របស់ព្រះបាទមហាវិជិតរាជ ក្នុងពួកបុគ្គលអ្នកទទួលនូវគ្រឿងបូជា ដោយអាការទាំង ១០ ក្នុងកាលមុនយញ្ញពិធី ។ (ថា) ពួកមនុស្សអ្នកសម្លាប់សត្វក៏មាន អ្នកវៀរចាកការសម្លាប់សត្វក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញរបស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកសម្លាប់សត្វ ផលរបស់ការសម្លាប់សត្វនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកវៀរចាកការសម្លាប់សត្វ សូមព្រះអង្គទ្រង់ព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះជនទាំងនោះចុះ ។

[១៤] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ អធិដ្ឋានា-យិនោបិ អធិដ្ឋានាជាបិ បដិវិរតា យេ តត្ថ អធិដ្ឋានា-យិនោ តេសំយេវ តេន យេ តត្ថ អធិដ្ឋានាជា បដិ-វិរតា តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[១៥] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ កាមេសុ មិច្ឆាចារិនោបិ កាមេសុ មិច្ឆាចារាបិ បដិវិរតា យេ តត្ថ កាមេសុ មិច្ឆាចារិនោ តេសំយេវ តេន យេ តត្ថ កា-មេសុ មិច្ឆាចារា បដិវិរតា តេ អារព្ភ យជតំ ភវំ សជ្ជ-តំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[១៤] ពួកមនុស្សអ្នកលួចទ្រព្យគេក៏មាន អ្នកវៀរចាកការលួចទ្រព្យគេក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញរបស់ព្រះអង្គ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកលួចទ្រព្យគេ ផលរបស់ការលួចទ្រព្យគេនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកវៀរចាកការលួចទ្រព្យគេ សូមឲ្យព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យរបស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[១៥] ពួកមនុស្សអ្នកប្រព្រឹត្តខុសក្នុងកាមក៏មាន អ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញ របស់ព្រះអង្គ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកប្រព្រឹត្តខុសក្នុងកាម ផលរបស់ការប្រព្រឹត្តខុសក្នុងកាមនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាម សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យរបស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

កូដទន្តសុត្តេ មហាវិជិតរាជមហាយញ្ញកថា

[១៦] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ មុសាវាទិនោបិ មុសាវាទា បដិវិរតាបិ យេ តត្ថ មុសាវាទិនោ តេសំយេវ តេន យេ តត្ថ មុសាវាទា បដិវិរតា តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[១៧] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ បិសុណាវាចិនោបិ បិសុណាយ វាចាយ បដិវិរតាបិ យេ តត្ថ បិសុណាវាចិនោ តេសំយេវ តេន យេ តត្ថ បិសុណាយ វាចាយ បដិវិរតា តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[១៦] ពួកមនុស្សអ្នកពោលពាក្យកុហកក៏មាន អ្នកវៀរចាកការពោលពាក្យកុហកក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយញ្ញ របស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកពោលពាក្យកុហក ផលរបស់ការពោលពាក្យកុហកនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ ពួកមនុស្សណាដែលជាអ្នកវៀរ ចាកការពោលពាក្យកុហក សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជ-ទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[១៧] ពួកមនុស្សអ្នកនិយាយញុះញង់ក៏មាន អ្នកវៀរចាកការនិយាយញុះញង់ក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយញ្ញរបស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកនិយាយញុះញង់ ផលរបស់ការនិយាយញុះញង់នោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកវៀរចាកការនិយាយញុះ-ញង់ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[១៨] អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ ផស្សាហារនិ យេ តត្ថ ផស្សាហារ ផស្សាហារាតិ...

[១៨] ពួកមនុស្សអ្នកនិយាយពាក្យទ្រគោះក៏មាន អ្នកវៀរចាកការនិយាយពាក្យទ្រគោះក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញរបស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកនិយាយពាក្យទ្រគោះ ផលរបស់ការនិយាយពាក្យទ្រគោះនោះ ក៏មានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ មនុស្សពួកណា ដែលជាអ្នកវៀរចាកការនិយាយពាក្យទ្រគោះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[១៩] ពួកមនុស្សអ្នកនិយាយពាក្យរោយរាយក៏មាន អ្នកវៀរចាកការនិយាយពាក្យរោយរាយក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញរបស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកនិយាយពាក្យរោយរាយ ផលរបស់ការនិយាយពាក្យរោយរាយនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកវៀរចាក ការនិយាយពាក្យរោយរាយ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

កូដទន្តសុត្តេ មហាវិជិតរាជមហាយញ្ញកថា

[២០] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ អភិជ្ឈា-លុនោបិ អនភិជ្ឈាលុនោបិ យេ តត្ថ អភិជ្ឈាលុនោ តេសំយេវ តេន យេ តត្ថ អនភិជ្ឈាលុនោ តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២១] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ ព្យាបន្ន-ចិត្តាបិ អព្យាបន្នចិត្តាបិ យេ តត្ថ ព្យាបន្នចិត្តាបិ តេសំយេវ តេន យេ តត្ថ អព្យាបន្នចិត្តា តេ អារព្ភ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

កូដទន្តសូត្រ ការពោលអំពីមហាយ័ញ្ញរបស់ព្រះបាទមហាវិជិតរាជ

[២០] ពួកមនុស្សអ្នកមានអភិជ្ឈាក៏មាន អ្នកមិនមានអភិជ្ឈាក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញ របស់ព្រះអង្គ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកមានអភិជ្ឈា ផលរបស់អភិជ្ឈានោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកមិនមានអភិជ្ឈា សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យរបស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[២១] ពួកមនុស្សដែលមានចិត្តព្យាបាទក៏មាន អ្នកមិនមានចិត្តព្យាបាទក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញរបស់ព្រះអង្គ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកមានចិត្តព្យាបាទ ផលរបស់ចិត្តព្យាបាទនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលជាអ្នកមិនមានចិត្តព្យាបាទ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យរបស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។

[២២] អាគមិស្សន្តិ ខោ ភោតោ យញ្ញំ មិច្ឆាទិដ្ឋិ-
កាបិ សម្មាទិដ្ឋិកាបិ យេ តត្ថ មិច្ឆាទិដ្ឋិកា តេសំ-
យេវ តេន យេ តត្ថ សម្មាទិដ្ឋិកា តេ អារព្ភ យជតំ
ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសា-
ទេតូតិ ។ ឥមេហិ ខោ ព្រាហ្មណ បុរោហិតោ ព្រាហ្ម-
ណោ រញ្ញោ មហាវិជិតស្ស បុព្វេ វ យញ្ញា ទសហា-
ការេហិ បដិគ្គាហកេសុ វិប្បដិសារំ បដិវិនេសិ ។

[២៣] អថខោ ព្រាហ្មណ បុរោហិតោ ព្រាហ្មណោ
រញ្ញោ មហាវិជិតស្ស មហាយញ្ញំ យជមានស្ស សោ-
ឡសហិ អាការេហិ ចិត្តំ សន្ទស្សេសិ សមាទបេសិ
សមុត្តេជេសិ សម្បហំសេសិ សិយា ខោ បន ភោតោ
រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា
ខោ មហាវិជិតោ មហាយញ្ញំ យជតិ នោ ច ខ្វស្ស
អាមន្តិតា ខត្តិយា អនុយន្តា[១] នេគមា ចេវ ជានបទា

---

១ ឱ. អនុយុត្តា ។

[២២] ពួកមនុស្ស ជាមិច្ឆាទិដ្ឋិក៏មាន ជាសម្មាទិដ្ឋិក៏មាន នឹងនាំគ្នាមកកាន់ទីសម្រាប់បូជាយ័ញ្ញ របស់ព្រះអង្គ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាមិច្ឆាទិដ្ឋិ ផលរបស់មិច្ឆាទិដ្ឋិនោះ ក៏នឹងមានដល់មនុស្សពួកនោះទៅ បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលជាសម្មាទិដ្ឋិ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមឲ្យខាងក្នុងព្រះហឫទ័យ របស់ព្រះអង្គជ្រះថ្លា ចំពោះមនុស្សទាំងនោះចុះ ។ ម្នាលព្រាហ្មណ៍ ព្រាហ្មណ៍បុរោហិត បានបន្ទោបង់នូវសេចក្តីក្តៅក្រហាយ របស់ព្រះបាទមហាវិជិតរាជ ក្នុងបដិគ្គាហកៈក្នុងកាលមុនយញ្ញពិធី ដោយអាការ ១០ នេះឯង ។

[២៣] ម្នាលព្រាហ្មណ៍ កាលនោះ ព្រាហ្មណ៍បុរោហិត បានញុំាងព្រះហឫទ័យ នៃព្រះបាទមហាវិជិតរាជ ដែលកំពុងបូជាមហាយ័ញ្ញ ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយអាការ ១៦ ថា កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយ័ញ្ញ ក្រែងមានអ្នកណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយ័ញ្ញ តែថា ពួកក្សត្រិយ៍នៅក្នុងនិគមនិងជនបទ ដែលនៅក្នុងព្រះរាជអំណាច ទ្រង់មិនមាន

ច អថ ច បន ភវំ រាជា ឯវរូបំ មហាយញ្ញំ យជតីតិ ។ ឯវំបិ ខោ ភោតោ រញ្ញោ វត្តា ធម្មតោ នត្ថិ ។ ភោតោ ខោ បន រញ្ញោ អាមន្តិតា ខត្តិយា អនុយន្តា នេគមា ចេវ ជានបទា ច ឥមិនាបេតំ ភវំ រាជា ជានាតុ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២៤] សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា ខោ មហាវិជិតោ មហាយញ្ញំ យជតិ នោ ច ខ្វស្ស អាមន្តិតា អមច្ចា បារិសជ្ជា នេគមា ចេវ ជានបទា ច ។ បេ ។ ព្រាហ្មណមហាសាលា នេគមា ចេវ ជានបទា ច ។ គហបតិនេចយិកា នេគមា ចេវ ជានបទា ច អថ ច បន ភវំ រាជា ឯវរូបំ មហាយញ្ញំ យជតីតិ ។ ឯវំបិ ខោ ភោតោ រញ្ញោ វត្តា ធម្មតោ នត្ថិ ។

ព្រះបន្ទូលហៅរកផង បើទុកជាដូច្នោះ ព្រះរាជាដ៏ចម្រើន ក៏គង់តែបូជាមហាយញ្ញមានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ ចំពោះមហារាជដ៏ចម្រើនយ៉ាងនេះ ក៏មិនមានឡើយ ។ ឯពួកក្សត្រិយ៍នៅក្នុងនិគមក្តី នៅក្នុងជនបទក្តី ដែលនៅក្នុងព្រះរាជអំណាច ព្រះរាជាដ៏ចម្រើន បានមានព្រះបន្ទូលហៅមកហើយ សូមព្រះរាជាដ៏ចម្រើន ទ្រង់ជ្រាបសេចក្តីនុ៎ះ ដោយអាការនេះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាងក្នុងចុះ ។

[២៤] កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយញ្ញ ក្រែងមានអ្នកណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយញ្ញ តែថាពួកអមាត្យ រាជបរិសទ្យ អ្នកនិគមនិងអ្នកជនបទ ព្រះអង្គក៏មិនមានព្រះបន្ទូលហៅមកឡើយ ។ បេ ។ ពួកព្រាហ្មណ៍មហាសាល អ្នកនិគមនិងអ្នកជនបទ ។ ពួកគហបតីអ្នកសន្សំទ្រព្យ ជាអ្នកនិគមនិងអ្នកជនបទ (ព្រះរាជាមិនមានព្រះបន្ទូលហៅមកឡើយ) បើទុកជាដូច្នោះព្រះរាជាដ៏ចម្រើន ក៏គង់តែបូជាមហាយញ្ញមានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ ចំពោះព្រះរាជាដ៏ចម្រើនយ៉ាងនេះ ក៏មិនមានឡើយ ។

ភោតោ ខោ បន រញ្ញោ អាមន្តិតា គហបតិនេច- យិកា នេគមា ចេវ ជានបទា ច ឥមិនាបេតំ ភវំ រាជា ជានាតុ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២៩] សិយា ខោ បន ភោតោ រញ្ញោ មហា- យញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា ខោ មហា- វិជិតោ មហាយញ្ញំ យជតិ នោ ច ខោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អថ ច បន ភវំ រាជា ឯវរូបំ មហាយញ្ញំ យជតីតិ ។ ឯវម្បិ ខោ ភោតោ រញ្ញោ វត្តា ធម្មោ នត្ថិ ។ ភវំ ខោ បន រាជា ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ

ឯពួកគហបតីអ្នកសន្សំទ្រព្យ ជាអ្នកនិគមនិងអ្នកជនបទ ព្រះរាជាដ៏ចម្រើន បានមានព្រះបន្ទូលហៅមកហើយ សូមព្រះរាជាដ៏ចម្រើន ទ្រង់ជ្រាបសេចក្តីនុ៎ះដោយអាការនេះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាងក្នុងចុះ ។

[២៥] កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយ័ញ្ញ ក្រែងមានអ្នកណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយ័ញ្ញ តែថា ព្រះអង្គមិនមែនជាស្តេចមានព្រះជាតិស្អាតទាំង ២ ខាង គឺខាងព្រះមាតានិងព្រះបិតា ទ្រង់ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃព្រះអយ្យកោព្រះអយ្យិកាជាគម្រប់ ៧ មក មិនមានអ្នកណា រិះគន់តិះដៀលដោយពោលដល់ជាតិបានឡើយ បើទុកជាដូច្នោះ ព្រះរាជាដ៏ចម្រើន គង់តែបូជាមហាយ័ញ្ញ មានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ចំពោះព្រះរាជាដ៏ចម្រើន យ៉ាងនេះមិនមានឡើយ ។ តែព្រះរាជាដ៏ចម្រើន មានព្រះជាតិស្អាតទាំងពីរខាង គឺខាងព្រះមាតានិងខាងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃព្រះអយ្យកោ ព្រះអយ្យិកាជាគម្រប់ ៧ មក ក៏មិនមានអ្នកណា រិះគន់តិះដៀល ដោយពោលដល់

ជាតិវាទេន ឥមិនាបេតំ ភវំ រាជា ជានាតុ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២៦] សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា ខោ មហាវិជិតោ មហាយញ្ញំ យជតិ នោ ច ខោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អក្ខុទ្ទាវកាសោ ទស្សនាយ ។ បេ ។ នោ ច ខោ អឌ្ឍោ មហទ្ធនោ មហាភោគោ បហូតជាតរូបរជតោ បហូតវិត្តូបករណោ បហូតធនធញ្ញោ បរិបុណ្ណកោសកោដ្ឋាគារោ ។ បេ ។ នោ ច ខោ ពលវា ចតុរង្គិនិយា សេនាយ សមន្នាគតោ អស្សវាយ ឱវាទប្បដិការាយ តបតិ(១) មញ្ញេ បច្ចត្ថិកេ យសសា នោ ច ខោ សទ្ធោ ទាយកោ

១ ឱ. ឱវាទប្បតិករាយ បតបតិ ។ ម. ឱវាទប្បដិករាយ សទបតិ ។

ជាតិបានឡើយ សូមព្រះរាជាដ៏ចម្រើន ទ្រង់ជ្រាបសេចក្តីនេះដោយអាការនេះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាក្នុងចុះ ។

[២៦] កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយញ្ញ ក្រែងមានអ្នកណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយញ្ញ ព្រះអង្គជាស្តេចមានព្រះរូបមិនល្អ មិនគួរមិលមើល មិនគួរឲ្យកើតសេចក្តីជ្រះ-ថ្លា មិនប្រកបដោយសម្បុរដ៏ល្អយ៉ាងក្រៃលែង មិនដូចជាសម្បុរនៃព្រហ្ម មិនមានសរីរៈស្រដៀងនឹងព្រហ្ម មិនមានសណ្ឋានរាងកាយគួរឲ្យមិលមើលមិនលែង ។ បេ ។ ព្រះអង្គជាស្តេចមិនស្តុកស្តម្ភ មិនមានទ្រព្យច្រើន មិនមានរបស់ប្រើប្រាស់ច្រើន មិនមានមាសប្រាក់ច្រើន មិនមានគ្រឿងឧបក-រណ៍ជាទីត្រេកអរច្រើន មិនមានធនធាននិងធញ្ញាហារច្រើន មិនមានឃ្លាំងនិងជង្រុកដ៏បរិបូណ៌ ។ បេ ។ ព្រះអង្គជាស្តេច មិនមានវេហ៍ពលប្រកបដោយចតុរង្គសេនា ដែលស្តាប់បង្គាប់ធ្វើតាមព្រះឱវាទ ព្រះអង្គមិនមានតេជានុភាព ហាក់ដូចជាដុតបំផ្លាញនូវពួកសត្រូវ ដោយព្រះរាជឥស្ស-រិយយសបាន ព្រះអង្គជាស្តេចមិនមានសទ្ធា មិនមែនជាទាយក មិនមែន

ធនបតិ អនាវដទ្វារោ សមណព្រាហ្មណកបណទ្ធិក-វណិព្វកយាចកានំ ឱបានភូតោ បុញ្ញានិ ករោតិ សោ ច ខោ ពហុស្សុតោ តស្ស តស្ស សុតជាតស្ស សោ ច ខោ តស្ស តស្សេវ ខោ បន ភាសិតស្ស អត្ថំ ជានាតិ អយំ ឥមស្ស ភាសិតស្ស អត្ថោ អយំ ឥមស្ស ភាសិតស្ស អត្ថោតិ សោ ច ខោ បណ្ឌិតោ វិយត្តោ មេធាវី បដិពលោ អតីតានាគតប្បច្ចុប្បន្នេ អត្ថេ ចិន្តេតុំ អថ ច បន ភវំ រាជា ឯវរូបំ មហាយញ្ញំ យជតីតិ ។ ឯវំបិ ខោ ភោតោ រញ្ញោ វត្តា ធម្មតោ នត្ថិ ។ ភវំ ខោ បន រាជា បណ្ឌិតោ វិយត្តោ មេធាវី បដិពលោ អតីតានាគតប្បច្ចុប្បន្នេ អត្ថេ ចិន្តេតុំ ឥមិ-នាបេតំ ភវំ រាជា ជានាតុ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២៧] សិយា ខោ បន ភោតោ រញ្ញោ មហាយញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា ខោ មហាវិជិតោ

ជាទានបតី មិនមែនជាអ្នកបើកទ្វារ មិនមែនដូចជាអណ្តូងទឹកសម្រាប់ផឹករបស់សមណព្រាហ្មណ៍ និងអ្នកកំព្រា អ្នកដំណើរ អ្នកពណ៌នាគុណរបស់ទានហើយសូម និងយាចកទាំងឡាយ ហើយធ្វើនូវបុណ្យ ព្រះអង្គមិនបានរេះចាំច្រើន មិនទ្រង់ជ្រាប នូវសេចក្តីអធិប្បាយនៃសុតៈនោះ ៗ នៃភាសិតនោះ ៗ ថានេះជាសេចក្តីអធិប្បាយនៃភាសិតនេះ នេះជាសេចក្តីអធិប្បាយនៃភាសិតនេះ ព្រះអង្គមិនមែនជាបណ្ឌិត វាងវៃ មិនមានព្រះប្រាជ្ញាអង់អាច ដើម្បីនឹងគិតសេចក្តីក្នុងអតីត អនាគត និងបច្ចុប្បន្នបានឡើយ បើទុកជាដូច្នោះ ព្រះរាជាដ៏ចម្រើន ក៏គង់តែបូជាមហាយ័ញ្ញ មានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ ចំពោះព្រះរាជាដ៏ចម្រើនយ៉ាងនេះ ក៏មិនមានឡើយ ។ ព្រះរាជាដ៏ចម្រើន ជាបណ្ឌិត ឈ្លាសវៃ មានព្រះប្រាជ្ញាអង់អាច ដើម្បីនឹងគិតសេចក្តីក្នុងអតីត អនាគត និងបច្ចុប្បន្នបាន សូមព្រះរាជាដ៏ចម្រើនទ្រង់ជ្រាបសេចក្តីនុ៎ះ ដោយហេតុនេះចុះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាងក្នុងចុះ ។

[២៧] កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយ័ញ្ញ ក្រែងមានអ្នកណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយ័ញ្ញ ទាស់

មហាយញ្ញំ យជតិ នោ ច ខ្វស្ស[១] បុរោហិតោ ព្រាហ្មណោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អថ ច បន ភវំ រាជា ឯវរូបំ មហាយញ្ញំ យជតីតិ ។ ឯវំបិ ខោ ភោតោ រញ្ញោ វត្តា ធម្មតោ នត្ថិ ។ ភោតោ ខោ បន រញ្ញោ បុរោហិតោ ព្រាហ្មណោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនាបេតំ ភវំ រាជា ជានាតុ យជតំ ភវំ សជ្ជតំ ភវំ មោទតំ ភវំ ចិត្តមេវ ភវំ អន្តរំ បសាទេតុ ។

[២៨] សិយា ខោ បន ភោតោ រញ្ញោ មហា-យញ្ញំ យជមានស្ស កោចិទេវ វត្តា រាជា ខោ មហា-វិជិតោ មហាយញ្ញំ យជតិ នោ ច ខ្វស្ស បុរោហិតោ ព្រាហ្មណោ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាស-

១ ឱ. ខោ តស្ស ។

តែព្រាហ្មណ៍បុរោហិត មិនមានកំណើតល្អទាំងពីរផ្នែក គឺខាងមាតានិង ខាងបិតា មិនបានប្រសូត្រចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃអយ្យកោ អយ្យិកាជាគម្រប់ ៧ មកឡើយ មិនមែនជាឥតមានអ្នកណា រិះគន់តិះដៀល ដោយពោលដល់ជាតិបានឡើយ បើទុកជាដូច្នោះព្រះរាជាដ៏ចម្រើនគង់តែ បូជាមហាយ័ញ្ញមានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ចំពោះ ព្រះរាជាដ៏ចម្រើនយ៉ាងនេះមិនមានឡើយ ។ ឯព្រាហ្មណ៍បុរោហិតរបស់ ព្រះរាជាដ៏ចម្រើន ជាអ្នកមានជាតិបរិសុទ្ធ ទាំងពីរចំណែកដែរ គឺខាងមាតា និងខាងបិតា ប្រសូត្រចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណអយ្យកោ អយ្យិកាជាគម្រប់ ៧ មក មិនមានអ្នករិះគន់តិះដៀល ដោយពោល ដល់ជាតិកំណើតបានឡើយ សូមព្រះរាជាដ៏ចម្រើន ទ្រង់ជ្រាបសេចក្តីនុ៎ះ ដោយហេតុនេះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយ សូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាងក្នុងចុះ ។

[២៨] កាលព្រះរាជាដ៏ចម្រើន កំពុងបូជាមហាយ័ញ្ញ ក្រែងមានអ្នក ណាមួយនិយាយថា ព្រះបាទមហាវិជិតរាជ ទ្រង់បូជាមហាយ័ញ្ញ ទាស់ តែព្រាហ្មណ៍បុរោហិតរបស់ព្រះអង្គ មិនមែនជាអ្នករាយមន្ត មិនចេះចាំមន្ត មិនចេះចាំនូវត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេតុភៈ ព្រមទាំង អក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នក

បញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហា-បុរិសលក្ខណេសុ អនវយោ ដោ ច ខ្វស្ស បុរោហិ-តោ ព្រាហ្មណោ សីលវា វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ ដោ ច ខ្វស្ស បុរោហិតោ ព្រាហ្មណោ បណ្ឌិតោ វិយត្តោ មេធាវី បឋមោ វា ទុតិយោ វា បូជំ បគ្គណ្ហន្តានំ អថ ច បន ករំ រាជា ឯវរូបំ មហា-យញ្ញំ យជតីតិ ។ ឯវំបិ ភោតោ រញ្ញោ វត្តា ជម្មតោ ឯត្ថិ ។ ភោតោ ខោ បន រញ្ញោ បុរោហិតោ ព្រាហ្ម-ណោ បណ្ឌិតោ វិយត្តោ មេធាវី បឋមោ វា ទុតិយោ វា បូជំ បគ្គណ្ហន្តានំ ឥមិនាបេតំ ករំ រាជា ជានាតុ យជតំ ករំ សជ្ជតំ ករំ មោទតំ ករំ ចិត្តមេវ ករំ អន្តរំ បសាទេតូតិ ។ ឥមេហិ ខោ ព្រាហ្មណា បុរោ-ហិតោ ព្រាហ្មណោ រញ្ញោ មហាវិជិតស្ស មហាយញ្ញំ យជមានស្ស សោឡសហិ អាការេហិ ចិត្តំ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

មិនដឹងនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនថយថោក គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ ទាស់តែព្រាហ្មណ៍បុរោហិតរបស់ព្រះរាជានោះ មិនមែនជាអ្នកមានសីល មានសីលដ៏ចម្រើន មិនប្រកបដោយសីលដ៏ចម្រើន ព្រាហ្មណ៍បុរោហិតរបស់ព្រះរាជានោះ មិនមែនជាបណ្ឌិតឈ្លាសវៃមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍អ្នកទទួលនូវការបូជាឡើយ បើទុកជាដូច្នោះ ព្រះរាជាដ៏ចម្រើន ក៏គង់តែបូជាមហាយ័ញ្ញមានសភាពយ៉ាងនេះបាន ។ ជនអ្នកពោលដោយធម៌ ចំពោះព្រះរាជាដ៏ចម្រើន យ៉ាងនេះមិនមានឡើយ ។ ឯព្រាហ្មណ៍បុរោហិតរបស់ព្រះរាជាដ៏ចម្រើន ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញាជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍អ្នកទទួលនូវការបូជាមែន សូមព្រះរាជាដ៏ចម្រើន ទ្រង់ជ្រាបនូវសេចក្តីនុ៎ះ ដោយហេតុនេះចុះ សូមព្រះអង្គព្រះរាជទាន សូមព្រះអង្គចំណាយព្រះរាជទ្រព្យ សូមព្រះអង្គរីករាយសូមទ្រង់តាំងព្រះហឫទ័យ ឲ្យជ្រះថ្លាតែខាងក្នុងចុះ ។ ម្នាលព្រាហ្មណ៍ព្រាហ្មណ៍បុរោហិត បានញុំាងព្រះហឫទ័យ របស់ព្រះបាទមហាវិជិតរាជដែលកំពុងបូជាមហាយ័ញ្ញឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហានឲ្យរីករាយ ដោយអាការទាំង ១៦ នេះឯង ។

[២៩] តស្មឹ ខោ បន(១) ព្រាហ្មណ យញ្ញេ នេវ គាវោ ហញ្ញឹសុ ន អជេឡកា ហញ្ញឹសុ ន កុក្កុដ-សូករា ហញ្ញឹសុ ន វិវិធា បាណា សង្ឃាតំ អាបជ្ជឹសុ ន រុក្ខា ឆិន្ទឹសុ(២) យូបត្ថាយ ន ទព្វា លាយឹសុ(៣) បរហឹសត្ថាយ ។ យេបិស្ស អហេសុំ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ ន ទណ្ឌតជ្ជិតា ន ភយតជ្ជិតា ន អស្សុមុខា រោទមានា(៤) បរិកម្មានិ អកំសុ ។ អថខោ យេ ឥច្ឆឹសុ តេ អកំសុ យេ ន ឥច្ឆឹសុ ន តេ អកំសុ ។ យំ ឥច្ឆឹសុ តំ អកំសុ យំ ន ឥច្ឆឹសុ ន តំ អកំសុ ។ សប្បិតេលនវនីតទធិមធុ-ផាណិតេន ចេវ សោ យញ្ញោ និដ្ឋានមគមាសិ ។

[៣០] អថខោ ព្រាហ្មណ ខត្តិយា អនុយន្តា នេគមា ចេវ ជានបទា ច ។ អមច្ចា បារិសជ្ជា នេគមា ចេវ ជានបទា ច ។ ព្រាហ្មណមហាសាលា

---

១ ឱ. ម. បនាតិ ន ទិស្សតិ ។ ២ ឆិជ្ជឹសូតិបិ បាឋោ ។ ៣ ឱ. ន ទព្វា លុយឹសុ ។ ម. ន ទព្ភា លុយឹសុ ។ ៤ ឱ. ម. រុទមានា ។

[២៩] ម្នាលព្រាហ្មណ៍ ក្នុងយ័ញ្ញនោះឯង មនុស្សទាំងឡាយ ក៏ខានសម្លាប់គោ ខានសម្លាប់ពពែនិងកែះ ខានសម្លាប់មាន់ ជ្រូក ពួកសត្វផ្សេង ៗ ក៏មិនបានដល់នូវសេចក្តីវិនាស ខានកាប់ដើមឈើ មកធ្វើជាគោល (សម្រាប់ចារឹកឈ្មោះ) ខានច្រូតស្បូវភ្លាំង ដើម្បីឲ្យលំបាក (ដល់ជនឯទៀត) ។ ចំណែកខាងពួកជនណា ដែលជាខ្ញុំកំដរក្តី ជាអ្នកបំរើក្តី ជាអ្នកធ្វើការងារក្តី ជនទាំងនោះព្រះរាជាក៏មិនបានគម្រាម ដោយអាជ្ញាមិនបានគម្រាមឲ្យភ័យ មិនមានមុខជោកដោយទឹកភ្នែក ស្រែកទ្រហោយំធ្វើការងារឡើយ ។ ដោយពិតនោះថា ពួកជនណា ចង់ធ្វើការងារពួកជននោះក៏ធ្វើទៅ ពួកជនណា មិនចង់ធ្វើការងារ ពួកជននោះក៏ខានធ្វើទៅ ។ ពួកជនចង់ធ្វើការណា ក៏ធ្វើការនោះទៅ មិនចង់ធ្វើការណាក៏ខានធ្វើការនោះទៅ ។ ឯយញ្ញពិធីនោះ ក៏សម្រេចដោយទឹកដោះថ្លាប្រេង ទឹកដោះខាប់ ទឹកដោះជូរ ទឹកឃ្មុំនិងទឹកអំពៅប៉ុណ្ណោះឯង ។

[៣០] ម្នាលព្រាហ្មណ៍ កាលនោះ ពួកក្សត្រិយ៍អ្នកនៅក្នុងនិគមនិងជនបទដែលនៅក្នុងព្រះរាជអំណាច ។ ពួកអមាត្យ រាជបរិសទ្យ ជាអ្នកនិគមនិងអ្នកជនបទ ។ ពួកព្រាហ្មណមហាសាល ជាអ្នកនិគមនិង

នេគមា ចេវ ជានបទា ច ។ គហបតិនេចយិកា នេគមា ចេវ ជានបទា ច បហូតំ សាបតេយ្យំ អាទាយ រាជានំ មហាវិជិតំ ឧបសង្កមិត្វា ឯវមាហំសុ ឥទំ តេ[១] ទេវ បហូតំ សាបតេយ្យំ ទេវំ យេវ[២] ឧទ្ទិស្ស អាភតំ តំ ទេវោ បដិគ្គណ្ហាតូតិ ។ អលំ ភោ មមាបិ ឥទំ[៣] បហូតំ សាបតេយ្យំ ធម្មិកេន ពលិនា អភិ-សង្ខតំ តញ្ច វោ ហោតុ ឥតោ ច ភិយ្យោ[៤] ហរ-ថាតិ ។ តេ រញ្ញា បដិក្ខិត្តា ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ[៥] ន ខោ ឯតំ អម្ហាកំ បដិរូបំ យំ[៦] មយំ ឥមានិ សាបតេយ្យានិ បុនទេវ សកានិ ឃរានិ បដិគ្គណ្ហេយ្យាម[៧] រាជា ខោ មហាវិជិតោ មហាយញ្ញំ យជតិ ហន្ទស្ស មយំ អនុយាតិនោ ហោមាតិ ។

---

១ ឱ. ម. តេតិបទំ ន ទិស្សតិ ។ ២ ម. ទេវញ្ញេវ ។ ៣ ឱ. មមបិ ឥទំ ។ ម. មមាបិទំ ។ ៤ ឱ. ភីយោ ។ ៥ ឱ. សម្មន្តេសុំ ។ ៦ ឱ. យំសទ្ទោ ន ទិស្សតិ ។ ៧ ឱ. ម. បដិហរេយ្យាម ។

អ្នកជនបទ ពួកគហបតីអ្នកសន្សំទ្រព្យ ជាអ្នកនិគមនិងអ្នកជនបទ ក៏នាំគ្នាយកទ្រព្យសម្បត្តិជាច្រើន ចូលទៅគាល់ព្រះបាទមហាវិជិតរាជ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ទ្រព្យសម្បត្តិច្រើនទាំងនេះជារបស់មហាបពិត្រ យើងខ្ញុំព្រះអង្គនាំមកថ្វាយ ចំពោះមហាបពិត្រ សូមមហាបពិត្រ ទ្រង់ទទួលនូវទ្រព្យសម្បត្តិនោះចុះ ។ ព្រះបាទមហាវិជិតរាជ ត្រាស់តបថា ណ្ហើយអ្នកទាំងឡាយ ទ្រព្យសម្បត្តិនៃខ្ញុំនេះឯង ដែលសម្រេចហើយ ដោយពលិកម្មប្រកបដោយធម៌ច្រើនណាស់ហើយ ទ្រព្យទាំងនោះ ត្រូវបានទៅអ្នកទាំងឡាយវិញចុះ មួយទៀត ចូរអ្នកទាំងឡាយ យកទ្រព្យរបស់ខ្ញុំឯង ថែមទៅទៀតខ្លះចុះ ។ ពួកជនទាំងនោះ កាលបើព្រះរាជាទ្រង់ប្រកែកហើយ ក៏ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយក៏គិតព្រមគ្នាយ៉ាងនេះថា បើពួកយើងយកទ្រព្យសម្បត្តិទាំងនេះទៅកាន់ផ្ទះខ្លួនវិញ ដោយហេតុណា ហេតុនោះឈ្មោះថាមិនសមគួរដល់ពួកយើងឡើយ ដ្បិតព្រះបាទមហាវិជិតរាជ កំពុងបូជាមហាយ័ញ្ញ បើដូច្នោះ ពួកយើង ចូរនាំគ្នាបូជាតាមព្រះអង្គទៅចុះ ។

៤១

កូដទន្តសុត្តេ  មហាវិជិតរាជមហាយញ្ញកថា

[៣១] អថខោ ព្រាហ្មណ បុរត្ថិមេន យញ្ញវាដស្ស[១] ខត្តិយា អនុយន្តា នេគមា ចេវ ជានបទា ច ទានានិ បដ្ឋបេសុំ ។ ទក្ខិណេន យញ្ញវាដស្ស អមច្ចា បារិសជ្ជា នេគមា ចេវ ជានបទា ច ទានានិ បដ្ឋបេសុំ ។ បច្ឆិមេន យញ្ញវាដស្ស ព្រាហ្មណមហាសាលា នេគមា ចេវ ជានបទា ច ទានានិ បដ្ឋបេសុំ ។ ឧត្តរេន យញ្ញវាដស្ស គហបតិនេចយិកា នេគមា ចេវ ជានបទា ច ទានានិ បដ្ឋបេសុំ ។ តស្មឹបិ ខោ[២] ព្រាហ្មណ យញ្ញេ នេវ គាវោ ហញ្ញឹសុ ន អជេឡកា ហញ្ញឹសុ ន កុក្កុដសូករា ហញ្ញឹសុ ន វិវិធា បាណា សង្ឃាតំ អាបជ្ជឹសុ ន រុក្ខា ឆិជ្ជឹសុ យូបត្ថាយ ន ទព្ភា លាយឹសុ ពរិហិសត្ថាយ ។ យេ នេសំ[៣] អហេសុំ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ ន ទណ្ឌតជ្ជិតា ន ភយតជ្ជិតា ន អស្សុមុខា រោទមានា បរិកម្មានិ អកំសុ ។ អថខោ យេ ឥច្ឆឹសុ

១ ឱ. ម. យញ្ញាវាដស្ស ។ ២ ឱ. ខោសទ្ទោ ន ទិស្សតិ ។ ៣ ឱ. យេបិ តេសំ ។ ម. យេបិ នេសំ ។

កូដទន្តសូត្រ ការពោលអំពីមហាយញ្ញរបស់ព្រះបាទមហាវិជិតរាជ

[៣១] ម្នាលព្រាហ្មណ៍ កាលនោះពួកក្សត្រិយ៍អ្នកនៅក្នុងនិគម និងនៅក្នុងជនបទ ដែលនៅក្នុងព្រះរាជអំណាច នាំគ្នាផ្តើមធ្វើទានក្នុងទិសខាងកើតនៃរោងយញ្ញ ។ ពួកអមាត្យ រាជបរិសទ្យ អ្នកនិគមនិងអ្នកជនបទ ក៏នាំគ្នាផ្តើមធ្វើទាន ក្នុងទិសខាងត្បូងនៃរោងយញ្ញ ។ ពួកព្រាហ្មណមហាសាល ជាអ្នកនិគមនិងអ្នកជនបទ ក៏នាំគ្នាផ្តើមធ្វើទានក្នុងទិសខាងលិចនៃរោងយញ្ញ ។ ពួកគហបតីអ្នកសន្សំទ្រព្យ ជាអ្នកនិគមនិងអ្នកជនបទ ក៏នាំគ្នាផ្តើមធ្វើទាន ក្នុងទិសខាងជើងនៃរោងយញ្ញ ។ ម្នាលព្រាហ្មណ៍ ក្នុងទីយញ្ញពិធីទាំងនោះ មនុស្សទាំងឡាយមិនបានសម្លាប់គោ មិនបានសម្លាប់ពពែនិងកែះ មិនបានសម្លាប់មាន់និងជ្រូក ពួកសត្វផ្សេង ៗ ក៏មិនដល់នូវសេចក្តីវិនាសឡើយ មិនបានកាប់ដើមឈើមកធ្វើជាគោល (សម្រាប់ចារឹកឈ្មោះ) ខានច្រូតស្បូវក្ញាំងដើម្បីឲ្យលំបាក (ដល់ជនឯទៀត) ។ ចំណែកខាងពួកមនុស្សណា ជាខ្ញុំកំដរក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការងារក្តី ជនទាំងនោះមិនបានត្រូវគម្រាមដោយអាជ្ញា មិនបានត្រូវគម្រាមឲ្យភ័យ មិនមានមុខជោកដោយទឹកភ្នែក ស្រែកទ្រហោយំធ្វើការងារឡើយ ។ ដោយសេចក្តីពិតនោះថា ពួកជនណា ចង់ធ្វើការងារ

តេ អកំសុ យេ ន ឥច្ឆឹសុ ន តេ អកំសុ ។ យំ ឥច្ឆឹសុ តំ អកំសុ យំ ន ឥច្ឆឹសុ តំ ន អកំសុ ។ សប្បិតេលនវនីតទធិមធុផាណិតេន ចេវ សោ យញ្ញោ និដ្ឋានមគមាសិ[១] ។ ឥតិ ចត្តារោ ច អនុមតិបក្ខា រាជា មហាវិជិតោ អដ្ឋហិ អង្គេហិ សមន្នាគតោ បុរោហិតោ ព្រាហ្មណោ ចតូហង្គេហិ សមន្នាគតោ តិស្សោ វិធា អយំ វុច្ចតិ ព្រាហ្មណ តិវិធា យញ្ញសម្បទា សោឡសបរិក្ខារាតិ ។

[៣២] ឯវំ វុត្តេ តេ ព្រាហ្មណា ឧន្នាទិនោ ឧច្ចាសទ្ទា មហាសទ្ទា អហោសុំ អហោ យញ្ញោ អហោ យញ្ញសម្បទាតិ ។ កូដទន្តោ បន ព្រាហ្មណោ តុណ្ហីភូតោ វ និសិន្នោ ហោតិ ។ អថខោ តេ ព្រាហ្មណា កូដទន្តំ ព្រាហ្មណំ ឯតទវោចុំ កស្មា បន ភវំ កូដទន្តោ សមណស្ស គោតមស្ស សុភាសិតំ សុភាសិតតោ នាព្ភនុមោទតីតិ ។ នាហំ ភោ

១ ឱ. តេ យញ្ញា និដ្ឋានមាគមឹសុ ។

ពួកជននោះក៏ធ្វើទៅ ពួកជនណា មិនចង់ធ្វើការងារ ពួកជននោះក៏ខាន ធ្វើទៅ ពួកជនចង់ធ្វើការងារណា ក៏ធ្វើការងារនោះទៅ មិនចង់ធ្វើការងារ ណា ក៏ខានធ្វើការងារនោះទៅ ។ ឯយញ្ញពិធីនោះ ក៏សម្រេចដោយទឹក ដោះថ្លា ប្រេង ទឹកដោះខាប់ ទឹកដោះជូរ ទឹកឃ្មុំ និងទឹកអំពៅប៉ុណ្ណោះ ឯង ។ ម្នាលព្រាហ្មណ៍ ជនទាំង ៤ ពួក មានគំនិតយល់ត្រូវគ្នា ១ ព្រះ បាទមហាវិជិតរាជប្រកបដោយអង្គ ៨ ប្រការ ១ ព្រាហ្មណបុរោហិត ប្រកបដោយអង្គ ៤ ប្រការ ១ រួមជាយញ្ញវិធី ៣ យ៉ាង នេះហៅថាយញ្ញ-សម្បទា ៣ យ៉ាង មានបរិក្ខារ ១៦ ដោយប្រការដូច្នេះឯង ។

[៣២] កាលបើព្រះសាស្តា ទ្រង់មានព្រះពុទ្ធតម្រាស់យ៉ាងនេះ ហើយ ពួកព្រាហ្មណ៍ទាំងនោះមានសំឡេងបន្ទឺគឹកកង មានសំឡេង ហ៊ោ សំឡេងស្រែកថា អើហ្ន៎ យ័ញ្ញ យញ្ញសម្បទាហ្ន៎ ។ ឯកូដទន្ត-ព្រាហ្មណ៍ក៏អង្គុយនៅស្ងៀម ។ លំដាប់នោះ ព្រាហ្មណ៍ទាំងនោះបាន ពោលពាក្យនេះនឹងកូដទន្តព្រាហ្មណ៍ថា ព្រោះហេតុអ្វី បានជាលោក កូដទន្តៈ មិនត្រេកអររីករាយ នឹងសុភាសិតរបស់ព្រះសមណគោតម ដោយ ពាក្យជាសុភាសិតសោះ ។ កូដទន្តព្រាហ្មណ៍ឆ្លើយថា នែអ្នក

៤៣

កូដទន្តសុត្តេ កូដទន្តព្រាហ្មណបរិវិតក្កោ

សមណស្ស គោតមស្ស សុភាសិតំ សុភាសិតតោ ន អព្ភនុមោទាមិ មុទ្ធាបិ តស្ស និប្បតេយ្យ[1] យោ សមណស្ស គោតមស្ស សុភាសិតំ សុភាសិតតោ ន អព្ភានុមោទេយ្យ អបិច មេ ភោ ឯវំ ហោតិ សមណោ គោតមោ ឯវមាហ[2] ឯវំ មេ សុតន្តិ វា ឯវំ អរហតិ ភវិតុន្តិ វា អបិច សមណោ គោតមោ ឯវំ តទា អាសិ ឥត្ថំ តទា អាសិត្វេវ ភាសតិ[3] តស្ស មយ្ហំ ភោ ឯវំ ហោតិ អទ្ធា សមណោ គោតមោ តេន សមយេន រាជា ហោតិ[4] មហាវិជិតោ យញ្ញសាមី បុរោហិតោ[5] តស្ស យញ្ញស្ស យាជេតាតិ ។ អភិជានាតិ បន ភវំ គោតមោ ឯវរូបំ យញ្ញំ យជិត្វា វា យាជេត្វា វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិតាតិ ។ អភិជានាមហំ ព្រាហ្មណ ឯវរូបំ

១ ឱ. ម. វិបតេយ្យ ។ ២ ឱ. ម. ន ឯវមាហ ។ ៣ ឱ. អភាសិ ។ ៤ ឱ. ម. រាជា វា អហោសិ ។ ៥ ឱ. ម. បុរោហិតោ វា ព្រាហ្មណោ ។

ទាំងឡាយដ៏ចម្រើន ខ្ញុំមិនមែនជាមិនត្រេអររីករាយ នឹងសុភាសិតរបស់ព្រះសមណគោតម ដោយពាក្យជាសុភាសិតទេ បើបុគ្គលណា មិនត្រេកអររីករាយ នឹងសុភាសិតរបស់ព្រះសមណគោតម ដោយពាក្យជាសុ-ភាសិតទេ ក្បាលរបស់បុគ្គលនោះនឹងបែកមិនខាន ម្នាលអ្នកទាំងឡាយដ៏ចម្រើន មួយទៀត ខ្ញុំនៅមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណ-គោតម មានព្រះពុទ្ធតម្រាស់យ៉ាងនេះថា តថាគតបានឮមកយ៉ាងនេះ ឬថាហេតុនោះគួរនឹងទៅជាយ៉ាងនេះ មួយយ៉ាងទៀត ព្រះសមណគោ-តម មានព្រះពុទ្ធតម្រាស់ថា រឿងយ៉ាងនេះបានមានហើយ ក្នុងកាលនោះ រឿងនេះបានមានហើយ ក្នុងកាលនោះឯង ម្នាលអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំមានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងសម័យនោះ ព្រះសមណគោតម ជាព្រះបាទមហាវិជិតរាជ ជាម្ចាស់យ័ញ្ញដោយពិត ឯបុរោហិតគ្រាន់តែជាអ្នកណែនាំឲ្យបូជាយ័ញ្ញ របស់ព្រះអង្គ ។ កូដទន្តព្រាហ្មណ៍ទូលសួរថា ចុះព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបថា បុគ្គលបូជាឯងក្តី ឲ្យគេបូជាក្តី នូវយ័ញ្ញមានសភាពយ៉ាងនេះ លុះទំលាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ នឹងបានចូលទៅកាន់លោក គឺមនុស្សសុគតិនិងឋានសួគ៌ដូច្នេះដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតដឹង

យញ្ញំ យជិត្វា ច[១] យាជេត្វា ច[២] កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិតាតិ អហំ តេន សមយេន ព្រាហ្មណ[៣] បុរោហិតោ ព្រាហ្មណោ អហោសឹ តស្ស យញ្ញស្ស យាជេតាតិ ។

[៣៣] អត្ថិ បន ភោ គោតម អញ្ញោ យញ្ញោ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ អត្ថិ[៤] ព្រាហ្មណ អញ្ញោ យញ្ញោ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ កតមោ បន ភោ គោតម សោ[៥] យញ្ញោ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ យានិ ខោ[៦] តានិ ព្រាហ្មណា និច្ចទានានិ អនុកុលយញ្ញានិ សីលវន្តេ បព្វជិតេ

---

១-២ ឱ. ម. វា ។ ៣ ឱ. ម. ព្រាហ្មណសទ្ទោ ន ទិស្សតិ ។ ៤ ឱ. ម. អត្ថិ ខោ ។ ៥ ឱ. ម. សោ ភោ គោតម ។ ៦ ម. ខោ បន ។

ច្បាស់ថា បុគ្គលបូជាឯងក្តី ឲ្យគេបូជាក្តី នូវយ័ញ្ញមានសភាពយ៉ាងនេះ លុះទំលាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ នឹងបានចូលទៅកាន់លោក គឺមនុស្សសុគតិនិងឋានសួគ៌ ម្នាលព្រាហ្មណ៍ សម័យនោះ តថាគតជាព្រាហ្មណបុរោហិត ជាអ្នកណែនាំឲ្យបូជាយ័ញ្ញ របស់ព្រះបាទមហាវិជិតរាជនោះ ។

[៣៣] កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ័ញ្ញឯទៀតមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ១៦នេះ មានដែរឬទេ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ យ័ញ្ញឯទៀតមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះ មានដែរ ។ កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ចុះយ័ញ្ញដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នោះតើដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ និច្ចកត្តទានគឺយ័ញ្ញដែលប្រព្រឹត្តទៅ តាមលំដាប់ត្រកូលណា ដែលបុគ្គលឲ្យចំពោះពួកបព្វជិត

ឧទ្ទិស្ស ទីយន្តិ អយំ ខោ បន[១] ព្រាហ្មណ យញ្ញោ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេន តំ[២] និច្ចទានំ អនុកុលយញ្ញំ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បដ្ឋតរញ្ច អប្បសមារម្ភតរញ្ច មហប្ផលតរញ្ច មហានិសំសតរញ្ចាតិ ។ ន ខោ ព្រាហ្មណ ឯវរូបំ យញ្ញំ ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ[៣] វា សមាបន្នា តំ កិស្ស ហេតុ ទិស្សន្តិ ហេត្ថ ព្រាហ្មណ ទណ្ឌប្បហារាបិ គលគ្គហាបិ តស្មា ឯវរូបំ យញ្ញំ ន ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា យានិ ខោ បន តានិ ព្រាហ្មណ និច្ចទានានិ អនុកុលយញ្ញានិ សីលវន្តេ បព្វជិតេ ឧទ្ទិស្ស ទីយន្តិ ឯវរូបំ ខោ បន ព្រាហ្មណ យញ្ញំ ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា

---

១ ឱ. ម. ខោ ។ ២ យេនេតន្តិបិ បាឋោ ។ ៣ ឱ. អរហន្តមគ្គំ ។

អ្នកមានសីល ម្នាលព្រាហ្មណ៍ យ័ញ្ញនេះឯងហើយដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិ-សង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះ ។ កូដទន្តព្រាហ្មណ៍ ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលធ្វើឲ្យនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូល មានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការដែលមានបរិក្ខារ ១៦ នេះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកអរហន្ត ឬពួកអ្នកដែលបានសម្រេចនូវអរហត្តមគ្គ មិនបានចូលទៅរកយញ្ញពិធីមានសភាពយ៉ាងនេះទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះការប្រហារដោយដំបងក្តី ការចាប់ត្រង់បំពង់កក្តី រមែងមានប្រាកដតែក្នុងយញ្ញវិធីនុ៎ះ ព្រោះហេតុដូច្នោះ ពួកព្រះអរហន្ត ឬពួកអ្នកដែលបានសម្រេចនូវអរហត្តមគ្គ មិនចូលទៅរកយញ្ញពិធីមានសភាពយ៉ាងនេះ ម្នាលព្រាហ្មណ៍ និច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូលណា ដែលគេឲ្យចំពោះពួកបព្វជិតអ្នកមានសីល ម្នាលព្រាហ្មណ៍ ពួកអរហន្តឬពួកលោកដែលបានសម្រេចនូវអរហត្តមគ្គ រមែង

តំ កិស្ស ហេតុ ន ហេត្ថ ព្រាហ្មណ ឆិស្សន្តិ ទណ្ឌាប្ប-ហារាបិ គលគ្គហាបិ តស្មា ឯវរូបំ យញ្ញំ ឧបសង្កមន្តិ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា អយំ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេន តំ និច្ចទានំ អនុកុលយញ្ញំ ឥមាយ តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ អប្បត្ថតរញ្ច អប្បសមារម្ភតរញ្ច មហប្ផលតរញ្ច មហានិសំសតរញ្ចាតិ ។

[៣៤] អត្ថិ បន ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសប-រិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន អប្បត្ថតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ អត្ថិ ខោ ព្រាហ្មណ អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្ប-ទាយ ។ បេ ។ កតមោ បន សោ ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ

ចូលទៅរកយ័ញ្ញមានសភាពយ៉ាងនេះ ដំណើរនោះ ព្រោះអ្វី ម្នាលព្រាហ្មណ៍ ព្រោះហេតុថា ការប្រហារដោយដំបងក្តី ការចាប់ត្រង់បំពង់កក្តី រមែងមិនប្រាកដ ក្នុងយញ្ញវិធីនុ៎ះទេ ហេតុដូច្នោះ បានជាពួកអរហន្ត ឬពួកអ្នកដែលបានសម្រេចអរហត្តមគ្គ រមែងចូលទៅរកយញ្ញ-ពិធីមានសភាពយ៉ាងនេះ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលធ្វើឲ្យនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូល ដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះឯង ។

[៣៤] កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន យ័ញ្ញឯទៀតដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទានគឺយ័ញ្ញដែលប្រ-ព្រឹត្តទៅតាមលំដាប់ត្រកូលនេះផង មានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ យ័ញ្ញឯទៀត មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ប្រការនេះផង មានដែរ ។ បេ ។ កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះយ័ញ្ញឯទៀត មានអានិសង្សច្រើនជាង

។ បេ ។ យោ ខោ ព្រាហ្មណ ចាតុទ្ទិសំ សង្ឃំ ឧទ្ទិស្ស វិហារំ ករោតិ អយម្បិ ខោ ព្រាហ្មណ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខា-រាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។

[៣៥] អត្ថិ បន ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ ។ បេ ។ មហានិសំសតរោ ចាតិ ។ អត្ថិ ខោ ព្រាហ្មណ អញ្ញោ យញ្ញោ ។ បេ ។ កតមោ បន សោ ភោ គោតម អញ្ញោ យញ្ញោ ។ បេ ។ យោ ខោ ព្រាហ្មណ បសន្នចិត្តោ ពុទ្ធំ សរណំ គច្ឆតិ ធម្មំ សរណំ គច្ឆតិ សង្ឃំ សរណំ គច្ឆតិ អយំ ខោ ព្រាហ្មណ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្ប-ទាយ សោឡសបរិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន ឥមិនា ច វិហារទានេន អប្បដ្ឋ-តរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។

យញ្ញសម្បទា ៣ ប្រការនេះផង តើដូចម្តេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលណា បានធ្វើវិហារចំពោះសង្ឃ ដែលមកអំពីទិសទាំង ៤ ម្នាលព្រាហ្មណ៍ យ័ញ្ញនេះឯង ដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន និងមានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូលនេះផង ។

[៣៩] កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ័ញ្ញឯទៀត ។ បេ ។ មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការនេះផង មានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ យ័ញ្ញឯទៀតមានដែរ ។ បេ ។ កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះយ័ញ្ញឯទៀតនោះ តើដូចម្តេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលណាមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធជាសរណៈ ដល់នូវព្រះធម៌ជាសរណៈ ដល់នូវព្រះសង្ឃជាសរណៈ ម្នាលព្រាហ្មណ៍ យ័ញ្ញនេះឯងដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូលនេះផង ជាងវិហារទាននេះផង ។

[៣៦] អត្ថិ បន ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន ។ បេ ។ អប្បត្ថតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ អត្ថិ ខោ ព្រាហ្មណ អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ ។ បេ ។ កតមោ បន សោ ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ ។ បេ ។ យោ ខោ ព្រាហ្មណ បសន្នចិត្តោ សិក្ខាបទានិ សមាទិយតិ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី អយំ ខោ ព្រាហ្មណ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន ។ បេ ។ អប្បត្ថតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។

[៣៦] កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន យ័ញ្ញឯទៀតមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុង-ប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូលនេះផង ។ បេ ។ មានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ យ័ញ្ញឯទៀត មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការនេះផង មានដែរ ។ បេ ។ កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន យ័ញ្ញឯទៀតមានអានិសង្សច្រើនជាងយញ្ញសម្បទា ៣ ប្រការនេះផង តើដូចម្តេច ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលណាមានចិត្តជ្រះថ្លា បានសមា-ទាននូវសិក្ខាបទទាំងឡាយ គឺចេតនាធម៌ជាហេតុវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ម្នាលព្រាហ្មណ៍ យ័ញ្ញនេះឯងដែលមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយញ្ញដែលប្រព្រឹត្តទៅតាមលំដាប់នៃត្រកូលនេះផង ។ បេ ។

កូដទន្តសុត្តេ ពុទ្ធយញ្ញកថា តថាគតស្ស ឧប្បាទោ

[៣៧] អត្ថិ បន ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន ។ បេ ។ អត្ថិ ខោ ព្រាហ្មណ អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ សោឡសបរិក្ខារាយ ឥមិនា ច និច្ចទានេន អនុកុលយញ្ញេន ឥមិនា ច វិហារទានេន ឥមេហិ ច សរណគមនេហិ ឥមេហិ ច សិក្ខាបទេហិ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ កតមោ បន សោ ភោ គោតម អញ្ញោ យញ្ញោ ឥមាយ ច តិវិធាយ យញ្ញសម្បទាយ ។ បេ ។ អប្បដ្ឋតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ចាតិ ។ ឥធ ព្រាហ្មណ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ សព្ពំ វិត្ថារេតព្ពំ) ។ បេ ។ ឯវំ ខោ ព្រាហ្មណ ភិក្ខុ សីលសម្បន្នោ ហោតិ ។

## កូដទន្តសូត្រ ពុទ្ធយញ្ញកថា ការកើតឡើងនៃព្រះតថាគត

[៣៧] កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះយ័ញ្ញឯទៀត មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅ តាមលំដាប់នៃត្រកូលនេះផង មានដែរឬ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ យ័ញ្ញឯទៀតមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ នេះផង ជាងនិច្ចភត្តទាន គឺយ័ញ្ញដែលប្រព្រឹត្តទៅ តាមលំដាប់ត្រកូលនេះផង ជាងវិហារទាននេះផង ជាងសរណគមន៍ទាំងនេះផង ជាងសិក្ខាបទទាំងនេះផង មានដែរ ។ កូដទន្តព្រាហ្មណ៍ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះយ័ញ្ញឯទៀតមានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញសម្បទា ៣ ប្រការនេះផង ។ បេ ។ នោះ តើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោកនេះ ។ បេ ។ (បណ្ឌិតគប្បីសំដែងពាក្យទាំងអស់ឲ្យពិស្តារ ដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលព្រាហ្មណ៍ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។

បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ ខោ ព្រាហ្មណ យញ្ញោ បុរិមេហិ យញ្ញេហិ អប្បត្ថតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ច ។ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំបិ ខោ ព្រាហ្មណ យញ្ញោ បុរិមេហិ យញ្ញេហិ អប្បត្ថតរោ ច អប្បសមារម្ភតរោ ច មហប្ផលតរោ ច មហានិសំសតរោ ច ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ ព្រាហ្មណ យញ្ញោ បុរិមេហិ យញ្ញេហិ អប្បត្ថតរោ ច អប្បសមារម្ភតរោ ច ព្រាហ្មណ យញ្ញសម្បទាយ អញ្ញា យញ្ញសម្បទា ឧត្តរិតរា វា បណីតតរា វា នត្ថីតិ ។

ភិក្ខុនោះឯង រមែងចូលដល់បឋមជ្ឈាន សម្រាន្តឥរិយាបថនៅ ។ ម្នាលព្រាហ្មណ៍ យញ្ញនេះឯង មានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញទាំងឡាយអំពីមុន ៗ ។ ភិក្ខុនោះ រមែងចូលដល់ទុតិយជ្ឈាន ។ តតិយជ្ឈាន ។ ចតុត្ថជ្ឈាន សម្រាន្តឥរិយាបថនៅ ។ ម្នាលព្រាហ្មណ៍ យញ្ញនេះឯង មានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញទាំងឡាយមុន ៗ ។ ភិក្ខុនោះរមែងតម្រង់ផ្ចង់បង្អោនចិត្តដើម្បីញាណទស្សនៈ ហើយដឹងច្បាស់ថា ជាតិរបស់អញអស់ហើយ ព្រហ្មចរិយៈអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចក៏អញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៅទៀតមិនមានឡើយ ។ ម្នាលព្រាហ្មណ៍ យញ្ញនេះឯង មានសេចក្តីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើន ជាងយញ្ញទាំងឡាយមុន ៗ ម្នាលព្រាហ្មណ៍ មួយទៀត យញ្ញសម្បទាឯទៀតលើសលុបជាង ឬថ្លៃថ្លាជាងយញ្ញសម្បទាននេះ មិនមានឡើយ ។

កូដទន្តសុត្តេ កូដទន្តព្រាហ្មណស្ស ឧបាសកត្តទេសនា

[៣៨] ឯវំ វុត្តេ កូដទន្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតំ ឯសាហំ ភោ គោតម សត្ត ច ឧសភសតានិ សត្ត ច វច្ឆតរសតានិ សត្ត ច វច្ឆតរិសតានិ សត្ត ច អជសតានិ សត្ត ច ឧរព្ភសតានិ មុញ្ចាមិ ជីវិតំ ទេមិ ហរិតានិ ចេវ តិណានិ ខាទន្តុ សីតានិ ច បានីយានិ បិវន្តុ សីតោ នេសំ វាតោ ឧបវាយតូតិ[១] ។

---

១ ឱ. សីតោ ច នេសំ វាតោ ឧបវាយតន្តិ ។

កូដទន្តសូត្រ ការសំដែងខ្លួនជាឧបាសកនៃកូដទន្តព្រាហ្មណ៍

[៣៨] កាលបើព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់យ៉ាងនេះហើយ កូដទន្ត-ព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់សំដែងហើយដោយអនេកបរិយាយនេះឯង ប្រៀបដូចជាគេបើករបស់ដែលផ្កាប់ឲ្យផ្ងារឡើង ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ឬដូចជាបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាគេទ្រោលប្រទីប ក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែកនឹងមើលឃើញរូបបាន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវរតនត្រ័យជាសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនេះនឹងដោះលែងគោឈ្មោល ៧០០ កូនគោឈ្មោល ៧០០ កូនគោញី ៧០០ ពពែ ៧០០ កែះ ៧០០ ខ្ញុំព្រះអង្គនឹងឲ្យជីវិត ចូរឲ្យសត្វទាំងនេះទំពាស៊ីនូវស្មៅស្រស់ផង ចូរផឹកនូវទឹកត្រជាក់ផង ចូរឲ្យខ្យល់ត្រជាក់បក់មកត្រូវសត្វទាំងនោះចុះ ។

[៣៩] អថខោ ភគវា ពោក្ខរសាតិស្ស ព្រាហ្មណស្ស អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ ពោក្ខរសាតិំ ព្រាហ្មណំ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ពោក្ខរសាតិស្ស ព្រាហ្មណស្ស តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ អថខោ ពោក្ខរសាតិ ព្រាហ្មណោ ទិដ្ឋធម្មោ បត្តធម្មោ

[៣៩] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងនូវអនុបុព្វីកថា ចំពោះកូដទន្តព្រាហ្មណ៍ អនុបុព្វីកថានោះដូចម្តេច គឺព្រះអង្គទ្រង់ប្រកាស ទានកថា សីលកថា សគ្គកថា ប្រកាសទោសរបស់កាមដ៏ថោកទាបសៅហ្មង ប្រកាសនូវអានិសង្ស ក្នុងកិរិយាចេញចាកកាម ។ កាលណាព្រះមានព្រះភាគ បានជ្រាបថា កូដទន្តព្រាហ្មណ៍មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាហើយ កាលនោះ ព្រះអង្គក៏ទ្រង់សំដែងធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺប្រកាសនូវទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ។ ធម្មតាសំពត់ដ៏ស្អាត ប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អបាន យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់កូដទន្តព្រាហ្មណ៍ លើអាសនៈនោះឯង ថា ធម្មជាតឯណានីមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានសេចក្តីរលត់ទៅជាធម្មតា យ៉ាងនោះឯង ។ លំដាប់នោះ កូដទន្តព្រាហ្មណ៍បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌

វិជិតជម្មោ បរិយោគាឡ្ហជម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុសាសនេ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ កូដទន្តោ ព្រាហ្មណោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[៤០] អថខោ កូដទន្តោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន សកេ យញ្ញវាដេ បណីតំ ខាទនីយភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន កូដទន្តស្ស ព្រាហ្មណស្ស យញ្ញវាដោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ កូដទន្តោ ព្រាហ្មណោ

បានដឹងច្បាស់អរិយសច្ចធម៌ បានជ្រៀបច្បាស់អរិយសច្ចធម៌ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវភាវៈជាអ្នកក្លាហានមិនបាច់អាងបុគ្គលដទៃ (ដឹកនាំ) ក្នុងសាសនារបស់ព្រះសាស្តា ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើនព្រមទាំងភិក្ខុសង្ឃ ទទួលនូវភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ កូដទន្តព្រាហ្មណ៍បានដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។

[៤០] គ្រាកាលដែលកន្លងរាត្រីនោះទៅ កូដទន្តព្រាហ្មណ៍ក៏ប្រើគេតាក់តែង នូវខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ក្នុងរោងយញ្ញពិធីរបស់ខ្លួន ហើយឲ្យក្រាបបង្គំទូលនូវភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលដល់ហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ទ្រង់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរទៅកាន់រោងយញ្ញពិធី របស់កូដទន្តព្រាហ្មណ៍ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ កូដទន្តព្រាហ្មណ៍ ក៏បានអង្គាស

ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជ-
នីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ
កូដទន្តោ ព្រាហ្មណោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ
អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នំ ខោ កូដទន្តំ ព្រាហ្មណំ ភគវា
ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេ-
ជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមីតិ ។

កូដទន្តសុត្តំ បញ្ចមំ និដ្ឋិតំ ។

ខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ត្រាតែឃាត់ ។ លុះកូដទន្ត-ព្រាហ្មណ៍ដឹងថា ព្រះមានព្រះភាគសោយរួចហើយ លែងលូកព្រះហស្ត ក្នុងបាត្រទៀតហើយ ក៏កាន់យកអាសនៈមួយទាបជាង ហើយអង្គុយក្នុង ទីដ៏សមគួរ ។ លុះកូដទន្តព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរស៊ប់ហើយ ព្រះ មានព្រះភាគ ក៏ទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាច ហាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈស្ដេច ចេញទៅ ។

ចប់ កូដទន្តសូត្រទី ៥ ។

# មហាលិសុត្តំ ឆដ្ឋំ

[៤១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សម្ពហុលា កោសលកា ច ព្រាហ្មណទូតា មាគធកា ច ព្រាហ្មណទូតា វេសាលិយំ បដិវសន្តិ កេនចិទេវ ករណីយេន ។ អស្សោសុំ ខោ តេ កោសលកា ច ព្រាហ្មណទូតា មាគធកា ច ព្រាហ្មណទូតា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា ។ បេ ។ ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ ។ បេ ។ តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ តេ កោស-

# មហាលិសូត្រ ទី ៦

[៤១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង ពួកព្រាហ្មណទូត អ្នកដែនកោសលនិងព្រាហ្មណទូត អ្នកដែនមគធៈច្រើននាក់ ចូលទៅអាស្រ័យនៅ ក្នុងក្រុងវេសាលី ដោយករណីយកិច្ចណានីមួយ ។ ពួកព្រាហ្មណទូត អ្នកដែនកោសលនិងព្រាហ្មណទូត អ្នកដែនមគធៈនោះ បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្ត ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួសហើយ ឥឡូវមកគង់នៅ ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយ សុះសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ (ជាព្រះអរហន្ត) ។ បេ ។ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះមានព្រះភាគនោះ ញ៉ាំងលោកនេះព្រមទាំងទេវលោក និងមារលោក ។ បេ ។ ការដែលបានឃើញបានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពយ៉ាងហ្នឹង (ជាការប្រពៃពេក) ។ គ្រានោះឯង ពួកព្រាហ្មណ-

លកា ច ព្រាហ្មណទូតា មាគធកា ច ព្រាហ្មណ-ទូតា យេន មហាវនំ កូដាគារសាលា តេនុបសង្ក-មឹសុ ។

[៤២] តេន ខោ បន សមយេន អាយស្មា នាគិតោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ តេ កោ-សលកា ច ព្រាហ្មណទូតា មាគធកា ច ព្រាហ្ម-ណទូតា យេនាយស្មា នាគិតោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ នាគិតំ ឯតទវោចុំ កហំ នុ ខោ ភោ នាគិត ឯតរហិ សោ ភវំ គោតមោ វិហរតិ ទស្សនកាមា ហិ មយំ តំ ភវន្តំ គោតមន្តិ ។ អកាលោ ខោ អាវុសោ ភគវន្តំ ទស្សនាយ បដិសល្លី-នោ ភគវាតិ ។ អថខោ តេ កោសលកា ច ព្រាហ្ម-ណទូតា មាគធកា ច ព្រាហ្មណទូតា តត្ថេវ ឯក-មន្តំ និសីទឹសុ ទិស្វា វ មយំ តំ ភវន្តំ គោតមំ គច្ឆិស្សាមាតិ[១] ។

១ ឱ. ម. គមិស្សាមាតិ ។

ទូត អ្នកដែនកោសលនិងពួកព្រាហ្មណទូត អ្នកដែនមគធៈនោះ ក៏បានចូលសំដៅទៅកាន់កូដាគារសាលាព្រៃមហាវ័ន ។

[៤២] សម័យនោះឯង ព្រះនាគិតត្ថេរមានអាយុ ជាឧបដ្ឋាកព្រះមានព្រះភាគ ។ គ្រានោះ ពួកព្រាហ្មណទូត អ្នកដែនកោសលនិងពួកព្រាហ្មណទូត អ្នកដែនមគធៈនោះ ចូលសំដៅទៅរកកន្លែងដែលព្រះនាគិតត្ថេរមានអាយុគង់នៅ លុះចូលទៅដល់ហើយ ទើបពោលពាក្យនេះនឹងព្រះនាគិតត្ថេរមានអាយុថា បពិត្រព្រះនាគិតៈដ៏ចម្រើន ឥឡូវនេះព្រះគោតមដ៏ចម្រើននោះ ព្រះអង្គគង់នៅទីណា ដ្បិតយើងខ្ញុំចង់ទៅគាល់ព្រះគោតមដ៏ចម្រើននោះ ។ ព្រះនាគិតត្ថេរមានអាយុពោលថា ម្នាលអ្នកមានអាយុទាំងឡាយ កាលនេះមិនមែនជាកាលគួរ នឹងទៅគាល់ព្រះមានព្រះភាគទេ (ព្រោះ) ព្រះមានព្រះភាគកំពុងសម្រាកព្រះអង្គ ។ គ្រានោះ ពួកព្រាហ្មណទូត អ្នកដែនកោសលនិងព្រាហ្មណទូត អ្នកដែនមគធៈនោះ អង្គុយនៅក្នុងទីសមគួរ ក្បែរកន្លែងនោះហើយប្រឹក្សាគ្នាថា យើងទាំងឡាយចាំគាល់ព្រះគោតមដ៏ចម្រើននោះឲ្យបាន ហើយសឹមទៅ ។

មហាលិសុត្តេ សុត្តនិទានំ

[៤៣] ឱដ្ឋទ្ធោបិ ខោ[១] លិច្ឆវី មហតិយា លិច្ឆវិបរិសាយ សទ្ធឹ យេន មហាវនំ កូដាគារសាលា យេនាយស្មា នាគិតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ នាគិតំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ឱដ្ឋទ្ធោបិ លិច្ឆវី អាយស្មន្តំ នាគិតំ ឯតទវោច កហន្នុ ខោ ភន្តេ នាគិត ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោ ទស្សនកាមា ហិ មយំ តំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អកាលោ ខោ មហាលិ ភគវន្តំ ទស្សនាយ បដិសល្លីនោ ភគវាតិ ។ ឱដ្ឋទ្ធោបិ លិច្ឆវី តត្ថេវ ឯកមន្តំ និសីទិ ទិស្វា វាហំ តំ ភគវន្តំ គមិស្សាមិ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។

[៤៤] អថខោ សីហោ សមណុទ្ទេសោ យេនាយស្មា នាគិតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ នាគិតំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ

១ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។

មហាលិសូត្រ សុត្តនិទាន

[៤៣] ឯក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវី[១] បានចូលសំដៅទៅកាន់កូដាគារ-សាលា នាព្រៃមហាវ័ន ត្រង់កន្លែងដែលព្រះនាគិតត្ថេរមានអាយុគង់នៅជាមួយនឹងលិច្ឆវិបរិសទ្យជាច្រើន លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះនាគិតត្ថេរមានអាយុ រួចបិតនៅក្នុងទីដ៏សមគួរ ។ លុះក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវីបិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះនាគិតត្ថេរមានអាយុថា បពិត្រព្រះនាគិតត្ថេរៈដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធគង់ក្នុងទីណា ដ្បិតយើងខ្ញុំចង់ទៅគាល់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ។ ព្រះនាគិតត្ថេរមានអាយុពោលថា ម្នាលមហាលិ កាលនេះមិនមែនជាកាលគួរនឹងគាល់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគកំពុងសម្រាកព្រះអង្គ ។ ក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវីក៏គង់នៅក្នុងទីសមគួរ[២] ក្បែរកន្លែងនោះ ហើយគិតថា អញចាំគាល់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះឲ្យបាន ហើយសឹមទៅ ។

[៤៤] គ្រានោះ សមណុទ្ទេសឈ្មោះសីហៈ ចូលសំដៅទៅត្រង់កន្លែងដែលព្រះនាគិតត្ថេរមានអាយុគង់នៅ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះនាគិតត្ថេរមានអាយុ រួចបិតនៅទីដ៏សមគួរ ។ លុះ

---

១ អដ្ឋកថា ថា បានជាមាននាមដូច្នេះ ព្រោះជាអ្នកតាំងនៅក្នុងដំណែងដ៏ស្អុកស្គម្ភ ។
២ អដ្ឋកថា ថា គង់ក្រោមម្លប់ឈើដ៏ស្រួល ហើយពោលសរសើរគុណព្រះរតនត្រ័យ ជាមួយនឹងលិច្ឆវិបរិសទ្យ ។

ឋិតោ ខោ សីហោ សមណុទ្ទេសោ អាយស្មន្តំ នា-
គិតំ ឯតទវោច ឯតេ ភន្តេ កស្សប សម្ពហុលា
កោសលកា ច ព្រាហ្មណទូតា មាគធកា ច
ព្រាហ្មណទូតា ឥធូបសង្កន្តា ភគវន្តំ ទស្សនាយ ឱដ្ឋ-
ទ្ធោបិ លិច្ឆវី មហតិយា លិច្ឆវិបរិសាយ សទ្ធឹ ឥធូប-
សង្កន្តោ ភគវន្តំ ទស្សនាយ សាធុ ភន្តេ កស្សប
លភតំ ឯសា ជនតា ភគវន្តំ[១] ទស្សនាយាតិ ។
តេនហិ សីហ ត្វញ្ញេវ ភគវតោ អារោចេហីតិ ។
ឯវំ ភន្តេតិ ខោ សីហោ សមណុទ្ទេសោ អាយស្មតោ
នាគិតស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។
ឯកមន្តំ ឋិតោ ខោ សីហោ សមណុទ្ទេសោ ភគវន្តំ
ឯតទវោច ឯតេ ភន្តេ សម្ពហុលា កោសលកា ច
ព្រាហ្មណទូតា មាគធកា ច ព្រាហ្មណទូតា ឥ-
ធូបសង្កន្តា ភគវន្តំ ទស្សនាយ ឱដ្ឋទ្ធោបិ លិច្ឆវី

---

១ ឱ. ភគវន្តន្តិ ន ទិស្សតិ ។

សីហសមណុទ្ទេសឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះនាគិតត្ថេរមានអាយុថា បពិត្រព្រះកស្សប(១) ដ៏ចម្រើន ពួកព្រាហ្មណ-ទូត អ្នកដែនកោសលនិងពួកព្រាហ្មណទូត អ្នកដែនមគធៈ ជាច្រើនទាំងនុ៎ះចូលមកក្នុងទីនេះ ដើម្បីគាល់ព្រះមានព្រះភាគ ក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវី ក៏ចូលមកក្នុងទីនេះ ជាមួយនឹងលិច្ឆវិបរិសទ្យជាច្រើន ដើម្បីគាល់ព្រះមានព្រះភាគដែរ បពិត្រព្រះកស្សបដ៏ចម្រើន សូមឲ្យប្រជុំជនទាំងនេះបានគាល់ព្រះមានព្រះភាគផង ។ ព្រះនាគិតត្ថេរពោលថា ម្នាលសីហៈ បើដូច្នោះចូរអ្នកក្រាបបង្គំទូលព្រះមានព្រះភាគខ្លួនឯងចុះ ។ សីហសមណុទ្ទេសទទួលពាក្យព្រះនាគិតត្ថេរមានអាយុថា យ៉ាងហ្នឹងហើយ ព្រះករុណាដ៏ចម្រើន ហើយចូលសំដៅទៅត្រង់កន្លែង ដែលព្រះមានព្រះភាគគង់នៅលុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ លុះសីហសមណុទ្ទេសឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណទូតអ្នកដែនកោសលនិងពួកព្រាហ្មណទូត អ្នកដែនមគធៈ ច្រើននាក់ទាំងនុ៎ះចូលមកក្នុងទីនេះ ដើម្បីគាល់ព្រះមានព្រះភាគ ទាំងក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវី

១ ហៅតាមគោត្តនាមរបស់ព្រះនាគិតត្ថេរ ។

មហាតិយា លិច្ឆវិបរិសាយ សទ្ធឹ ឥដូបសង្កន្តោ ភគវន្តំ ឧស្សជាយ សាធុ ភន្តេ លភតំ ឯសា ជនតា ភគវន្តំ ឧស្សជាយាតិ ។ តេនហិ សីហ វិហារបច្ឆាយាយំ អាសនំ បញ្ញបេហីតិ ។ ឯវំ ភន្តេតិ ខោ សីហោ ស-មណុទ្ទេសោ ភគវតោ បដិស្សុត្វា វិហារបច្ឆាយាយំ អាសនំ បញ្ញបេសិ ។ អថខោ ភគវា វិហារា និក្ខម្ម វិហារបច្ឆាយាយំ បញ្ញត្តាសនេ និសីទិ ។ អថខោ តេ កោសលកា ច ព្រាហ្មណទូតា មាគធកា ច ព្រាហ្មណទូតា យេន ភគវា តេនុបសង្កមឹសុ ឧប-សង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។

[៤៩] ឱដ្ឋទ្ធោបិ លិច្ឆវី មហាតិយា លិច្ឆវិបរិសាយ សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឱដ្ឋទ្ធោបិ[១] លិច្ឆវី ភគវន្តំ ឯតទវោច បុរិមានិ

---

១ ឱ. ម. អបិសទ្ទោ ន ទិស្សតិ ។

ក៏ចូលមកក្នុងទីនេះ ជាមួយនឹងលិច្ឆវិបរិសទ្យជាច្រើន ដើម្បីគាល់ព្រះមានព្រះភាគដែរ បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យប្រជុំជននេះបានគាល់ព្រះមានព្រះភាគផង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ បើដូច្នោះ ចូរអ្នកក្រាលអាសនៈត្រង់ម្លប់ខាងមុខវិហារចុះ ។ សីហសមណុទ្ទេស ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលអាសនៈត្រង់ម្លប់ខាងមុខវិហារ ។ គ្រានោះឯង ព្រះមានព្រះភាគស្ដេចចេញអំពីវិហារ (ទៅ) គង់លើអាសនៈដែលគេក្រាលត្រង់ម្លប់ខាងមុខវិហារ ។ លំដាប់នោះ ពួកព្រាហ្មណទូត អ្នកដែនកោសលនិងពួកព្រាហ្មណទូត អ្នកដែនមគធៈទាំងនោះ ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[៤៥] ចំណែកខាងឱដ្ឋទ្ធលិច្ឆវី ព្រមទាំងលិច្ឆវិបរិសទ្យជាច្រើន ក៏ចូលទៅគាល់ព្រះមានព្រះភាគដែរ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះក្សត្រិយ៍ឱដ្ឋទ្ធលិច្ឆវីគង់ស៊ប់ ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា

ភន្តេ ទិវសានិ បុរិមតរានិ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ ឯតទវោច យទគ្គេ អហំ មហាលិ ភគវន្តំ ឧបនិស្សាយ វិហរាមិ[១] ន ចិរំ តីណិ វស្សានិ ទិព្វានិ ហិ ខោ រូបានិ បស្សាមិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ ច ខោ ទិព្វានិ សទ្ទានិ សុណាមិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ សន្តានេវ នុ ខោ ភន្តេ សុនក្ខត្តោ លិច្ឆវិបុត្តោ ទិព្វានិ សទ្ទានិ នាស្សោសិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តានិ ឧទាហុ អសន្តានីតិ ។ សន្តានេវ ខោ មហាលិ សុនក្ខត្តោ លិច្ឆវិបុត្តោ ទិព្វានិ សទ្ទានិ នាស្សោសិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ អសន្តានីតិ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន សុនក្ខត្តោ លិច្ឆវិបុត្តោ សន្តានេវ ទិព្វានិ សទ្ទានិ ន អស្សោសិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ អសន្តានីតិ ។

---

១ ឱ. វិហរិស្សាមិ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលថ្ងៃមុន ៗ សុនក្ខត្តលិច្ឆវិបុត្តចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយបានពោលពាក្យនេះនឹងខ្ញុំព្រះអង្គថា ម្នាលមហាលិ ខ្ញុំចូលទៅនៅអាស្រ័យនឹងព្រះមានព្រះភាគ រាប់តាំងពីថ្ងៃខាងដើមមក មិនយូរប៉ុន្មានបានត្រឹមតែ ៣ ឆ្នាំ ខ្ញុំបានឃើញរូបទិព្វទាំងឡាយដែលមានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល ទាល់តែស្តាប់សំឡេងទិព្វដែលមានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលមិនឮ បពិត្រព្រះអង្គដ៏ចម្រើន សំឡេងទិព្វមានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលមានពិតមែន តែសុនក្ខត្តលិច្ឆវិបុត្តស្តាប់មិនឮ ឬក៏សំឡេងទាំងនោះពុំមានទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមហាលិ សំឡេងទិព្វ ដែលមានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលមានពិតមែន តែសុនក្ខត្តលិច្ឆវិបុត្តស្តាប់មិនឮ មិនមែនជាគ្មានទេ ។ មហាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំឡេងទិព្វមានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលមានពិតមែន មិនមែនជាពុំមានទេ ចុះអ្វីជាហេតុ អ្វីជាបច្ច័យហ្ន៎ បានជាសុនក្ខត្តលិច្ឆវិបុត្តស្តាប់មិនឮ ។

មហាលិសុត្តេ ឯកំសភាវិតសមាធិ ទិព្វរូបទស្សនំ

[៤៦] ឥធ មហាលិ ភិក្ខុនោ បុរត្ថិមាយ ទិសាយ ឯកំសភាវិតោ សមាធិ ហោតិ ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ សោ បុរត្ថិមាយ ទិសាយ ឯកំសភាវិតេ សមាធិម្ហិ ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ បុរត្ថិមាយ ទិសាយ ទិព្វានិ រូបានិ បស្សតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ ច ខោ ទិព្វានិ សទ្ទានិ សុណាតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តំ កិស្ស ហេតុ ឯវំ ហេតំ មហាលិ ហោតិ ភិក្ខុនោ បុរត្ថិមាយ ទិសាយ ឯកំសភាវិតេ សមាធិម្ហិ ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ។

[៤៦] ព្រះមានព្រះភាគត្រាស់ថា ម្នាលមហាលិ ភិក្ខុក្នុងសាស-នានេះ បានចម្រើនសមាធិចំណែកមួយ ក្នុងទិសបូព៌ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល តែសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលឡើយ កាលបើសមាធិ ដែលភិក្ខុនោះបានចម្រើនក្នុងទិសបូព៌ ដើម្បីឃើញរូបដ៏ជាទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល តែសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (ដូច្នេះ) ភិក្ខុនោះ រមែងឃើញរូបទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលក្នុងទិសបូព៌បាន តែជាមិនឮសំឡេងទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលមហាលិ ដំណើរនុ៎ះយ៉ាងនេះគឺ កាលបើសមាធិដែលភិក្ខុនោះ បានចម្រើនហើយមួយចំណែកក្នុងទិសបូព៌ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (តែប៉ុណ្ណោះ) បានជាសមាធិនោះមិនប្រព្រឹត្តទៅដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបានឡើយ ។

[៤៧] បុន ចបរំ មហាលិ ភិក្ខុនោ ឧត្តរាយ និសាយ ។ បេ ។ បច្ឆិមាយ និសាយ ។ បេ ។ ឧត្តរាយ និសាយ ។ បេ ។ ឧទ្ធមធោ តិរិយំ ឯកំសភាវិតោ សមាធិ ហោតិ និព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ និព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ សោ ឧទ្ធមធោ តិរិយំ ឯកំសភាវិតេ សមាធិម្ហិ និព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ និព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ឧទ្ធមធោ តិរិយំ និព្វានិ រូបានិ បស្សតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ ច ខោ និព្វានិ សទ្ទានិ សុណាតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តំ កិស្ស ហេតុ ឯវំ ហេតំ មហាលិ ហោតិ ភិក្ខុនោ ឧទ្ធមធោ តិរិយំ ឯកំសភាវិតេ សមាធិម្ហិ

[៤៧] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា កាលបើសមាធិដែលភិក្ខុនោះបានចម្រើនដោយចំណែកមួយក្នុងទិសទក្សិណ ។ បេ ។ ក្នុងទិសបស្ចិម ។ បេ ។ ក្នុងទិសឧត្តរ ។ បេ ។ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសតូច ៗ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល តែមិនប្រព្រឹត្តទៅដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ប្រកបដោយកាម គួរត្រេកត្រអាលឡើយ កាលបើសមាធិ ដែលភិក្ខុនោះ បានចម្រើនមួយចំណែកក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ប្រកបដោយកាម គួរត្រេកត្រអាល មិនមែនប្រព្រឹត្តទៅ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (ដូច្នោះ) ភិក្ខុនោះ រមែងឃើញរូបដ៏ជាទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងបាន តែមិនឮសំឡេងដ៏ជាទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបានទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលមហាលិ ដំណើរនុ៎ះយ៉ាងនេះ គឺ កាលបើសមាធិ ដែលភិក្ខុនោះ បានចម្រើនមួយចំណែក ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង

៦៣



ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ។

[៤៨] ឥធ មហាលិ ភិក្ខុនោ បុរត្ថិមាយ ទិសាយ ឯកំសភាវិតោ សមាធិ ហោតិ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ សោ បុរត្ថិមាយ ទិសាយ ឯកំសភាវិតេ សមាធិម្ហិ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ បុរត្ថិមាយ ទិសាយ ទិព្វានិ សទ្ទានិ សុណាតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ ច ខោ ទិព្វានិ រូបានិ បស្សតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តំ កិស្ស ហេតុ ឯវំ ហេតំ

ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (តែប៉ុណ្ណោះ) បានជាសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបានឡើយ ។

[៤៨] ម្នាលមហាលិ ភិក្ខុក្នុងសាសនានេះ ចម្រើនសមាធិចំណែកមួយ ក្នុងទិសបូព៌ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រលាញ់ ប្រកបដោយកាម គួរត្រេកត្រអាល សមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលឡើយ កាលបើសមាធិ ដែលភិក្ខុបានចម្រើនមួយចំណែក ក្នុងទិសបូព៌ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល តែសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (ដូច្នោះ) ភិក្ខុនោះរមែងឮសំឡេងដ៏ជាទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល ក្នុងទិសបូព៌បាន ទាល់តែមើលរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលមិនឃើញ ដំណើរនោះព្រោះហេតុអ្វី ម្នាលមហាលិ ដំណើរនុ៎ះយ៉ាងនេះ គឺកាលបើ

មហាលិ ហោតិ ភិក្ខុនោ បុរត្ថិមាយ ទិសាយ ឯកំ-
សភាវិតេ សមាធិម្ហិ ទិព្វានំ សទ្ទានំ សវនាយ បិយ-
រូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ
ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ
រជនិយានំ ។

[៤៩] បុន ចបរំ មហាលិ ភិក្ខុនោ ទក្ខិណាយ
ទិសាយ ។ បេ ។ បច្ឆិមាយ ទិសាយ ។ បេ ។ ឧត្ត-
រាយ ទិសាយ ។ បេ ។ ឧទ្ធមធោ តិរិយំ ឯកំសភា-
វិតោ សមាធិ ហោតិ ទិព្វានំ សទ្ទានំ សវនាយ បិយ-
រូបានំ កាមូបសញ្ហិតានំ រជនិយានិ នោ ច ខោ
ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូប-
សញ្ហិតានំ រជនិយានំ សោ ឧទ្ធមធោ តិរិយំ ឯកំ-
សភាវិតេ សមាធិម្ហិ ទិព្វានំ សទ្ទានំ សវនាយ បិ-
យរូបានំ កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ
ទិព្វានំ រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតា-
នំ រជនិយានំ ឧទ្ធមធោ តិរិយំ ទិព្វានិ សទ្ទានិ
សុណាតិ បិយរូបានិ កាមូបញ្ហិតានិ រជនិយានិ

សមាធិដែលភិក្ខុនោះបានចម្រើនមួយចំណែក ក្នុងទិសបូព៌ ដើម្បីស្តាប់សំ-ឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (តែប៉ុណ្ណោះ) បានជាសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបានឡើយ ។

[៤៩] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា កាលបើសមាធិដែលភិក្ខុនោះបានចម្រើនចំណែកមួយ ក្នុងទិសទក្សិណ ។ បេ ។ ក្នុងទិសបស្ចិម ។ បេ ។ ក្នុងទិសឧត្តរ ។ បេ ។ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល សមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលទេ កាលបើសមាធិដែលភិក្ខុនោះ បានចម្រើនមួយចំណែក ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដើម្បីស្តាប់សំឡេងទិព្វ មានសភាពគួរស្រ-ឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល ដូច្នោះបានជាសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលឡើយ ភិក្ខុនោះរមែងឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល ក្នុងទិសខាងលើ ទិស

នោ ច ខោ ទិព្វានិ រូបានិ បស្សតិ បិយរូបានិ កាមូ-
បសញ្ហិតានិ រជនិយានិ តំ កិស្ស ហេតុ ឯវំ ហេតំ
មហាលិ ហោតិ ភិក្ខុនោ ឧទ្ធមធោ តិរិយំ ឯកំសភា-
វិតេ សមាធិម្ហិ ទិព្វានំ សទ្ទានំ សវនាយ បិយរូបានំ
កាមូបសញ្ហិតានំ រជនិយានំ នោ ច ខោ ទិព្វានំ
រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជ-
និយានំ ។

[៤០] ឥធ មហាលិ ភិក្ខុនោ បុរត្ថិមាយ ទិសា-
យ ឧភយំសភាវិតោ សមាធិ ហោតិ ទិព្វានញ្ច រូបានំ
ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ
ទិព្វានញ្ច សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិ-
តានំ រជនិយានំ សោ បុរត្ថិមាយ ទិសាយ ឧភយំស-
ភាវិតេ សមាធិម្ហិ ទិព្វានញ្ច រូបានំ ទស្សនាយ ។ បេ ។
ទិព្វានញ្ច សទ្ទានំ សវនាយ ។ បេ ។ បុរត្ថិមាយ ទិ-
សាយ ទិព្វានិ ច រូបានិ បស្សតិ បិយរូបានិ កាមូប-
សញ្ហិតានិ រជនិយានិ ទិព្វានិ ច សទ្ទានិ សុណាតិ
បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តំ កិស្ស

ខាងក្រោម និងទិសបន្ទាប់បាន តែមិនឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល ដំណើរនោះ ព្រោះហេតុអ្វី ម្នាលមហាលិ ដំណើរនុ៎ះយ៉ាងនេះ គឺកាលបើសមាធិដែលភិក្ខុនោះបានបំពេញមួយចំណែក ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល (តែប៉ុណ្ណោះ) បានជាសមាធិនោះមិនប្រព្រឹត្តទៅ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបាន ។

[៥០] ម្នាលមហាលិ ភិក្ខុក្នុងសាសនានេះ ចម្រើនសមាធិទាំង ២ ចំណែកក្នុងទិសបូព៌ គឺដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង កាលបើសមាធិដែលភិក្ខុនោះ បានចម្រើនទាំង ២ ចំណែក ក្នុងទិសបូព៌ គឺដើម្បីឃើញរូបទិព្វផង ។ បេ ។ ដើម្បីឮសំឡេងទិព្វផង ។ បេ ។ ភិក្ខុនោះរមែងឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង រមែងឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ក្នុងទិសបូព៌ ដំណើរនោះព្រោះហេតុអ្វី

ហោតុ ឯវំ ហោតំ មហាលិ ហោតិ ភិក្ខុនោ បុរត្ថិមាយ ទិសាយ ឧភយំសភាវិតេ សមាធិម្ហិ ទិព្វានញ្ច រូបានំ ទស្សនាយ ។ បេ ។ ទិព្វានញ្ច សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ។

[៤១] បុន ចបរំ មហាលិ ភិក្ខុនោ ទក្ខិណាយ ទិសាយ ។ បេ ។ បច្ឆិមាយ ទិសាយ ។ បេ ។ ឧត្តរាយ ទិសាយ ។ បេ ។ ឧទ្ធមធោ តិរិយំ ឧភយំសភាវិតោ សមាធិ ហោតិ ទិព្វានញ្ច រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ទិព្វានញ្ច សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ សោ ឧទ្ធមធោ តិរិយំ ឧភយំសភាវិតេ សមាធិម្ហិ ទិព្វានញ្ច រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ទិព្វានញ្ច សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ឧទ្ធមធោ តិរិយំ ទិព្វានិ រូបានិ បស្សតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ ទិព្វានិ ច សទ្ទានិ សុណាតិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ តំ កិស្ស ហេតុ ឯវំ ហោតំ មហាលិ

ម្នាលមហាលិ ដំណើរនុ៎ះយ៉ាងនេះគឺ ព្រោះតែសមាធិដែលភិក្ខុនោះបាន ចម្រើនទាំង ២ ចំណែក ក្នុងទិសបូព៌ គឺដើម្បីឃើញរូបទិព្វផង ។ បេ ។ ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ។

[៥១] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា សមាធិដែលភិក្ខុបាន ចម្រើនទាំង ២ ចំណែកក្នុងទិសទក្សិណ ។ បេ ។ ក្នុងទិសបស្ចិម ។ បេ ។ ក្នុងទិសឧត្តរ ។ បេ ។ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល និងដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល កាលបើសមាធិដែលភិក្ខុនោះបានចម្រើន ទាំង ២ ចំណែក ក្នុងទិសខាងលើ ទិសខាងក្រោមនិងទិសបន្ទាប់ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង (ដូច្នោះ) បានជាភិក្ខុនោះឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលបានផង ទាំងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលមហាលិ

ហោតិ ភិក្ខុនោ ឧភតោ តិរិយំ ឧភយំសភាវិតេ សមាធិម្ហិ ទិព្វានញ្ច រូបានំ ទស្សនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ ទិព្វានញ្ច សទ្ទានំ សវនាយ បិយរូបានំ កាមូបសញ្ហិតានំ រជនិយានំ អយំ ខោ មហាលិ ហេតុ អយំ បច្ចយោ យេន សន្ទោ លិច្ឆវិបុត្តោ ទិព្វានិ សទ្ទានិ ន អស្សោសិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ ... [illegible] សុនក្ខត្តោ លិច្ឆវិបុត្តោ ទិព្វានិ សទ្ទានិ ន អស្សោសិ បិយរូបានិ កាមូបសញ្ហិតានិ រជនិយានិ នោ អសន្តានីតិ ។

[៤២] ឯតាសំ នូន ភន្តេ សមាធិភាវនានំ សច្ឆិកិរិយាហេតុ ភិក្ខូ ភគវតិ ព្រហ្មចរិយំ ចរន្តីតិ ។ ន ខោ មហាលិ ឯតាសំ សមាធិភាវនានំ សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ អត្ថិ ខោ មហាលិ អញ្ញេ ធម្មា[១] ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តីតិ ។ កតមេ បន[២] ភន្តេ ធម្មា ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ ភគវតិ ព្រហ្មចរិយំ

---

១ ឱ. អញ្ញេ ច ធម្មា ។ ម. អញ្ញេវ ធម្មា ។ ២ ឱ. ម. បន តេ ។

ដំណើរនុ៎ះយ៉ាងនេះគឺ ព្រោះតែភិក្ខុបានចម្រើនសមាធិទាំង ២ ចំណែក ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសបន្ទាប់ ដើម្បីឃើញរូបទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង ដើម្បីឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលផង (នោះឯង) ម្នាលមហាលិ នេះជាហេតុ នេះជាបច្ច័យ ដែលសុនក្ខត្ត-លិច្ឆវិបុត្ត មិនបានឮសំឡេងទិព្វ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាលដែលមានពិត មិនមែនជាមិនមាន (នោះ) ទេ ។

[៩២] មហាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគ គ្រាន់តែជាហេតុធ្វើឲ្យច្បាស់នូវសមាធិភាវនាប៉ុណ្ណោះទេឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមហាលិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់តថាគត មិនមែនគ្រាន់តែជាហេតុធ្វើឲ្យច្បាស់ នូវសមាធិភាវនាប៉ុណ្ណោះទេ ម្នាលមហាលិ នៅមានធម៌ដទៃទៀតដែលលើសលុបជាង ប្រសើរជាងសមាធិភាវនា ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ។ មហាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចុះធម៌ដែលលើសលុបជាង ដែលប្រសើរជាងសមាធិភាវនា ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគ (អាច) ធ្វើឲ្យជាក់ច្បាស់បាន

ចរន្តីតិ ។ ឥធ មហាលិ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ អយំ ខោ[១] មហាលិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។

[៥៣] បុន ចបរំ មហាលិ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ អយំបិ ខោ មហាលិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។

[៥៤] បុន ចបរំ មហាលិ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា

---

១ ឱ. ម. អយំបិ ខោ ។

តើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមហាលិ ភិក្ខុក្នុងសាសនានេះ ជាសោតាបន្នបុគ្គល មិនមានកិរិយាធ្លាក់ទៅក្នុងអបាយទាំង ៤ ជាធម្មតា គឺលែងទៅកាន់អបាយ ជាបុគ្គលទៀងទាត់ មានកិរិយាត្រាស់ដឹងទៅខាងមុខ ព្រោះកិរិយាអស់ទៅនៃសំយោជនៈ ៣ ម្នាលមហាលិ ធម៌នេះឯងដែលឈ្មោះថា លើសលុបជាង ប្រសើរជាងសមាធិភាវនា ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ។

[៩៣] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា ភិក្ខុជាសកទាគាមិបុគ្គល មកកាន់លោកនេះត្រឹមតែម្តងទៀត ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់ទៅនៃសំយោជនៈ ៣ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ មោហៈ ម្នាលមហាលិ ធម៌នេះឯងឈ្មោះថា លើសលុបជាង ប្រសើរជាង ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ។

[៩៤] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា ភិក្ខុជាឧបបាតិកៈកំណើត ព្រោះអស់ទៅនៃសំយោជនៈជាចំណែកខាងអាយ ៥ ហើយបរិនិព្វាន ក្នុងភពនោះ មានកិរិយាមិនត្រឡប់មក អំពីលោកនោះវិញ

អយំបិ ខោ មហាលិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។

[៥៥] បុន ចបរំ មហាលិ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អយំបិ ខោ មហាលិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ឥមេ ខោ តេ[១] មហាលិ ធម្មា ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តីតិ ។

[៥៦] អត្ថិ បន ភន្តេ[២] មគ្គោ អត្ថិ បដិបទា ឯតេសំ ធម្មានំ សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ មហាលិ មគ្គោ អត្ថិ បដិបទា ឯតេសំ ធម្មានំ សច្ឆិកិរិយាយាតិ ។ កតមោ បន ភន្តេ មគ្គោ កតមា បដិបទា ឯតេសំ ធម្មានំ សច្ឆិកិរិយាយាតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ

១ ឱ. តេតិបទំ ន ទិស្សតិ ។ ២ ឱ. ម. អត្ថិ បន ភន្តេ ។

ធម្មតា ម្នាលមហាលិ ធម៌នេះឯងឈ្មោះថា លើសលុបជាង ប្រសើរជាង ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ។

[៨៥] ម្នាលមហាលិ សេចក្តីផ្សេងទៀតថា ភិក្ខុដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ហើយដល់ស៊ប់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយក្នុងអត្តភាពនេះឯង ម្នាលមហាលិ ធម៌នេះឯងឈ្មោះថាលើសលុបជាង ប្រសើរជាង ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ម្នាលមហាលិ ធម៌ទាំងនេះហើយ ដែលឈ្មោះថាលើសលុបជាង ប្រសើរជាង ដែលពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់តថាគត (អាច) ធ្វើឲ្យជាក់ច្បាស់បាន ។

[៨៦] មហាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចុះមគ្គនិងបដិបទា សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនុ៎ះ តើមានដែរឬទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមហាលិ មគ្គនិងបដិបទា សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនុ៎ះមានជាប្រាកដ ។ មហាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចុះមគ្គនិងបដិបទា សម្រាប់ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ តើដូចម្តេចខ្លះ ។ ព្រះអង្គទ្រង់ត្រាស់ថា មគ្គប្រកបដោយអង្គ ៨

មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ អយំ ខោ មហាលិ មគ្គោ អយំ បដិបទា ឯតេសំ ធម្មានំ សច្ឆិកិរិយាយ ។

[៤៧] ឯកមិទាហំ មហាលិ សមយំ កោសម្ពិយំ វិហរាមិ ឃោសិតារាមេ ។ អថខោ ទ្វេ បព្វជិតា មណ្ឌិយោ[១] ច បរិព្វាជកោ ជាលិយោ ច ទារុបត្តិកន្តេវាសី យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មយា[២] សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តេ[៣] ទ្វេ បព្វជិតា មំ ឯតទវោចុំ កិន្នុ ខោ អាវុសោ គោតម[៤] តំ ជីវំ តំ សរីរំ ឧទាហុ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ។ តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមិ[៥] ។ ឥធាវុសោ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ

---

១ ឱ. មណ្ឌិស្សោ ។ ម. មុណ្ឌិយោ ។ ២ ឱ. មម ។ ៣ ឱ. តេតិបទំ ន ទិស្សតិ ។ ៤ ឱ. អាវុសោ ភោ គោតម ។ ៥ ឱភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ទ្វេ បព្វជិតា មម បច្ចស្សោសុំ ។ អថខោ ចាហំ ឯតទវោចំ ។ ម. អហំ ឯតទវោចំ ។

ជាផ្លូវដ៏ប្រសើរនេះឯង គឺសេចក្តីឃើញត្រូវ ១ ត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ រលឹកត្រូវ ១ តម្កល់ចិត្តត្រូវ ១ ម្នាលមហាលិ នេះឯងឈ្មោះថាមគ្គ នេះឯងឈ្មោះថាបដិបទាសម្រាប់ធ្វើឲ្យជាក់ច្បាស់ នូវធម៌ទាំងឡាយនុ៎ះ ។

[៩៧] ម្នាលមហាលិ សម័យមួយ តថាគតនៅក្នុងឃោសិតារាម ទៀបនគរកោសម្ពី ។ គ្រានោះ មានបព្វជិត ២ រូប គឺមណ្ឌិយបរិព្វាជក ១ ជាលិយជាអន្តេវាសិកនៃទារុបត្តិកបរិព្វាជក[១] ១ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ។ លុះបព្វជិតទាំង ២ រូបនោះ ឈរនៅក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតដូច្នេះថា អាវុសោគោតម ជីវៈនោះក៏គឺសរីរៈនោះឬ ។ ក៏ជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ តថាគតប្រាប់ថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ ម្នាលអាវុសោ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហំ

---

១ អដ្ឋកថាថា ឧបជ្ឈាយ៍របស់ជាលិយៈនោះតែងត្រាច់ទៅបិណ្ឌបាតដោយបាត្រឈើ បានជាហៅថា ទារុបត្តិកៈ ។

សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ វិត្ថារេ-តព្វំ) ។ បេ ។ ឯវំ ខោ អាវុសោ ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ កាល្លំ នុ ខោ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន[1] កាល្លំ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ។ អហំ ខោ បនេតំ អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ អថ ច បនាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ[2] ។ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ កាល្លំ នុ ខោ តស្សេតំ

១ ឱ. នសទ្ធោ ន ទិស្សតិ ។ ២ ឱ. ឥតិសទ្ធោ ន ទិស្សតិ ។

សម្មាសម្ពុទ្ធ ។ បេ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលអាវុសោ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ។ បេ ។ បានដល់នូវបឋមជ្ឈាន ។ ម្នាលអាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះ តើគួរនឹងពោលថា ជីវៈនោះក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ បរិព្វាជកទាំងពីររូបប្រាប់តថាគតថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះមិនគួរពោលថា ជីវៈនោះក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ លុះបរិព្វាជកទាំង ២ រូបពោលដូច្នោះហើយ តថាគតប្រាប់ថា ម្នាលអាវុសោ ចំណែកខាងតថាគតដឹងហេតុនេះយ៉ាងនេះ ឃើញហេតុនេះយ៉ាងនេះដែរ បានជាតថាគតមិនបានពោលថា ជីវៈនោះ ក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ភិក្ខុបានដល់នូវទុតិយជ្ឈាន ។ នូវតតិយជ្ឈាន ។ នូវចតុត្ថជ្ឈាន ។ ម្នាលអាវុសោ បើភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះរបស់ភិក្ខុនោះ តើគួរនឹងពោលថា

វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន[១] កល្លំ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ អហំ ខោ បនេតំ អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ អថ ច បនាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ[២] ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ កល្លំ នុ ខោ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន កល្លំ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ អហំ ខោ បនេតំ

---

១ ឱ. នសទ្ទោ ន ទិស្សតិ ។ ២ ឱ. ឥតិសទ្ទោ នត្ថិ ។

ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ បរិព្វាជកពីររូបពោលថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះ មិនគួរនឹងពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ លុះបរិព្វាជកពីររូបពោលដូច្នោះហើយតថាគតប្រាប់ថា ម្នាលអាវុសោ ចំណែកខាងតថាគតក៏ដឹងយ៉ាងនេះ ឃើញយ៉ាងនេះដែរ បានជាតថាគតមិនបានពោលថា ជីវៈនោះក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ភិក្ខុតម្រង់ផ្ចង់បង្អោនចិត្តទៅដើម្បីញាណទស្សនៈ ។ ម្នាលអាវុសោ ភិក្ខុណា ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃក្រៅពីនេះទៀតមិនមានទេ ។ ម្នាលអាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះ តើគួរនឹងពោលថា ជីវៈនោះក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ បរិព្វាជកទាំងពីររូបពោលថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះមិនគួរនឹងពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ (លុះបរិព្វាជកពីររូបពោលដូច្នោះហើយ) តថាគតប្រាប់ថា

៧៣

មហាលិសុត្តេ ភគវតោ ភាសិតំ អភិនន្ទនំ

អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ អថ ច ប-
ណាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជី-
វំ អញ្ញំ សរីរន្តិ វាតិ ។ ឥទមវោច ភគវា ។
អត្តមនោ ឱដ្ឋទ្ធោ លិច្ឆវី ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាលិសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

ម្នាលអាវុសោ តថាគតដឹងហេតុនោះយ៉ាងនេះ ឃើញហេតុនោះយ៉ាងនេះដែរ បានជាតថាគតមិនបានពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះ (ចប់ហើយ) ។ ឱដ្ឋទ្ធលិច្ឆវី ក៏មានចិត្តរីករាយ ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាលិសូត្រ ទី ៦ ។

# ជាលិយសុត្តំ សត្តមំ

[៥៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោ-
សម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ ទ្វេ បព្វជិ-
តា មណ្ឌិយោ ច បរិព្វាជកោ ជាលិយោ ច ទា-
រុបត្តិកន្តេវាសី យេន ភគវា តេនុបសង្កមឹសុ ឧប-
សង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ
កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋំសុ ។
ឯកមន្តំ ឋិតា ខោ តេ ទ្វេ បព្វជិតា ភគវន្តំ ឯ-
តទវោចុំ កិន្នុ ខោ អាវុសោ ភោ គោតម តំ
ជីវំ តំ សរីរំ ឧទាហុ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ។
តេនហាវុសោ សុណាថ សាធុកំ មនសិករោថ
ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ទ្វេ បព្វ-
ជិតា ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច
ឥធ អាវុសោ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ

# ជាលិយសូត្រ ទី ៧

[៩៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងឃោសិតារាម[១] ទៀបក្រុងកោសម្ពី ។ គ្រានោះ មានបព្វជិត ២ រូប គឺបរិព្វាជកឈ្មោះមណ្ឌិយៈ ១ ឈ្មោះជាលិយៈ ជាអន្តេវាសិកនៃទារុបត្តិកបរិព្វាជក ១ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ។ លុះបព្វជិត ២ រូបនោះ ឈរនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា អាវុសោ គោតមដ៏ចម្រើន ជីវៈនោះគឺសរីរៈនោះឬ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ បព្វជិតទាំង ២ រូបនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា យ៉ាងហ្នឹងហើយអាវុសោ ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ម្នាលអាវុសោ ព្រះតថាគតកើតឡើងក្នុងលោកនេះជាអរហន្ត

---

១ អារាមដែលឃោសិតសេដ្ឋីកសាង ។

សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឯវំ ខោ អាវុសោ ភិក្ខុ សីលសម្បន្នោ ហោតិ ។

[៥៩] ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជា-ជាតិ ឯវំ បស្សតិ កាល្លំ នុ ខោ តស្សេតំ វច-នាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន កាល្លំ តស្សេតំ វចនា-យ ។ បេ ។ អហំ ខោ បនេតំ អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ អថ ច បនាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។

[៦០] ទុតិយំ ឈានំ ។ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ កាល្លំ នុ

សម្មាសម្ពុទ្ធ ។ បេ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផង់ចុះ) ។ បេ ។ ម្នាលអាវុសោ ភិក្ខុជាអ្នកបរិបូណ៌ ដោយសីលយ៉ាងនេះឯង ។

[៥៩] ។ បេ ។ ភិក្ខុបានដល់នូវបឋមជ្ឈាន ។ ម្នាលអាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះគួរពោលថា ជីវៈនោះក៏គឺសរីរៈនោះដែរឬ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ បរិព្វាជកទាំងពីរពោលថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះមិនគួរនឹងពោលទេ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ ចំណែកខាងតថាគតដឹងនូវហេតុនោះយ៉ាងនេះ ឃើញយ៉ាងនេះដែរ បានជាតថាគត មិនពោលថា ជីវៈនោះ ក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។

[៦០] ភិក្ខុបានដល់នូវទុតិយជ្ឈាន ។ នូវតតិយជ្ឈាន ។ នូវចតុត្ថជ្ឈាន ។ ម្នាលអាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ

ខោ តស្សេតំ ហេតុ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន កល្លំ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ អហំ ខោ បនេតំ អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ អថ ច បនាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។

[៦១] ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យោ នុ ខោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ កល្លំ នុ ខោ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ យោ សោ អាវុសោ ភិក្ខុ ឯវំ ជានាតិ ឯវំ បស្សតិ ន កល្លំ តស្សេតំ វចនាយ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ អហំ ខោ បនេតំ អាវុសោ ឯវំ ជានាមិ ឯវំ បស្សាមិ

ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះ តើគួរនឹងពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនពីគ្នាដែរឬ ។ បរិញ្វជកទាំងនោះពោលថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះមិនគួរនឹងពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ ចំណែកតថាគតដឹងហេតុនុ៎ះយ៉ាងនេះ ឃើញយ៉ាងនេះដែរហើយ ប៉ុន្តែតថាគតមិនបានពោលថា ជីវៈនោះគឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។

[៦១] ភិក្ខុតម្រង់ផ្ចង់បង្អោនចិត្តមកដើម្បីញាណទស្សនៈ ។ ម្នាលអាវុសោ ភិក្ខុណា ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃក្រៅពីនេះទៀតមិនមានទេ ។ ម្នាលអាវុសោ ភិក្ខុណា ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះ តើគួរនឹងពោលថា ជីវៈនោះគឺស-រីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនដែរឬ ។ បរិញ្វជកទាំងនោះពោលថា អាវុសោ ភិក្ខុណាដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ការដឹងនិងការឃើញនុ៎ះ របស់ភិក្ខុនោះមិនគួរនឹងពោលថា ជីវៈនោះគឺសរីរៈនោះឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ ចំណែកខាងតថាគត ក៏ដឹងនូវហេតុនេះយ៉ាងនេះ ឃើញយ៉ាងនេះដែរ

## ៧៧

ជាលិយសុត្តេ ភគវតោ ភាសិតំ អភិនន្ទនំ

អថ ច បនាហំ ន វទាមិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ទ្វេ បព្វជិតា ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ជាលិយសុត្តំ សត្តមំ និដ្ឋិតំ ។

*បានជាតថាគត មិនពោលថា ជីវៈនោះក៏គឺសរីរៈនោះ ឬថាជីវៈដោយខ្លួន សរីរៈដោយខ្លួន ។ ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះ* (ចប់) *ហើយ ។ បព្វជិតទាំង ២ រូបនោះ ក៏មានចិត្តរីករាយ ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។*

ចប់ ជាលិយសូត្រ ទី ៧ ។

# មហាសីហនាទសុត្តំ អដ្ឋមំ

[៦២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧជុញ្ញាយំ[១] វិហរតិ កណ្ណកថលេ មិគទាយេ ។ អថខោ អចេលោ កស្សបោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អចេលោ កស្សបោ ភគវន្តំ ឯតទវោច សុតមេតំ[២] ភោ គោតម សមណោ គោតមោ សព្វន្តបំ គរហតិ សព្វន្តបស្សឹ លូខាជីវឹ ឯកំសេន ឧបក្កោសតិ ឧបវទតីតិ យេ តេ ភោ គោតម ឯវមាហំសុ សមណោ គោតមោ សព្វន្តបំ គរហតិ សព្វន្តបស្សឹ លូខាជីវឹ ឯកំសេន ឧបក្កោសតិ ឧបវទតីតិ

---

១ ឧរុញ្ញាយន្តិ កត្ថចិ អម្ហាកំ បោត្ថកេ ទិស្សតិ ។ អដ្ឋកថាយញ្ច ឯវមេវ ។ ២ ឱ. សុតម្មេតំ ។

# មហាសីហនាទសូត្រ ទី ៨

[៦២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងព្រៃឈ្មោះកណ្ណកថលៈ ជាទីឲ្យអភ័យដល់ម្រឹគ ទៀបក្រុងឧជុញ្ញា ។ គ្រានោះ អចេលៈ (បរិព្វាជកអាក្រាត) ឈ្មោះកស្សប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹក ហើយក៏ឈរនៅក្នុងទីដ៏សមគួរ ។ លុះអចេលកស្សប ឈរក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំបានឮពាក្យដូច្នេះថា ព្រះសមណគោតម រមែងតិះដៀលតបៈទាំងពួង រមែងចំអកមើលងាយតែមួយយ៉ាង នូវអ្នកកាន់តបៈទាំងអស់គ្នា ដែលមានអាជីវៈសៅហ្មង បពិត្រព្រះគោតមដ៏ចម្រើន ពួកសមណព្រាហ្មណ៍ណា បានពោលយ៉ាងនេះថា ព្រះសមណគោតម រមែងតិះដៀលតបៈទាំងពួង រមែងចំអកមើលងាយតែមួយយ៉ាង នូវអ្នកកាន់តបៈទាំងអស់គ្នា ដែលមានអាជីវៈសៅហ្មង

## ៧៩

មហាសីហនាទសុត្តេ សព្វន្តបំ គរហាទិកំ

កច្ចិ តេ ភោតោ គោតមស្ស វុត្តវាទិនោ ន ច ភវន្តំ គោតមំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ អនព្ភក្ខាតុកាមា ហិ មយំ ភវន្តំ គោតមន្តិ ។ យេ តេ កស្សប ឯវមាហំសុ សមណោ គោតមោ សព្វន្តបំ គរហតិ សព្វន្តបស្សឹ លូខាជីវឹ ឯកំសេន ឧបក្កោសតិ ឧបវទតីតិ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ន ច មំ តេ អសតា អភូតេន ។ ឥធាហំ កស្សប ឯកច្ចំ តបស្សឹ លូ-ខាជីវឹ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមា-នុសកេន កាយស្ស ភេទា បរំ មរណា អបាយំ

សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកពោលតាមហេតុ ដែលព្រះគោតមដ៏ចម្រើនពោលហើយ ឬមិនពោលបង្កាច់ព្រះគោតមដ៏ចម្រើន ដោយពាក្យមិនពិតទេ ឬពោលនូវធម៌ដ៏សមគួរដល់ធម៌ ឬវាទានុវាទៈណាមួយ ប្រកបដោយធម៌ មិនដល់នូវឋានៈដែលពួកវិញ្ញូជនគួរតិះដៀលទេឬ ឯយើងទាំងឡាយមិនប៉ងនឹងពោលបង្កាច់ព្រះគោតមដ៏ចម្រើនទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកស្សប ពួកសមណព្រាហ្មណ៍ណា បានពោលហើយយ៉ាងនេះថា ព្រះសមណគោតម រមែងតិះដៀលតបៈទាំងពួង រមែងចំអកមើលងាយតែមួយយ៉ាង នូវអ្នកកាន់តបៈទាំងអស់គ្នា ដែលមានអាជីវៈសៅហ្មង ពួកសមណព្រាហ្មណ៍ទាំងនោះ មិនមែនពោលតាមវាទៈដែលតថាគតពោលហើយ (ដោយសព្វគ្រប់) ទេ ពោលបង្កាច់តថាគត (ខ្លះក៏មាន) មួយវិញទៀត ពួកសមណព្រាហ្មណ៍ទាំងនោះ មិនមែនពោលបង្កាច់តថាគត ដោយពាក្យមិនមានមិនពិត (ក៏មាន) ។ ម្នាលកស្សប តថាគតបានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងវិស័យរបស់មនុស្សមើលឃើញបុគ្គលអ្នកកាន់តបៈ ដែលមានអាជីវៈសៅហ្មង ពួកខ្លះក្នុងលោកនេះ ដែលរំលាងខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ ទៅកើតក្នុងអបាយ

ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ។ ឥធ បនាហំ កស្សប ឯកច្ចំ តបស្សឹ លូខាជីវឹ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នំ ។ ឥធ បនាហំ កស្សប ឯកច្ចំ តបស្សឹ អប្បទុក្ខវិហារឹ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ។ ឥធ បនាហំ កស្សប ឯកច្ចំ តបស្សឹ អប្បទុក្ខវិហារឹ បស្សាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នំ ។ សោហំ កស្សប ឥមេសំ តបស្សីនំ ឯវំ អាគតិញ្ច គតិញ្ច ចុតិញ្ច ឧបបត្តិញ្ច យថាភូតំ បជានាមិ សោហំ កឹ សព្វន្តបំ គរហិស្សាមិ សព្វន្តបស្សឹ លូខាជីវឹ ឯកំសេន ឧបក្កោសិស្សាមិ ឧបវទិស្សាមិ ។

ទុគ្គតិ វិនិបាត នរក ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វដ៏បរិសុទ្ធកន្លង វិស័យរបស់មនុស្ស តថាគតមើលឃើញបុគ្គលអ្នកកាន់តបៈ ពួកខ្លះក្នុង លោកនេះ ជាអ្នកចិញ្ចឹមជីវិតសៅហ្មង ដែលរំលាងខន្ធខាងមុខអំពីសេចក្តី ស្លាប់ ទៅកាន់លោកគឺមនុស្ស សុគតិ និងឋានសួគ៌ ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វកន្លងវិស័យរបស់មនុស្ស មើលឃើញបុគ្គលអ្នកកាន់ តបៈ ពួកខ្លះក្នុងលោកនេះ ដែលនៅដោយមានសេចក្តីទុក្ខតិច លុះរំលាង ខន្ធខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វកន្លងវិស័យរបស់មនុស្ស មើលឃើញ បុគ្គលអ្នកកាន់តបៈ ពួកខ្លះក្នុងលោកនេះ ដែលនៅដោយមានសេចក្តីទុក្ខ តិច លុះរំលាងខន្ធអំពីសេចក្តីស្លាប់ ទៅកាន់លោកគឺមនុស្ស សុគតិ និង ស្ថានសួគ៌ ។ ម្នាលកស្សប តថាគតដឹងជាក់នូវដំណើរមកផង ដំណើរ ទៅផង ដំណើរឃ្លាតចេញផង ដំណើរកើតផង របស់ពួកអ្នកកាន់តបៈទាំង នេះ តាមពិតយ៉ាងនេះឯង តថាគតឯងនឹងតិះដៀលតបៈទាំងពួង នឹងចំអក មើលងាយតែមួយយ៉ាង នូវអ្នកកាន់តបៈទាំងអស់គ្នា ដែលមានអាជីវៈ សៅហ្មងដូចម្តេចបាន (តថាគតតិះដៀលតែកម្មដែលគួរតិះដៀល សរសើរ កម្មដែលគួរសរសើរទេតើ) ។

មហាសីហនាទសុត្តេ អកុសលប្បហានកថា

[៦៣] សន្តិ កស្សប ឯកេ សមណព្រាហ្មណា បណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា តេ[១] ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេហិ-បិមេ សទ្ធឹ ឯកច្ចេសុ ឋានេសុ សមេន្តិ ឯកច្ចេសុ ឋានេសុ ន សមេន្តិ ។ យន្តេ ឯកច្ចំ វទេន្តិ[២] សា-ធូតិ មយំបិ តំ ឯកច្ចំ វទេម សាធូតិ ។ យន្តេ ឯ-កច្ចំ វទេន្តិ ន សាធូតិ មយំបិ តំ ឯកច្ចំ វទេម ន សាធូតិ ។ យន្តេ ឯកច្ចំ វទេន្តិ សាធូតិ មយំ តំ ឯកច្ចំ វទេម ន សាធូតិ ។ យន្តេ ឯកច្ចំ វទេន្តិ ន សាធូតិ មយំ តំ ឯកច្ចំ វទេម សាធូតិ ។ យំ មយំ ឯកច្ចំ វទេម សាធូតិ បរេបិ តំ ឯកច្ចំ វទេន្តិ សាធូតិ ។ យំ មយំ ឯកច្ចំ វទេម ន សាធូតិ បរេបិ តំ ឯកច្ចំ វទេន្តិ ន សាធូតិ ។ យំ មយំ ឯកច្ចំ វទេម សាធូតិ បរេបិ តំ ឯកច្ចំ វទេន្តិ ន សាធូតិ ។ យំ មយំ ឯកច្ចំ វទេម ន សាធូតិ បរេបិ តំ ឯកច្ចំ វទេន្តិ

១ ឱ. វោ ។ ២ ម. វទន្តិ ។

មហាសីហនាទសូត្រ ពោលអំពីការលះអកុសលធម៌

[៦៣] ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាបណ្ឌិត មានប្រាជ្ញាល្អិត ដឹងច្បាស់នូវវាទៈរបស់អ្នកដទៃ អាចទម្លាយនូវទិដ្ឋិរបស់បុគ្គលដទៃ ដោយកម្លាំងប្រាជ្ញារបស់ខ្លួន ដូចជាខ្មាន់ធ្នូអ្នកបាញ់នូវសរសែសក់បាន ។ សមណព្រាហ្មណ៍ទាំងនោះ ត្រូវគ្នានឹងតថាគតក្នុងស្ថានខ្លះក៏មាន មិនត្រូវគ្នាក្នុងស្ថានខ្លះក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ[១]ថាល្អ យើងក៏ពោលថាល្អដែរក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ[២]ថាមិនល្អ យើងក៏ពោលថាមិនល្អដែរក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ[៣] ថាល្អ តែយើងពោលថាមិនល្អក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ[៤] ថាមិនល្អ តែយើងពោលថាល្អក៏មាន ។ យើងពោលនូវអ្វីខ្លះថាល្អ ពួកសមណព្រាហ្មណ៍ដទៃ ក៏ពោលថាល្អដែរក៏មាន ។ យើងពោលនូវអ្វីខ្លះថាមិនល្អ ពួកសមណព្រាហ្មណ៍ដទៃ ពោលថាមិនល្អដែរក៏មាន ។ យើងពោលនូវអ្វីខ្លះថាល្អ តែពួកសមណព្រាហ្មណ៍ដទៃពោលថា មិនល្អ ក៏មាន ។ យើងពោលនូវអ្វីខ្លះថា មិនល្អ តែពួកសមណព្រាហ្មណ៍ដទៃ ពោលថា

---

១ អដ្ឋកថា ថា សំដៅយកបញ្ចពិធសីល ។ ២ សំដៅយកបញ្ចវេរា ។ ៣ សង្រួមក្នុងទ្វារទាំង ៥ ។ ៤ អដ្ឋកថា ថា មិនសង្រួមក្នុងទ្វារទាំង ៥ ។

សាធូតិ ។ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ យេសុ ដោ អាវុសោ ឋានេសុ ន សមេន្តិ តិដ្ឋន្តុ តានិ ឋានានិ យេសុ ឋានេសុ សមេន្តិ តត្ថ វិញ្ញូ សមនុយុញ្ជន្តំ សមនុគ្គាហន្តំ សមនុភាសន្តំ សត្ថារា វា សត្ថារំ ស-ង្ឃេន វា សង្ឃំ យេ ឥមេសំ ភវតំ ធម្មា អកុសលា អកុសលសង្ខាតា សាវជ្ជា សាវជ្ជសង្ខាតា អសេវិតព្វា អសេវិតព្វសង្ខាតា នអលមរិយា នអលមរិយសង្ខា-តា កណ្ហា កណ្ហសង្ខាតា កោ ឥមេ ធម្មេ អនវ-សេសំ បហាយ វត្តតិ សមណោ គោតមោ បរេ វា បន ភោន្តោ គណាចរិយាតិ ។

[៦៤] ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា ឯវំ វទេយ្យុំ យេ ឥមេសំ ភវតំ ធម្មា អកុសលា អកុ-សលសង្ខាតា សាវជ្ជា សាវជ្ជសង្ខាតា អសេវិតព្វា អសេវិតព្វសង្ខាតា នអលមរិយា នអលមរិយសង្ខាតា កណ្ហា កណ្ហសង្ខាតា សមណោ គោតមោ ឥមេ

ល្អក៏មាន ។ តថាគតចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោទាំងឡាយ ស្ថានណា ដែលមិនត្រូវគ្នានឹងតថាគត ស្ថាននោះលើកទុកសិនចុះ ស្ថានណាដែលត្រូវគ្នានឹងតថាគត ពួកវិញ្ញូជន ត្រូវសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុទាំងពីរ ប្រៀបធៀបគ្រូនឹងគ្រូ ឬពួកនឹងពួកក្នុងស្ថាននោះថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថាជាអកុសល មានទោស រាប់ថាមានទោស មិនគួរសេព រាប់ថាមិនគួរសេព មិនប្រសើរ រាប់ថាមិនប្រសើរ ជាចំណែកខ្មៅ រាប់ថាជាចំណែកខ្មៅ របស់ជនដ៏ចម្រើនទាំងនេះ តើនរណា លះបង់ធម៌ទាំងនេះ មិនឲ្យសេសសល់ ហើយប្រព្រឹត្តកាន់បាន សមណគោតមឬ ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។

[៦៤] ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ កាលបើពួកវិញ្ញូជន សួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏និយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថាជាអកុសល មានទោស រាប់ថាមានទោស មិនគួរសេព រាប់ថាមិនគួរសេពមិនប្រ-សើរ រាប់ថាមិនប្រសើរ ជាចំណែកខ្មៅ រាប់ថាជាចំណែកខ្មៅ របស់ជនដ៏ចម្រើនទាំងនេះ ព្រះសមណគោតមលះបង់ធម៌ទាំងនេះមិនឲ្យសេសសល់

ធម្មេ អនវសេសំ បហាយ វត្តតិ យំ វា បន ភោន្តោ បរេ គណាចរិយាតិ ។ ឥតិហ កស្សប វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា អម្ហេ វ តត្ថ យេភុយ្យេន បសំសេយ្យុំ ។

[៦៩] អបរំបិ ដោ កស្សប វិញ្ញូ សមនុយុញ្ជន្តំ សមនុគ្គាហន្តំ សមនុភាសន្តំ សត្ថារា វា សត្ថារំ សង្ឃេន វា សង្ឃំ យេ ឥមេសំ ភវតំ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា សេវិតព្វសង្ខាតា អលមរិយា អលមរិយសង្ខាតា សុក្កា សុក្កសង្ខាតា កោ ឥមេ ធម្មេ អនវសេសំ សមាទាយ វត្តតិ សមណោ គោតមោ បរេ វា បន ភោន្តោ គណាចរិយាតិ ។ ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា ឯវំ វទេយ្យុំ យេ ឥមេសំ ភវតំ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា

ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌ទាំងនោះ ដោយប្រការដូច្នេះឯង ។

[៦៥] ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជន កាលបើមិនសួររកលទ្ធិ មិនដេញដោលរកហេតុ មិនសួរស្ទាក់រកលទ្ធិនិងហេតុ មិនប្រៀបធៀបគ្រូនឹងគ្រូ ឬពួកនឹងពួកថា ធម៌ទាំងឡាយ ដែលជាកុសល រាប់ថាជាកុសល មិនមានទោស រាប់ថាមិនមានទោស គួរសេព រាប់ថាគួរសេព ប្រសើរ រាប់ថាប្រសើរ ជាចំណែកស រាប់ថាជាចំណែកស របស់ពួកជនដ៏ចម្រើនទាំងនេះ តើនរណាសមាទានធម៌ទាំងនេះមិនឲ្យសេសសល់ ហើយប្រព្រឹត្តកាន់បាន ព្រះសមណគោតម ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ពួកវិញ្ញូជន កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយ ដែលជាកុសល រាប់ថាជាកុសល មិនមានទោស រាប់ថាមិនមានទោស គួរសេព រាប់ថា

សេវិតព្វសង្ខាតា អលមរិយា អលមរិយសង្ខាតា សុក្កា សុក្កសង្ខាតា សមណោ គោតមោ ឥមេ ធម្មេ អនវសេសំ សមាទាយ វត្តតិ យំ វា បន ភោន្តោ បរេ គណាចរិយាតិ ។ ឥតិហ កស្សប វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា អម្ហេ វ តត្ថ យេភុយ្យេន បសំសេយ្យុំ ។

[៦៦] អបរម្បិ ខោ កស្សប វិញ្ញូ សមនុយុញ្ជន្តំ សមនុគ្គាហន្តំ សមនុភាសន្តំ សត្ថារា វា សត្ថារំ សង្ឃេន វា សង្ឃំ យេ ឥមេសំ ភវតំ ធម្មា អកុសលា អកុសលសង្ខាតា សាវជ្ជា សាវជ្ជសង្ខាតា អសេវិតព្វា អសេវិតព្វសង្ខាតា នអលមរិយា នអលមរិយសង្ខាតា កណ្ហា កណ្ហសង្ខាតា កោ ឥមេ ធម្មេ អនវសេសំ បហាយ វត្តតិ គោតមសាវកសង្ឃោ វា បរេ វា បន ភោន្តោ គណាចរិយសាវកសង្ឃាតិ ។ ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា ឯវំ វទេយ្យុំ យេ

គួរសេព ប្រសើរ រាប់ថាប្រសើរ ជាចំណែកស រាប់ថាជាចំណែកស របស់ជនដ៏ចម្រើនទាំងនេះ ព្រះសមណគោតម សមាទានធម៌ទាំងនេះមិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជន ក្នុងលោកនេះ កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏ច្រើនតែសរសើរពួកតថាគតក្នុងធម៌នោះ ដោយប្រការដូច្នេះឯង ។

[៦៦] ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជន កាលបើមិនសួររកលទ្ធិ មិនដេញដោលរកហេតុ មិនសួរស្ទាក់រកលទ្ធិនិងហេតុ មិនប្រៀបធៀបគ្រូនិងគ្រូ ឬពួកនិងពួកថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថាជាអកុសល មានទោស រាប់ថាមានទោស មិនគួរសេព រាប់ថាមិនគួរសេព មិនប្រសើរ រាប់ថាមិនប្រសើរ ជាចំណែកខ្មៅ រាប់ថាជាចំណែកខ្មៅ របស់ពួកជនដ៏ចម្រើនទាំងនេះ នរណាលះបង់ធម៌ទាំងនេះ មិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ពួកសាវ័ករបស់ព្រះគោតម ឬក៏ពួកសាវ័ករបស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ពួកវិញ្ញូជន កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជា

ឥមេសំ ភវតំ ធម្មា អកុសលា អកុសលសង្ខាតា សាវជ្ជា សាវជ្ជសង្ខាតា អសេវិតព្វា អសេវិតព្វសង្ខាតា នអលមរិយា នអលមរិយសង្ខាតា កណ្ហា កណ្ហសង្ខាតា គោតមសាវកសង្ឃោ ឥមេ ធម្មេ អនវសេសំ បហាយ វត្តតិ យំ វា បន ភោន្តោ បរេ គណាចរិយសាវកសង្ឃាតិ ។ ឥតិហ កស្សប វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា អម្ហេវ តត្ថ យេភុយ្យេន បសំសេយ្យុំ ។

[៦៧] អបរំបិ ខោ កស្សប វិញ្ញូ សមនុយុញ្ជន្តំ សមនុគ្គាហន្តំ សមនុភាសន្តំ សត្ថារា វា សត្ថារំ សង្ឃេន វា សង្ឃំ យេ ឥមេសំ ភវតំ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា សេវិតព្វសង្ខាតា អលមរិយា អលមរិយសង្ខាតា សុក្កា សុក្កសង្ខាតា កោ ឥមេ ធម្មេ អនវសេសំ សមាទាយ វត្តតិ គោតមសាវកសង្ឃោ វា បរេ វា បន ភោន្តោ គណាចរិយសាវកសង្ឃាតិ ។ ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ វិញ្ញូ

អកុសល រាប់ថាជាអកុសល មានទោស រាប់ថាមានទោស មិនគួរសេព រាប់ថាមិនគួរសេព មិនប្រសើរ រាប់ថាមិនប្រសើរ ជាចំណែកខ្មៅ រាប់ថាជាចំណែកខ្មៅ របស់ជនដ៏ចម្រើនទាំងនេះ ពួកសាវ័ករបស់ព្រះគោតមលះបង់ធម៌ទាំងនេះ មិនសេសសល់ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកសាវ័ករបស់ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌នោះ ដោយប្រការដូច្នេះឯង ។

[៦៧] ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជន កាលបើមិនសួររកលទ្ធិ មិនដេញដោលរកហេតុ មិនសួរស្ទាក់រកលទ្ធិនិងហេតុ មិនប្រៀបធៀបគ្រូនិងគ្រូ ឬពួកនិងពួកថា ធម៌ទាំងឡាយដែលជាកុសល រាប់ថាជាកុសល មិនមានទោស រាប់ថាមិនមានទោស គួរសេព រាប់ថាគួរសេព ប្រសើរ រាប់ថាប្រសើរ ជាចំណែកស រាប់ថាជាចំណែកស របស់ជនដ៏ចម្រើនទាំងនេះ នរណាសមាទានធម៌ទាំងនេះ មិនសេសសល់ហើយប្រព្រឹត្តកាន់បាន ពួកសាវ័ករបស់ព្រះគោតម ឬក៏ពួកសាវ័ករបស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ពួកវិញ្ញូជន

៨៦



សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា ឯវំ វទេយ្យុំ យេ ឥមេសំ ភវតំ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា សេវិតព្វសង្ខាតា អលមរិយា អលមរិយសង្ខាតា សុក្កា សុក្កសង្ខាតា គោតមសាវកសង្ឃោ ឥមេ ធម្មេ អនវសេសំ សមាទាយ វត្តតិ យំ វា បន ភោន្តោ បរេ គណាចរិយសាវកសង្ឃាតិ ។ ឥតិហ កស្សប វិញ្ញូ សមនុយុញ្ជន្តា សមនុគ្គាហន្តា សមនុភាសន្តា អម្ហេ វ តត្ថ យេភុយ្យេន បសំសេយ្យុំ ។ អត្ថិ កស្សប មគ្គោ អត្ថិ បដិបទា យថាបដិបន្នោ សាមញ្ញេវ ញស្សតិ សាមំ ទក្ខតិ សមណោ គោតមោ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទីតិ ។ កតមោ ច កស្សប មគ្គោ កតមា ច បដិបទា យថាបដិបន្នោ សាមញ្ញេវ ញស្សតិ សាមំ ទក្ខតិ សមណោ គោតមោ កាលវាទី ភូតវាទី

កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាកុសល រាប់ថាជាកុសល មិនមានទោស រាប់ថាមិនមានទោស គួរសេព រាប់ថាគួរសេព ប្រសើរ រាប់ថាប្រសើរ ជាចំណែកស រាប់ថាជាចំណែកស របស់ពួកជនដ៏ចម្រើនទាំងនេះ ពួកសាវ័ករបស់ព្រះគោតម សមាទានធម៌ទាំងនេះ មិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកសាវ័ក របស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជន ក្នុងលោកនេះ កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌ទាំងនោះ ដោយប្រការដូច្នេះឯង ។ ម្នាលកស្សប លោកុត្តរមគ្គក៏មាន បុព្វភាគប្បដិបទា (សេចក្តីប្រតិបត្តិជាចំណែកខាងដើម) ក៏មាន ដែលបុគ្គលប្រតិបត្តិឲ្យសមគួរហើយ គង់ដឹងជាក់ច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតម និយាយត្រូវតាមកាល និយាយពិត និយាយប្រកបដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។ ម្នាលកស្សប ចុះលោកុត្តរមគ្គនោះ តើដូចម្តេច បុព្វភាគប្បដិបទា តើដូចម្តេច ដែលបុគ្គលប្រតិបត្តិឲ្យសមគួរហើយ គង់ដឹងជាក់ច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតម និយាយត្រូវតាមកាល និយាយពិត និយាយប្រកប

អត្ថវាទី ធម្មវាទី វិនយវាទីតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មា-សង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ កស្សប មគ្គោ អយំ បដិបទា យថាបដិបន្នោ សាមញ្ញេវ ញស្សតិ សាមំ ទក្ខតិ សមណោ គោតមោ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទីតិ ។

[៦៨] ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯត-ទវោច ឥមេបិ[១] ខោ អាវុសោ គោតម តបោបក្កមា ឯតេសំ[២] សមណព្រាហ្មណានំ សាមញ្ញសង្ខាតា ច ព្រហ្មញ្ញសង្ខាតា ច អចេលកោ ច ហោតិ មុត្តាចារោ ហត្ថាវលេខនោ ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ នាភិហតំ ន ឧទ្ទិស្ស កតំ ន និមន្តនំ សាទិយតិ

---

១ ឱ. ឥមេ ។ ២ ឱ. ឯកេសំ ។

ដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។ នេះឯងជាមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ សេចក្តីរលឹកត្រូវ ១ តម្កល់ចិត្តត្រូវ ១ ។ ម្នាលកស្សប នេះឯងជាលោកុត្តរមគ្គ នេះឯងជាបុព្វភាគប្បដិបទា ដែលបុគ្គលប្រតិបត្តិឲ្យសមគួរហើយ គង់ដឹងច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតម និយាយត្រូវតាមកាល និយាយពិត និយាយប្រកបដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។

[៦៨] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា អាវុសោគោតម ការផ្តើមនូវតបៈទាំងនេះ ដែលរាប់ថាជាកិច្ចការរបស់សមណៈផង រាប់ថាជាកិច្ចការរបស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺជាបុគ្គលគ្មានសំពត់ (អាក្រាត) លះបង់មារយាទល្អ ស៊ីលិទ្ធដៃ ឬជម្រះឧច្ចារៈដោយម្រាមដៃ គេអញ្ជើញថាចូលមក ក៏មិនមក គេឃាត់ថាឈប់ ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្តន៍

សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ សត្តាគារិកោ វា ហោតិ សត្តា-លោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ សត្តហិបិ ទត្តីហិ យាបេតិ ឯកា-ហិកំបិ អាហារំ អាហារេតិ ទ្វីហិកំបិ អាហារំ អា-ហារេតិ សត្តាហិកំបិ អាហារំ អាហារេតិ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគម-នុយុត្តោ វិហរតិ ។ ឥមេបិ ខោ អាវុសោ គោតម

អចេលកៈនោះមិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្តដែលគេនាំមក ត្រង់ចន្លោះធរណីទ្វារ មិនទទួលភត្តដែលគេនាំមកត្រង់ចន្លោះកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកត្រង់ចន្លោះអង្រេ មិនទទួលភត្តរបស់មនុស្សពីរនាក់ កំពុងបរិភោគ មិនទទួលភត្តរបស់ស្រីមានគភ៌ មិនទទួលភត្តរបស់ស្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្រីដែលនៅក្នុងចន្លោះបុរស មិនទទួលភត្តក្នុងទីដែលពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ ។ អចេលកៈនោះ ទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅចំពោះតែក្នុងដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ១ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ២ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍ ៧ ខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ ។ អចេលកៈប្រកបដោយសេចក្ដីព្យាយាម ក្នុងការផ្លាស់ប្ដូរនូវការបរិភោគភត្តរំលងកន្លះខែ មានសភាពយ៉ាងនេះដូច្នេះឯង ។ អាវុសោ គោតម

មហាសីហនាទសុត្តេ អចេលកស្សបស្ស តបោបក្កមកថា

តចោបក្កមា ឯតេសំ សមណព្រាហ្មណានំ សាមញ្ញ-សង្ខាតា ច ព្រហ្មញ្ញសង្ខាតា ច សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ និវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ និយាសភក្ខោ វា ហោតិ ហាតកភក្ខោ វា ហោតិ កណភក្ខោ វា ហោតិ អា-ចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិ-ណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ ឥមេបិ ខោ អាវុសោ គោតម តចោបក្កមា ឯតេសំ សមណ-ព្រាហ្មណានំ សាមញ្ញសង្ខាតា ច ព្រហ្មញ្ញសង្ខាតា ច សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិ-បិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដានិបិ ធារេតិ អជិនានិបិ ធារេតិ អជិនក្ខិបំបិ ធារេតិ កុសចីរំបិ ធារេតិ វាកចីរំបិ ធារេតិ ផលកចីរំបិ ធារេតិ

ការផ្ដើមតបៈទាំងនេះ ដែលរាប់ថាជាកិច្ចការ របស់សមណៈផង រាប់ថាជាកិច្ចការ របស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺបុគ្គលមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្គួយជាអាហារខ្លះ មានកម្ទេចស្បែក (ចំនៀរស្បែក) ជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្មៅឬសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើនិងផ្លែឈើព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ អាវុសោ គោតម ការផ្ដើមតបៈទាំងនេះ រាប់ថាជាកិច្ចការ របស់សមណៈផង រាប់ថាជាកិច្ចការ របស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បំសុកូលខ្លះ ទ្រទ្រង់សំបកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវក្តាំងក្រងជាសំពត់ខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសំបកក្រថៅខ្លះ ទ្រទ្រង់ចម្រៀកក្តារជាសំពត់ខ្លះ ទ្រទ្រង់

កេសកម្ពលំបិ ធារេតិ វាលកម្ពលំបិ ធារេតិ ឧលូ-
កបក្ខំបិ ធារេតិ កេសមស្សុលោចកោបិ ហោតិ
កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ
ហោតិ អាសនប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុ-
ដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ
កណ្ដកាបស្សយេ សេយ្យំ កប្បេតិ ផលកសេយ្យំបិ
កប្បេតិ ថណ្ឌិលសេយ្យំបិ កប្បេតិ ឯកបស្សយិកោ-
បិ ហោតិ រជោជល្លធរោ អព្ភោកាសិកោ[១] ហោតិ
យថាសន្ថតិកោ វេកដិកោបិ ហោតិ វិកដភោជនា-
នុយោគមនុយុត្តោ អាបានកោបិ ហោតិ អាបានក-
មនុយុត្តោ[២] សាយំ តតិយកំបិ ឧទកោរោហនានុយោ-
គមនុយុត្តោ វិហរតីតិ ។

[៦៩] អចេលកោ ចេបិ កស្សប ហោតិ មុត្តាចា-
រោ ហត្ថាវលេខនោ ។ បេ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំ-
បិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។

---

១ ឱ. រជោជល្លធរោ អព្ភោកាសិកោបិ ។ ២ ឱ. ម. អាបានកត្តមនុយុត្តោ ។

សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់និងពុកមាត់ ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមទុកសក់និងពុកមាត់ខ្លះ ឈរសម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោង ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមច្រហោងខ្លះ ផ្អែកលើបន្លា សម្រេចការដេកលើបន្លាខ្លះ សម្រេចការដេកលើផែនក្តារខ្លះ សម្រេចការដេកផ្ទាល់ផែនដីខ្លះ ដេកផ្អៀងតែម្ខាងមានសរីរៈប្រឡាក់ដោយធូលីខ្លះ នៅកណ្តាលវាលអង្គុយលើអាសនៈតាមតែបានខ្លះ បរិភោគតែលាមក ប្រព្រឹត្តកាន់វត្តក្នុងការព្យា-យាមបរិភោគតែលាមកខ្លះ តមទឹកត្រជាក់ ប្រព្រឹត្តកាន់វត្តតមទឹកត្រជាក់ខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។

[៦៩] ម្នាលកស្សប បើអចេលកៈ ជាអ្នកលះបង់មារយាទល្អ បរិភោគលិទ្ធដៃ ។ បេ ។ ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមផ្លាស់ប្តូរនូវការបរិភោគភត្តរំលងកន្លះខែ មានសភាពយ៉ាងនេះដូច្នេះឯង ។ ចំណែកខាង

៩១

មហាសីហនាទសុត្តេ តិវិធា សម្បទា

តស្ស វាយំ សីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទា អភាវិតា ហោតិ អសច្ឆិកតា ។ អថខោ សោ អារកា ច[១] សាមញ្ញា អារកា ច[២] ព្រហ្មញ្ញា ។ យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបិ ។ សាកភក្ខោ ចេបិ កស្សប ហោតិ សាមាកភក្ខោ ។ បេ ។ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ តស្ស វាយំ[៣] សីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទា អភាវិតា ហោតិ អសច្ឆិកតា ។ អថខោ សោ អារកា ច សាមញ្ញា អារកា ច ព្រហ្មញ្ញា ។ យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ

១.២ ឱ. ម. វ ។ ៣ ឱ. ម. ចាយំ ។

មហាសីហនាទសូត្រ សម្បទា ៣ ប្រការ

សីលសម្បទា ចិត្តសម្បទានិងបញ្ញាសម្បទានេះ ក៏អចេលកៈនោះ មិនបានចម្រើន មិនបានធ្វើឲ្យជាក់ច្បាស់ឡើយ ។ អចេលកៈនោះ ឈ្មោះថាឆ្ងាយចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាលកស្សប ភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯងក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថាសមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈមានបន្លែស្រស់ជាអាហារ មានអង្ករស្រងែជាអាហារ ។ បេ ។ មានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ខាងឯសីលសម្បទា ចិត្តសម្បទានិងបញ្ញាសម្បទានេះ ក៏អចេលកៈនោះមិនដែលបានចម្រើន មិនដែលបានធ្វើឲ្យជាក់ច្បាស់ឡើយ ។ អចេលកៈនោះឈ្មោះថាឆ្ងាយចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាលកស្សប ភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯងក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្ត មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន

ព្រាហ្មណោ ឥតិបិ ។ សាណាធិ ចេបិ កស្សប ជាវេតិ មសាណាធិបិ ជាវេតិ ។ បេ ។ សាយំ តតិយកំបិ ឧជកោពេហាជានុយោគមនុយុត្តោ វិហរតិ ។ តស្ស វាយំ សីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទា អភាវិតា ហោតិ អសច្ឆិកតា ។ អថខោ សោ អារកា ច សាមញ្ញា អារកា ច ព្រហ្មញ្ញា ។ យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបីតិ ។

[៧០] ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯត-ទវោច ទុក្ករំ ភោ គោតម សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញ-ន្តិ ។ បកតិ ខោ ឯសា កស្សប លោកស្មឹ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ ។ អចេលកោ ចេបិ

ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈនោះទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។ បេ ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ចំណែកខាងសីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទានេះ ក៏អចេលកៈនោះ មិនបានចម្រើន មិនបានធ្វើឲ្យជាក់ច្បាស់ឡើយ ។ អចេលកៈនោះឈ្មោះថាឆ្ងាយចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថាសមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។

[៧០] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សាមញ្ញគុណកម្រធ្វើបានណាស់ ព្រហ្មញ្ញគុណកម្រធ្វើបានណាស់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប សំដីដែលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាននេះ ជាសំដីប្រក្រតីក្នុងលោកទេ ។ ម្នាលកស្សប បើអចេលកៈលះបង់នូវមារ-

៩៣



កស្សប ហោតិ មុត្តាចារោ ហត្ថាវលេខនោ ។ បេ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ ឥមាយ ច កស្សប មត្តាយ ឥមិនា ច តចោបក្កមេន សាមញ្ញំ វា អកវិស្ស ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ នេតំ អកវិស្ស កល្លំ វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ សក្កា ច បនេតំ អកវិស្ស កាតុំ គហបតិនា វា គហបតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ ហន្ទាហំ អចេលកោ ហោមិ មុត្តាចារោ ហត្ថាវលេខនោ ។ បេ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរាមីតិ ។ យស្មា ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច[1] មត្តាយ អញ្ញត្រ ឥមិនា ច[2] តចោបក្កមេន សាមញ្ញំ វា ហោតិ ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ តស្មា ឯតំ កល្លំ វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ ។

---

១.២ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

យាទល្អ បរិភោគលិទ្ធដៃ ។ បេ ។ ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាម ផ្លាស់ប្តូរនូវការបរិភោគភត្តរំលងកន្លះខែ មានសភាពយ៉ាងនេះដូច្នេះ ។ ម្នាលកស្សប សាមញ្ញគុណឬព្រហ្មញ្ញគុណ ដែលថាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែសេចក្តីប្រតិបត្តិបន្តិចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណធ្វើបានដោយលំបាក នុ៎ះមិនគួរទេ ព្រោះគហបតីនិងបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណនិងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះអាត្មាអញធ្លាប់ជាអ្នកអាក្រាត ជាអ្នកលះបង់មារយាទល្អ ជាអ្នកបរិភោគលិទ្ធដៃ ។ បេ ។ អាត្មាអញប្រព្រឹត្តកាន់វត្តបរិភោគភត្តផ្លាស់ប្តូររំលងកន្លះខែ មានសភាពយ៉ាងនេះហើយ ។ ម្នាលកស្សប កាលណាបើវៀចាកអចេលកវត្តបន្តិចប៉ុណ្ណោះ និងវៀរចាកការផ្តើមតបៈនេះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណឬព្រហ្មញ្ញគុណដែលថាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថាសាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានក្រៃពេក នុ៎ះក៏គួរខ្លះដែរ ។

យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្ត-
ចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ
បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិក-
ត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប
ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបិ ។
សាកភក្ខោ ចេបិ កស្សប ហោតិ សាមាក-
ភក្ខោ ។ បេ ។ វនមូលផលាហារោ យាបេតិ បវត្ត-
ផលភោជី ។ ឥមាយ ច កស្សប មត្តាយ ឥមិ-
នា ច តបោបក្កមេន សាមញ្ញំ វា អភវិស្ស
ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ នេតំ អភវិស្ស កល្លំ
វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ សក្កា
ច បនេតំ អភវិស្ស កាតុំ គហបតិនា វា គហ-
បតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ ហន្ទាហំ
សាកភក្ខោ ហោមិ សាមាកភក្ខោ វា ។ បេ ។
វនមូលផលាហារោ យាបេមិ បវត្តផលភោជីតិ ។

ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈ មានបន្លែស្រស់ជាអាហារ មានអង្ករស្រងែជាអាហារ ។ បេ ។ មានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ម្នាលកស្សប សាមញ្ញគុណឬព្រហ្មញ្ញគុណដែលថា កម្រធ្វើបាន រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែសេចក្តីប្រតិបត្តិបន្តិចបន្តួចនេះនិងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សាមញ្ញ-គុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាន នុ៎ះមិនគួរឡើយ ព្រោះគហបតីនិងបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណ និងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះ អាត្មាអញធ្លាប់ជាអ្នកមានបន្លែស្រស់ជាអាហារ ឬអង្ករស្រងែជាអាហារ ។ បេ ។ អាត្មាអញធ្លាប់ជាអ្នកមានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។

យស្មា ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច មត្តាយ អញ្ញត្រ ឥមិនា ច តចោបក្កមេន សា-មញ្ញំ វា ហោតិ ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ តស្មា ឯតំ កល្លំ វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញ-ន្តិ ។ យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេ-តោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបិ ។ សាណានិ ចេបិ កស្សប ធារេតិ មសាណានិបិ ធារេតិ ។ បេ ។ សាយំ តតិយកំបិ ឧទកោរោហនានុយោគមនុ-យុត្តោ វិហរតិ ។ ឥមាយ ច កស្សប មត្តាយ ឥមិនា ច តចោបក្កមេន សាមញ្ញំ វា អភវិស្ស ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ នេតំ អភវិស្ស កល្លំ វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ សក្កា ច បនេតំ អភវិស្ស កាតុំ គហបតិនា វា គហ-បតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ ហន្ទាហំ

ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្តិចនេះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណឬព្រហ្មញ្ញ-គុណ ដែលជាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ក៏គួរនឹងពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានដូច្នេះក៏គួរដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្តមិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។ បេ ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាច ។ ម្នាលកស្សប សាមញ្ញគុណឬព្រហ្មញ្ញគុណដែលជាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែអចេលក-វត្តបន្តិចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែមិនគួរនឹងពោលថា សាមញ្ញ-គុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានដូច្នេះទេ ព្រោះគហបតីនិងបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណនិងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះ អាត្មា

សាណានិបិ ជានេមិ មសាណានិបិ ជានេមិ ។ បេ ។ សាយំ តតិយកំបិ ឧឧកោរោហនានុយោគមនុយុត្តោ វិហរាមីតិ ។ យស្មា ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច មត្តាយ អញ្ញត្រ ឥមិនា ច តបោ-បក្កមេន សាមញ្ញំ វា ហោតិ ព្រហ្មញ្ញំ វា ទុក្ករំ សុទុក្ករំ តស្មា ឯតំ កល្លំ វចនាយ ទុក្ករំ សាមញ្ញំ ទុក្ករំ ព្រហ្មញ្ញន្តិ ។ យតោ ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបីតិ ។

[៧១] ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯត-ទវោច ទុជ្ជានោ ភោ គោតម សមណោ ទុជ្ជានោ ព្រាហ្មណោតិ ។ បកតិ ខោ ឯសា កស្សប លោក-ស្មឹ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ ។

អញធ្លាប់ទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។ បេ ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តមានប្រមាណតិចប៉ុណ្ណោះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណឬព្រហ្មញ្ញគុណ ដែលជាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានទុំះក៏គួរខ្លះ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថាសមណៈក៏បាន ថាព្រាហ្មណ៍បាន ។

[៧១] កាលបើ ព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ អចេលកស្សប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ដែលហៅថា សមណៈ បុគ្គលដឹងបានដោយកម្រ ហៅថាព្រាហ្មណ៍ ក៏បុគ្គលដឹងបាន ដោយកម្រ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប សំដីដែលថា សមណៈ បុគ្គលដឹងបានដោយកម្រព្រាហ្មណ៍ក៏បុគ្គលដឹងបានដោយកម្រ នេះជាសំដីប្រក្រតីក្នុងលោកទេ ។

៩៧

មហាសីហនាទសុត្តេ មេត្តចិត្តភាវនាកថា

អចេលកោ ចេបិ កស្សប ហោតិ មុត្តាចារោ ហត្ថាវលេខនោ ។ បេ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ ឥមាយ ច កស្សប មត្តាយ ឥមិនា ច តបោបក្កមេន សមណោ វា អភវិស្ស ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ នេតំ អភវិស្ស កល្លំ វចនាយ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ សក្កា ច បនេតំ[១] អភវិស្ស ញាតុំ គហបតិនា វា គហបតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ អយំបិ[២] អចេលោ មុត្តាចារោ ហត្ថាវលេខនោ ។ បេ ។ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតីតិ ។ យស្មា ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច មត្តាយ អញ្ញត្រ ឥមិនា ច តបោបក្កមេន សមណោ វា ហោតិ ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ តស្មា ឯតំ កល្លំ វចនាយ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ ។ យតោ ខោ កស្សប ភិក្ខុ

១ ឱ. ម. បនេសោ ។ ២ ឱ. ម. អបិសទ្ទោ ន ទិស្សតិ ។

មហាសីហនាទសូត្រ ពោលអំពីការចម្រើនមេត្តាចិត្ត

ម្នាលកស្សប បើអចេលកៈលះបង់នូវមារយាទល្អ បរិភោគលិទ្ធដៃ ។ បេ ។ ប្រព្រឹត្តកាន់វត្តបរិភោគកត្តផ្លាស់ប្តូរ រំលងកន្ទះខែ មានសភាពយ៉ាងនេះដូច្នេះ ។ ម្នាលកស្សប សមណៈឬព្រាហ្មណ៍ដែលថាបុគ្គលដឹងបានដោយកម្រ ក៏រឹតតែដឹងបានដោយកម្រក្រៃពេក ព្រោះតែអចេលកវត្តបន្តិចនេះនិងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថាសមណៈបុគ្គលដឹងបានដោយកម្រ ព្រាហ្មណ៍ក៏បុគ្គលដឹងបានដោយកម្រនុ៎ះ មិនគួរទេ ព្រោះគហបតី ឬបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសីក៏អាចដឹងនូវបុគ្គលនេះថា នេះជាអចេលកៈ អ្នកលះបង់មារយាទល្អ បរិភោគលិទ្ធដៃ ។ បេ ។ ប្រព្រឹត្តកាន់វត្តបរិភោគកត្តផ្លាស់ប្តូរ រំលងកន្ទះខែ មានសភាពយ៉ាងនេះដូច្នេះ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្តិចនេះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញហើយ សមណៈឬព្រាហ្មណ៍ដែលថា គេដឹងបានដោយក្រ ក៏រឹតតែដឹងបានដោយក្រក្រៃពេក ព្រោះហេតុនោះក៏គួរនឹងពោលថា សមណៈគេដឹងបានដោយក្រដូច្នេះដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត

អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបិ ។ សាកភក្ខោ ចេបិ កស្សប ហោតិ សាមាកភក្ខោ ។ បេ ។ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ ឥមាយ ច កស្សប មត្តាយ ឥមិនា ច តបោបក្កមេន សមណោ វា អភវិស្ស ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ នេតំ អភវិស្ស កល្លំ វចនាយ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ សក្កា ច បនេសោ អភវិស្ស ញាតុំ គហបតិនា វា គហបតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ អយំ សាកភក្ខោ វា ហោតិ សាមាកភក្ខោ ។ បេ ។ វនមូលផលាហារោ យាបេតិ បវត្តផលភោជីតិ ។ យស្មា ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច មត្តាយ អញ្ញត្រ ឥមិនា ច តបោបក្កមេន សមណោ វា ហោតិ ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ តស្មា ឯតំ កល្លំ វចនាយ

មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈមានបន្លែស្រស់ជាអាហារ មានអង្ករស្រងែជាអាហារ ។ បេ ។ មានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគផ្លែឈើដែលជ្រុះស្រាប់ ចម្អែតអាត្មា ។ ម្នាលកស្សប សមណៈឬព្រាហ្មណ៍ឈ្មោះថា គេដឹងបាន ដោយក្រ ក៏រឹតតែដឹងបានដោយក្រក្រៃពេក ព្រោះអចេលកវត្តនិងការផ្តើមនូវតបៈមានប្រមាណប៉ុណ្ណោះ តែពាក្យដែលពោលថា សមណៈគេដឹងបាន ដោយក្រ ព្រាហ្មណ៍ក៏គេដឹងបានដោយក្រ នុ៎ះមិនគួរឡើយ ទោះបីគហបតី ឬបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចដឹងនូវបុគ្គល នេះបាន ថាបុគ្គលនេះមានបន្លែស្រស់ជាអាហារ ឬមានអង្ករស្រងែ ជា អាហារ ។ បេ ។ មានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគតែ ផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ម្នាលកស្សប កាលណាបើវៀរ ចាកអចេលកវត្តបន្តិចនេះ និងវៀរចាកការផ្តើមតបៈ ប៉ុណ្ណោះចេញហើយ សមណៈឬព្រាហ្មណ៍ ដែលថា គេដឹងបានដោយក្រ ក៏រឹតតែដឹងបាន ដោយក្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថា សមណៈគេដឹង

មហាសីហនាទសុត្តេ  មេត្តចិត្តភាវនាកថា

ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ ។ យតោ ច[១] ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបិ ។ សាណានិ ចេបិ កស្សប ធារេតិ មសាណានិបិ ធារេតិ ។ បេ ។ សាយំ តតិយកំបិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ ។ ឥមាយ ច កស្សប មត្តាយ ឥមិនា ច តបោបក្កមេន សមណោ វា អភវិស្ស ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ នេតំ អភវិស្ស កល្លំ វចនាយ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ សក្កា ច បនេសោ អភវិស្ស ញាតុំ គហបតិនា វា គហបតិបុត្តេន វា អន្តមសោ កុម្ភទាសិយាបិ អយំ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ។ បេ ។ សាយំ តតិយកំបិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតីតិ ។ យស្មា

១ ឱ. ចសទ្ទោ ន ទិស្សតិ ។

បានដោយក្រ ព្រាហ្មណ៍គេដឹងបានដោយក្រនុំះក៏គួរដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោ-វិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើបុគ្គលទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។ បេ ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ៣ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប សមណៈឬព្រាហ្មណ៍ដែលថាគេដឹងបានដោយក្រ ក៏រឹតតែដឹងបានដោយក្រក្រៃពេក ព្រោះតែអចេលក-វត្តបដិបត្តិនេះនិងការផ្តើមតបៈប៉ុណ្ណោះ ពាក្យដែលពោលថា សមណៈគេដឹងបានដោយក្រ ព្រាហ្មណ៍គេដឹងបានដោយក្រនុំះ មិនគួរទេ ទោះបីគហបតីឬបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចដឹងបុគ្គលនេះបានថា បុគ្គលនេះទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។ បេ ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប កាលណាបើវៀរចាក

ច ខោ កស្សប អញ្ញត្រេវ ឥមាយ ច មត្តាយ អញ្ញត្រ ឥមិនា ច តបោបក្កមេន សមណោ វា ហោតិ ព្រាហ្មណោ វា ទុជ្ជានោ សុទុជ្ជានោ តស្មា ឯតំ កល្លំ វចនាយ ទុជ្ជានោ សមណោ ទុជ្ជានោ ព្រាហ្មណោតិ ។ យតោ ច ខោ កស្សប ភិក្ខុ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតិ អាសវានញ្ច ខយា អនាសវញ្ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ កស្សប ភិក្ខុ សមណោ ឥតិបិ ព្រាហ្មណោ ឥតិបីតិ ។

[៧២] ឯវំ វុត្តេ អចេលោ កស្សបោ ភគវន្តំ ឯតទវោច កតមា បន សា ភោ គោតម សីលសម្បទា កតមា ចិត្តសម្បទា កតមា បញ្ញាសម្បទាតិ ។ ឥធ កស្សប តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ វិត្ថារេតព្វោ ។ កាចញ្ច កស្សប ភិក្ខុ សីលសម្បន្នោ ហោតិ ឥធ កស្សប ភិក្ខុ

អចេលកវត្តបន្ទិចនេះ និងការផ្តើមតបៈប៉ុណ្ណោះចេញហើយ សមណៈឬព្រាហ្មណ៍ ដែលថា គេដឹងបានដោយក្រ ក៏រឹតតែដឹងបានដោយក្រក្រៃពេក ព្រោះហេតុនោះពាក្យដែលនិយាយថា សមណៈគេដឹងបានដោយក្រ ព្រាហ្មណ៍គេដឹងបានដោយក្រ នុ៎ះក៏គួរដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។

[៧២] កាលបើ ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អចេលកស្សប បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សីលសម្បទា តើដូចម្តេច ចិត្តសម្បទា តើដូចម្តេច បញ្ញាសម្បទា តើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកស្សប ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហំសម្មាសម្ពុទ្ធ ។ បេ ។ បណ្ឌិតគប្បីសំដែងឲ្យពិស្តារផងចុះ ។ ម្នាលកស្សប ដូចម្តេចដែលហៅថា ភិក្ខុជាអ្នកបរិបូណ៌ដោយសីល ម្នាលកស្សប ភិក្ខុក្នុងសាសនានេះ លះបង់

១០១

មហាសីហនាទសុត្តេ តិវិធា សម្បទា

បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វប្បាណភូតហិតានុកម្បី វិហរតិ ឥទំបិស្ស ហោតិ សីលសម្បទាយ ។ បេ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិ-សំវេទេតិ ឯវំ កស្សប ភិក្ខុ សីលសម្បន្នោ ហោតិ អយំ ខោ សា កស្សប សីលសម្បទា ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំបិស្ស ហោតិ ចិត្ត-សម្បទាយ អយំ ខោ កស្សប ចិត្តសម្បទា ។ បេ ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ឥទំបិស្ស ហោតិ បញ្ញាសម្បទាយ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ឥទំបិស្ស ហោតិ បញ្ញាសម្ប-ទាយ អយំ ខោ កស្សប បញ្ញាសម្បទា ។ ឥមាយ ច កស្សប សីលសម្បទាយ ចិត្តសម្បទាយ បញ្ញា-សម្បទាយ អញ្ញា សីលសម្បទា ចិត្តសម្បទា បញ្ញា-សម្បទា ឧត្តរិតរា វា បណីតតរា វា នត្ថិ ។

មហាសីហនាទសូត្រ សម្បទា ៣ យ៉ាង

បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីអៀនខ្មាស ដល់ហើយនូវសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងពួង នេះជាសីលសម្បទា នៃភិក្ខុនោះឯង ។ បេ ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ រមែងទទួលនូវសេចក្តីសុខ មិនមានទោសតាំងនៅខាងក្នុង ម្នាលកស្សប យ៉ាងនេះហៅថា ភិក្ខុបរិបូណ៌ដោយសីល ម្នាលកស្សប នេះឯងឈ្មោះថាសីលសម្បទា ។ បេ ។ បានដល់នូវបឋមជ្ឈាន នេះជាចិត្តសម្បទានៃភិក្ខុនោះឯង ម្នាលកស្សប នេះឯងឈ្មោះថា ចិត្តសម្បទា ។ បេ ។ ភិក្ខុផ្ចង់តម្រង់បង្អោនចិត្តដើម្បីញាណទស្សនៈ នេះឯងជាបញ្ញាសម្បទារបស់ភិក្ខុនោះ ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃក្រៅអំពីនេះមិនមានឡើយ នេះឯងជាបញ្ញាសម្បទារបស់ភិក្ខុនោះ ម្នាលកស្សប នេះឯងឈ្មោះថាបញ្ញាសម្បទា ។ ម្នាលកស្សប សីលសម្បទា ចិត្តសម្បទានិងបញ្ញាសម្បទាឯទៀតដ៏លើសលប់ថ្លៃថ្លា ជាងសីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះគ្មានទេ ។

[៧៣] សន្តិ កស្សប ឯកេ សមណព្រាហ្មណា សីលវាទា តេ អនេកបរិយាយេន សីលវណ្ណំ[១] ភាសន្តិ ។ យាវតា កស្សប អរិយំ បរមំ សីលំ នាហំ តត្ថ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិសីលំ ។ សន្តិ កស្សប ឯកេ សមណព្រាហ្មណា តបោជិគុច្ឆវាទា តេ អនេកបរិយាយេន តបោជិគុច្ឆាយ វណ្ណំ ភាសន្តិ ។ យាវតា កស្សប អរិយា បរមា តបោជិគុច្ឆា នាហំ តត្ថ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិជេគុច្ឆំ ។ សន្តិ កស្សប ឯកេ សមណព្រាហ្មណា បញ្ញាវាទា តេ អនេកបរិយាយេន បញ្ញាយ វណ្ណំ ភាសន្តិ ។ យាវតា កស្សប អរិយា បរមា បញ្ញា នាហំ តត្ថ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ

១ ឱ. ម. សីលស្ស វណ្ណំ ។

[៧៣] ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាសីលវាទៈ (អ្នកពោលអាងសីល) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់សីលដោយអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) អរិយសីលដ៏ក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹមស្មើតថាគតក្នុងអរិយសីលនោះទេ ក្រៃលែងជាងមកពីណាបាន តថាគតឯង ជាអ្នកក្រៃលែងក្នុងគុណ គឺអធិសីលនោះដោយពិត ។ ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយជា តបោជិគុច្ឆវាទៈ (អ្នកពោលអាងការខ្ពើមកិលេសដោយតបៈ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណនៃការខ្ពើមកិលេស ដោយតបៈជាអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) ការខ្ពើមកិលេសដោយតបៈ ដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណា ត្រឹមស្មើនឹងការខ្ពើមកិលេស របស់តថាគតក្នុងតបៈនោះទេ ក្រៃលែងមកពីណាបាន តថាគតឯង ជាអ្នកក្រៃលែងក្នុងគុណ គឺការខ្ពើមកិលេសដោយពិត ។ ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាបញ្ញាវាទៈ (អ្នកពោលអាងបញ្ញា) សមណព្រាហ្មណ៍ ទាំងនោះ តែងសរសើរគុណនៃបញ្ញា ដោយអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) បញ្ញាដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹមស្មើនឹងបញ្ញា របស់តថាគតក្នុងបញ្ញានោះទេ ក្រៃលែងមកពីណា

អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិបញ្ញា ។ សន្តិ កស្សប ឯកេ សមណព្រាហ្មណា វិមុត្តិវាទា តេ អនេកបរិយាយេន វិមុត្តិយា វណ្ណំ ភាសន្តិ ។ យាវតា កស្សប អរិយា បរមា វិមុត្តិ នាហំ តត្ថ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិវិមុត្តិ ។

[៧៤] ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សីហនាទំ ខោ សមណោ គោតមោ នទតិ តញ្ច ខោ សុញ្ញាគារេ នទតិ នោ ច បរិសាសូតិ ។ តេ មា ហេវន្តិស្សុ វចនីយា ។ សីហនាទញ្ច សមណោ គោតមោ នទតិ បរិសាសុ ច នទតិ នោ ច សុញ្ញាគារេ នទតីតិ ឯវមស្សុ កស្សប វចនីយា ។ ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ អញ្ញតិត្ថិយា

បាន តថាគតឯង៍ជាអ្នកក្រៃលែងក្នុងគុណ គឺអធិបញ្ញានោះដោយពិត ។ ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាវិមុត្តិវាទៈ (អ្នកពោលអាងវិមុត្តិ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់វិមុត្តិដោយអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) វិមុត្តិដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណា ត្រឹមស្មើនឹងវិមុត្តិរបស់តថាគតក្នុងវិមុត្តិនោះទេ ក្រៃលែងមកពីណាបាន តថាគតឯង៍ជាអ្នកក្រៃលែងក្នុងគុណគឺអធិវិមុត្តិនោះដោយពិត ។

[៧៤] ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ដែលពួកអន្យតិរ្ថិយ៍បរិញ្វាជកនិយាយ យ៉ាងនេះថា ព្រះសមណគោតម តែងតែបន្លឺសីហនាទ ប៉ុន្តែបន្លឺសីហនាទនោះ បានតែក្នុងផ្ទះស្ងាត់ មិនបន្លឺក្នុងពួកបរិសទ្យទេ ។ អ្នកត្រូវប្រាប់ពួកគេថា អ្នកទាំងឡាយកុំពោលយ៉ាងនេះឡើយ ម្នាលកស្សប អ្នកត្រូវប្រាប់គេថា ព្រះសមណគោតមតែងតែបន្លឺសីហនាទ បន្លឺតែក្នុងពួកបរិសទ្យ មិនបន្លឺក្នុងផ្ទះស្ងាត់ទេ ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ដែលពួកអន្យតិរ្ថិយ៍បរិញ្វាជក

បរិព្វាជកា ឯវំ វទេយ្យុំ សីហនាទំ សមណោ គោតមោ នទតិ បរិសាសុ ច នទតិ នោ[១] ច ខោ វិសារទោ នទតីតិ ។ តេ មា ហេវន្តិស្សុ វចនីយា ។ សីហនាទញ្ច សមណោ គោតមោ នទតិ បរិសាសុ ច នទតិ វិសារទោ ច នទតីតិ ឯវមស្សុ កស្សប វចនីយា ។ ឋានំ ខោ បនេតំ កស្សប វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សីហ-នាទញ្ច សមណោ គោតមោ នទតិ បរិសាសុ ច នទតិ វិសារទោ ច នទតិ នោ ច ខោ នំ បញ្ហំ បុច្ឆន្តិ បញ្ហញ្ច នំ បុច្ឆន្តិ នោ ច ខោ នេសំ បញ្ហំ បុដ្ឋោ ព្យាករោតិ បញ្ហញ្ច នេសំ បុដ្ឋោ ព្យាករោតិ នោ ច ខោ បញ្ហស្ស ព្យាករណេន ចិត្តំ អារាធេតិ បញ្ហស្ស ច ព្យាករណេន ចិត្តំ អារាធេតិ នោ ច ខោ សោតព្វំ មញ្ញន្តិ សោតព្វ-ញ្ចស្ស មញ្ញន្តិ នោ ច ខោ សុត្វា បសីទន្តិ សុត្វា ចស្ស បសីទន្តិ នោ ច ខោ បសន្នា បសន្នាការំ ករោន្តិ បសន្នា ច បសន្នាការំ ករោន្តិ នោ ច ខោ តថត្តាយ

១ ឱ. ន ។

និយាយយ៉ាងនេះថា ព្រះសមណគោតម តែងតែបន្លឺសីហនាទ បន្លឺក្នុងពួកបរិសទ្យដែរហើយ តែមិនជាអ្នកក្លៀវក្លាបន្លឺទេ ។ អ្នកត្រូវប្រាប់ពួកបរិព្វាជកទាំងនោះថា អ្នកទាំងឡាយ កុំពោលយ៉ាងនេះឡើយ ។ ម្នាលកស្សប អ្នកត្រូវប្រាប់ពួកគេថា ព្រះសមណគោតមបន្លឺសីហនាទ តែងបន្លឺក្នុងពួកបរិសទ្យជាអ្នកក្លៀវក្លាបន្លឺ ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ដែលពួកតិរ្ថិយបរិព្វាជក និយាយយ៉ាងនេះថា ព្រះសមណគោតមបន្លឺសីហនាទ តែងបន្លឺក្នុងពួកបរិសទ្យ ជាអ្នកក្លៀវក្លាបន្លឺ តែទេវតានិងមនុស្សទាំងឡាយមិនដែលសួរប្រស្នានឹងលោកឡើយ ទោះបីសួរប្រស្នានឹងលោក លោកក៏ដោះប្រស្នា ដែលពួកទេវតានិងមនុស្សទាំងនោះសួរ មិនបានទេ ទោះបីលោកដោះប្រស្នា ដែលពួកទេវតានិងមនុស្សទាំងនោះសួរបាន លោកក៏មិនញុំាងចិត្ត ឲ្យត្រេកអរដោយការដោះប្រស្នា បើទុកជាញុំាងចិត្តឲ្យត្រេកអរ ដោយការដោះប្រស្នាបាន ជនទាំងឡាយ ក៏មិនសំគាល់ថាគួរស្តាប់ទេ ទោះសំគាល់ថាគួរស្តាប់ ក៏គ្រាន់តែស្តាប់ហើយមិនជ្រះថ្លាទេ ទុកជាស្តាប់ហើយជ្រះថ្លា ក៏គ្រាន់តែជ្រះថ្លាប៉ុណ្ណោះ តែមិនធ្វើអាការជ្រះថ្លា (មែនទែន) ទេ ទុកជាជ្រះថ្លា ហើយធ្វើអាការជ្រះថ្លា ក៏មិនប្រតិបត្តិតាម

១០៤



បដិបជ្ជន្តិ តថត្តាយ ច បដិបជ្ជន្តិ ដោ ច ខោ បដិបន្នា អារាធេន្តីតិ ។ តេ មា ហេវន្តិស្សុ វចនីយា ។ សីហនាទញ្ច សមណោ គោតមោ នទតិ បរិសាសុ ច នទតិ វិសារទោ ច នទតិ បញ្ហញ្ច នំ បុច្ឆន្តិ បញ្ហញ្ច នេសំ បុដ្ឋោ ព្យាករោតិ បញ្ហស្ស ច វេយ្យាករណេន ចិត្តំ អារាធេតិ សោតព្វញ្ចស្ស មញ្ញន្តិ សុត្វា ចស្ស បសីទន្តិ បសន្នា ច បសន្នាការំ ករោន្តិ តថត្តាយ[១] បដិបជ្ជន្តិ បដិបន្នា ច អារាធេន្តីតិ ឯវមស្សុ កស្សប វចនីយា ។ ឯកមិទាហំ កស្សប សមយំ រាជគហេ វិហរាមិ គិជ្ឈកូដេ បព្វតេ ។ តត្រ មំ អញ្ញតរោ តេ សព្រហ្មចារី[២] និគ្រោធោ នាម បរិព្វាជកោ[៣] អធិជេគុច្ឆេ បញ្ហំ បុច្ឆិ តស្សាហំ អធិជេគុច្ឆេ បញ្ហំ បុដ្ឋោ ព្យាកាសឹ ព្យាកតេ ច បន មេ អត្តមនោ អហោសិ បរំ វិយ មត្តាយាតិ ។

---

១ ឱ. ម. ចសទ្ទោ ឥធ ទិស្សតិ ។ ២ ឱ. តបសព្រហ្មចារី ។ ម. តបព្រហ្មចារី ។ ៣ ឱ. ម. បរិព្វាជកោតិ ន ទិស្សតិ ។

សេចក្តីជ្រះថ្លានោះទេ បើទុកជាប្រតិបត្តិ តាមសេចក្តីជ្រះថ្លានោះបាន ក៏មិនប្រតិបត្តិ ឲ្យពេញព្រះទ័យនៃលោកបានទេ ។ អ្នកត្រូវប្រាប់ពួកគេថា អ្នកទាំងឡាយកុំពោលយ៉ាងនេះឡើយ ។ ម្នាលកស្សប អ្នកត្រូវប្រាប់ពួកគេថា ព្រះសមណគោតមបន្លឺសីហនាទ តែងបន្លឺក្នុងពួកបរិសទ្យជាអ្នកក្លៀវក្លាបន្លឺ ពួកទេវតានិងមនុស្សសួរប្រស្នានឹងលោក លោកក៏ដោះប្រស្នាដែលពួកទេវតា និងមនុស្សទាំងនោះសួរបាន លោកញុំាងចិត្តឲ្យត្រេកអរដោយការដោះប្រស្នាបាន ទាំងពួកជន ក៏សំគាល់ថា ពាក្យរបស់លោកជាពាក្យគួរស្តាប់ លុះស្តាប់ហើយក៏ជ្រះថ្លានឹងលោក លុះជ្រះ-ថ្លាហើយក៏ធ្វើអាការជ្រះថ្លា ប្រតិបត្តិតាមសេចក្តីជ្រះថ្លានោះ ប្រតិបត្តិឲ្យពេញព្រះទ័យលោកបាន ។ ម្នាលកស្សប សម័យមួយ តថាគតនៅលើភ្នំគិជ្ឈកូដ ជិតនគររាជគ្រឹះ ។ មានបរិព្វាជកម្នាក់ឈ្មោះនិគ្រោធជាសព្រហ្មចារី នៃអ្នកក្នុងនគររាជគ្រឹះទាំងនោះ មកសួរប្រស្នានឹងតថាគតក្នុងការខ្ពើមកិលេស យ៉ាងក្រៃលែង តថាគតក៏បានដោះប្រស្នាដែលនិគ្រោធបរិព្វាជកនោះសួរ ក្នុងការខ្ពើមកិលេសយ៉ាងក្រៃលែង លុះតថា-គតដោះប្រស្នារួចហើយ បរិព្វាជកនោះក៏មានចិត្តត្រេកអរពន់ប្រមាណ ។

[៧៥] កោ ហិ ភន្តេ ភគវតោ ធម្មំ សុត្វា ន អត្តមនោ អស្ស បរំ វិយ មត្តាយ អហំបិ ភន្តេ ភគវតោ ធម្មំ សុត្វា អត្តមនោ បរំ វិយ មត្តាយ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។

[៧៦] យោ ខោ កស្សប អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ

[៧៥] បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ ដែលបានស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ មិនមានចិត្តត្រេកអរពន់ប្រមាណ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គស្តាប់ធម៌ របស់ព្រះមានព្រះភាគហើយ មានចិត្តត្រេកអរពន់ប្រមាណណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលគេផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែកភ្លឺ នឹងឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។

[៧៦] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយមកហើយ តែចង់ចូលមកក្នុងធម្មវិន័យនេះ ចង់បព្វជ្ជានិងឧបសម្បទា អន្យតិរ្ថិយនោះ ត្រូវនៅបរិវាសអស់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបភិក្ខុទាំងឡាយមានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា

មហាសីហនាទសុត្តេ តិត្ថិយបរិវាសោ អចេលកស្សបស្ស បព្វជ្ជូបសម្បទា

ភិក្ខុភាវាយ អបិច មេត្ថ បុគ្គលវេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវា-យាតិ ។ អលត្ថ ខោ អចេលោ កស្សបោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា កស្សបោ ឯកោ វូបកដ្ឋោ អប្ប-មត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោ-សានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា

ដើម្បីភាវៈជាភិក្ខុ ឯតថាគតដឹងនូវសេចក្ដីផ្សេងគ្នា នៃបុគ្គលក្នុងកិច្ចដែលនៅបរិវាសនេះ[១] ។ អចេលកស្សបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលធ្លាប់ជាអន្យតិរ្ថិយមកហើយ ចង់ចូលមកក្នុងធម្មវិន័យនេះ ចង់បព្វជ្ជានិងឧបសម្បទា ត្រូវនៅបរិវាសអស់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបភិក្ខុទាំងឡាយមានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភាវៈជាភិក្ខុ ដូច្នេះខ្ញុំព្រះអង្គនឹងនៅបរិវាសរហូត ៤ ឆ្នាំបាន លុះកន្លង ៤ ឆ្នាំហើយ ភិក្ខុទាំងឡាយគង់មានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទាដើម្បីភាវៈជាភិក្ខុ ។ អចេលកស្សប ក៏បានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ លុះព្រះកស្សបមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ឥតមានសេចក្ដីប្រមាទ ខំព្យាយាមដុតនូវកិលេស ប្រថុយលះបង់នូវអត្តភាព ពួកកុលបុត្ត ដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ដោយបញ្ញារបស់ខ្លួន ដោយខ្លួនឯង ក្នុងអត្តភាពនេះ

---

១ អដ្ឋកថា ថា ទ្រង់ជ្រាបថា បុគ្គលនេះគួរនៅបរិវាស បុគ្គលនេះមិនគួរនៅបរិវាស ។

១០៨



ឧបសម្បជ្ជ វិហរតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា កស្សបោ អរហតំ អហោសីតិ ។

មហាសីហនាទសុត្តំ អដ្ឋមំ និដ្ឋិតំ ។

សម្រាន្តនៅ ដោយឥរិយាបថទាំង ៤ មិនយូរប៉ុន្មាន ក៏បានដឹងច្បាស់ថា ជាតិ (កំណើត) របស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញ ក៏បានអប់រំចប់ហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញ ក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីនេះតទៅទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្ត ទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តអង្គមួយដែរ ។

ចប់ មហាសីហនាទសូត្រទី ៨ ។

# បោដ្ឋបាទសុត្តំ នវមំ

[៧៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តេន ខោ បន សមយេន បោដ្ឋបាទោ បរិព្វាជកោ សមយប្បវាទកេ តិណ្ឌុកាចិរេ ឯកសាលិកេ មល្លិ-ការាមេ[១] បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ តឹសមត្តេហិ បរិព្វាជកសតេហិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បាវិសិ ។ អថខោ ភគវតោ ឯតទហោសិ អតិប្បគោ ខោ តាវ សាវត្ថិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន សមយប្បវាទកោ តិណ្ឌុកាចិរោ ឯកសាលិកោ មល្លិការាមោ យេន បោដ្ឋបាទោ បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ

១ ឱ. ម. តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ ។

# បោដ្ឋបាទសូត្រ ទី ៩

[៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង មានបរិព្វាជកម្នាក់ ឈ្មោះបោដ្ឋបាទ នៅអាស្រ័យ ក្នុងមល្លិការាម[១] ដែលមានសាលាមួយ[២] មានជួរនៃដើមទន្លាប់ព័ទ្ធជុំវិញ ជាទី (សម្រាប់ពួកជនមានព្រាហ្មណ៍ជាដើម) ប្រជុំគ្នាជជែកអំពីលទ្ធិ (របស់ខ្លួន) ជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើនចំនួន ៣០០០ នាក់ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅ បិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា ការត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី នៅព្រឹកពេកណាស់ បើដូច្នោះគួរតែ តថាគតចូលទៅរកបោដ្ឋបាទបរិព្វាជកនៅ ក្នុងមល្លិការាម ដែលមានសាលាមួយ មានជួរនៃដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រជុំគ្នាជជែកអំពីលទ្ធិ ។ គ្រា

---

១. អដ្ឋកថា ថា សួនដែលបរិបូណ៌ដោយផ្កានិងផ្លែឈើរបស់នាងមល្លិកា ជាព្រះរាជទេពី របស់ព្រះបាទបសេនទិកោសល ។ ២ អារាមនោះដំបូងឡើយ មានសាលាតែមួយមែន តែដល់កាលជាខាងក្រោយមក មានគេកសាងសាលាច្រើនឡើង ព្រោះអាស្រ័យបរិព្វាជកម្នាក់ មានបុណ្យច្រើន ។

ភគវា យេន សមយប្បវាទកោ តិណ្ឌុកាចិរោ ឯកសាលិកោ មល្លិកាយ អារាមោ តេនុបសង្កមិ ។

[៧៨] តេន ខោ បន សមយេន បោដ្ឋបាទោ បរិព្វាជកោ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ បោដ្ឋបាទោ បរិព្វាជកោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ

នោះឯង ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរ ចូលទៅឯមល្លិការាម ដែលមានសាលាមួយ មានជួរនៃដើមទន្ទាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រជុំគ្នាជជែកអំពីលទ្ធិ ។

[៧៨] សម័យនោះឯង បោដ្ឋបាទបរិព្វាជក អង្គុយជាមួយនឹងបរិព្វា-ជកបរិសទ្យច្រើននាក់ កំពុងតែនិយាយពាក្យតិរច្ឆានកថា ច្រើនយ៉ាង ដោយសំឡេងហ៊ោ សំឡេងឮខ្លាំងកងរំពង គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីមហាមាត្យ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីគ្រឿងស៊ី និយាយអំពីគ្រឿងផឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្រី និយាយអំពីប្រុស និយាយអំពីយោធាដែលក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីបុព្វប្រេត គឺញាតិដែលចែកឋានទៅហើយ និយាយអំពីពាក្យឥតប្រយោជន៍ មានប្រការផ្សេង ៗ និយាយអំពីលោក (មានរឿងក្អែកសនិងកុកក្រហមជាដើម) និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យដូច្នេះ ៗ ។ បោដ្ឋបាទបរិព្វាជក បានឃើញព្រះមានព្រះភាគកំពុងស្តេចមកអំពីចម្ងាយ

និស្វាន សកាបរិសំ[១] សណ្ឋាបេសិ អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ សមណោ គោតមោ អាគច្ឆតិ អប្បសទ្ទកាមោ ខោ បនាយស្មា សោ អប្បសទ្ទស្ស វណ្ណវាទី អប្បេវនាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ ឯវំ វុត្តេ តេ បរិព្វាជកា តុណ្ហី អហេសុំ ។

[៧៩] អថខោ ភគវា យេន ចោដ្ឋចាទោ បរិព្វាជកោ តេនុបសង្កមិ ។ អថខោ ចោដ្ឋចាទោ បរិព្វាជកោ ភគវន្តំ ឯតទវោច ឯតុ ខោ ភន្តេ ភគវា ស្វាគតំ[២] ភន្តេ ភគវតោ ចិរស្សំ ខោ ភន្តេ ភគវា ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភន្តេ ភគវា ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ ចោដ្ឋចាទោបិ ខោ បរិព្វាជកោ អញ្ញតរំ នីចំ អាសនំ គហេត្វា

---

១ ឱ. ទិស្វា សកំ បរិសំ ។ ២ ឱ. សាគតំ ។

លឹម ៗ លុះឃើញហើយក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា ម្នាលគ្នាយើង ចូរនិយាយសំឡេងតិច ៗ ម្នាលគ្នាយើង កុំនិយាយសំឡេងឮខ្លាំងឡើយ (ដ្បិត) ព្រះសមណគោតមអង្គនេះស្ដេចមក ឯព្រះសមណគោតមមានអាយុនោះឯង លោកពេញព្រះទ័យនឹងសំឡេងតិច តែងពោលសរសើរសំឡេងតិច ធ្វើដូចម្ដេចឲ្យលោកជ្រាបថា បរិសទ្យនិយាយ សំឡេងតិច ហើយសំគាល់ថាគួរនឹងចូលមកបាន ។ កាលបោដ្ឋបាទបរិព្វាជកនិយាយឃាត់យ៉ាងនេះហើយ បរិព្វាជកទាំងនោះក៏នាំគ្នាស្ងៀម ។

[៧៩] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលសំដៅទៅរកកន្លែង ដែលបោដ្ឋបាទបរិព្វាជកនៅ ។ បោដ្ឋបាទបរិព្វាជកក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ស្ដេចមក បពិត្រព្រះអង្គដ៏ចម្រើន ដំណើរដែលព្រះមានព្រះភាគស្ដេចមកល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន យូរណាស់ហើយតើ ព្រះមានព្រះភាគ បានធ្វើបរិយាយនេះ ដើម្បីមកក្នុងទីនេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ និមន្តគង់ អាសនៈដែលរៀបចំស្រាប់នេះ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលគេរៀបចំស្រាប់ហើយ ។ ឯបោដ្ឋបាទបរិព្វាជក ក៏កាន់យកអាសនៈទាបមួយ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ បោដ្ឋបាទំ បរិព្វាជកំ ភគវា ឯតទវោច កាយ នុត្ថ[១] បោដ្ឋ- បាទ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។

[៨០] ឯវំ វុត្តេ បោដ្ឋបាទោ បរិព្វាជកោ ភគវន្តំ ឯតទវោច តិដ្ឋតេសា ភន្តេ កថា យាយ មយំ ឯ- តរហិ កថាយ សន្និសិន្នា នេសា ភន្តេ កថា ភគ- វតោ ទុល្លភា ភវិស្សតិ បច្ឆាបិ សវនាយ បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ នានាតិត្ថិយានំ សមណ- ព្រាហ្មណានំ កោតុហលសាលាយ[២] សន្និសិន្នានំ សន្និបតិតានំ អភិសញ្ញានិរោធេ កថា[៣] ឧទបាទិ កថំ នុ ខោ ភោ អភិសញ្ញានិរោធោ ហោតីតិ ត- ត្រេកច្ចេ ឯវមាហំសុ អហេតូ អប្បច្ចយា បុរិសស្ស សញ្ញា ឧប្បជ្ជតិបិ និរុជ្ឈតិបិ យស្មឹ សមយេ ឧប្ប-

---

១ ឱ. នុត្ត ។ ២ ឱ. កុតូហលសាលាយ ។ ៣ ម. អភិសញ្ញានិរោធកថា ។

ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះពោដ្ឋបាទបរិព្វាជកអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលពោដ្ឋបាទ ក្នុងកាលអម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំគ្នា និយាយពាក្យដូចម្តេច ចុះពាក្យជាចន្លោះដូចម្តេច[១] ដែលអ្នកទាំងឡាយនិយាយមិនទាន់ស្រេច ។

[៨០] កាលបើ ព្រះមានព្រះភាគទ្រង់ត្រាស់សួរ យ៉ាងនេះហើយ ពោដ្ឋបាទបរិព្វាជក ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលយើងខ្ញុំទាំងឡាយ ប្រជុំគ្នានិយាយអម្បាញ់មិញនេះ ទុកស្ទះសិនចុះ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនុ៎ះ ព្រះមានព្រះភាគមិនមែនបានដោយកម្រទេ នឹងបានទ្រង់ព្រះសណ្តាប់ ក្នុងកាលខាងក្រោយមិនខាន បពិត្រព្រះអង្គដ៏ចម្រើន កាលពីថ្ងៃមុន ៗ មក មានពួកសមណព្រាហ្មណ៍ដែលមានលទ្ធិផ្សេង ៗ អង្គុយប្រជុំគ្នាក្នុងកោតុហលសាលា[២] ក៏បានផ្តួចផ្តើមនិយាយគ្នា ក្នុងអភិសញ្ញានិរោធថា អ្នកដ៏ចម្រើន អភិសញ្ញានិរោធ តើដូចម្តេច បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ខ្លះ ពោលយ៉ាងនេះថា សញ្ញារបស់បុរសកើតក្តី រលត់ក្តី មិនមានហេតុ មិនមានបច្ច័យឡើយ សញ្ញាកើតឡើងក្នុងសម័យណា

---

១ អដ្ឋកថា ថា ពាក្យក្នុងរវាងនៃកាលពួកបរិព្វាជក ប្រជុំនិយាយគ្នាតាំងអំពីដំបូងមកទល់នឹងកាលដែលព្រះមានព្រះភាគស្តេចមកដល់ ។ ២ សាលាដែលសមណព្រាហ្មណ៍មានលទ្ធិខុសគ្នា ប្រជុំនិយាយពាក្យផ្សេង ៗ ទ្រហឹងអឺងកង ។

ជ្ជតិ សញ្ញី តស្មឹ សមយេ ហោតិ យស្មឹ សមយេ និរុជ្ឈតិ អសញ្ញី តស្មឹ សមយេ ហោតីតិ ឥត្ថេកេ អភិសញ្ញានិរោធំ បញ្ញបេន្តិ តមញ្ញោ ឯវមាហ ន ខោ បន មេតំ[១] កោ ឯវំ ភវិស្សតិ សញ្ញា ហិ ភោ បុរិសស្ស អត្តា សោ[២] ច ខោ ឧបេតិបិ អបេតិបិ យស្មឹ សមយេ ឧបេតិ សញ្ញី តស្មឹ សមយេ ហោតិ យស្មឹ សមយេ អបេតិ អសញ្ញី តស្មឹ សមយេ ហោ-តីតិ ឥត្ថេកេ អភិសញ្ញានិរោធំ បញ្ញបេន្តិ តមញ្ញោ ឯវមាហ ន ខោ បន មេតំ ភោ ឯវំ ភវិស្សតិ សន្តិ ហិ ភោ សមណព្រាហ្មណា មហិទ្ធិកា មហានុភាវា តេ ឥមស្ស បុរិសស្ស សញ្ញំ ឧបក្កឌ្ឍន្តិបិ អបក្ក-ឌ្ឍន្តិបិ យស្មឹ សមយេ ឧបក្កឌ្ឍន្តិ សញ្ញី តស្មឹ ស-មយេ ហោតិ យស្មឹ សមយេ អបក្កឌ្ឍន្តិ អសញ្ញី តស្មឹ សមយេ ហោតីតិ ឥត្ថេកេ អភិសញ្ញានិរោធំ បញ្ញបេន្តិ តមញ្ញោ ឯវមាហ ន ខោ បន មេតំ ភោ

១ ឱ. ន ខោ នាមេតំ ។ ២ ឱ. ម. សា ។

បោដ្ឋបាទសូត្រ ការពោលអំពីអភិសញ្ញានិរោធ

សត្វក៏មានសញ្ញាក្នុងសម័យនោះ សញ្ញារលត់ទៅក្នុងសម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ បានបញ្ញត្តអភិសញ្ញានិរោធ ដោយប្រការយ៉ាងនេះ តែសមណព្រាហ្មណ៍ដទៃក្រៅអំពីនោះពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ចម្រើន ដំណើរនុ៎ះមិនមែនជាយ៉ាងនេះទេ នៃអ្នកទាំងឡាយដ៏ចម្រើន ព្រោះថាសញ្ញាជាខ្លួនរបស់បុរស ឯខ្លួននោះមាននៅខ្លះ ប្រាសទៅខ្លះ ខ្លួនមាននៅក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ខ្លួនប្រាសទៅក្នុងសម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ បញ្ញត្តអភិសញ្ញានិរោធ ដោយប្រការយ៉ាងនេះ សមណព្រាហ្មណ៍ដទៃក្រៅអំពីនោះពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ចម្រើន ដំណើរនុ៎ះមិនមែនយ៉ាងនេះទេ អ្នកទាំងឡាយដ៏ចម្រើន ព្រោះថា សមណព្រាហ្មណ៍មានឫទ្ធិច្រើន មានអានុភាពច្រើនក៏មាន សមណព្រាហ្មណ៍ទាំងនោះឯងទាញចូលខ្លះ ដកចេញខ្លះ នូវសញ្ញារបស់បុរសនេះ ទាញសញ្ញាចូល ក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ដកសញ្ញាចេញក្នុងសម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ បញ្ញត្តអភិសញ្ញានិរោធ ដោយប្រការយ៉ាងនេះ សមណ-ព្រាហ្មណ៍ដទៃក្រៅអំពីនោះ ពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ចម្រើន

ឯវំ ភវិស្សតិ សន្តិ ហិ ភោ ទេវា មហិទ្ធិកា មហានុ-ភាវា តេ ឥមស្ស បុរិសស្ស សញ្ញំ ឧបក្កឌ្ឍន្តិបិ អបក្កឌ្ឍន្តិបិ យស្មឹ សមយេ ឧបក្កឌ្ឍន្តិ សញ្ញី តស្មឹ សមយេ ហោតិ យស្មឹ សមយេ អបក្កឌ្ឍន្តិ អសញ្ញី តស្មឹ សមយេ ហោតីតិ ឥត្ថេកេ អភិសញ្ញានិរោធំ បញ្ញបេន្តិ តស្ស មយ្ហំ ភន្តេ ភគវន្តំយេវ អារព្ភ សតិ ឧទបាទិ អហោ នូន ភគវា អហោ នូន សុ-គតោ យោ ឥមេសំ ធម្មានំ សុកុសលោតិ ភគវា ភន្តេ កុសលោ[១] ភគវា បកតញ្ញូ អភិសញ្ញានិរោ-ធស្ស កថន្នុ ខោ ភន្តេ អភិសញ្ញានិរោធោ ហោតីតិ ។

[៨១] តត្រ ពោដ្ឋបាទ យេ តេ សមណ-ព្រាហ្មណា ឯវមាហំសុ អហេតូ អប្បច្ចយា បុរិសស្ស សញ្ញា ឧប្បជ្ជតិបិ និរុជ្ឈតិបីតិ អាទិតោ វ តេសំ

១ ឱ. ភគវា ភន្តេ កុសលោតិ ន ទិស្សន្តិ ។

ដំណើរនុ៎ះមិនមែនយ៉ាងនេះទេ អ្នកទាំងឡាយដ៏ចម្រើន ព្រោះថា ពួកទេវតាមានឫទ្ធិច្រើន មានអានុភាពច្រើនក៏មាន ទេវតាទាំងនោះទាញចូលខ្លះ ដកចេញខ្លះ នូវសញ្ញារបស់បុរសនេះ ទាញសញ្ញាចូលក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ដកសញ្ញាចេញក្នុងសម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ បញ្ញត្តអភិសញ្ញានិរោធ ដោយប្រការយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានចាប់ភ្ញាក់នឹកប្រារព្ធ ចំពោះព្រះមានព្រះភាគ តែមួយយ៉ាងថា ព្រះមានព្រះភាគណាទ្រង់ឈ្លាសវៃ ក្នុងធម៌ទាំងនេះ ព្រះមានព្រះភាគអង្គនោះ គប្បីសំដែងបាន ដោយអស្ចារ្យក្រៃលែង ព្រះសុគតណាទ្រង់ឈ្លាសវៃ ក្នុងធម៌ទាំងនេះ ព្រះសុគតអង្គនោះគប្បីសំដែងបាន ដោយអស្ចារ្យក្រៃលែង បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ព្រះអង្គឈ្លាសវៃ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ នូវអភិសញ្ញានិរោធ បពិត្រព្រះអង្គដ៏ចម្រើន អភិសញ្ញានិរោធនោះ តើដូចម្តេច ។

[៨១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបោដ្ឋបាទ បណ្តាពួកសមណព្រាហ្មណ៍ ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ដែលពោលយ៉ាងនេះថា សញ្ញារបស់បុរសកើតក្តី រលត់ក្តី មិនមានហេតុ មិនមានបច្ច័យដូច្នេះ សេចក្តីយល់ឃើញ របស់សមណព្រាហ្មណ៍ទាំងនោះ

អបរទ្ធំ[១] ។ តំ កិស្ស ហេតុ ។ សហេតូ ហិ ចោដ្ឋបាទ សប្បច្ចយា បុរិសស្ស សញ្ញា ឧប្បជ្ជតិបិ និរុជ្ឈតិបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិបិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិបិ កា ច សិក្ខាតិ ភគវា អវោច ។ ឥធ ចោដ្ឋបាទ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ វិត្ថារេតព្វំ) ។ ឯវំ ខោ ចោដ្ឋបាទ ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ តស្សិមេ បញ្ចនីវរណេ បហីនេ អត្តនិ សមនុបស្សតោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ[២] សុខិនោ ចិត្តំ សមាធិយតិ ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា កាមសញ្ញា សា និរុជ្ឈតិ

---

១ ឱ. ម. អាទិសោ វ តេសំ អបរទ្ធំ ។ ២ ឱ. ម. វេទេតិ ។

ចាត់ជាខុសតាំងអំពីដើមទាំងស្រុង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាល បោដ្ឋបាទ ព្រោះថាសញ្ញារបស់បុរសប្រកបដោយហេតុ ប្រកបដោយ បច្ច័យទាំងកើតទាំងរលត់ សញ្ញាខ្លះកើតព្រោះការហាត់ក៏មាន សញ្ញាខ្លះ រលត់ទៅ ព្រោះការហាត់ក៏មាន ក៏ការហាត់សញ្ញានោះ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលបោដ្ឋបាទ ព្រះ តថាគតជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកនេះ ។ បេ ។ (បណ្ឌិត គប្បីសំដែងឲ្យពិស្តារ ដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ ម្នាលបោដ្ឋបាទ ភិក្ខុអ្នកបរិបូណ៌ដោយសីល យ៉ាងនេះឯង ។ បេ ។ កាលភិក្ខុនោះពិចារណា ឃើញនូវនីវរណៈទាំង ៥ នេះ ក្នុងខ្លួនដែលលះបង់បានហើយ បាមោជ្ជៈគឺ សេចក្តីរីករាយក៏កើតឡើង កាលបើភិក្ខុមានចិត្តរីករាយហើយ បីតិក៏កើត ឡើង កាលបើ ភិក្ខុមានចិត្តប្រកប ដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ ភិក្ខុដែលមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសុខ ចិត្តរបស់ភិក្ខុដែល មានសុខក៏តាំងនៅមាំ ។ ភិក្ខុនោះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាក អកុសលធម៌ទាំងឡាយ ហើយក៏បានដល់នូវបឋមជ្ឈាន ដែលប្រកប ដោយវិតក្កៈវិចារៈ មានបីតិនិងសុខកើតអំពីសេចក្តីស្ងាត់នោះ កាមសញ្ញា (តម្រេកប្រកបដោយកាមគុណទាំង ៥) ខាងដើមរបស់ភិក្ខុនោះក៏រលត់ទៅ

វិវេកជប្បីតិសុខសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ វិវេកជប្បីតិសុខសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨២] បុន ចបរំ ពោដ្ឋបាទ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា វិវេកជប្បីតិសុខ-សុខុមសច្ចសញ្ញា សា និរុជ្ឈតិ សមាធិជប្បីតិសុខ-សុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ សមាធិជប្បី-តិសុខសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨៣] បុន ចបរំ ពោដ្ឋបាទ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ

សច្ចសញ្ញាដ៏ល្អិត ពោលគឺបីតិនិងសុខដែលកើត អំពីសេចក្តីស្ងាត់ ក៏មានឡើងក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិតពោលគឺបីតិនិងសុខដែលកើត អំពីវិវេកក្នុងសម័យនោះឯង សញ្ញាខ្លះកើត ព្រោះការហាត់ សញ្ញាខ្លះរលត់ទៅ ព្រោះការហាត់ (ដូចពណ៌នាមកនេះ) នេះឯងដែលហៅថា ការហាត់សញ្ញា ។

[៨២] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះរម្ងាប់វិតក្កៈវិចារៈចេញបាន ភិក្ខុក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្តាននៃខ្លួន មានសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈគ្មានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈានសច្ចសញ្ញាដ៏ល្អិតពោលគឺបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់ជាខាងដើម របស់ភិក្ខុនោះ ក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិត ពោលគឺបីតិនិងសុខដែលកើតអំពីសមាធិ ក៏មានក្នុងសម័យនោះឡើង ភិក្ខុនោះឈ្មោះថាមានសច្ចសញ្ញាដ៏ល្អិត ពោលគឺបីតិនិងសុខ ដែលកើតអំពីសមាធិ ក្នុងសម័យនោះឯង សញ្ញាខ្លះកើត ព្រោះការហាត់ សញ្ញាខ្លះរលត់ទៅ ព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់ ។

[៨៣] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះនឿយណាយចាកបីតិប្រកបដោយឧបេក្ខា ភិក្ខុមានសតិនិងសម្បជញ្ញៈ រមែង

សុខញ្ច កាយេន បដិសំវេទេតិ យំ តំ អរិយា អា-
ចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ
ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា សមា-
ធិជប្បីតិសុខសុខុមសច្ចសញ្ញា សា និរុជ្ឈតិ ឧបេក្ខា-
សុខសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ ឧបេក្ខា-
សុខសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ
សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា
និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨៤] បុន ចបរំ ពោដ្ឋបាទ ភិក្ខុ សុខស្ស ច
បហានា ទុក្ខស្ស ច បហានា បុព្វេ វ សោមនស្ស-
ទោមនស្សានំ អត្ថង្គមា[១] អទុក្ខមសុខំ ឧបេក្ខាសតិ-
បារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្ស យា
បុរិមា ឧបេក្ខាសុខសុខុមសច្ចសញ្ញា សា និរុជ្ឈតិ អ-
ទុក្ខមសុខសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ
អទុក្ខមសុខសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ

១ អដ្ឋង្គមាតិបិ ឯវំ សព្វត្ថ ។

ទទួលនូវសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយតែងសរសើរ បុគ្គលអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី មានប្រក្រតីនៅជាសុខ ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ សច្ចសញ្ញាដ៏ល្អិត ពោលគឺបីតិនិងសុខដ៏កើតអំពីសមាធិ ជាខាងដើមរបស់ភិក្ខុនោះ ក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិតពោលគឺឧបេក្ខានិងសុខ ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិតពោលគឺឧបេក្ខានិងសុខ ក្នុងសម័យនោះឯង សញ្ញាខ្លះកើតព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់សញ្ញា ។

[៨៤] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះលះបង់នូវសុខនិងទុក្ខហើយ ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្ស ក្នុងកាលមុន ភិក្ខុក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ សច្ចសញ្ញាដ៏ល្អិតពោលគឺឧបេក្ខានិងសុខ ជាខាងដើមរបស់ភិក្ខុនោះ ក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិតដែលឥតទុក្ខឥតសុខ ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិតឥតទុក្ខឥតសុខក្នុង

ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨៥] បុន ចបរំ ពោដ្ឋបាទ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា រូបសញ្ញា សា និរុជ្ឈតិ អាកាសានញ្ចាយតនសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ អាកាសានញ្ចាយតនសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

សម័យនោះ សញ្ញាខ្លះកើតឡើងព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់សញ្ញា ។

[៨៥] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្លង នូវរូបសញ្ញា[១] ព្រោះអស់ទៅនៃបដិឃសញ្ញា[២] ព្រោះលែងធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា[៣] ដោយប្រការទាំងពួងហើយ ភិក្ខុក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ រូបសញ្ញាជាខាងដើម របស់ភិក្ខុនោះ ក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិត ពោលគឺអាកាសានញ្ចាយតនជ្ឈាន ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថាមានសច្ចសញ្ញាដ៏ល្អិត ពោលគឺអាកាសានញ្ចាយតនជ្ឈាន ក្នុងសម័យនោះឯង សញ្ញាខ្លះកើត ព្រោះការហាត់ សញ្ញាខ្លះរលត់ទៅ ព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់សញ្ញា ។

---

១ សេចក្តីសំគាល់ក្នុងរូបាវចរជ្ឈាននិងអារម្មណ៍របស់ឈាននោះ ។ ២ សេចក្តីសំគាល់ដែលកើតឡើងដោយវត្ថុមានចក្ខុជាដើម ប៉ះពាល់គ្នានឹងអារម្មណ៍មានរូបជាដើម ។ ៣ សញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងគ្នា ឬសញ្ញាដែលផ្សេងគ្នា (វិសុទ្ធិមគ្គ) ។

### បោដ្ឋបាទសុត្តេ វិញ្ញាណញ្ចាយតនជ្ឈានាទីនិ

[៨៦] បុន ចបរំ បោដ្ឋបាទ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា អាកាសានញ្ចាយតនសុខុមសច្ចសញ្ញា សា និរុជ្ឈតិ វិញ្ញាណញ្ចាយតនសុខុមសច្ចសញ្ញា តស្មឹ ស-មយេ ហោតិ វិញ្ញាណញ្ចាយតនសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨៧] បុន ចបរំ បោដ្ឋបាទ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ តស្ស យា បុរិមា វិញ្ញាណញ្ចាយតនសុខុមសច្ចសញ្ញា សា និរុជ្ឈតិ អា-កិញ្ចញ្ញាយតនសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ

[៨៦] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ភិក្ខុបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សច្ចសញ្ញាដ៏ល្អិតពោលគឺអាកាសានញ្ចាយតនជ្ឈានជាខាងដើម របស់ភិក្ខុនោះក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិតពោលគឺវិញ្ញាណញ្ចាយតនជ្ឈាន ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិតពោលគឺវិញ្ញាណញ្ចាយតនជ្ឈាន ក្នុងសម័យនោះឯង សញ្ញាខ្លះកើតព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់សញ្ញា ។

[៨៧] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ភិក្ខុក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សច្ចសញ្ញាដ៏ល្អិតពោលគឺវិញ្ញាណញ្ចាយតនជ្ឈានជាខាងដើម របស់ភិក្ខុនោះក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិតពោលគឺអាកិញ្ចញ្ញាយតនជ្ឈាន ក៏មានក្នុងសម័យនោះ ភិក្ខុនោះ

អាកិញ្ចញ្ញាយតនសុខុមសច្ចសញ្ញីយេវ តស្មឹ សមយេ ហោតិ ឯវំបិ សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ សិក្ខា ឯកា សញ្ញា និរុជ្ឈតិ អយំបិ សិក្ខាតិ ភគវា អវោច ។

[៨៨] យតោ ខោ[១] បោដ្ឋបាទ ភិក្ខុ ឥធ សកសញ្ញី ហោតិ សោ តតោ អមុត្រ តតោ អមុត្រ អនុបុព្វេន សញ្ញគ្គំ ផុសតិ តស្ស សញ្ញគ្គេ ឋិតស្ស ឯវំ ហោតិ ចេតយមានស្ស មេ បាបិយោ អចេតយមានស្ស មេ សេយ្យោ អហញ្ចេវ ខោ បន ចេតេយ្យំ អភិសង្ខរេយ្យំ ឥមា ច មេ សញ្ញា និរុជ្ឈេយ្យុំ អញ្ញា ច ឱឡារិកា សញ្ញា ឧប្បជ្ជេយ្យុំ យន្នូនាហំ ន ចេវ ចេតេយ្យំ ន ច អភិសង្ខរេយ្យន្តិ[២] ។ សោ ន ចេវ ចេតេតិ ន ច អភិសង្ខរោតិ តស្ស

---

១ ឱ. ម. យតោ ខោ ។ ២ ឱ. ម. ន ចេតេយ្យំ ន អភិសង្ខរេយ្យន្តិ ។

ឈ្មោះថាមានសច្ចសញ្ញាដ៏ល្អិតពោលគឺអាកិញ្ចញ្ញាយតនជ្ឈាន ក្នុងសម័យនោះឯង សញ្ញាខ្លះ កើតព្រោះការហាត់ សញ្ញាខ្លះ រលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់សញ្ញា ។

[៨៨] ម្នាលបោដ្ឋបាទ ភិក្ខុណាក្នុងសាសនានេះមានសេចក្ដីសំគាល់ (ក្នុងបឋមជ្ឈាន) របស់ខ្លួន ភិក្ខុនោះចេញចាកបឋមជ្ឈាននោះហើយ ចូលទុតិយជ្ឈានឯណោះ ចេញចាកទុតិយជ្ឈាននោះហើយ ចូលតតិយជ្ឈានឯណោះ (លុះចូលឈាន) តាមលំដាប់ហើយ ក៏បាននូវសញ្ញាជាកំពូលគឺអាកិញ្ចញ្ញាយតនជ្ឈាន កាលបើភិក្ខុនោះ ឋិតនៅក្នុងសញ្ញាជាកំពូលគឺអាកិញ្ចញ្ញាយតនជ្ឈានហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញ ចូលឈានមិនប្រសើរឡើយ បើអាត្មាអញមិនចូលឈាន ទើបប្រសើរ ព្រោះថាប្រសិនបើអាត្មាអញចូលឈាន រវល់តែនឹងចូលឈានសញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ទាំងនេះរបស់អាត្មាអញមុខជារលត់ទៅសញ្ញាដ៏គ្រោតគ្រាតឯទៀតគឺភវង្គសញ្ញាមុខជាកើតឡើង បើដូច្នោះអាត្មាអញមិនគួរនឹងចូលឈាន មិនគួររវល់តែនឹងចូលឈានឡើយ ។ ភិក្ខុនោះឯង ក៏លែងចូលឈាន លែងរវល់នឹងចូលឈាន កាលបើភិក្ខុនោះលែង

១២១



អចេតយតោ អនភិសង្ខរោតោ តា ចេវ សញ្ញា និរុជ្ឈន្តិ អញ្ញា ច ឱឡារិកា សញ្ញា ន ឧប្បជ្ជន្តិ សោ និរោធំ ផុសតិ ។ ឯវំ ខោ បោដ្ឋបាទ អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ ហោតិ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ អបិ នុ ខោ តេ ឥតោ បុព្វេ ឯវរូបា អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ សុតបុព្វាតិ ។ នោ ហេតំ ភន្តេ ឯវំ ខោ អហំ ភន្តេ ភគវតោ ធម្មំ ទេសិតំ អាជានាមីតិ[១] ។ យតោ ខោ បោដ្ឋបាទ ភិក្ខុ[២] សកសញ្ញី ហោតិ សោ តតោ អមុត្រ តតោ អមុត្រ អនុបុព្វេន សញ្ញគ្គំ ផុសតិ តស្ស សញ្ញគ្គេ ឋិតស្ស ឯវំ ហោតិ ចេតយមានស្ស មេ បាបិយោ

១ ឱ. ម. ភគវតោ ភាសិតំ អាជានាមិ ។ ២ ឱ. ម. ឯត្ថន្តរេ ឥធាតិ ទិស្សតិ ។

ចូលឈាន លែងវល់នឹងចូលឈាន សញ្ញាទាំងនោះក៏រលត់ទៅ សញ្ញាដ៏គ្រោតគ្រាតឯទៀតគឺកវឡ្គសញ្ញា ក៏មិនកើតឡើង ភិក្ខុនោះ បាននូវនិរោធ ។ ម្នាលបោដ្ឋបាទ យ៉ាងនេះហៅថាអនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ[១] ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ មានសភាពយ៉ាងនេះ អ្នកធ្លាប់បានឮមកក្នុងកាលមុនអំពីកាលនេះដែរឬ ។ បោដ្ឋបាទបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះខ្ញុំព្រះអង្គមិនធ្លាប់បានឮទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទើបតែនឹងដឹងនូវធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងដោយអាការយ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបោដ្ឋបាទ ភិក្ខុណាមានសេចក្តីសំគាល់ (ក្នុងបឋមជ្ឈាន) របស់ខ្លួន ភិក្ខុនោះចេញចាកបឋមជ្ឈាននោះហើយ ចូលទុតិយជ្ឈានឯណោះ ចេញចាកទុតិយជ្ឈាននោះហើយ ចូលតតិយជ្ឈានឯណោះ (លុះចូលឈាន) តាមលំដាប់ ក៏បាននូវសញ្ញាជាកំពូលគឺអាកិញ្ចញ្ញាយតនជ្ឈាន កាលបើភិក្ខុនោះឋិតនៅក្នុងសញ្ញា ជាកំពូលគឺអាកិញ្ចញ្ញាយតនជ្ឈាន ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើ អាត្មាអញ ចូលឈាន មិនប្រសើរឡើយ

១ សមាបត្តិរបស់ភិក្ខុដែលមានសេចក្តីដឹងខ្លួនដោយល្អ ប្រកបដោសេចក្តីរលត់នៃសញ្ញាដោយលំដាប់ ។

អចេតយមានស្ស មេ សេយ្យោ អហាញ្ចេវ ខោ បន ចេតេយ្យំ អភិសង្ខរេយ្យំ ឥមា ច មេ សញ្ញា និរុជ្ឈេយ្យុំ អញ្ញា ច ឱឡារិកា សញ្ញា ឧប្បជ្ជេយ្យុំ យន្នូនាហំ ន ចេវ ចេតេយ្យំ ន ច អភិសង្ខរេយ្យន្តិ ។ សោ ន ចេវ ចេតេតិ ន ច អភិសង្ខរោតិ តស្ស អចេតយតោ អនភិសង្ខរោតោ តា ចេវ សញ្ញា និរុជ្ឈន្តិ អញ្ញា ច ឱឡារិកា សញ្ញា ន ឧប្បជ្ជន្តិ សោ និរោធំ ផុសតិ ។ ឯវំ ខោ បោដ្ឋបាទ អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ ហោតីតិ ។

[៨៩] ឯវំ[១] បោដ្ឋបាទោតិ ។ ឯកញ្ញេវ[២] នុ ខោ ភន្តេ ភគវា សញ្ញគ្គំ បញ្ញបេតិ ឧទាហុ បុថូបិ សញ្ញគ្គេ បញ្ញបេតីតិ ។ ឯកំបិ ខោ បោដ្ឋបាទ អហំ[៣] សញ្ញគ្គំ បញ្ញបេមិ បុថូបិ សញ្ញគ្គេ បញ្ញបេមីតិ ។ យថាកថំ បន ភន្តេ ភគវា

១ ឱ. ម. ឯវំ ខោ ។ ២ ឱ. ឯកំយេវ ។ ម. ឯកញ្ញេវ ។ ៣ ឱ. ម. អហំ បោដ្ឋបាទ ។

បើអាត្មាអញ មិនចូលឈានទើបប្រសើរ ព្រោះថាប្រសិនបើអាត្មាអញ ចូលឈាន រវល់តែនឹងចូលឈាន សញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈានទាំងនេះ របស់អាត្មាអញ មុខជារលត់ទៅ សញ្ញាដ៏គ្រោតគ្រាតដទៃ គឺភវង្គសញ្ញាមុខជាកើតឡើង បើដូច្នោះអាត្មាអញ មិនគួរនឹងចូលឈាន មិនគួររវល់តែនឹងឈាន ។ ភិក្ខុនោះឯង ក៏លែងចូលឈាន លែងរវល់នឹងចូលឈាន កាលបើភិក្ខុនោះ លែងចូលឈាន លែងរវល់នឹងឈាន សញ្ញាទាំងនោះក៏រលត់ទៅ សញ្ញាដ៏គ្រោតគ្រាតឯទៀត គឺភវង្គសញ្ញាក៏មិនកើតឡើង ភិក្ខុនោះបាននូវនិរោធ ។ ម្នាលបោដ្ឋបាទ យ៉ាងនេះហៅថា អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ ។

[៨៩] ម្នាលបោដ្ឋបាទ អភិសញ្ញានិរោធយ៉ាងនេះឯង ។ បោដ្ឋបាទបរិព្វាជក ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បញ្ញត្តនូវសញ្ញា ជាកំពូលតែមួយយ៉ាងប៉ុណ្ណោះទេ ឬទ្រង់បញ្ញត្តនូវសញ្ញាជាកំពូលច្រើនយ៉ាង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបោដ្ឋបាទ តថាគត បញ្ញត្តនូវសញ្ញាជាកំពូលតែមួយប៉ុណ្ណោះក៏មាន បញ្ញត្តនូវសញ្ញាជាកំពូលច្រើនយ៉ាងក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ

ឯកំបិ សញ្ញគ្គំ បញ្ញបេតិ ពុថូបិ សញ្ញគ្គេ បញ្ញ-បេតីតិ ។ យថា យថា ខោ ចោដ្ឋបាទ និរោធំ ផុសតិ តថា តថា អហំ សញ្ញគ្គំ បញ្ញបេមិ ឯវំ ខោ អហំ ចោដ្ឋបាទ ឯកំបិ សញ្ញគ្គំ បញ្ញបេមិ ពុថូបិ សញ្ញគ្គេ បញ្ញបេតីតិ ។

[៩០] សញ្ញា នុ ខោ ភន្តេ បឋមំ ឧប្បជ្ជតិ បច្ឆា ញាណំ ឧទាហុ ញាណំ បឋមំ(១) ឧប្បជ្ជតិ បច្ឆា សញ្ញា ឧទាហុ សញ្ញា ច ញាណំ ច អបុព្វំ អចរិមំ ឧប្បជ្ជន្តីតិ ។ សញ្ញា ខោ ចោដ្ឋបាទ បឋមំ ឧប្បជ្ជតិ បច្ឆា ញាណំ សញ្ញុប្បាទា ច បន ញាណុប្បាទោ ហោតិ សោ ឯវំ បជានាតិ ឥទប្បច្ចយា កិរ មេ ញាណំ ឧទបាទីតិ ។ ឥមិនា ច ខោ ឯតំ(២) ចោដ្ឋ-បាទ បរិយាយេន វេទិតព្វំ យថា សញ្ញា បឋមំ ឧប្បជ្ជតិ បច្ឆា ញាណំ សញ្ញុប្បាទា ច បន ញា-ណុប្បាទោ ហោតីតិ ។

---

១ ឱ. បឋមំ ញាណំ ។ ២ ឱ. ឥមិនាបេតំ ។ ម. ឥមិនា ខោ ឯតំ ។

ទ្រង់បញ្ញត្តនូវសញ្ញា ជាកំពូលតែមួយយ៉ាងក៏មាន ទ្រង់បញ្ញត្តនូវសញ្ញា ជាកំពូលច្រើនយ៉ាងក៏មាន តើដូចម្តេច ។ ម្នាលបោដ្ឋបាទ ភិក្ខុបាននូវនិរោធ យ៉ាងណា ៗ តថាគត ក៏បញ្ញត្តនូវសញ្ញាជាកំពូលយ៉ាងនោះ ៗ ។ ម្នាលបោដ្ឋបាទ តថាគតបញ្ញត្តនូវសញ្ញាជាកំពូល តែមួយយ៉ាងក៏មាន បញ្ញត្តនូវសញ្ញា ជាកំពូលច្រើនយ៉ាងក៏មាន យ៉ាងនេះឯង ។

[៩០] បពិត្រព្រះអង្គដ៏ចម្រើន សញ្ញា[១] កើតមុន ញាណ[២] កើតក្រោយ ឬញាណ កើតមុន សញ្ញា កើតក្រោយ ឬក៏ទាំងសញ្ញាទាំងញាណ កើតដំណាលគ្នាតែម្តង ។ ម្នាលបោដ្ឋបាទ សញ្ញាកើតមុន ញាណកើតក្រោយ ដ្បិតថា ការកើតឡើងនៃញាណបាន ក៏ព្រោះតែសេចក្តីកើតឡើងនៃសញ្ញា ភិក្ខុនោះក៏ដឹងយ៉ាងនេះថា ញាណរបស់អាត្មាអញកើតហើយ ព្រោះសញ្ញានេះជាបច្ច័យ ។ ម្នាលបោដ្ឋបាទ រឿងនេះអ្នកត្រូវដឹងតាមទំនងនេះចុះថា សញ្ញាកើតមុន ញាណកើតក្រោយ ដ្បិតញាណកើតឡើងបាន ក៏ព្រោះតែសញ្ញាកើតឡើង ។

---

១ សញ្ញាក្នុងទីនេះ សំដៅយកឈានសញ្ញាក៏មាន វិបស្សនាក៏មាន ន័យខ្លះទៀតថា មគ្គសញ្ញា ។ ២ ញាណក្នុងទីនេះ សំដៅយក វិបស្សនាញាណក៏មាន មគ្គញ្ញាណក៏មាន ផលញ្ញាណក៏មាន អដ្ឋកថា ប្រាប់ថា ៣ ន័យយ៉ាងនេះ ។

[៩១] សញ្ញា នុ ខោ ភន្តេ បុរិសស្ស អត្តា ឧទាហុ អញ្ញា សញ្ញា អញ្ញោ អត្តាតិ ។ កំ បន ត្វំ បោដ្ឋបាទ អត្តានំ បច្ចេសីតិ ។ ឱឡារិកំ ខោ អហំ ភន្តេ អត្តានំ បច្ចេមិ រូបឹ ចាតុម្មហាភូតិកំ កពឡីការាហារភក្ខន្តិ[១] ។ ឱឡារិកោ ច ហិ តេ បោដ្ឋបាទ អត្តា អភវិស្ស រូបី ចាតុម្មហាភូតិកោ កពឡីការាហារភក្ខោ ។ ឯវំ សន្តំ ខោ តេ បោដ្ឋ-បាទ អញ្ញា ច[២] សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តទមិនាបេតំ បោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តិដ្ឋតេវ អយំ បោដ្ឋបាទ ឱឡារិកោ អត្តា រូបី ចាតុម្មហា-ភូតិកោ កពឡីការាហារភក្ខោ អថ ឥមស្ស បុរិ-សស្ស អញ្ញា វ សញ្ញា ឧប្បជ្ជតិ អញ្ញា វ សញ្ញា និរុជ្ឈតិ ឥមិនា ខោ ឯតំ បោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តាតិ ។

១ ឱ. កពលីការហារភក្ខន្តិ ។ ម. កពលីការភក្ខន្តិ ។ ២ ឱ. ម. វ ។

[៩១] បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាឈ្មោះថា ខ្លួនរបស់បុរស ឬក៏សញ្ញាដទៃ ខ្លួនដទៃទេ ។ ម្នាលបោដ្ឋបាទ អ្នកជឿថា ខ្លួនដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿថាខ្លួនដ៏គ្រោតគ្រាតមានរូប ប្រកបដោយមហាភូតរូប ៤ មានកវលិង្ការាហារជាចំណី ។ ម្នាលបោដ្ឋបាទ មែនហើយ ខ្លួនរបស់អ្នកដ៏គ្រោតគ្រាតមានរូប ប្រកបដោយមហាភូតរូប ៤ មានកវលិង្ការាហារជាចំណី ។ ម្នាលបោដ្ឋបាទ កាលបើហេតុយ៉ាងនេះមានហើយ សញ្ញារបស់អ្នកក៏ដទៃ ខ្លួនក៏ដទៃ ។ ម្នាលបោដ្ឋបាទ អ្នកត្រូវដឹងសេចក្តីនុ៎ះតាមទំនងនេះចុះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃដោយពិត ។ ម្នាលបោដ្ឋបាទ ខ្លួនដែលគ្រោតគ្រាតមានរូប ប្រកបដោយមហាភូតរូប ៤ មានកវលិង្ការាហារជាចំណីនេះ ចូរលើកទុកសិនចុះ កាលបើដូច្នោះសញ្ញាដទៃរបស់បុរសនេះកើតឡើង សញ្ញាឯទៀតរលត់ទៅ ម្នាលបោដ្ឋបាទ អ្នកត្រូវដឹងសេចក្តីនុ៎ះតាមទំនងនេះចុះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃដោយពិត ។

[៩២] មនោមយំ ខោ អហំ ភន្តេ អត្តានំ បច្ចេមិ សព្វង្គប្បច្ចង្គិំ អហីនិន្ទ្រិយន្តិ ។ មនោមយោ ច ហិ តេ បោដ្ឋបាទ អត្តា អភវិស្ស សព្វង្គប្បច្ចង្គី អហី-និន្ទ្រិយោ ។ ឯវំ សន្តំបិ ខោ តេ បោដ្ឋបាទ អញ្ញា ច សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តទិមិនាបេតំ បោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តិដ្ឋតេវ អយំ បោដ្ឋបាទ មនោមយោ អត្តា សព្វង្គប្បច្ចង្គី អហីនិន្ទ្រិយោ អថ ឥមស្ស បុរិសស្ស អញ្ញា វ សញ្ញា ឧប្បជ្ជតិ អញ្ញា វ សញ្ញា និរុជ្ឈតិ ។ ឥមិនាបិ ខោ ឯតំ បោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តាតិ ។

[៩៣] អរូបឹ ខោ អហំ ភន្តេ អត្តានំ បច្ចេមិ សញ្ញាមយន្តិ ។ អរូបី ច ហិ តេ បោដ្ឋបាទ អត្តា អភវិស្ស សញ្ញាមយោ ។ ឯវំ សន្តំបិ ខោ

[៩២] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿថា ខ្លួនសម្រេចដោយចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកទាប ។ ម្នាលបោដ្ឋបាទ ប្រសិនបើខ្លួនរបស់អ្នកសម្រេចដោយចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកទាប ។ ម្នាលបោដ្ឋបាទ កាលបើ ហេតុដូច្នេះមានហើយ សញ្ញារបស់អ្នកក៏ដទៃ ខ្លួនរបស់អ្នកក៏ដទៃ ។ ម្នាលបោដ្ឋបាទ អ្នកត្រូវដឹងសេចក្ដីនុ៎ះ តាមបរិយាយនេះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃមែន ។ ម្នាលបោដ្ឋបាទ ក៏ខ្លួនសម្រេច ដោយចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកទាបនេះ ចូរលើកទុកសិនចុះ កាលបើដូច្នោះសញ្ញាដទៃរបស់បុរសនេះកើតឡើង សញ្ញាឯទៀតក៏រលត់ទៅវិញដោយពិត ។ ម្នាលបោដ្ឋបាទ អ្នកត្រូវដឹងសេចក្ដីនុ៎ះ ដោយបរិយាយនេះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃមែន ។

[៩៣] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿថា ខ្លួនមិនមានរូប សម្រេចដោយសញ្ញាដោយពិត ។ ម្នាលបោដ្ឋបាទ ខ្លួនរបស់អ្នកមិនមានរូប សម្រេចដោយសញ្ញាមែនហើយ ។ ម្នាលបោដ្ឋបាទ កាលបើ

តេ ចោដ្ឋបាទ អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តទិមិនាបេតំ ចោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តា ។ តិដ្ឋតេវ អយំ ចោដ្ឋបាទ អរូបី អត្តា សញ្ញាមយោ អថ ឥមស្ស បុរិសស្ស អញ្ញា វ សញ្ញា ឧប្បជ្ជតិ អញ្ញា វ សញ្ញា និរុជ្ឈតិ ។ ឥមិនាបិ ខោ ឯតំ ចោដ្ឋបាទ បរិយាយេន វេទិតព្វំ យថា អញ្ញា វ សញ្ញា ភវិស្សតិ អញ្ញោ អត្តាតិ ។

[៩៤] សក្កា ច បនេតំ[១] ភន្តេ មយា ញាតុំ សញ្ញា បុរិសស្ស អត្តាតិ វា អញ្ញា ច[២] សញ្ញា អញ្ញោ ច[៣] អត្តាតិ វាតិ ។ ទុជ្ជានំ ខោ ឯតំ ចោដ្ឋបាទ តយា អញ្ញទិដ្ឋិកេន អញ្ញក្ខន្តិកេន អញ្ញរុចិកេន អញ្ញត្ថអាយោគេន អញ្ញត្ថាចរិយកេន[៤] សញ្ញា បុរិសស្ស អត្តាតិ វា អញ្ញា ច សញ្ញា អញ្ញោ ច អត្តាតិ វាតិ ។ សចេ តំ ភន្តេ មយា ទុជ្ជានំ អញ្ញទិដ្ឋិកេន អញ្ញក្ខន្តិកេន អញ្ញរុចិកេន អញ្ញត្ថ-

១ ឱ. ម. សក្កា បនេនំ ។ ២-៣ ឱ. ចសទ្ទទ្វយំ ន ទិស្សតិ ។ ៤ ឱ. ម. អញ្ញត្រាយោគេន អញ្ញត្រាចរិយកេន ។

ហេតុយ៉ាងនេះមានហើយ សញ្ញារបស់អ្នកក៏ដទៃ ខ្លួនក៏ដទៃពិត ។ ម្នាលពោដ្ឋបាទ អ្នកគប្បីដឹងសេចក្តីនុ៎ះ ដោយបរិយាយនេះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃដោយពិត ។ ម្នាលពោដ្ឋបាទ ខ្លួនមិនមានរូប សម្រេចដោយសញ្ញានេះ ចូរលើកទុកសិនចុះ កាលបើយ៉ាងនេះ សញ្ញាដទៃរបស់បុរសនេះតែងកើតឡើង សញ្ញាដទៃតែងរលត់ទៅ ។ ម្នាលពោដ្ឋបាទ អ្នកគប្បីដឹងសេចក្តីនុ៎ះ ដោយបរិយាយនេះថា សញ្ញាក៏ដទៃ ខ្លួនក៏ដទៃដោយពិត ។

[៩៤] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ អាចដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួន របស់បុរសដូច្នេះខ្លះ សញ្ញាក៏ដទៃ ខ្លួនក៏ដទៃដូច្នេះខ្លះ ។ ម្នាលពោដ្ឋបាទ អ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីផ្សេង មានអាចារ្យក្នុងទីផ្សេង កម្រនឹងដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួន របស់បុរសដូច្នេះខ្លះ សញ្ញាក៏ដទៃ ខ្លួនក៏ដទៃ ដូច្នេះខ្លះបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គជាអ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានការព្យាយាមក្នុងទីផ្សេង

អាយោគេន អញ្ញត្ថាចរិយកេន សញ្ញា បុរិសស្ស អត្តាតិ វា អញ្ញា ច សញ្ញា អញ្ញោ ច អត្តាតិ វា ។ កឹ បន ភន្តេ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ អព្យាកតំ ខោ បោដ្ឋបាទ មយា សស្សតោ លោកោ[1] ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភន្តេ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ អព្យាកតំ ខោ បោដ្ឋបាទ មយា អព្យាកតំ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភន្តេ អន្តវា លោកោ ។ បេ ។ អនន្តវា លោកោ ។ តំ ជីវំ តំ សរីរំ ។ អញ្ញំ ជីវំ អញ្ញំ សរីរំ ។ ហោតិ តថាគតោ បរម្មរណា ។ ន ហោតិ តថាគតោ បរម្មរណា ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ

១ ឱ. អព្យាកតំ ខោ បោដ្ឋបាទ មយា សស្សតោ លោកោ ។ ម. អព្យាកតំ ខោ ឯវំ បោដ្ឋបាទ មយា សស្សតោ លោកោ ។

មានអាចារ្យក្នុងទីផ្សេង កម្រនឹងដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួន របស់បុរសដូច្នេះខ្លះ សញ្ញាក៏ដទៃ ខ្លួនក៏ដទៃ ដូច្នេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ចុះដែលគេថាលោកទៀងនេះឯង ជាពាក្យពិត ពាក្យដទៃជាពាក្យឥតអំពើឬ ។ ម្នាលបោដ្ឋបាទ តថាគត មិនដែលព្យាករសេចក្តីនុ៎ះថា ពាក្យថាលោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាពាក្យឥតអំពើដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពាក្យថា លោកមិនទៀងនេះឯងជាពាក្យពិត ពាក្យដទៃ ជាពាក្យឥតអំពើទេឬ ។ ម្នាលបោដ្ឋបាទ តថាគត មិនដែលព្យាករសេចក្តីនុ៎ះថា ពាក្យថា លោកមិនទៀងនេះឯងជាពាក្យពិត ពាក្យដទៃជាពាក្យឥតអំពើដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពាក្យថា លោកមានទីបំផុត ។ បេ ។ លោកមិនមានទីបំផុត ។ ជីវៈនោះ ក៏គឺសរីរៈនោះ ។ ជីវៈផ្សេង សរីរៈក៏ផ្សេងទេ ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមាន ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមិនមាន ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមានខ្លះមិនមានខ្លះ ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែន នេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យ

មោឃមញ្ញន្តិ ។ ឯតំបិ ខោ ចោដ្ឋបាទ មយា អព្យាកតំ នេវ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កស្មា បនេតំ ភន្តេ ភគវតា អព្យាកតន្តិ ។ ន ហេតំ ចោដ្ឋបាទ អត្ថសញ្ហិតំ ន ធម្មសញ្ហិតំ ន អាទិព្រហ្មចរិយកំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ តស្មា តំ មយា អព្យាកតន្តិ ។

[៩៥] កឹ បន ភន្តេ ភគវតា ព្យាកតន្តិ ។ ឥទំ ទុក្ខន្តិ ខោ[១] ចោដ្ឋបាទ មយា ព្យាកតំ អយំ ទុក្ខសមុទយោតិ ខោ ចោដ្ឋបាទ មយា ព្យាកតំ អយំ ទុក្ខនិរោធោតិ ខោ ចោដ្ឋបាទ មយា ព្យាកតំ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ខោ ចោដ្ឋបាទ

១ ឱ. ខោសទ្ទោ ន ទិស្សតិ ។

ឥតអំពើឬ ។ ម្នាលបោដ្ឋបាទ តថាគតមិនដែលព្យាករសេចក្ដីនុ៎ះថា ពាក្យថា សត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃ ជាមោឃៈ (ពាក្យឥតអំពើ) ដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រោះហេតុអ្វី បានជាព្រះមានព្រះភាគ មិនទ្រង់ព្យាករសេចក្ដីនុ៎ះ ។ ម្នាលបោដ្ឋបាទ ព្រោះថាពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយនវលោកុត្តរធម៌ មិនមែនជាអាទិព្រហ្មចរិយកាសិក្ខា គឺមិនមែនអធិសីលសិក្ខាទេ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយក្នុងសំសារវដ្ដ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេកក្នុងវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីរំលត់វដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីរម្ងាប់វដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីដឹងចំពោះវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់នូវវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនព្យាករសេចក្ដីនោះឡើយ ។

[៩៥] បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គ ទ្រង់ព្យាករពាក្យអ្វីទៅវិញ ។ ម្នាលបោដ្ឋបាទ តថាគតព្យាករដូច្នេះឯងថា នេះជាទុក្ខ ម្នាលបោដ្ឋបាទ តថាគតព្យាករដូច្នេះឯងថា នេះជាហេតុនាំឲ្យកើតទុក្ខ ម្នាលបោដ្ឋបាទ តថាគតព្យាករដូច្នេះឯងថា នេះជាធម៌ដែលរំលត់ទុក្ខ ម្នាលបោដ្ឋបាទ តថាគតព្យាករដូច្នេះឯងថា នេះបដិបទាជាដំណើរទៅកាន់ធម៌

មយា ព្យាកតន្តិ ។ កស្មា ចេតំ ភន្តេ ភគវតា ព្យាកតន្តិ ។ ឯតំ ហិ[១] បោដ្ឋបាទ អត្ថសញ្ហិតំ ឯតំ ធម្មសញ្ហិតំ ឯតំ អាទិព្រហ្មចរិយកំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោ-ធាយ និព្វានាយ សំវត្តតិ តស្មា ហេតំ[២] មយា ព្យាកតន្តិ ។ ឯវមេតំ ភគវា ឯវមេតំ សុគត យស្ស-ទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា ឧដ្ឋាយាសនា បក្កាមិ ។

[៩៦] អថខោ តេ បរិព្វាជកា អចិរប្បក្កន្តស្ស ភគវតោ បោដ្ឋបាទំ បរិព្វាជកំ សមន្តតោ វាចាយ សន្និតោទកេន សញ្ឈព្ភរិមកំសុ[៣] ឯវមេវ បនាយំ ភវំ បោដ្ឋបាទោ យញ្ញទេវ[៤] សមណោ គោតមោ ភាសតិ តន្តទេវស្ស[៥] អព្ភនុមោទតិ ឯវមេតំ ភគវា

១ ឱ. ហិ ខោ ។ ២ ឱ. តំ ។ ម. ឯតំ ។ ៣ ឱ. សញ្ឈព្ភរិយំ អកំសុ ។ ៤ ឱ. យំ យទេវ ។ ៥ ឱ. ម. តំ តទេវស្ស ។

រំលត់ទុក្ខ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគទ្រង់ព្យាករពាក្យនេះ ។ ម្នាលបោដ្ឋបាទ ព្រោះថាពាក្យនេះប្រកបដោយប្រយោជន៍ ពាក្យនេះប្រកបដោយធម៌ ពាក្យនេះជាអាទិព្រហ្មចរិយកាសិក្ខា គឺអធិសីលសិក្ខា ប្រព្រឹត្តទៅ ដើម្បីនឿយណាយក្នុងសង្សារវដ្ត ដើម្បីប្រាសចាកតម្រេកក្នុងវដ្តៈ ដើម្បីរំលត់នូវវដ្តៈ ដើម្បីរម្ងាប់នូវវដ្តៈ ដើម្បីដឹងចំពោះនូវវដ្តៈ ដើម្បីដឹងច្បាស់នូវវដ្តៈ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតព្យាករពាក្យនេះ ។ បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់សំគាល់នូវកាលដែលនឹងធ្វើនូវពុទ្ធដំណើរចុះ ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ក្រោកអំពីអាសនៈ ហើយទ្រង់ពុទ្ធដំណើរចេញទៅ ។

[៩៦] លំដាប់នោះឯង កាលបើ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ មិនទាន់បានយូរប៉ុន្មាន ស្រាប់តែពួកបរិព្វាជកទាំងនោះ ពោលពាក្យចាក់ដោត នូវបោដ្ឋបាទបរិព្វាជក ដោយជន្ទញគឺសំដីជុំវិញខ្លួនថា ព្រះសមណគោតម និយាយពាក្យណា ៗ បោដ្ឋបាទដ៏ចម្រើននេះក៏អនុមោទនាពាក្យនោះ ៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះ

ឯវមេតំ សុគតាតិ ឯ ខោ បន មយំ កិញ្ចិ សមណស្ស គោតមស្ស ឯកំសិកំ ធម្មំ ទេសិតំ អាជានាម សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។

[៩៧] ឯវំ វុត្តេ ចោដ្ឋបាទោ បរិព្វាជកោ តេ បរិព្វាជកេ ឯតទវោច អហំបិ ខោ ភោ ន កិញ្ចិ សមណស្ស គោតមស្ស ឯកំសិកំ ធម្មំ ទេសិតំ អាជានាមិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា អបិច សមណោ គោតមោ ភូតំ តច្ឆំ តថំ បដិ-បទំ បញ្ញបេតិ ធម្មដ្ឋិតតំ ធម្មនិយាមតំ[១] ភូតំ ខោ បន តច្ឆំ តថំ បដិបទំ បញ្ញបេន្តស្ស ធម្មដ្ឋិតតំ ធម្មនិយាមតំ កថំ ហិ នាម មាទិសោ វិញ្ញូ បុរិសោ[២] សមណស្ស គោតមស្ស សុភាសិតំ សុភាសិតតោ ន អព្ភនុមោទេយ្យាតិ ។

១ ឱ. ធម្មដ្ឋិតំ ធម្មនិយាមកំ ។ ២ ឱ. ម. បុរិសោតិ បាឋោ ន ទិស្សតិ ។

មានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ឯពួកយើងមិនទាន់ដឹងច្បាស់នូវធម៌ណាមួយ ដោយដាច់ខាត ដែលព្រះសមណគោតម ទ្រង់សំដែងហើយថា លោកទៀង ឬថាលោកមិនទៀង ។ បេ ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះទេ ។

[៩៧] កាលបើ ពួកបរិព្វាជកទាំងនោះ ពោលពាក្យយ៉ាងនេះហើយ បោដ្ឋបាទបរិព្វាជក ក៏និយាយទៅនឹងបរិព្វាជកទាំងនោះយ៉ាងនេះថា នែអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំឯងក៏មិនដឹងច្បាស់នូវធម៌ណាមួយដោយដាច់ខាត ដែលព្រះសមណគោតម ទ្រង់សំដែងហើយថា លោកទៀងឬ ។ បេ ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះដែរទេ ប៉ុន្តែព្រះសមណគោតមទ្រង់បញ្ញត្តបដិបទា ដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងនៃធម៌ ក៏កាលបើព្រះសមណគោតម ទ្រង់បញ្ញត្តបដិបទា ដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនង នៃធម៌ ដូច្នោះហើយ មិនសមបើបុរសជាវិញ្ញូដូចយ៉ាងខ្ញុំ មិនអនុមោទនាសុភាសិតរបស់ព្រះសមណគោតម ដោយសុភាសិតវិញសោះ ។

## បោដ្ឋបាទសុត្តេ  ចិត្តហត្ថិសារីបុត្តបោដ្ឋបាទបរិព្វាជកា

[៩៨] អថខោ ទ្វីហតីហស្ស អច្ចយេន ចិត្តោ ច ហត្ថិសារីបុត្តោ បោដ្ឋបាទោ ច បរិព្វាជកោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ចិត្តោ ហត្ថិសា-រីបុត្តោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ បោដ្ឋ-បាទោ បន បរិព្វាជកោ ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បោដ្ឋបាទោ បរិព្វា-ជកោ ភគវន្តំ ឯតទវោច តទា មំ ភន្តេ តេ[១] បរិព្វា-ជកា អចិរបក្កន្តស្ស ភគវតោ សមន្តតោ វាចាយ សន្និតោទកេន សញ្ជម្ភរិមកំសុ ឯវមេវ បនាយំ ភវំ បោដ្ឋបាទោ បរិព្វាជកោ យញ្ញទេវ សមណោ គោត-មោ ភាសតិ តន្តទេវស្ស អព្ភនុមោទតិ ឯវមេតំ ភគវា

---

១ ឱ. តេតិ បទំ ន ទិស្សតិ ។

បោដ្ឋបាទសូត្រ ចិត្តហត្ថិសារីបុត្តនិងបោដ្ឋបាទបរិព្វាជក

[៩៨] លុះកន្លងពីនោះទៅបាន ២-៣ ថ្ងៃ ចិត្តហត្ថិសារីបុត្ត[១] និង បោដ្ឋបាទបរិព្វាជក ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ទើបចិត្តហត្ថិសារីបុត្ត ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯបោដ្ឋបាទបរិព្វាជក ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបោដ្ឋបាទបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអង្គទ្រង់ពុទ្ធដំណើរចេញមក មិនទាន់បានយូរប៉ុន្មាន ក្នុងកាលនោះ ក៏ស្រាប់តែពួកបរិព្វាជកទាំងនោះ ពោលពាក្យចាក់ដោតខ្ញុំព្រះអង្គ ដោយជន្លួញគឺវាចាជុំវិញខ្លួនថា ព្រះសមណគោតម និយាយពាក្យណា ៗ បោដ្ឋបាទបរិព្វាជកដ៏ចម្រើននេះ ក៏អនុមោទនាពាក្យនោះ ៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត

---

១ អដ្ឋកថា ថា ចិត្តហត្ថិសារីបុត្តនោះជាកូននៃហ្មដំរីក្នុងក្រុងសាវត្ថី បានបួសក្នុងសំណាក់ព្រះមានព្រះភាគ បានរៀនព្រះត្រៃបិដកជាអ្នកឈ្លាសក្នុងអត្ថដ៏សុខុម តែសឹកចេញជាគ្រហស្ថអស់វារៈ ៧ លើក លុះលើកក្រោយបំផុតទើបតែនឹងសឹកបាន ២-៣ ថ្ងៃ ក៏បានទៅកាន់សំណាក់បោដ្ឋបាទបរិព្វាជក ៗ ក៏នាំទៅថ្វាយបង្គំព្រះមានព្រះភាគ ។

ឯវមេតំ សុគតាតិ ន ខោ បន មយំ កិញ្ចិ សមណស្ស គោតមស្ស ឯកំសិកំ ធម្មំ ទេសិតំ អាជានាម សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វាតិ ឯវំ វុត្តាហំ ភន្តេ តេ បរិព្វាជកេ ឯតទវោចំ អហំបិ ខោ ភោ ន កិញ្ចិ សមណស្ស គោតមស្ស ឯកំសិកំ ធម្មំ ទេសិតំ អាជានាមិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ វា អបិច សមណោ គោតមោ ភូតំ តច្ឆំ តថំ បដិបទំ បញ្ញបេតិ ធម្មដ្ឋិតតំ ធម្មនិយាមតំ ភូតំ ខោ បន តច្ឆំ តថំ បដិបទំ បញ្ញបេន្តស្ស ធម្មដ្ឋិតតំ ធម្មនិយាមតំ កថំ ហិ នាម មាទិសោ វិញ្ញូ បុរិសោ សមណស្ស គោតមស្ស សុភាសិតំ សុភាសិតតោ ន អនុមោទេយ្យាតិ ។

ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ពួកយើងមិនដឹងច្បាស់នូវធម៌ណាមួយ ដោយដាច់ខាត ដែលព្រះសមណគោតមបានសំដែងថា លោកទៀងឬថាលោកមិនទៀង ។ បេ ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះទេ បពិត្រព្រះអង្គដ៏ចម្រើន កាលបើបរិព្វាជកទាំងនោះ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏និយាយទៅនឹងបរិព្វាជកទាំងនោះដូច្នេះថា នែអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំឯងក៏មិនដឹងច្បាស់នូវធម៌ណាមួយដោយដាច់ខាត ដែលព្រះសមណគោតមបានសំដែងថា លោកទៀងឬ ។ បេ ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះដែរ ប៉ុន្តែព្រះសមណគោតម ទ្រង់បញ្ញត្តបដិបទាដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងធម៌ ក៏កាលព្រះសមណគោតម ទ្រង់បញ្ញត្តបដិបទា ដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ដែលត្រឹមត្រូវតាមទំនងនៃធម៌ដូច្នោះ មិនសមបើបុរសជាវិញ្ញូដូចយ៉ាងខ្ញុំ ហើយមិនអនុមោទនាសុភាសិតរបស់ព្រះសមណគោតម ដោយសុភាសិតវិញសោះ ។

១៣៣

## បោដ្ឋបាទសុត្តេ ឯកំសិកាបិ អនេកំសិកាបិ ធម្មា

[៩៩] សព្វេហេវ ខោ[១] ឯតេ បោដ្ឋបាទ បរិព្វាជកា អន្ធា អចក្ខុកា ត្វញ្ញេវ[២] នេសំ ឯកោ ចក្ខុមា ។ ឯកំសិកាបិ ហិ ខោ[៣] បោដ្ឋបាទ មយា ធម្មា ទេសិតា បញ្ញត្តា ។ អនេកំសិកាបិ ហិ ខោ បោដ្ឋបាទ មយា ធម្មា ទេសិតា បញ្ញត្តា ។ កតមេ ច បោដ្ឋបាទ មយា អនេកំសិកា ធម្មា ទេសិតា បញ្ញត្តា ។ សស្សតោ លោកោតិ ខោ[៤] បោដ្ឋបាទ មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ បេ ។ អសស្សតោ លោកោតិ ខោ បោដ្ឋបាទ មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អន្តវា លោកោតិ ខោ បោដ្ឋបាទ មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អនន្តវា លោកោតិ ខោ បោដ្ឋបាទ មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។

---

១ ឱ. ម. សព្វេវ ខោ ។ ២ ឱ. ម. ត្វំយេវ ។ ៣ ឱ. ខោសទ្ទោ ន ទិស្សតិ ។ ៤ ឱ. វា ។ ម. វា ខោ ។

[៩៩] ម្នាលបោដ្ឋបាទ ឯបរិព្វាជកទាំងអស់គ្នានោះឯង សុទ្ធតែជាបុគ្គលខ្វាក់ឥតមានចក្ខុគឺបញ្ញាសោះឡើយ បណ្ដាបរិព្វាជកទាំងនោះ មានតែអ្នកឯងមួយជាបុគ្គលមានចក្ខុគឺបញ្ញាដោយពិត ។ ម្នាលបោដ្ឋបាទ ព្រោះថាធម៌ដែលប្រព្រឹត្តទៅដោយចំណែក ១ តថាគតបានសំដែងហើយ បានបញ្ញត្តហើយក៏មាន ។ ម្នាលបោដ្ឋបាទ ធម៌ទាំងឡាយដែលមិនប្រព្រឹត្តទៅដោយចំណែក ១ តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ក៏មាន ។ ម្នាលបោដ្ឋបាទ ធម៌ទាំងឡាយដែលមិនប្រព្រឹត្តទៅ ដោយចំណែក ១ តថាគតបានសំដែងហើយ បានបញ្ញត្តហើយ តើដូចម្ដេច ។ ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅ ដោយចំណែកមួយថា លោកទៀងដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ បេ ។ ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅ ដោយចំណែកមួយថា លោកមិនទៀងដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅ ដោយចំណែកមួយថា លោកមានទីបំផុតដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅ ដោយចំណែកមួយថា លោកមិនមានទីបំផុតដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។

តំ ជីវំ សរីរន្តិ ខោ ចោទ្ធចាន មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ ខោ ចោទ្ធចាន មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ ហោតិ តថាគតោ បរំ មរណាតិ ខោ ចោទ្ធចាន មយា ។ បេ ។ ន ហោតិ តថាគតោ បរំ មរណាតិ ខោ ចោទ្ធចាន មយា ។ បេ ។ ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណាតិ ខោ ចោទ្ធចាន មយា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណាតិ ខោ ចោទ្ធចាន មយា អនេកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ កស្មា ចេតេ[១] ចោទ្ធចាន មយា អនេកំសិកា ធម្មា ទេសិតា បញ្ញត្តា ។ ន ហេតេ ចោទ្ធចាន អត្ថសញ្ហិតា ន ធម្មសញ្ហិតា ន អាទិព្រហ្មចរិយកា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន

១ ឱ. ម. ច តេ ។

ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា ជីវៈនោះគឺសរីរៈនោះដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា ជីវៈផ្សេង សរីរៈផ្សេងដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មាន ។ បេ ។ ម្នាលបោដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចកក្ដីស្លាប់ទៅ មិនមាន ។ បេ ។ ម្នាលបោដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានខ្លះ មិនមានខ្លះ ។ បេ ។ ម្នាលបោដ្ឋបាទ ធម៌មិនប្រព្រឹត្តទៅដោយចំណែកមួយ តថាគតបានសំដែងហើយ បានបញ្ញត្តហើយថា សត្វខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះឯង ។ ម្នាលបោដ្ឋបាទ ក៏ធម៌មិនប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៎ះ ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ព្រោះហេតុអ្វី ។ ម្នាលបោដ្ឋបាទ ព្រោះថាធម៌ទាំងនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយធម៌ មិនមែនជាអាទិព្រហ្មចរិយកាសិក្ខា មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីរំលត់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីរម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីត្រាស់ដឹង មិនប្រព្រឹត្តទៅ

និព្វានាយ សំវត្តន្តិ តស្មា ឯតេ(១) មយា អនេកំសិកា ធម្មា ទេសិតា បញ្ញត្តា ។

[១០០] កតមេ ច(២) បោដ្ឋបាទ មយា ឯកំសិកា ធម្មា ទេសិតា បញ្ញត្តា ។ ឥទំ ទុក្ខន្តិ ខោ បោដ្ឋបាទ មយា ឯកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អយំ ទុក្ខសមុទយោតិ ខោ បោដ្ឋបាទ មយា ឯកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អយំ ទុក្ខនិរោធោតិ ខោ បោដ្ឋបាទ មយា ឯកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ខោ បោដ្ឋបាទ មយា ឯកំសិកោ ធម្មោ ទេសិតោ បញ្ញត្តោ ។ កស្មា ចេតេ បោដ្ឋបាទ មយា ឯកំសិកា ធម្មា ទេសិតា បញ្ញត្តា ។ ឯតេ បោដ្ឋបាទ មយា(៣) អត្ថសញ្ហិតា ឯតេ ធម្មសញ្ហិតា ឯតេ អាទិព្រហ្មចរិយកា ឯតេ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ

១ ឱ. ម. តេ ។ ២ ឱ. ម. ច តេ ។ ៣ ឱ. ម. មយាតិ បាឋោ ន ទិស្សតិ ។

ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៎ះ បានជាតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។

[១០០] ម្នាលបោដ្ឋបាទ ចុះធម៌ទាំងឡាយប្រព្រឹត្តទៅ ដោយចំណែកមួយ ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ តើដូចម្តេច ។ ម្នាលបោដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាទុក្ខដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាហេតុនាំឲ្យកើតទុក្ខដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាសេចក្តីរំលត់ទុក្ខដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋ-បាទ ធម៌ប្រពឹត្តទៅដោយចំណែកមួយថា នេះជាបដិបទាដំណើរទៅកាន់ធម៌រំលត់ទុក្ខដូច្នេះឯង តថាគតបានសំដែងហើយ បានបញ្ញត្តហើយ ។ ម្នាលបោដ្ឋបាទ ចុះធម៌ប្រព្រឹត្តទៅ ដោយចំណែកមួយទាំងនុ៎ះ ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ តើព្រោះហេតុអ្វី ។ ម្នាលបោដ្ឋបាទ ព្រោះថា ធម៌ទាំងនុ៎ះប្រកបដោយប្រយោជន៍ ធម៌ទាំងនុ៎ះប្រកបដោយធម៌ ធម៌ទាំងនុ៎ះជាអាទិព្រហ្មចរិយកាសិក្ខា ធម៌ទាំងនុ៎ះប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ ដើម្បីរម្ងាប់

អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ តស្មា ឯតេ មយា ឯកំសិកា ធម្មា ទេសិតា បញ្ញត្តា ។

[១០១] សន្តិ ខោ ពោដ្ឋបាទ ឯកេ សមណ-ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរម្មរណាតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំ-ទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរម្មរណា-តិ ។ តេ ចេ មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ អបិច បន[១] តុម្ហេ អាយស្មន្តោ ឯកន្តសុខំ លោកំ ជានំ បស្សំ វិហរថាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ

១ ឱ. ម. អបិ បន ។

ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅ ដោយចំណែកមួយទាំងនុ៎ះ បានជាតថាគត បានសំដែងហើយ បានបញ្ញត្តហើយ ។

[១០១] ម្នាលបោដ្ឋបាទ មានសមណព្រាហ្មណ៍ទាំងនុ៎ះ តែងមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុឮថា អ្នកទាំងឡាយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅដូច្នេះពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើ តថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ករុណា (ពិតមែន) តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបានដឹង បានឃើញថា សត្វលោកមានសេចក្តីសុខតែមួយយ៉ាងមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ

១៣៧



ឯកំ វា រត្តឹ ឯកំ វា ទិវសំ ឧបឌ្ឍំ វា រត្តឹ ឧបឌ្ឍំ វា ទិវសំ ឯកន្តសុខី អត្តានំ សម្បជានថាតិ[១] ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ ជានាថ អយំ មគ្គោ អយំ បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ យា តា ទេវតា ឯកន្តសុខំ លោកំ ឧបបន្នា តាសំ ភាសមានានំ សទ្ទំ សុណាថ សុប្បដិបន្នត្ថ មារិសា ឧជុប្បដិបន្នត្ថ មារិសា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយ មយំបិ ហិ មារិសា ឯវំបដិបន្នា ឯកន្តសុខំ លោកំ ឧបបន្នាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ ននុ ឯវំ សន្តេ

១ ឱ. សញ្ជានាថាតិ ។ ម. សម្បជានាថាតិ ។

ចាំបាននូវខ្លួនថាមានសេចក្តីសុខតែមួយយ៉ាង អស់យប់មួយថ្ងៃមួយឬអស់កន្លះយប់ កន្លះថ្ងៃដូច្នេះ ឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណ-ព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយស្គាល់ថានេះជាមគ្គ នេះជាបដិបទាប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានសេចក្តីសុខតែមួយយ៉ាងឬ ។ សមណ-ព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថាមិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ បានឮសំឡេង របស់ពួកទេវតាដែលកើតក្នុងលោកមានសេចក្តីសុខតែមួយយ៉ាង និយាយប្រាប់ថា ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំងឡាយប្រតិបត្តិដោយល្អទៅ ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំងឡាយប្រតិបត្តិដោយត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានសេចក្តីសុខតែមួយយ៉ាង ម្នាលគ្នាយើងទាំង-ឡាយ ព្រោះថាបើពួកយើងប្រតិបត្តិយ៉ាងនេះហើយ នឹងទៅកើតក្នុងលោកដែលមានសេចក្តីសុខតែមួយយ៉ាងដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះថា ដូចម្តេច កាលបើហេតុយ៉ាងនេះ

តេសំ សមណព្រាហ្មណានំ អប្បាដិហិរិកតំ(១) ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តេសំ សមណ-ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

[១០២] សេយ្យថាបិ ពោដ្ឋពាទ(២) បុរិសោ ឯវំ វទេយ្យ អហំ យា ឥមស្មឹ ជនបទេ ជនបទកល្យាណី តំ ឥច្ឆាមិ តំ កាមេមីតិ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆាសិ កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ខត្តិយឹ វា ព្រាហ្មណឹ វា វេស្សឹ វា សុទ្ទឹ វាតិ(៣) ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ឯវំនាមា វា ឯវំគោត្តា វា ទីឃា វា រស្សា វា មជ្ឈិមា វា កណ្ហា(៤) វា សាមា វា មង្គុរច្ឆវី វាតិ អសុកស្មឹ គាមេ វា និគមេ វា នគរេ វាតិ ។ ឥតិ បុដ្ឋោ នោតិ

---

១ ឱ. អប្បាដិហីរកតំ ។ ម. អប្បាដិហីរកតំ ។ ២ ឱ. បោដ្ឋបាទាតិ បាឋោ ន ទិស្សតិ ។ ៣ ឱ. ខត្តី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតិ ។ ម. ខត្តិយី វា ។ ល ។ សុទ្ទី វាតិ ។ ៤ ឱ. ម. កាឡី ។

មានហើយ ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនមែនជាអស្ចារ្យដោយពិតទេ ។

[១០២] ម្នាលបោដ្ឋបាទ ប្រៀបដូចបុរស និយាយយ៉ាងនេះថា ខ្ញុំត្រូវការចង់បាននូវនាងជនបទកល្យាណី[១] ក្នុងជនបទនេះ ពួកជនសួរទៅបុរសនោះ យ៉ាងនេះថា នែបុរសអើយ អ្នកត្រូវការចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់នូវនាងជនបទកល្យាណីនោះថា ជាក្សត្រិយានី ព្រាហ្មណី វេស្សី ឬសុទ្ទីដែរឬ ។ បុរសនោះលុះពួកជនសួរយ៉ាងនេះហើយ ប្រាប់ថា មិនស្គាល់ទេ ជនទាំងឡាយសួរទៅបុរសនោះយ៉ាងនេះទៀតថា នែបុរសអើយ អ្នកប្រាថ្នា ចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់នូវនាងជនបទកល្យាណីនោះថា មានឈ្មោះយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ ខ្ពស់ទាប ឬយ៉ាងកណ្តាល មានសម្បុរខ្មៅ សម្បុរខ្មៅស្រឯម ឬសម្បុរខ្មៅស្រស់ ក្នុងស្រុកឬនិគម ឬក៏ក្នុងនគរឯណោះដូច្នេះដែរឬ ។ បុរសនោះលុះពួកជនសួរយ៉ាង

១ ស្ត្រីដែលល្អឆ្នើមក្នុងជនបទ ។

វទេយ្យ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តំ ត្វំ ឥច្ឆសិ កាមេសីតិ ។ ឥតិ បុដ្ឋោ អាមាតិ[១] វទេយ្យ ។ តំ កឹ មញ្ញសិ ចោដ្ឋចាទ ននុ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវ-មេវ ខោ ចោដ្ឋចាទ យេ តេ សមណព្រាហ្មណា ឯវំ-វាទិនោ ឯវំទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរម្មរណាតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរម្មរណាតិ ។ តេ ចេ មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ អបិច

១ ឱ. អាមោតិ ។

នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ជនទាំងឡាយ សួរទៅបុរសនោះ យ៉ាងនេះទៀតថា នែបុរសអើយ អ្នកឯងមិនស្គាល់ មិនឃើញនូវស្ត្រីណាហើយ ប្រាថ្នាចង់បាននូវស្ត្រីនោះដែរឬ ។ បុរសនោះលុះពួកជនសួរយ៉ាងនេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ សំដីរបស់បុរសនោះមិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ សំដីរបស់បុរសនោះមិនជាអស្ចារ្យដោយពិត ។ ម្នាលបោដ្ឋបាទ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខបន្ទាប់ អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះហើយសួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ បានឮថា អ្នកទាំងឡាយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខបន្ទាប់ អំពីសេចក្តីស្លាប់ទៅដូច្នេះពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើតថាគតសួរយ៉ាងនេះហើយ ប្តេជ្ញាថា ករុណាពិតមែន តថាគត សួរទៅសមណព្រាហ្មណ៍ទាំងនោះ

បន តុម្ហេ អាយស្មន្តោ ឯកន្តសុខំ លោកំ ជានំ បស្សំ វិហរថាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ ឯកំ វា រត្តឹ ឯកំ វា ទិវសំ ឧបឌ្ឍំ វា រត្តឹ ឧបឌ្ឍំ វា ទិវសំ ឯកន្តសុខឹ អត្តានំ សម្បជានថាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ ជានាថ អយំ មគ្គោ អយំ បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ យា តា ទេវតា ឯកន្តសុខំ លោកំ ឧបបន្នា តាសំ ភាសមានានំ សទ្ទំ សុណាថ សុប្បដិបន្នត្ថ មារិសា ឧជុប្បដិបន្នត្ថ មារិសា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយ

យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបាន ដឹង បានឃើញថាលោកមានសេចក្តីសុខតែម្យ៉ាងដែរឬ ។ សមណព្រាហ្ម-ណ៍ ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយក៏ឆ្លើយថា មិនដឹង មិនឃើញ ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នក ទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយចាំបាននូវខ្លួន ដែលមានសេច-ក្តីសុខតែម្យ៉ាងអស់យប់មួយ ថ្ងៃមួយ ឬ អស់ត្រឹមតែកន្លះយប់កន្លះថ្ងៃដូច្នេះ ដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាង នេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយស្គាល់ថា នេះជាមគ្គ នេះជាបដិបទា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាងដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំង នោះ លុះតថាគតសួរយ៉ាងនេះហើយ ឆ្លើយថា មិនស្គាល់ទេ តថាគត សួរទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំង-ឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបានឮសំឡេងរបស់ពួកទេវតាដែល កើតក្នុងលោក ដែលមានសេចក្តីសុខតែមួយយ៉ាង និយាយប្រាប់ថា នែ គ្នាយើងទាំងឡាយ ចូរអ្នកប្រតិបត្តិដោយល្អទៅ នែគ្នាយើងទាំងឡាយ ចូរអ្នកប្រតិបត្តិដោយត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមាន

មយំបិ ហិ មារិសា ឯវំបដិបន្នា ឯកន្តសុខំ លោកំ ឧបបន្នាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ ននុ ឯវំ សន្តេ តេសំ សមណព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តេសំ សមណព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

[១០៣] សេយ្យថាបិ បោដ្ឋបាទ បុរិសា ចាតុម្មហាបថេ និស្សេណឹ ករេយ្យ បាសាទស្ស អារោហណាយ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យស្ស ត្វំ បាសាទស្ស អារោហណាយ និស្សេណឹ ករោសិ ជានាសិ តំ បាសាទំ បុរត្ថិមាយ វា ទិសាយ ទក្ខិណាយ វា ទិសាយ បច្ឆិមាយ វា ទិសាយ ឧត្តរាយ វា ទិសាយ ឧច្ចោ វា នីចោ វា មជ្ឈោ វាតិ ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តស្ស ត្វំ បាសាទស្ស អារោហណាយ និស្សេណឹ ករោសីតិ ។ ឥតិ បុដ្ឋោ អាមាតិ វទេយ្យ ។

សេចក្តីសុខតែមួយយ៉ាង នៃគ្នាយើងទាំងឡាយ ព្រោះថាបើពួកយើងទាំង-ឡាយប្រតិបត្តិយ៉ាងនេះហើយ នឹងទៅកើត ក្នុងលោក ដែលមានសេចក្តីសុខតែមួយយ៉ាងដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថា-គត សួរយ៉ាងនេះហើយឆ្លើយថា មិនបានឮទេ ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ភាសិតរបស់សមណ-ព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យដោយពិតទេ ។

[១០៣] ម្នាលបោដ្ឋបាទ ពុំនោះសោត ប្រៀបដូចបុរសធ្វើជណ្តើរក្នុងផ្លូវធំទាំង ៤ បម្រុងនឹងឡើងទៅកាន់ប្រាសាទ ជនទាំងឡាយ សួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរបម្រុងនឹងឡើងទៅកាន់ប្រាសាទណា អ្នកស្គាល់ប្រាសាទនោះថា នៅក្នុងទិសខាងកើត ឬខាងត្បូង ខាងលិចឬខាងជើង ជាប្រាសាទខ្ពស់ទាប ឬយ៉ាងកណ្តាលដែរឬ ។ បុរសនោះដែលគេសួរដូច្នេះហើយ ក៏ប្រាប់ថា មិនស្គាល់ទេ ពួកជនក៏សួរទៅបុរសនោះ យ៉ាងនេះទៀតថា នែបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរបម្រុងនឹងឡើងទៅកាន់ ប្រាសាទដែលខ្លួនមិនស្គាល់ មិនឃើញបានដែរឬ ។ បុរសនោះ លុះគេសួរដូច្នេះហើយ ក៏ប្រាប់ថា បាទ ។

តំ កឹ មញ្ញសិ ពោដ្ឋបាទ ឥធ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ ពោដ្ឋបាទ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរំ មរណាតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកន្តសុខី អត្តា ហោតិ អរោគោ បរំ មរណាតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ ឯកន្តសុខំ លោកំ ជានំ បស្សំ វិហរថាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិច បន តុម្ហេ អាយស្មន្តោ ឯកំ វា រត្តឹ ឯកំ វា ទិវសំ

ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះ មានហើយ សំដីរបស់បុរសនោះ មិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះ មានហើយ សំដីរបស់បុរសនោះមិនជាអស្ចារ្យដោយពិតទេ ។ ម្នាលបោដ្ឋបាទ មានឧបមេយ្យ ដូចពួកសមណ-ព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ បានឮថាអ្នកទាំងឡាយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើតថាគតសួរដូច្នេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏សួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ បានដឹងបានឃើញថា លោកមានសេចក្តីសុខតែម្យ៉ាងដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយឆ្លើយថា ទេ តថាគត សួរទៅសមណព្រាហ្មណ៍ ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយចាំបាននូវខ្លួន ដែលមានសេចក្តីសុខតែមួយយ៉ាង អស់យប់មួយថ្ងៃមួយ

១៤៣

បោដ្ឋបាទសុត្តេ សមណព្រាហ្មណានំ ទិដ្ឋិកថា

ឧបឌ្ឍំ វា រត្តឹ ឧបឌ្ឍំ វា ទិវសំ ឯកន្តសុខឹ អត្តានំ សម្បជានថាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិ ច បន តុម្ហេ អាយស្មន្តោ ជា-នាថ អយំ មគ្គោ អយំ បដិបទា ឯកន្តសុខស្ស លោ-កស្ស សច្ឆិកិរិយាយាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ត្យាហំ ឯវំ វទាមិ អបិ ច បន តុម្ហេ អាយស្មន្តោ យា តា ទេវតា ឯកន្តសុខំ លោកំ ឧបបន្នា តាសំ ភា-សមានានំ សទ្ទំ សុណាថ សុប្បដិបន្នត្ថ មារិសា ឧ-ជុប្បដិបន្នត្ថ មារិសា ឯកន្តសុខស្ស លោកស្ស សច្ឆិ-កិរិយាយ មយំបិ ហិ មារិសា ឯវំបដិបន្នា ឯកន្តសុខំ លោកំ ឧបបន្នាតិ ។ ឥតិ បុដ្ឋា នោតិ វទន្តិ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ ននុ ឯវំ សន្តេ តេសំ សមណ-ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

ឬត្រឹមតែកន្ទះយប់កន្ទះថ្ងៃដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ក៏ឆ្លើយថា ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយស្គាល់ថា នេះជាមគ្គ នេះជាបដិបទា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានសេចក្តីសុខតែមួយយ៉ាងដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ក៏ឆ្លើយថា ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបានឮសំឡេងរបស់ពួកទេវតា ដែលកើតក្នុងលោក ដែលមានសេចក្តីសុខតែមួយយ៉ាង និយាយប្រាប់ថា ម្នាលគ្នាយើងទាំងឡាយ អ្នកទាំងឡាយចូរប្រតិបត្តិដោយល្អទៅ ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំងឡាយ ប្រតិបត្តិដោយត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាង ម្នាលគ្នាយើងទាំងឡាយ ព្រោះថា បើពួកយើង ប្រតិបត្តិយ៉ាងនេះហើយ នឹងទៅកើតក្នុងលោកដែលមានសេចក្តីសុខតែមួយយ៉ាង ដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគត សួរដូច្នេះហើយឆ្លើយថា ទេ ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្តីនោះថា ដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យទេឬ ។

អញ្ញា ខោ ភន្តេ ឯវំ សន្តេ តេសំ សមណព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

[១០៤] តយោ ខោមេ ចោដ្ឋបាទ អត្តប្បដិលាភា ឱឡារិកោ អត្តប្បដិលាភោ មនោមយោ អត្តប្បដិលាភោ អរូបោ អត្តប្បដិលាភោ ។ កតមោ ច ចោដ្ឋបាទ ឱឡារិកោ អត្តប្បដិលាភោ ។ រូបី ចាតុម្មហាភូតិកោ កវលីការភក្ខោ[១] អយំ ឱឡារិកោ អត្តប្បដិលាភោ ។ កតមោ មនោមយោ អត្តប្បដិលាភោ ។ រូបី មនោមយោ សព្វង្គប្បច្ចង្គី អហីនិន្ទ្រិយោ អយំ មនោមយោ អត្តប្បដិលាភោ ។ កតមោ អរូបោ អត្តប្បដិលាភោ ។ អរូបី សញ្ញាមយោ អយំ អរូបោ អត្តប្បដិលាភោ ។

១ ឱ. កពលីការាហារភក្ខោ ។ ម. កពលីការភក្ខោ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យដោយពិតទេ ។

[១០៤] ម្នាលបោដ្ឋបាទ ការបានទូវអត្តភាពនេះមាន ៣ យ៉ាង គឺ បានទូវឱឡារិកអត្តភាព[១] (អត្តភាពគ្រោតគ្រាត) ១ បានទូវមនោមយ-អត្តភាព[២] (អត្តភាពសម្រេចអំពីចិត្ត) ១ បានទូវអរូបអត្តភាព[៣] (អត្ត-ភាពគ្មានរូប) ១ ។ ម្នាលបោដ្ឋបាទ ចុះការបានទូវឱឡារិកអត្តភាព តើដូចម្តេច ។ កាយដែលមានរូបប្រកបដោយមហាភូតរូប ៤ មានកវលីកា-រាហារជាចំណី នេះឈ្មោះថា ការបានទូវឱឡារិកអត្តភាព ។ ការបានទូវមនោមយអត្តភាពតើដូចម្តេច ។ កាយដែលមានរូបសម្រេចហើយដោយចិត្ត មានអវយវៈតូចធំគ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប នេះឈ្មោះថា ការបានទូវមនោមយអត្តភាព ។ ការបានទូវអរូបអត្តភាព តើដូចម្តេច ។ សត្វដែលមិនមានរូបសម្រេចហើយដោយសញ្ញា នេះឈ្មោះថា ការបានទូវអរូបអត្តភាព ។

---

១ អដ្ឋកថា ថា ឱឡារិកអត្តភាពនោះបានដល់កាមាវចរសត្វ រាប់តាំងអំពីអវិចីរៀងរហូតដល់បរនិម្មិតវសវត្តី ។ ២ មនោមយត្តភាពនោះបានដល់រូបព្រហ្ម ។ ៣ អរូបអត្តភាពនោះបានដល់អរូបព្រហ្ម ។

[១០៤] ឱឡារិកស្សាបិ ខោ អហំ បោដ្ឋបាទ អត្តប្បដិលាភស្ស បហានាយ ធម្មំ ទេសេមិ យថា-បដិបន្នានំ វោ សង្កិលេសិកា ធម្មា បហីយិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ វេបុល្ល-ត្តញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ សិយា ខោ បន តេ បោដ្ឋបាទ ឯវមស្ស សង្កិលេសិកា ធម្មា បហីយិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ វេបុល្លត្តញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ ទុក្ខោ ច[១] វិហារោតិ ។ ន ខោ បនេតំ បោដ្ឋបាទ ឯវំ ទដ្ឋព្វំ ។ សង្កិលេសិកា ចេវ ធម្មា បហីយិស្សន្តិ វោទានិយា ច ធម្មា អភិ-

១ ឱ. ម. ច ខោ ។

បោដ្ឋបាទសូត្រ ការបាននូវឱឡារិកអត្តភាព

[១០៥] ម្នាលបោដ្ឋបាទ តថាគតសំដែងធម៌ដើម្បីឲ្យលះបង់នូវការបានឱឡារិកអត្តភាពចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមហើយ សង្កិលេសិកធម៌[១] ទាំងឡាយ ពួកអ្នកនឹងលះបង់បាន វោទានិយធម៌[២] ទាំងឡាយនឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយ នឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញនិងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថនៅ ។ ម្នាលបោដ្ឋបាទ ប្រសិនបើអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា សង្កិលេសិកធម៌ទាំងឡាយបុគ្គលនឹងលះបង់បាន វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើងបាន បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថនៅ តែការសម្រេចឥរិយាបថនៅ រមែងនាំមកនូវសេចក្តីលំបាក ។ ម្នាលបោដ្ឋបាទ អ្នកមិនគួរយល់ឃើញដំណើរនុ៎ះយ៉ាងនេះឡើយ ។ សង្កិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅផង វោទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាល

១ អដ្ឋកថា ថា បានដល់អកុសលចិត្តុប្បាទ ១២ ។ ២ បានដល់សមថៈនិងវិបស្សនា ។

វឌ្ឍិស្សន្តិ បញ្ញាចារិបូរឹ វេបុល្លត្តញ្ច ឌិដ្ឋេ វ ជម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ ចាមោជ្ជញ្ចេវ ភវិស្សតិ បីតិ ច បស្សទ្ធិ ច សតិ ច សម្បជញ្ញញ្ច សុខោ ច វិហារោ ។

[១០៦] មនោមយស្សបិ ខោ អហំ ចោដ្ឋចាទ អត្តប្បដិលាភស្ស បហានាយ ជម្មំ ទេសេមិ យថាប-ដិបន្នានំ វោ សង្កិលេសិកា ជម្មា បហីយិស្សន្តិ វោទានិយា ជម្មា អភិវឌ្ឍិស្សន្តិ បញ្ញាចារិបូរឹ វេបុល្លត្តញ្ច ឌិដ្ឋេ វ ជម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ សិយា ខោ បន តេ ចោដ្ឋចាទ ឯវមស្ស សង្កិលេសិកា ជម្មា បហីយិស្សន្តិ វោទានិយា ជម្មា អភិវឌ្ឍិស្សន្តិ បញ្ញាចារិបូរឹ វេបុល្លត្តញ្ច ឌិដ្ឋេ វ ជម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ

ឡើងផង បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ ឯបាមោជ្ជៈ បីតិ បស្សទ្ធិ សតិសម្បជញ្ញៈ ការសម្រេចឥរិយាបថនៅជាសុខ ក៏នឹងកើតមានឡើង ។

[១០៦] ម្នាលបោដ្ឋបាទ តថាគតសំដែងធម៌ ដើម្បីឲ្យលះបង់នូវការបាននូវមនោមយអត្តភាពនោះចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញនិងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ ។ ម្នាលបោដ្ឋបាទ ប្រសិនបើអ្នក មានសេចក្តីត្រិះរិះយ៉ាងនេះថា សង្កិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញា ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ

ទុក្ខោ ច វិហារោតិ ។ ន ខោ បនេតំ បោដ្ឋបាទ ឯវំ ទដ្ឋព្វំ ។ សង្កិលេសិកា ចេវ ធម្មា បហីយិស្សន្តិ វោទានិយា ច ធម្មា អភិវឌ្ឍិស្សន្តិ (បេយ្យាលោ) បាមោជ្ជញ្ចេវ ភវិស្សតិ បីតិ ច បស្សទ្ធិ ច សតិ ច សម្បជញ្ញញ្ច សុខោ ច វិហារោ ។

[១០៧] អរូបស្សបិ ខោ អហំ បោដ្ឋបាទ អត្តប្ប-ដិលាភស្ស បហានាយ ធម្មំ ទេសេមិ យថាបដិបន្នានំ វោ សង្កិលេសិកា ធម្មា បហីយិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ វេបុល្លត្តញ្ច ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហ-រិស្សថាតិ ។ (បេយ្យាលោ) បាមោជ្ជញ្ចេវ ភវិស្សតិ បីតិ ច បស្សទ្ធិ ច សតិ ច សម្បជញ្ញញ្ច សុខោ ច វិហារោ ។

[១០៨] បរេ ចេ បោដ្ឋបាទ អម្ហេ ឯវំ បុច្ឆេយ្យុំ កតមោ បន សោ អាវុសោ ឱឡារិកោ អត្តប្បដិលា-ភោ យស្ស តុម្ហេ បហានាយ ធម្មំ ទេសេថ យថា-បដិបន្នានំ វោ សង្កិលេសិកា ធម្មា បហីយិស្សន្តិ

តែការសម្រេចឥរិយាបថនៅ រមែងនាំមកនូវសេចក្តីលំបាក ។ ម្នាលបោដ្ឋ-បាទ អ្នកមិនគួរយល់ឃើញដំណើរនុ៎ះយ៉ាងនេះឡើយ ។ សង្កិលេសិក-ធម៌ទាំងឡាយនឹងសាបសូន្យទៅផង វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះ-ដាលឡើងផង (សេចក្តីបំប្រួញ) បាមោជ្ជៈ បីតិ បស្សទ្ធិ សតិ សម្បជញ្ញៈ ការសម្រេចឥរិយាបថនៅជាសុខ ក៏កើតមានឡើង ។

[១០៧] ម្នាលបោដ្ឋបាទ តថាគតសំដែងធម៌ ដើម្បីឲ្យលះបង់នូវការបាននូវអរូបអត្តភាពនោះចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញនិងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅ ។ (សេចក្តីបំប្រួញ) បាមោជ្ជៈ បីតិ បស្សទ្ធិ សតិ សម្បជញ្ញៈ និងការសម្រេចឥរិយាបថនៅជាសុខ ក៏កើតមានឡើង ។

[១០៨] ម្នាលបោដ្ឋបាទ ប្រសិនបើពួកជនដទៃ សួរយើងយ៉ាងនេះថា ម្នាលអាវុសោ អ្នកទាំងឡាយសំដែងធម៌ថា កាលបើអ្នកទាំង-ឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ

វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ វេ-
បុល្លត្តញ្ច ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា
ឧបសម្បជ្ជ វិហរិស្សថាតិ ។ តេសំ មយំ ឯវំ បុដ្ឋា
ឯវំ ព្យាករេយ្យាម អយំ វា សោ អាវុសោ ឱឡារិកោ
អត្តប្បដិលាភោ យស្ស មយំ បហានាយ ធម្មំ ទេ-
សេម យថាបដិបន្នានំ វោ សង្កិលេសិកា ធម្មា បហី-
យិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ
វេបុល្លត្តញ្ច ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា
ឧបសម្បជ្ជ វិហរិស្សថាតិ ។

[១០៩] បរេ ចេ តុម្ហេ អម្ហេ ឯវំ បុច្ឆេយ្យុំ
កតមោ បន សោ អាវុសោ មនោមយោ អត្តប្បដិ-

វោទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញនិងភាវៈធំទូលាយ នៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបាននូវឱឡារិកអត្តភាពណា ការបាននូវឱឡារិកអត្តភាពនោះ តើដូចម្តេច ។ យើងកាលបើពួកជនទាំងនោះសួរយ៉ាងនេះហើយ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងសំដែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិ-លេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយ នឹងធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយ នៃមគ្គបញ្ញានិងផលបញ្ញា ក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់ នូវការបាននូវឱឡារិកអត្តភាពណា ការបាននូវឱឡារិកអត្តភាពនោះ គឺអត្តភាពប្រកបដោយមហាភូតរូប ៤ នេះឯង ។

[១០៩] ម្នាលបោដ្ឋបាទ ប្រសិនបើពួកជនដទៃសួរពួកយើងយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវមនោមយអត្តភាព

លាភោ ។ (សោយេវ បេយ្យាលោ) ។ កតមោ បន សោ អរូចោ អត្តប្បដិលាភោ យស្ស តុម្ហេ បហាជាយ ជម្មំ ទេសេថ យថាបដិបន្នានំ វោ សង្កិលេសិកា ជម្មា បហីយិស្សន្តិ វោទានិយា ជម្មា អភិវឌ្ឍិស្សន្តិ ។ បេ ។ ឧបសម្បជ្ជ វិហរិស្សថាតិ ។ តំ កឹ មញ្ញសិ ចោដ្ឋចាទ ននុ ឯវំ សន្តេ សប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ សប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

[១១០] សេយ្យថាបិ ខោ[១] ចោដ្ឋចាទ បុរិសោ ជិស្សេណឹ ការេយ្យ ចាសាទស្ស អារោហាជាយ តស្សេវ ចាសាទស្ស ហេដ្ឋា តមេនំ ឯវំ វទេយ្យ អម្ភោ បុរិស យស្ស ត្វំ ចាសាទស្ស អារោហាជាយ ជិស្សេ-ណឹ ករោសិ ជាជាសិ តំ ចាសាទំ បុរត្ថិមាយ វា ទិសាយ ទក្ខិណាយ វា ទិសាយ បច្ឆិមាយ វា ទិសាយ ឧត្តរាយ វា ទិសាយ ឧច្ចោ វា នីចោ វា

១ ឱ. ខោសទ្ទោ ន ទិស្សតិ ។

នោះ តើដូចម្ដេច ។ (សេចក្ដីបំប្រួញដូចគ្នានឹងន័យមុននោះដែរ) អ្នកទាំងឡាយសំដែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង ។ បេ ។ នឹងសម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបាននូវអរូបអត្តភាពណា ការបាននូវអរូបអត្តភាពនោះ តើដូចម្ដេច ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់សេចក្ដីនោះថា ដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ ភាសិត (របស់តថាគត) ប្រកបដោយសេចក្ដីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ភាសិត (របស់ព្រះអង្គ) ប្រកបដោយសេចក្ដីអស្ចារ្យដោយពិត ។

[១១០] ម្នាលបោដ្ឋបាទ ប្រៀបដូចបុរសធ្វើជណ្ដើរ បម្រុងនឹងឡើងកាន់ប្រាសាទ ដាក់ខាងក្រោមប្រាសាទនោះឯង ពួកជនសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកធ្វើជណ្ដើរ បម្រុងនឹងឡើងកាន់ប្រាសាទណា អ្នកស្គាល់ប្រាសាទនោះថា នៅក្នុងទិសខាងកើត ឬទិសខាងត្បូង ទិសខាងលិច ឬទិសខាងជើង ជាប្រាសាទខ្ពស់ទាប

មជ្ឈោ វាតិ ។ សោ ចេ ឯវំ វទេយ្យ អយំ វា សោ អាវុសោ បាសាទោ យស្សាហំ អារោហណាយ និស្សេណឹ ករោមិ តស្សេវ បាសាទស្ស ហេដ្ឋាតិ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ ននុ ឯវំ សន្តេ តស្ស បុរិសស្ស សប្បាដិហីរកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តស្ស បុរិសស្ស សប្បាដិហីរកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ បោដ្ឋបាទ បរេ ចេ អម្ហេ ឯវំ បុច្ឆេយ្យុំ កតមោ បន សោ អាវុសោ ឱឡារិកោ អត្តប្បដិលាភោ ។ បេ ។ កតមោ បន សោ អាវុសោ មនោមយោ អត្តប្បដិលាភោ ។ កតមោ បន សោ អាវុសោ អរូបោ អត្តប្បដិលាភោ យស្ស តុម្ហេ បហានាយ ធម្មំ ទេសេថ យថាបដិបន្នានំ វោ សង្កិលេសិកា ធម្មា បហីយិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ បញ្ញាបារិបូរឹ វេបុល្លត្តញ្ច ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ តេសំ មយំ ឯវំ បុដ្ឋា ឯវំ

ឬយ៉ាងណាលដូច្នេះដែរឬ ។ បើបុរសនោះប្រាប់ពួកជនយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ខ្ញុំធ្វើជណ្តើរបម្រុងនឹងឡើងទៅកាន់ប្រាសាទណា ដាក់ខាងក្រោមប្រាសាទនោះឯង ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់នូវសេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ សំដីរបស់បុរសនោះ ប្រកបដោយសេចក្តីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ សំដីរបស់បុរសនោះ ប្រកបដោយសេចក្តីអស្ចារ្យដោយពិត ។ ម្នាលបោដ្ឋបាទ បើពួកជនដទៃសួរពួកយើងយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវឱឡារិកអត្តភាពនោះ តើដូចម្តេច ។ បេ ។ ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវមនោមយអត្តភាពនោះ តើដូចម្តេច ។ ម្នាលអ្នកទាំងឡាយមានអាយុ អ្នកទាំងឡាយសំដែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញនិងភាវៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញា ក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបាននូវអរូបអត្តភាពណា ការបាននូវអរូបអត្តភាពនោះ តើដូចម្តេច ។ យើងកាលដែលជនទាំងនោះសួរយ៉ាងនេះហើយ

ព្យាករេយ្យាម អយំ វា សោ អាវុសោ អរូបោ អត្តប្បដិលាភោ យស្ស មយំ បហានាយ ។ បេ ។ តំ កឹ មញ្ញសិ បោដ្ឋបាទ ននុ ឯវំ សន្តេ សប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ សប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។

[១១១] ឯវំ វុត្តេ ចិត្តោ ហត្ថិសារីបុត្តោ ភគវន្តំ ឯតទវោច យស្មឹ ភន្តេ សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ មោឃស្ស តស្មឹ សមយេ មនោមយោ អត្តប្បដិលាភោ ហោតិ មោឃោ អរូបោ អត្តប្បដិលាភោ ហោតិ ឱឡារិកោវស្ស[១] អត្តប្បដិលាភោ តស្មឹ សមយេ សច្ចោ ហោតិ យស្មឹ ភន្តេ សមយេ មនោមយោ អត្តប្បដិលាភោ ហោតិ មោឃស្ស តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ មោឃោ អរូបោ អត្តប្បដិលាភោ ហោតិ មនោមយោ[២] អត្តប្បដិលាភោ តស្មឹ សមយេ សច្ចោ ហោតិ

១ ឱ. ឱឡារិកោ អស្ស ។ ម. ឱឡារិកោ វាស្ស ។ ២ ឱ. មនោមយោ អស្ស ។

គប្បីព្យាករយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ការបាននូវអរូប-អត្តភាពនោះគឺសត្វដែលមិនមានរូប សម្រេចដោយសញ្ញានេះឯង ។ បេ ។ ម្នាលបោដ្ឋបាទ អ្នកសំគាល់នូវសេចក្តីនេះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ ភាសិត (របស់តថាគត) ប្រកបដោយសេចក្តីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះ មានហើយ ភាសិតរបស់ព្រះអង្គ ប្រកបដោយសេចក្តីអស្ចារ្យដោយពិត ។

[១១១] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចិត្ត-ហត្ថិសារីបុត្ត ក៏ក្រាបទូលសួរចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវឱឡារិកអត្តភាពក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវមនោមយអត្តភាព ការបាននូវអរូប-អត្តភាពរបស់សត្វនោះ ក៏ទទេសោះសូន្យ គឺខានបាន ក្នុងសម័យនោះ បានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះឬ បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវមនោមយអត្តភាព ក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវឱឡារិកអត្តភាព ការបាននូវអរូបអត្តភាពរបស់សត្វនោះក៏ទទេសោះសូន្យ ក្នុងសម័យនោះ បានត្រឹមតែមនោមយអត្តភាពប៉ុណ្ណោះឬ

យស្មឹ កង្ខេ សមយេ អរូបោ អត្តប្បដិលាភោ ហោតិ មោឃស្ស តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ មោឃោ មនោមយោ អត្តប្បដិលាភោ ហោតិ អរូបោ អត្តប្បដិលាភោ តស្មឹ សមយេ សច្ចោ ហោតីតិ ។ យស្មឹ ចិត្ត សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ មនោមយោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ន ច[១] អរូបោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ឱឡារិកោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ យស្មឹ ចិត្ត សមយេ មនោមយោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ន ច អរូបោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ មនោមយោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ យស្មឹ ចិត្ត សមយេ អរូបោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ

១ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវអរូបអត្តភាព ក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវឱឡារិកអត្តភាព ការបាននូវមនោ-មយអត្តភាព របស់សត្វនោះទទេសោះសូន្យ ក្នុងសម័យនោះ បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចិត្តៈ ការបាននូវឱឡារិកអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាព ទាំងមិនដល់នូវការរាប់ថាបាននូវអរូបអត្តភាពក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែឱឡារិកអត្ត-ភាពប៉ុណ្ណោះ ម្នាលចិត្តៈ ការបាននូវមនោមយអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាននូវឱឡារិកអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវអរូបអត្តភាពទេ ក្នុងសម័យនោះដល់នូវការរាប់ថា បានត្រឹមតែមនោមយអត្តភាពប៉ុណ្ណោះ ម្នាលចិត្តៈ ការបាននូវអរូបអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាននូវឱឡារិក-

១៨៣



ន ច មនោមយោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ អរូបោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ ។

[១១២] សចេ តំ ចិត្ត ឯវំ បុច្ឆេយ្យុំ អហោសិ ត្វំ អតីតមទ្ធានំ ន ត្វំ ន អហោសិ ភវិស្សសិ ត្វំ អនាគតមទ្ធានំ ន ត្វំ ន ភវិស្សសិ អត្ថិ ត្វំ ឯតរហិ ន ត្វំ នត្ថីតិ ។ ឯវំ បុដ្ឋោ ត្វំ ចិត្ត កិន្តិ ព្យាក-រេយ្យាសីតិ ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យុំ អហោ-សិ ត្វំ អតីតមទ្ធានំ ន ត្វំ ន អហោសិ ភវិស្សសិ ត្វំ អនាគតមទ្ធានំ ន ត្វំ ន ភវិស្សសិ អត្ថិ ត្វំ ឯតរហិ ន ត្វំ នត្ថីតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ អហោសាហំ អតីតមទ្ធានំ នាហំ ន អហោសឹ ភវិស្សាមហំ អនាគតមទ្ធានំ នាហំ ន ភវិស្សាមិ អត្ថាហំ ឯតរហិ នាហំ នត្ថីតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

អត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះ ។

[១១២] ម្នាលចិត្តៈ បើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា អ្នកធ្លាប់កើតក្នុងអតីតកាល អ្នកមិនមែនជាមិនធ្លាប់កើតទេ អ្នកនឹងកើតក្នុងអនាគតកាល អ្នកមិនមែនជាមិនកើតទេ អ្នកកើតក្នុងកាលឥឡូវនេះ អ្នកមិនមែនជាមិនកើតទេឬ ។ ម្នាលចិត្តៈ កាលបើគេសួរយ៉ាងនេះហើយ អ្នកគប្បីដោះស្រាយដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើជនទាំងឡាយសួរខ្ញុំព្រះអង្គយ៉ាងនេះថា អ្នកធ្លាប់កើតក្នុងអតីតកាល អ្នកមិនមែនជាមិនធ្លាប់កើតទេ អ្នកនឹងកើតក្នុងអនាគតកាល អ្នកមិនមែនជានឹងមិនកើតទេ អ្នកកើតក្នុងកាលឥឡូវនេះ អ្នកមិនមែនជាមិនកើតទេឬ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ខ្ញុំធ្លាប់កើតក្នុងអតីតកាល ខ្ញុំមិនមែនជាមិនធ្លាប់កើតទេ ខ្ញុំនឹងកើតក្នុងអនាគតកាល ខ្ញុំមិនមែនជានឹងមិនកើតទេ ខ្ញុំកើតក្នុងកាលឥឡូវនេះ ខ្ញុំមិនមែនជាមិនកើតទេ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។

[១១៣] សចេ បន តំ ចិត្ត ឯវំ បុច្ឆេយ្យុំ យោ តេ អហោសិ អតីតោ អត្តប្បដិលាភោ សោយេវ[១] តេ អត្តប្បដិលាភោ សច្ចោ មោឃោ អនាគតោ មោឃោ បច្ចុប្បន្នោ យោ តេ ភវិស្សតិ អនាគតោ អត្តប្បដិលាភោ សោយេវ តេ អត្តប្បដិលាភោ សច្ចោ មោឃោ អតីតោ មោឃោ បច្ចុប្បន្នោ យោ តេ ឯតរហិ បច្ចុប្បន្នោ អត្តប្បដិលាភោ សោយេវ តេ អត្តប្បដិលាភោ សច្ចោ មោឃោ អតីតោ មោឃោ អនាគតោតិ ឯវំ បុដ្ឋោ ត្វំ ចិត្ត កិន្តិ ព្យាករេយ្យាសីតិ ។ សចេ បន មំ ភន្តេ ឯវំ បុច្ឆេយ្យុំ យោ តេ អហោសិ អតីតោ អត្តប្បដិលាភោ សោយេវ តេ អត្តប្បដិលាភោ សច្ចោ មោឃោ អនាគតោ មោឃោ បច្ចុប្បន្នោ យោ តេ[២] ភវិស្សតិ អនាគតោ អត្តប្បដិលាភោ សោយេវ តេ អត្តប្បដិលាភោ សច្ចោ

១ ឱ. ស្វេវ ។ ម. សោ វ ។ ២ ឱ. យោ វា តេ ។

[១១៣] ម្នាលចិត្តៈ បើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា ការបាននូវអតីតអត្តភាពណា របស់អ្នក ការបាននូវអត្តភាពនោះ របស់អ្នកជាសភាវៈពិត ចំណែកអនាគតនិងបច្ចុប្បន្ន ជាការសូន្យទទេ ការបាននូវអនាគតអត្តភាពណា របស់អ្នក ការបាននូវអត្តភាពនោះ របស់អ្នកជាសភាវៈពិត ចំណែកអតីតនិងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវបច្ចុប្បន្នអត្តភាពណា របស់អ្នកក្នុងកាលឥឡូវនេះ ការបាននូវអត្តភាពនោះរបស់អ្នកជាសភាវៈពិត ឯអតីតនិងអនាគត ជាការសោះសូន្យទទេឬ ម្នាលចិត្តៈ កាលដែលគេសួរយ៉ាងនេះហើយ តើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើជនទាំងឡាយសួរខ្ញុំព្រះអង្គយ៉ាងនេះថា ការបាននូវអតីតអត្តភាពណា របស់អ្នក ការបាននូវអត្តភាពនោះ របស់អ្នកជាសភាវៈពិត ចំណែកអនាគតនិងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវអនាគតអត្តភាពណា របស់អ្នក ការបាននូវអត្តភាពនោះ

មោឃោ អតីតោ មោឃោ បច្ចុប្បន្នោ យោ តេ ឯតរហិ បច្ចុប្បន្នោ អត្តប្បដិលាភោ សោយេវ តេ អត្តប្បដិលាភោ សច្ចោ មោឃោ អតីតោ មោឃោ អនាគតោតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យំ យោ ច មេ[១] អហោសិ អតីតោ អត្តប្បដិលាភោ សោយេវ មេ អត្តប្បដិលាភោ តស្មឹ សមយេ សច្ចោ អហោសិ មោឃោ អនាគតោ មោឃោ បច្ចុប្បន្នោ យោ ច មេ ភវិស្សតិ អនាគតោ អត្តប្បដិលាភោ សោយេវ មេ អត្តប្បដិលាភោ តស្មឹ សមយេ សច្ចោ ភវិស្សតិ មោឃោ អតីតោ មោឃោ បច្ចុប្បន្នោ យោ ច មេ ឯតរហិ បច្ចុប្បន្នោ អត្តប្បដិលាភោ សោយេវ មេ អត្តប្បដិលាភោ សច្ចោ មោឃោ អតីតោ មោឃោ អនាគតោតិ ឯវំ បុដ្ឋោ អហំ ភន្តេ ឯវំ ព្យាករេយ្យន្តិ ។

[១១៤] ឯវមេវ ខោ ចិត្ត យស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ មនោមយោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ

១ ឱ. ម. យោ មេ ។

របស់អ្នកជាសភាវៈពិត ចំណែកអតីតនិងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវបច្ចុប្បន្នអត្តភាពណា របស់អ្នកក្នុងកាលឥឡូវនេះ ការបាននូវអត្តភាពនោះរបស់អ្នកជាសភាវៈពិត ឯអតីតនិងអនាគត ជាការសោះសូន្យទទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយ យ៉ាងនេះថា ការបាននូវអតីតអត្តភាពណារបស់ខ្ញុំ ការបាននូវអត្តភាពនោះ របស់ខ្ញុំជាសភាវៈពិត ក្នុងសម័យនោះ ចំណែកអនាគតនិងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវអនាគត-អត្តភាពណារបស់ខ្ញុំ ការបាននូវអត្តភាពនោះ របស់ខ្ញុំជាសភាវៈពិតក្នុងសម័យនោះ ចំណែកអតីតនិងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវបច្ចុប្បន្នអត្តភាព របស់ខ្ញុំក្នុងកាលឥឡូវនេះ ការបាននូវអត្តភាពនោះរបស់ខ្ញុំជាសភាវៈពិត ឯអតីតនិងអនាគត ជាការសោះសូន្យទទេ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។

[១១៤] ម្នាលចិត្តៈ យ៉ាងនោះឯងហើយ ការបាននូវឱឡារិកអត្ត-ភាពក្នុងសម័យណា សម័យនោះ មិនដល់នូវការរាប់ថា បាននូវមនោម-

ន អរូបោ អត្តប្បដិលាភោតិ សង្ខំ គច្ឆតិ ឱឡារិកោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សង្ខំ គច្ឆតិ យស្មឹ ចិត្ត សមយេ មនោមយោ អត្តប្បដិលាភោ ហោតិ ។ បេ ។ យស្មឹ ចិត្ត សមយេ អរូបោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោតិ សង្ខំ គច្ឆតិ ន មនោមយោ អត្តប្បដិលាភោតិ សង្ខំ គច្ឆតិ អរូបោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សង្ខំ គច្ឆតិ ។ សេយ្យថាបិ ចិត្ត គវា ខីរំ ខីរម្ហា ទធិ ទធិម្ហា នវនីតំ នវនីតម្ហា សប្បិ សប្បិម្ហា សប្បិមណ្ឌោ យស្មឹ សមយេ ខីរំ ហោតិ នេវ តស្មឹ សមយេ ទធីតិ សង្ខំ គច្ឆតិ ន ច[១] នវនីតន្តិ សង្ខំ គច្ឆតិ ន ច សប្បីតិ សង្ខំ គច្ឆតិ ន ច សប្បិមណ្ឌោតិ សង្ខំ គច្ឆតិ ខីរំត្វេវ តស្មឹ សមយេ សង្ខំ គច្ឆតិ ។ យស្មឹ សមយេ ទធិ ហោតិ ។ នវនីតំ ហោតិ ។ សប្បិ ហោតិ ។ សប្បិមណ្ឌោ ហោតិ នេវ តស្មឹ សមយេ ខីរន្តិ សង្ខំ គច្ឆតិ

១ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

យអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវអរូបអត្តភាព ក្នុងសម័យនោះ ដល់នូវការរាប់ថាបានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះ ម្នាលចិត្ត: ការបាននូវមនោមយអត្តភាព ។ បេ ។ ម្នាលចិត្ត: ការបាននូវអរូបអត្តភាពក្នុងសម័យណា សម័យនោះក៏មិនដល់នូវការរាប់ថា បាននូវឱឡារិកអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាពទេ ក្នុងសម័យនោះដល់នូវការរាប់ថា បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះ ។ ម្នាលចិត្ត: ប្រៀបដូចទឹកដោះស្រស់ (កើត) អំពីមេគោ ទឹកដោះជូរ (កើត) អំពីទឹកដោះស្រស់ ទឹកដោះខាប់ (កើត) អំពីទឹកដោះជូរ ទឹកដោះរាវ (កើត) អំពីទឹកដោះខាប់ ទឹកដោះថ្លា (កើត) អំពីទឹកដោះរាវ ទឹកដោះស្រស់មានក្នុងសម័យណា សម័យនោះ មិនដល់នូវការរាប់ថា ទឹកដោះជូរ មិនដល់នូវការរាប់ថា ទឹកដោះខាប់ មិនដល់នូវការរាប់ថា ទឹកដោះរាវ មិនដល់នូវការរាប់ថា ទឹកដោះថ្លា ដល់នូវការរាប់ថាត្រឹមតែទឹកដោះស្រស់ប៉ុណ្ណោះ ។ សម័យណាជាទឹកដោះជូរ ។ ជាទឹកដោះខាប់ ។ ជាទឹកដោះរាវ ។ ជាទឹកដោះថ្លា សម័យនោះមិនដល់នូវការរាប់ថា ទឹកដោះស្រស់

១៨៧



ន ឧជីតិ សំខ្យំ គច្ឆតិ ន នវនីតន្តិ សំខ្យំ គច្ឆតិ ន សប្បីតិ សំខ្យំ គច្ឆតិ សប្បិមណ្ឌោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ ។ ឯវមេវ ខោ ចិត្ត យស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ មនោមយោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ន អរូបោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ឱឡារិកោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ ។ យស្មឹ សមយេ ចិត្ត មនោមយោ អត្តប្បដិលាភោ ហោតិ ។ បេ ។ អរូបោ អត្តប្បដិលាភោ ហោតិ នេវ តស្មឹ សមយេ ឱឡារិកោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ ន ច មនោមយោ អត្តប្បដិលាភោតិ សំខ្យំ គច្ឆតិ អរូបោ អត្តប្បដិលាភោត្វេវ តស្មឹ សមយេ សំខ្យំ គច្ឆតិ ។ ឥមា ខោ ចិត្ត លោកសមញ្ញា លោកនិរុត្តិយោ លោកវោហារា លោកប្បញ្ញត្តិយោ យាហិ តថាគតោ វោហរតិ អបរាមសន្តោតិ[១] ។

១ ឱ. អបរាមសន្តិ ។

បោដ្ឋបាទសូត្រ ការបាននូវអត្តភាពមានឱឡារិកអត្តភាពជាដើម

មិនដល់នូវការរាប់ថាទឹកដោះជូរ មិនដល់នូវការរាប់ថាទឹកដោះខាប់ មិនដល់នូវការរាប់ថាទឹកដោះរាវ ក្នុងសម័យនោះដល់នូវការរាប់ត្រឹមតែថាទឹកដោះថ្លាប៉ុណ្ណោះ ។ ម្នាលចិត្តៈ ការបាននូវឱឡារិកអត្តភាព ក្នុងសម័យណា សម័យនោះមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាព មិនដល់នូវការរាប់ថា បាននូវអរូបអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថាបានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះ ។ ម្នាលចិត្តៈ ការបាននូវមនោមយអត្តភាព ។ បេ ។ ការបាននូវអរូបអត្តភាព ក្នុងសម័យណា សម័យនោះមិនដល់នូវការរាប់ថា បាននូវឱឡារិកអត្តភាព មិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថាបានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះ ក៏យ៉ាងនោះឯង ។ ម្នាលចិត្តៈ សំដីទាំងនេះឯង ជាឈ្មោះសម្រាប់លោក ជាភាសាសម្រាប់លោក ជាវោហាររបស់លោក ជាបញ្ញត្តិក្នុងលោក តថាគតរមែងពោលដែរ តែមិនប៉ះពាល់ដោយសេចក្តីប្រកាន់ទេ ។

[១១៩] ឯវំ វុត្តេ ចោដ្ឋបាទោ បរិព្វាជកោ ភគវន្តមេតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។ ចិត្តោ បន ហត្ថិសារីបុត្តោ ភគវន្តមេតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ បដិច្ឆន្នំ ។ បេ ។ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ ចិត្តោ ហត្ថិសារីបុត្តោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ[១] អាយស្មា ហត្ថិសារីបុត្តោ ឯកោ វូបកដ្ឋោ អប្បមត្តោ

---
១ ខោ បន ។

[១១៥] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ បោដ្ឋបាទបរិព្វាជក ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ។ បេ ។ សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់សរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះទៅ ។ ចំណែកខាងចិត្តហត្ថិសារីបុត្ត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចគេបើកនូវរបស់ដែលកំបាំង ។ បេ ។ ទ្រោលបំភ្លឺប្រទីបដោយគិតថា មនុស្សមានភ្នែកភ្លឺ នឹងឃើញរូបទាំងឡាយបាន ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ គួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ចិត្តហត្ថិសារីបុត្តក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ចិត្តហត្ថិសារីបុត្តដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ដោះខ្លួនចេញចាកពួក ជាបុគ្គលតែម្នាក់ឯង ឥតមាន

១៨៩

បោដ្ឋបាទសុត្តេ អាយស្មា ហត្ថិសារីបុត្តោ អរហត្តប្បត្តោ

អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តា-យាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ អាយស្មា ហត្ថិសារីបុត្តោ អរហតំ អហោសីតិ ។

បោដ្ឋបាទសុត្តំ នវមំ និដ្ឋិតំ ។

សេចក្ដីប្រមាទឡើយ ព្យាយាមដុតកិលេស បញ្ជូនចិត្តឲ្យបែរទៅកាន់ (ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈក្នុងបច្ចុប្បន្ន មិនយូរប៉ុន្មាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ បានដឹងច្បាស់ថា ជាតិរបស់អាត្មាអញ អស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញ ក៏បានអប់រំហើយ សោឡសកិច្ច អាត្មាអញ ក៏បានធ្វើរួចហើយ កិច្ចដទៃក្រៅពីនេះទៅទៀតគ្មានឡើយ ។ បណ្ដាព្រះអរហន្តទាំង-ឡាយ ព្រះចិត្តហត្ថិសារីបុត្តមានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។

ចប់ បោដ្ឋបាទសូត្រ ទី ៩ ។

# សុភសុត្តំ ទសមំ

[១១៦] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា អានន្ទោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ អចិរបរិនិព្វុតេ ភគវតិ ។

[១១៧] តេន ខោ បន សមយេន សុភោ មាណវោ តោទេយ្យបុត្តោ សាវត្ថិយំ បដិវសតិ កេនចិទេវ ករណីយេន ។ អថខោ សុភោ មាណវោ តោទេយ្យបុត្តោ អញ្ញតរំ មាណវកំ អាមន្តេសិ ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុភោ មាណវោ តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ

# សុភសូត្រ ទី ១០

[១១៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ មិនទាន់យូរប៉ុន្មាន[១] ព្រះអានន្ទមានអាយុ គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។

[១១៧] សម័យនោះឯង សុភមាណព ជាកូននៃតោទេយ្យព្រាហ្មណ៍ នៅអាស្រ័យក្នុងក្រុងសាវត្ថី ដោយកិច្ចឯណានីមួយ ។ លំដាប់នោះ សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ ហៅមាណពម្នាក់មកថា ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយនឹងព្រះសមណៈឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយឯងចូរនិមន្តថា សូមព្រះ

---

១ ក្នុងអដ្ឋកថា ថា ព្រះមានព្រះភាគ បរិនិព្វាន ទៅបានជាង ១ ខែ ។

១៦១

សុភសុត្តេ មាណវកស្ស អានន្ទត្ថេរស្ស សន្តិកុបសង្កមនំ

សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវំ ភោតិ ខោ សោ មាណវកោ សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស បដិស្សុត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ មាណវកោ អាយស្មន្តំ អានន្ទំ ឯតទវោច សុភោ ខោ មាណវោ តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។

[១១៨] ឯវំ វុត្តេ អាយស្មា អានន្ទោ តំ មាណវកំ ឯតទវោច អកាលោ ខោ មាណវក អត្ថិ មេ អជ្ជ

អានន្ទជាម្ចាស់ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ។ មាណពនោះទទួលពាក្យសុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ថា បាទអ្នកម្ចាស់ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះមាណពនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលស្នើសេចក្តីនេះនឹងព្រះអានន្ទមានអាយុថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ សួរនូវអាការមិនមានអាពាធ មិនមានរោគ ក្រោកទៅមកបានរហ័សរហួនកម្លាំងនិងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទជាម្ចាស់ រួចហើយឲ្យនិមន្តយ៉ាងនេះថា សូមព្រះអានន្ទដ៏ចម្រើន អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់លំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ។

[១១៨] កាលមាណព ពោលពាក្យយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មានថេរវាចាដូច្នេះទៅនឹងមាណពនោះថា ម្នាលមាណព កាលនេះមិនគួរ (នឹងទៅទេ) ដ្បិតថ្ងៃនេះ យើងបានផាន់

ភេសជ្ជមត្តា បីតា អប្បេវនាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយាតិ ។ ឯវំ ភោតិ ខោ សោ មាណវកោ អានន្ទស្ស បដិស្សុត្វា ឧដ្ឋាយាសនា យេន សុភោ មាណវោ តោ-ទេយ្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា សុភំ មាណវំ តោទេយ្យបុត្តំ ឯតទវោច អវោចុម្ហា ខោ មយំ ភោតោ វចនេន តំ ភវន្តំ អានន្ទំ សុភោ មាណវោ តោទេយ្យ-បុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ឯវំ វុត្តេ ភោ សមណោ អានន្ទោ មំ ឯតទវោច អកាលោ ខោ មាណវក អត្ថិ មេ អជ្ជ ភេសជ្ជមត្តា បីតា អប្បេវនាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សម-យញ្ច ឧបាទាយាតិ ឯត្តាវតាបិ ខោ ភោ កតមេវ ឯតំ យតោ ខោ សោ ភវំ អានន្ទោ ឱកាសមកាសិ ស្វាតនាយបិ ឧបសង្កមនាយាតិ ។

ថ្ងៃខ្លះទៅហើយ បើដូច្នោះ ចាំយើងពិចារណានូវកាលនិងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក ។ មាណពនោះទទួលពាក្យព្រះអានន្ទមានអាយុថា ករុណាលោកម្ចាស់ ហើយក្រោកចាកអាសនៈចូលទៅរកសុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងសុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ថា ខ្ញុំបាននិយាយនឹងព្រះអានន្ទដ៏ចម្រើននោះ តាមពាក្យរបស់អ្នករួចហើយថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ សួរនូវអាការមិនមានអាពាធ មិនមានរោគក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយចំពោះព្រះអានន្ទដ៏ចម្រើន ហើយនិមន្តយ៉ាងនេះថា សូមព្រះអានន្ទដ៏ចម្រើនអាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់លំនៅសុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន បពិត្រអ្នកម្ចាស់ កាលដែលខ្ញុំពោលយ៉ាងនេះហើយ ព្រះសមណអានន្ទ បានពោលពាក្យនេះនឹងខ្ញុំថា ម្នាលមាណព កាលនេះមិនគួរ (នឹងទៅទេ) ដ្បិតថ្ងៃនេះយើងបានឆាន់ថ្នាំខ្លះទៅហើយ បើដូច្នោះចាំយើងពិចារណា នូវកាលនិងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក បពិត្រអ្នកម្ចាស់ ព្រះអានន្ទដ៏ចម្រើននោះ បានធ្វើឱកាសដើម្បីនិមន្តមកឆាន់ក្នុងថ្ងៃស្អែក ដោយកិច្ចណា កិច្ចនេះខ្ញុំបានធ្វើសម្រេចហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

១៦៣

សុភសុត្តេ អានន្ទត្ថេរស្ស សុភមាណវនិវេសនុបសង្កមនំ

[១១៩] អថខោ អាយស្មា អានន្ទោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ចេតកេន ភិក្ខុនា បច្ឆាសមណេន យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សុភោ មាណវោ តោទេយ្យបុត្តោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុភោ មាណវោ តោទេយ្យបុត្តោ អាយស្មន្តំ អានន្ទំ ឯតទវោច ភវញ្ហិ អានន្ទោ តស្ស ភោតោ គោតមស្ស ទីឃរត្តំ ឧបដ្ឋាកោ សន្តិកាវចរោ សមីបចារី ភវមេតំ អានន្ទោ ជានេយ្យ យេសំ សោ ភវំ គោតមោ ធម្មានំ វណ្ណវាទី អហោសិ យត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសិ កតមេសានំ ខោ ភោ អានន្ទ ធម្មានំ សោ ភវំ គោតមោ វណ្ណវាទី អហោសិ

សុភសូត្រ ព្រះអានន្ទត្ថេរចូលទៅកាន់លំនៅរបស់សុភមាណព

[១១៩] លុះកន្លងរាត្រីនោះហើយ ព្រះអានន្ទមានអាយុ ទ្រង់ស្បង់និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ មានភិក្ខុ ១ រូបឈ្មោះចេតកៈជាបច្ឆាសមណៈ ក៏ចូលសំដៅទៅត្រង់ទីលំនៅ របស់សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក ។ លំដាប់នោះ សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល នឹងព្រះអានន្ទមានអាយុ លុះបញ្ចប់នូវពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយ ក្នុងទីដ៏សមគួរ ។ លុះសុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលស្នើរឿងនេះ នឹងព្រះអានន្ទមានអាយុថា ព្រះអានន្ទដ៏ចម្រើន ជាឧបដ្ឋាក ជាអ្នកនៅជិតដិត ជាអ្នកបម្រើជិត នៃព្រះគោតមដ៏ចម្រើននោះ អស់កាលជាអង្វែង ព្រះអានន្ទដ៏ចម្រើនគួរនឹងដឹងរឿងនុ៎ះ ព្រះគោតមដ៏ចម្រើននោះ បានពោលសរសើរធម៌ទាំងឡាយណា ទាំងណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋានក្នុងធម៌ទាំងឡាយណា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះគោតមដ៏ចម្រើននោះ បានពោលសរសើរធម៌ទាំងឡាយ

កាត្វ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសីតិ ។ តិណ្ណំ ខោ មាណវក[១] ខន្ធានំ សោ ភគវា វណ្ណវាទី អហោសិ ឯត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសិ កតមេសំ តិណ្ណំ អរិយស្ស សីលក្ខន្ធស្ស អរិយស្ស សមាធិក្ខន្ធស្ស អរិយស្ស បញ្ញាខន្ធស្ស ឥមេសំ ខោ មាណវក[២] តិណ្ណំ ខន្ធានំ សោ ភគវា វណ្ណវាទី អហោសិ ឯត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសីតិ ។

[១៦០] កតមោ បន សោ ភោ អានន្ទ អរិយោ សីលក្ខន្ធោ យស្ស សោ ភវំ គោតមោ វណ្ណវាទី អហោសិ យត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសីតិ ។ ឥធ មាណវ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ ។ បេ ។ សោ ឥមំ លោកំ សទេវកំ សមារកំ ។ បេ ។ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា

---

១-២ ឱ. មាណវ ។

នោះដូចម្តេចខ្លះ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន ក្នុងធម៌ដូចម្តេចខ្លះ ។ ព្រះអានន្ទ តបថា ម្នាលមាណព ព្រះមានព្រះភាគនោះ ព្រះអង្គបានពោលសរសើរខន្ធ ៣ យ៉ាង ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន ក្នុងខន្ធទាំង ៣ យ៉ាងនុ៎ះ ខន្ធទាំង ៣ យ៉ាងនោះ តើដូចម្តេចខ្លះ គឺ អរិយសីលក្ខន្ធ ១ អរិយសមាធិក្ខន្ធ ១ អរិយបញ្ញាខន្ធ ១ ម្នាលមាណព ព្រះមានព្រះភាគនោះ ព្រះអង្គបានពោលសរសើរខន្ធទាំង ៣ យ៉ាងនេះឯង ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន ក្នុងខន្ធទាំង ៣ យ៉ាងនេះ ។

[១២០] សុភមាណពទូលសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយសីលក្ខន្ធដែលព្រះគោតមដ៏ចម្រើននោះ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាននោះ តើដូចម្តេច ។ ព្រះអានន្ទតបថា ម្នាលមាណព ព្រះតថាគតកើតឡើង ក្នុងលោកនេះ បានជាអរហន្តសម្មាសម្ពុទ្ធបរិបូណ៌ ដោយវិជ្ជានិងចរណៈ ។ បេ ។ ព្រះអង្គញុំាងលោកនេះ ព្រមទាំងទេវលោកមារលោក ។ បេ ។ ព្រះអង្គទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ។ គហបតីក្តី កូនរបស់គហបតីក្តី ឬបុគ្គល

១៦៤

សុភសុត្តេ តថាគតសទ្ធាបដិលាភោ

កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ សោ តេន សទ្ធាបដិលាភេន ស-មន្នាគតោ ឥតិបិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិ-ខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហា-រេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគា-រិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិ-វដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។ សោ ឯវំ បព្វជិតោ សមានោ ចាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយ-ទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ កាយ-កម្មវចីកម្មេន សមន្នាគតោ កុសលេន បរិសុទ្ធាជីវោ

កើតក្នុងត្រកូលឯណានីមួយ ជាខាងក្រោយក្តី ស្តាប់នូវធម៌នោះ លុះបុគ្គលនោះ ស្តាប់នូវធម៌នោះហើយ រមែងបាននូវសទ្ធា ក្នុងព្រះតថាគត លុះបុគ្គលនោះ ប្រកបដោយការបាននូវសទ្ធានេះហើយ រមែងពិចារណាឃើញច្បាស់ថា ឃរាវាសចង្អៀតចង្អល់ ជាផ្លូវហូរមកនៃធូលីគឺកិលេស បព្វជ្ជាទើបមានឱកាសទំនេរ បុគ្គលដែលនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ពេញលេញ ឲ្យបរិសុទ្ធពេញលេញ ដូចស័ង្ខដែលគេខាត់ហើយនោះទេ បើដូច្នោះមានតែ អាត្មាអញកោរសក់និងពុកមាត់ ពុកចង្ការួចហើយ ស្លៀកដណ្តប់នូវសំពត់ជ្រលក់អម្ចត់ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះកាលជាខាងក្រោយមក បុគ្គលនោះលះបង់គំនរភោគៈតិចក្តី លះបង់គំនរភោគៈច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី កោរសក់និងពុកមាត់ ពុកចង្ការួចហើយ ស្លៀកដណ្តប់សំពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ កាលបើបុគ្គលនោះបួស យ៉ាងនេះហើយ ក៏សង្រួមក្នុងបាតិមោក្ខសំវរសីល ប្រកបដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំង-ឡាយ ប្រកបដោយកាយកម្មនិងវចីកម្មជាកុសល មានអាជីវៈដ៏បរិសុទ្ធ

សីលសម្បន្នោ ឥន្ទ្រិយេសុ គុត្តទ្វារោ សតិសម្ប-
ជញ្ញេន សមន្នាគតោ សន្តុដ្ឋោ ។

[១២១] កថញ្ច មាណវ ភិក្ខុ សីលសម្បន្នោ ហោតិ ឥធ មាណវ ភិក្ខុ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិ-តសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុ-កម្បី វិហរតិ ។ យំបិ មាណវ ភិក្ខុ បាណាតិ-បាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបា-ណភូតហិតានុកម្បី វិហរតិ ឥទម្បិស្ស ហោតិ សីលស្មឹ (តតោ បរំ សព្វំ វិត្ថារេតព្វំ) ។ បេ ។

[១២២] យថា វា បនេកេ ភោន្តោ សមណ-ព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ

បរិបូណ៌ដោយសីល រក្សានូវទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ប្រកបដោយសតិសម្បជញ្ញៈ ជាអ្នកសន្តោស ។

[១៦១] ម្នាលមាណព ចុះភិក្ខុជាអ្នកបរិបូណ៌ដោយសីល តើដូចម្តេច ម្នាលមាណព ភិក្ខុក្នុងសាសនានេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកមានគ្រឿងវាយសំពង់ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ។ ម្នាលមាណព ភិក្ខុលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកមានគ្រឿងវាយសំពង់ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ដោយអំពើណា អំពើនេះឯងជាសីល របស់ភិក្ខុនោះ (សីលទាំងពួងក្រៅអំពីនោះ បណ្ឌិតគប្បីសំដែងឲ្យពិស្តារផងចុះ) ។ បេ ។

[១៦២] មួយយ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យ ដោយសទ្ធាហើយ តែសមណ-

១៦៧

សុភសុត្តេ តិរច្ឆានវិជ្ជាយ មិច្ឆាជីវោ

ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សន្តិកម្មំ បណិធិកម្មំ ភូមិកម្មំ ភូរិ-កម្មំ វស្សកម្មំ វោស្សកម្មំ វត្ថុកម្មំ វត្ថុបរិការណំ អាចមនំ នហាបនំ ជុហានំ[១] វមនំ វិរេចនំ ឧទ្ធវិរេចនំ អធោវិរេចនំ សីសវិរេចនំ កណ្ណតេលំ នេត្តប្បានំ នត្ថុ-កម្មំ អញ្ជនំ បច្ចញ្ជនំ សាលាកិយំ សល្លកត្តិយំ ទារកតិកិច្ឆំ[២] មូលភេសជ្ជានំ អនុប្បទានំ ឱសធីនំ បដិមោក្ខោ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជា-យ មិច្ឆាជីវា បដិវិរតោ ហោតិ ។ យំបិ មាណវ ភិក្ខុ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា

---

១ ប. ជូហានំ ។ ២ ម. ទារកតិកិច្ឆា ។

ព្រាហ្មណ៍ទាំងនោះ តែងចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះ តើដូចម្តេច ។ គឺវិធីបន់ស្រន់ខ្លះ វិធីលាបំណន់ខ្លះ វិធីធ្វើប្រយោគមន្តដែលបុគ្គលនៅក្នុងភូមិផ្ទះគួររៀនខ្លះ វិធីធ្វើមនុស្សខ្ទើយឲ្យដូចជាមនុស្សប្រុសខ្លះ វិធីធ្វើមនុស្សប្រុសឲ្យដូចជាមនុស្សខ្ទើយខ្លះ វិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ វិធីធ្វើពលីកម្មចំពោះសំណង់ផ្ទះខ្លះ វិធីជម្រះមុខឲ្យស្អាតដោយទឹកខ្លះ វិធីស្រោចទឹកបង្កក់ប្រសិទ្ធិឲ្យជនដទៃខ្លះ វិធីបូជាភ្លើងខ្លះ វិធីផ្សំថ្នាំក្អួតខ្លះ វិធីផ្សំថ្នាំបញ្ចុះខ្លះ វិធីផ្សំថ្នាំកំចាត់បង់នូវទោសខាងលើ មានប្រមាត់ជាដើមខ្លះ វិធីផ្សំថ្នាំកំចាត់បង់នូវទោសខាងក្រោម មានបំពង់បស្សាវៈជាដើមខ្លះ វិធីផ្សំថ្នាំកំចាត់បង់នូវទោសក្នុងក្បាលនាំចេញនូវស្លេស្មជាដើមខ្លះ វិធីស្លប្រេងបន្តក់ត្រចៀកខ្លះ វិធីស្លប្រេងសម្រាប់ស្អំភ្នែកខ្លះ វិធីផ្សំថ្នាំសម្រាប់ហិតខ្លះ វិធីផ្សំថ្នាំសម្រាប់បន្តក់ភ្នែកខ្លះ វិធីផ្សំថ្នាំត្រជាក់សម្រាប់លាបភ្នែកខ្លះ វិធីធ្វើវេជ្ជកម្មរក្សាភ្នែកខ្លះ វិធីធ្វើកម្មរបស់ពេទ្យវះខ្លះ វិធីធ្វើពេទ្យរក្សាកូនក្មេងខ្លះ វិធីឲ្យកំលាំងថ្នាំក្រោយដល់ថ្នាំមុនខ្លះ វិធីលាងថ្នាំដើម[១] ចេញខ្លះ ។ ភិក្ខុវៀរស្រឡះ ចាកការចិញ្ចឹមជីវិតខុស ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ ម្នាលមាណព ដូចជាសមណព្រាហ្មណ៍

---

១ អដ្ឋកថា ថា កាលបើមានរោគដំបៅ ដាក់ថ្នាំមានថ្នាំផ្សាជាដើមក្នុងដំបៅនោះ កាលបើដំបៅស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សន្តិកម្មំ បណិធិកម្មំ ។ បេ ។ ឱសធីនំ បដិមោក្ខោ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ឥទម្បិស្ស[១] ហោតិ សីលស្មឹ ។ ស ខោ[២] សោ មាណវ ភិក្ខុ ឯវំ សីលសម្បន្នោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ សីលសំវរតោ ។ សេយ្យថាបិ មាណវ រាជា ខត្តិយោ មុទ្ធាវសិត្តោ និហតបច្ចាមិត្តោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ បច្ចត្ថិកតោ ឯវមេវ ខោ មាណវ ភិក្ខុ ឯវំ សីលសម្បន្នោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ សីលសំវរតោ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ ឯវំ ខោ មាណវ ភិក្ខុ

---

១ ម. ឥទមស្ស ។ ២ ម. អយំ ខោ ។

ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះ តើដូចម្តេច ។ វិធីបន់ស្រន់ខ្លះ វិធីលាបំណន់ខ្លះ ។ បេ ។ វិធីលាងថ្នាំដើមចេញខ្លះ ។ ភិក្ខុវៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ព្រោះតែតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ដោយប្រការដូច្នេះ ដោយអំពើណា អំពើនេះឯង ជាសីលរបស់ភិក្ខុនោះដែរ ។ ម្នាលមាណព ភិក្ខុនោះឯងបានបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនឃើញនូវភ័យ អំពីទីណាមួយ ដែលកើតអំពីសេចក្តីសង្រួមក្នុងសីលឡើយ ។ ម្នាលមាណព ប្រៀបដូចព្រះបរមក្សត្រិយ៍ដែលបានមុទ្ធាភិសេកជាស្តេចហើយ បានកំចាត់បង់នូវសត្រូវអស់ហើយ រមែងមិនឃើញនូវភ័យអំពីទីណាមួយ ដែលកើតអំពីសត្រូវឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនឃើញនូវភ័យអំពីទីណាមួយ ដែលកើតអំពីសេចក្តីសង្រួមក្នុងសីលដូច្នោះឯង ។ ភិក្ខុនោះប្រកបព្រមដោយអរិយសីលក្ខន្ធនេះហើយ រមែងទទួលសេចក្តីសុខឥតមានទោសក្នុងសន្តាននៃខ្លួន ។ ម្នាលមាណព ភិក្ខុជាអ្នក

## សុភសុត្តេ សីលសម្បទា

សីលសម្បន្នោ ហោតិ ។ អយំ ខោ សោ មាណវ អរិយោ សីលក្ខន្ធោ យស្ស សោ ភគវា វណ្ណវាទី អហោសិ ឯត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសិ អត្ថិ ចេវេត្ថ ឧត្តរឹ ការណីយន្តិ ។ អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ សោ ចាយំ ភោ អានន្ទ អរិយោ សីលក្ខន្ធោ បរិបុណ្ណោ នោ អបរិបុណ្ណោ ឯវំ បរិបុណ្ណញ្ចាហំ ភោ អានន្ទ អរិយំ សីលក្ខន្ធំ ឥតោ ពហិទ្ធា អញ្ញេសុ សមណព្រាហ្មណេសុ ន សមនុបស្សាមិ ។ ឯវំ បរិបុណ្ណញ្ច ភោ អានន្ទ អរិយំ សីលក្ខន្ធំ ឥតោ ពហិទ្ធា អញ្ញេ សមណព្រាហ្មណា អត្តនិ សមនុបស្សេយ្យុំ តេ តាវតកេនេវ អត្តមនា អស្សុ អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ការណីយន្តិ ។ អថ ច បន ភវំ អានន្ទោ ឯវមាហ អត្ថិ ចេវេត្ថ ឧត្តរឹ ការណីយន្តិ ។

បរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលមាណព នេះឯងជាអរិយ-សីលក្ខន្ធ ដែលព្រះមានព្រះភាគ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះ ឲ្យតាំងនៅ ឲ្យប្រតិស្ឋាន កិច្ចដែលគួរធ្វើតទៅក្នុងសាសនានេះនៅមានទៀត ។ សុភមាណពពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះជាអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះមិនធ្លាប់មានបែរជាមានបាន បពិត្រព្រះអានន្ទដ៏ចម្រើន ក៏អរិយ-សីលក្ខន្ធនោះ បរិបូណ៌ហើយ មិនមែនជាមិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាមិនដែលឃើញនូវអរិយសីលក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងពួកសមណៈដទៃខាងក្រៅព្រះពុទ្ធសាសនានេះទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ពួកសមណៈដទៃខាងក្រៅព្រះពុទ្ធសាសនានេះ គង់បានឃើញអរិយសីលក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះក្នុងខ្លួនដែរ តែសមណព្រាហ្មណ៍ទាំងនោះ ពេញចិត្តដោយគុណត្រឹមតែសីលក្ខន្ធប៉ុណ្ណោះថា ល្មមហើយដោយគុណ មានប្រមាណប៉ុណ្ណោះ សម្រេចហើយដោយគុណមានប្រមាណប៉ុណ្ណោះ ប្រយោជន៍នៃសាមញ្ញគុណ យើងបានដល់ដោយលំដាប់ហើយ កិច្ចនីមួយដែលយើងទាំងឡាយគប្បីធ្វើតទៅ មិនមានឡើយ ។ ចំណែកព្រះអានន្ទដ៏ចម្រើនពោលយ៉ាងនេះថា កិច្ចដែលគួរធ្វើតទៅក្នុងសាសនានេះនៅមានទៀត ។

[១៦៣] កថញ្ច បន សោ ភោ អានន្ទ អរិយោ សមាធិក្ខន្ធោ យស្ស សោ ភវំ គោតមោ វណ្ណវាទី អហោសិ យត្ថ ច ឥមំ ជនតំ សមាទបេសិ និវេ- សេសិ បតិដ្ឋាបេសីតិ ។ កថញ្ច បន មាណវ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ មាណវ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជន- គ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្ស- វេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នា- នុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំ- វុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។

[១២៣] បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយសមាធិក្ខន្ធ ដែលព្រះគោតមដ៏ចម្រើន ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាននោះ តើដូចម្តេច ។ ម្នាលមាណព ចុះភិក្ខុជាអ្នករក្សានូវទ្វារក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ ឃើញនូវរូបារម្មណ៍ដោយចក្ខុហើយ តែមិនបានក្ដួចកាន់នូវនិមិត្ត មិនបានក្ដួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀកហើយ ។ បេ ។ បានធុំក្លិនដោយច្រមុះហើយ ។ បានទទួលរសដោយអណ្តាតហើយ ។ បានពាល់ត្រូវផោដ្ឋព្វារម្មណ៍ដោយកាយហើយ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែមិនក្ដួចកាន់នូវនិមិត្ត មិនក្ដួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមកតែងជាប់តាមនូវបុគ្គល ដែលមិនសង្រួមនូវមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។

សុភសុត្តំ សតិសម្បជញ្ញំ

សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ ឯវំ ខោ មាណវ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

[១២៤] កថញ្ច មាណវ ភិក្ខុ សតិសម្បជញ្ញេន សមន្នាគតោ ហោតិ ។ ឥធ មាណវ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិ-លោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសា-រិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សា-យិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ឯវំ ខោ មាណវ ភិក្ខុ សតិសម្បជញ្ញេន សមន្នា-គតោ ហោតិ ។

ភិក្ខុនោះ បានប្រកបព្រមដោយឥន្ទ្រិយសំវរៈ ដ៏ប្រសើរនេះហើយ រមែង ទទួលនូវអធិចិត្ត សុខដែលមិនបានប្រឡូកប្រឡំ ដោយកិលេស ក្នុង សន្តាននៃខ្លួន ។ ម្នាលមាណព ភិក្ខុជាអ្នករក្សានូវទ្វារ ក្នុងឥន្ទ្រិយទាំង-ឡាយយ៉ាងនេះឯង ។

[១២៤] ម្នាលមាណព ភិក្ខុជាអ្នកប្រកបដោយសតិសម្បជញ្ញៈ តើ ដូចម្ដេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ កាលដើរទៅមុខឬថយ ក្រោយ ក៏មានសេចក្ដីដឹងខ្លួន កាលក្រឡេកមើលទៅមុខ ឬក្រឡេក មើលទៅទិសផ្សេង ៗ (ឆ្វេងស្ដាំ) ក៏មានសេចក្ដីដឹងខ្លួន កាលបត់ដៃជើងឬ លាដៃជើង ក៏មានសេចក្ដីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដីបាត្រនិងចីវរ ក៏ មានសេចក្ដីដឹងខ្លួន កាលបរិភោគភោជនឬផឹកទឹកទំពាស៊ីខាទនីយៈលិទ្ធភ្លក់ នូវភេសជ្ជៈមានសប្បិជាដើម ក៏មានសេចក្ដីដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ក៏មានសេចក្ដីដឹងខ្លួន កាលដើរឬឈរ អង្គុយ ដិតដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀមក៏មានសេចក្ដីដឹងខ្លួន ម្នាលមាណព ភិក្ខុជាអ្នក ប្រកបដោយសតិនិងសម្បជញ្ញៈយ៉ាងនេះឯង ។

[១២៥] កថញ្ច មាណវ ភិក្ខុ សន្តុដ្ឋោ ហោតិ ។ ឥធ មាណវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន សោ យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ សេយ្យថាបិ មាណវ បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោយេវ ឌេតិ ឯវមេវ ខោ មាណវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន សោ យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ ឯវំ ខោ មាណវ ភិក្ខុ សន្តុដ្ឋោ ហោតិ ។

[១២៦] សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ ឥមាយ ច អរិយាយ សន្តុដ្ឋិយា សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ

[១២៥] ម្នាលមាណព ចុះភិក្ខុជាអ្នកសន្តោស តើដូចម្តេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ភិក្ខុនោះកាលបើ ចៀសចេញទៅក្នុងទិសណា ៗ តែងកាន់យក (នូវគ្រឿងបរិក្ខារតែ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅ ម្នាលមាណព ប្រៀបដូចជាសត្វសកុណជាតិដែលមានស្លាប កាលហើរទៅក្នុងទិសណា ៗ រមែងមានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅដូចម្តេចមិញ ម្នាលមាណព ភិក្ខុជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ភិក្ខុនោះកាលបើចេញទៅទិសណា ៗ តែងកាន់យក (នូវគ្រឿងបរិក្ខារតែ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅក៏ដូច្នោះឯង ។ ម្នាលមាណព ភិក្ខុជាអ្នកសន្តោសយ៉ាងនេះឯង ។

[១២៦] ភិក្ខុនោះប្រកបដោយអរិយសីលក្ខន្ធនេះផង ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិសម្បជញ្ញៈ ដ៏ប្រសើរនេះផង ប្រកបដោយសេចក្តីសន្តោសដ៏ប្រសើរនេះផង តែងគប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃឆ្ងាយ ទីវាល គំនរចំបើងឬស្លឹកឈើ ។ ភិក្ខុនោះលុះត្រឡប់ពីបិណ្ឌបាត

១៧៣



និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

[១២៧] សេយ្យថាបិ មាណវ បុរិសោ ឥណំ អាទាយ កម្មន្តេ បយោជេយ្យ តស្ស តេ កម្មន្តា

ក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏អង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខចំពោះ (ទៅរកកម្មដ្ឋាន) ។ ភិក្ខុនោះក៏លះបង់នូវអភិជ្ឈាក្នុងលោកគឺបញ្ចុបាទានក្ខន្ធ មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់នូវព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តឲ្យស្អាតចាកព្យាបាទនិងសេចក្តីប្រទូស្ត លះបង់នូវថីនមិទ្ធៈ គឺសេចក្តីងងុយនិងងោកងក់ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសំគាល់នូវពន្លឺ ជាអ្នកបរិបូណ៌ដោយសតិនិងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយនិងសេចក្តីសោយចិត្ត មានចិត្តមិនរាយមាយ ជាអ្នកមានចិត្តស្ងប់ស្ងាត់ក្នុងសន្តានរបស់ខ្លួន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆា គឺសេចក្តីសង្ស័យ ជាអ្នកឆ្លងផុតវិចិកិច្ឆាហើយ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយទេ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[១២៧] ម្នាលមាណព ដូចជាបុរសដែលយកទ្រព្យជាបំណុលទៅប្រកបការងារទាំងឡាយ ឯការងារទាំងនោះ របស់បុរសនោះក៏បាន

សមិជ្ឈេយ្យុំ ។ សោ យានិ ច បោរាណានិ ឥណាមូលានិ តានិ ច ព្យន្តីករេយ្យ(១) សិយា ចស្ស ឧត្តរឹ អវសិដ្ឋំ ទារភរណាយ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ឥណំ អាទាយ កម្មន្តេ បយោជេសឹ តស្ស តេ មេ កម្មន្តា សមិជ្ឈឹសុ សោហំ យានិ បោរាណានិ ឥណាមូលានិ តានិ ច ព្យន្តីអកាសឹ(២) អត្ថិ ច មេ ឧត្តរឹ អវសិដ្ឋំ ទារភរណាយាតិ ។ សោ តតោនិទានំ លភេថ បាមោជ្ជំ អធិគច្ឆេ(២) សោមនស្សំ ។ សេយ្យថាបិ មាណវ បុរិសោ អាពាធិកោ អស្ស ទុក្ខិតោ ពាឡ្ហគិលានោ ភត្តញ្ចស្ស នច្ឆាទេយ្យ ន ចស្ស កាយេ ពលមត្តា ។ សោ អបរេន សមយេន តម្ហា អាពាធា មុច្ចេយ្យ ភត្តញ្ចស្ស ឆាទេយ្យ សិយា ចស្ស កាយេ ពលមត្តា ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ អាពាធិកោ អហោសឹ ទុក្ខិតោ ពាឡ្ហគិលានោ ភត្តញ្ច មេ នច្ឆាទេសិ ន ច មេ អាសិ កាយេ ពលមត្តា សោម្ហិ ឯតរហិ តម្ហា អាពាធា មុត្តោ

---

១-២ ម. ព្យន្តឹ ករេយ្យ ព្យន្តឹ អកាសឹ ។ ៣ ម. អធិគច្ឆេយ្យ ។ ឯវំ សព្វត្ថ ។

សម្រេច ។ បុរសនោះបានសងទ្រព្យជាដើមបំណុលចាស់រួច ឯទ្រព្យដែលចំណេញរបស់បុរសនោះ ក៏មានសល់នៅច្រើន ល្មមចិញ្ចឹមប្រពន្ធ (កូន)បាន ។ ទើបបុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញ បានយកទ្រព្យជាបំណុលមក ប្រកបការងារទាំងឡាយ ឯការងារទាំងនោះ របស់អាត្មាអញបានសម្រេច អាត្មាអញសោតក៏បានសងទ្រព្យជាដើមបំណុលចាស់អស់ហើយ ទាំងទ្រព្យដែលចំណេញរបស់អាត្មាអញក៏មានសល់នៅច្រើនល្មមចិញ្ចឹមប្រពន្ធ (កូន) បាន ។ បុរសនោះគប្បីបាននូវបាមោជ្ជៈគឺសេចក្តីរីករាយ គប្បីបាននូវសេចក្តីសោមនស្សមានទ្រព្យដែលចំណេញនោះជាហេតុ ។ ម្នាលមាណព មួយទៀត ដូចជាបុរសដែលមានអាពាធ ដល់នូវសេចក្តីទុក្ខវេទនាមានជំងឺធ្ងន់ បរិភោគអាហារក៏មិនបាន ទាំងកម្លាំងក្នុងខ្លួនក៏មិនមាន ។ លុះសម័យជាខាងក្រោយមក បុរសនោះឯងបានជាសះស្បើយអំពីអាពាធនោះ បរិភោគអាហារក៏បាន ទាំងកម្លាំងក្នុងខ្លួនក៏មាន ។ ទើបបុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញមានអាពាធ ដល់នូវសេចក្តីទុក្ខវេទនា មានជំងឺធ្ងន់ បរិភោគអាហារក៏មិនបាន ទាំងកម្លាំងក្នុងខ្លួនក៏មិនមាន ឥឡូវនេះអាត្មាអញបានជាសះស្បើយ អំពីអាពាធនោះហើយ

១៧៤

សុភសុត្តេ  បញ្ចនីវរណូបមា

ភត្តញ្ច មេ ឆាទេសិ អត្ថិ ច មេ កាយេ ពលមត្តាតិ ។ សោ តតោនិទានំ លភេថ ចាមោជ្ជំ អធិគច្ឆេ សោមនស្សំ ។ សេយ្យថាបិ មាណវ បុរិសោ ពន្ធនាគារេ ពទ្ធោ អស្ស សោ អបរេន សមយេន តម្ហា ពន្ធនាគារា មុច្ចេយ្យ សោត្ថិនា អភយេន ន ចស្ស កិញ្ចិ ភោគានំ វយោ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ពន្ធនាគារេ ពទ្ធោ អហោសឹ សោម្ហិ ឯតរហិ តម្ហា ពន្ធនាគារា មុត្តោ សោត្ថិនា អភយេន នត្ថិ ច មេ កិញ្ចិ ភោគានំ វយោតិ ។ សោ តតោនិទានំ លភេថ ចាមោជ្ជំ អធិគច្ឆេ សោមនស្សំ ។ សេយ្យថាបិ មាណវ បុរិសោ ទាសោ អនត្តាធីនោ បរាធីនោ ន យេនកាមង្គមោ ។ សោ អបរេន សមយេន តម្ហា ទាសព្យា មុច្ចេយ្យ អត្តាធីនោ អបរាធីនោ ភុជិស្សោ យេនកាមង្គមោ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ទាសោ អហោសឹ ន អត្តាធីនោ

សុភសូត្រ សេចក្ដីឧបមានៃនីវរណធម៌ទាំង ៥

បរិភោគអាហារក៏បាន ទាំងកម្លាំងក្នុងខ្លួនក៏មាន ។ បុរសនោះគប្បីបាននូវបាមោជ្ជៈ គប្បីបាននូវសោមនស្ស មានជាអំពីអាពាធនេះជាហេតុ ។ ម្នាលមាណព មួយទៀតដូចជាបុរសដែលជាប់គុក លុះសម័យខាងក្រោយមក បុរសនោះបានរួចពីគុកនោះដោយសួស្ដីឥតមានភិតភ័យ ទាំងសេចក្ដីបង់ខាតនៃភោគៈរបស់បុរសនោះ សូម្បីបន្តិចបន្តួចក៏មិនមាន ។ ទើបបុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញជាប់គុក ឥឡូវ-នេះអាត្មាអញបានរួចអំពីគុកនោះដោយសួស្ដីឥតមានភិតភ័យ ទាំងសេចក្ដីបង់ខាតនៃភោគៈរបស់អាត្មាអញសូម្បីបន្តិចបន្តួចក៏មិនមាន ។ បុរសនោះគប្បីបាននូវបាមោជ្ជៈ គប្បីបាននូវសោមនស្ស មានការរួចអំពីគុកនោះជាហេតុ ។ ម្នាលមាណព មួយទៀត ដូចជាបុរសដែលជាទាសៈគេ តែងមិនបានធ្វើការអ្វីមួយ តាមអំពើចិត្តរបស់ខ្លួន ប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ ទៅទីណាតាមសេចក្ដីពេញចិត្តខ្លួន មិនបានទេ ។ លុះសម័យជាខាងក្រោយមក បុរសនោះបានរួចអំពីភាវៈនៃខ្លួន ជាទាសៈគេនោះ ជាអ្នកធ្វើការងារអ្វីមួយតាមអំពើចិត្តរបស់ខ្លួនបាន មិនប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ បានរួចជាអ្នកជា ទៅទីណាតាមសេចក្ដីពេញចិត្តរបស់ខ្លួនក៏បាន ។ បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញជាទាសៈគេ មិនបានធ្វើការអ្វីមួយ តាមអំពើចិត្តរបស់ខ្លួន

បរាធីនោ ន យេនកាមង្គមោ សោម្ហិ ឯតរហិ តម្ហា ទាសព្យា មុត្តោ អត្តាធីនោ អបរាធីនោ ភុជិស្សោ យេនកាមង្គមោតិ ។ សោ តតោនិទានំ លភេថ បាមោជ្ជំ អធិគច្ឆេ សោមនស្សំ ។ សេយ្យថាបិ មាណវ បុរិសោ សធនោ សភោគោ កន្តារទ្ធានមគ្គំ បដិបជ្ជេយ្យ ទុព្ភិក្ខំ សប្បដិភយំ ។ សោ អបរេន សមយេន តំ កន្តារំ និត្ថរេយ្យ សោត្ថិនា គាមន្តំ អនុបាបុណេយ្យ ខេមំ អប្បដិភយំ ។ តស្ស ឯវ-មស្ស អហំ ខោ បុព្វេ សធនោ សភោគោ កន្តា-រទ្ធានមគ្គំ បដិបជ្ជឹ ទុព្ភិក្ខំ សប្បដិភយំ សោម្ហិ ឯតរហិ តំ កន្តារំ និត្តិណ្ណោ សោត្ថិនា គាមន្តំ អនុប្បត្តោ ខេមំ អប្បដិភយន្តិ ។ សោ តតោនិ-ទានំ លភេថ បាមោជ្ជំ អធិគច្ឆេ សោមនស្សំ ។

ប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ ទៅទីណាតាមសេចក្តីពេញចិត្តខ្លួនមិនបានឡើយ ឥឡូវនេះ អាត្មាអញរួចអំពីភាវៈនៃខ្លួន ជាទាសៈគេហើយ ជាអ្នកធ្វើការងារអ្វីមួយ តាមអំពើចិត្តរបស់ខ្លួនបាន មិនប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ បានជាអ្នកជា ទៅទីណាតាមសេចក្តីពេញចិត្តខ្លួនក៏បាន ។ បុរសនោះគប្បីបាននូវបាមោជ្ជៈ បាននូវសោមនស្សមានការរួចអំពីភាវៈនៃខ្លួន ជាទាសៈគេនោះជាហេតុ ។ ម្នាលមាណពមួយទៀត ដូចបុរសដែលមានទ្រព្យ មានភោគៈ ដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ដែលជាផ្លូវរកអាហារបានដោយក្រ ជាផ្លូវប្រកបដោយភ័យ ចំ-ពោះមុខ ។ លុះសម័យខាងក្រោយមក បុរសនោះក៏បានឆ្លងផុតអំពីផ្លូវដាច់ស្រយាលនោះ បានដល់ទៅខាងក្នុងស្រុក ដែលជាទីក្សេមឥតមានកិតភ័យ ដោយសួស្តី ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញសោត ជាអ្នកមានទ្រព្យ មានភោគៈ បានដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ដែលជាផ្លូវរកអាហារបានដោយក្រ ជាផ្លូវប្រកបដោយភ័យចំពោះមុខ ឥឡូវនេះអាត្មាអញបានឆ្លងផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះហើយ បានចូលមកដល់ខាងក្នុងស្រុកដែលជាទីក្សេម ឥតមានកិតភ័យដោយសួស្តី ។ បុរសនោះក៏បាននូវបាមោជ្ជៈ បាននូវសោមនស្សមានការដល់មកខាងក្នុងស្រុក ជាទីក្សេមនោះជាហេតុ យ៉ាងណាមិញ ។

១៧៧

សុភសុត្តេ ឈានកថា ឈានូបមា

ឯវមេវ ខោ មាណវ ភិក្ខុ យថា ឥណំ យថា រោគំ យថា ពន្ធនាគារំ យថា ទាសព្យំ យថា កន្តារទ្ធានមគ្គំ ឥមេ បញ្ច នីវរណេ អប្បហីនេ អត្តនិ សមនុបស្សតិ ។ សេយ្យថាបិ មាណវ យថា អាណណ្យំ យថាអារោគ្យំ យថា ពន្ធនាមោក្ខំ យថា ភុជិស្សំ យថា ខេមន្តភូមឹ ឯវមេវ ភិក្ខុ ឥមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុបស្សតិ តស្សិមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុបស្សតោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស

សុភសូត្រ ការពោលអំពីឈាន សេចក្តីឧបមានៃឈាន

ម្នាលមាណព ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះ ក្នុងខ្លួន ដែលមិនទាន់លះបង់បាន ដូចជាបំណុល ដូចជារោគ ដូចជាគុក ដូចជាអ្នករូបជាអ្នកជា ឬដូចជាផ្លូវឆ្ងាយដាច់ស្រយាល ដូច្នោះឯង ។ ម្នាលមាណព ភិក្ខុដែលពិចារណាឃើញ នូវនីវរណៈទាំង ៥ ប្រការនេះ ក្នុងខ្លួន ដែលលះបង់បានហើយ ដូចជាមិនជំពាក់បំណុល ដូចជាមិនមានរោគ ដូចរួចអំពីគុក ដូចជាអ្នករួចជាអ្នកជា ដូចជាទីដ៏ក្សេមដូច្នោះឯង កាលបើភិក្ខុនោះ ពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះ ក្នុងខ្លួន ដែលលះបង់បានហើយ បាមោជ្ជៈគឺសេចក្តីរីករាយ រមែងកើតឡើង កាលបើភិក្ខុនោះ មានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្ត ប្រកបដោយបីតិហើយ កាយរមែងស្ងប់រម្ងាប់ កាលបើភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ រមែងតាំងខ្ជាប់ ។ ភិក្ខុនោះក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកពួកអកុសលធម៌ហើយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខកើតអំពីសេចក្តីស្ងាត់ សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញុាំងករជកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះឈ្មោះថា មិន

វិវេកជេន បីតិសុខេន អប្ផុតំ ហោតិ ។ សេយ្យថាបិ មាណវ ទក្ខោ នហាបកោ វា នហាបកន្តេវាសី វា កំសថាលេ នហានីយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ សន្នេយ្យ បរិសន្នេយ្យ សាយំ នហានីយបិណ្ឌិ ស្នេហានុគតា ស្នេហបរេតា សន្តរពាហិរា ផុតា ស្នេហេន ន ច បគ្ឃរតិ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំ ហិ មាណវ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្នេតិ បរិសន្នេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុតំ ហោតិ ។ ឥទម្បិស្ស ហោតិ សមាធិស្មិំ ។

បានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ មិនមានឡើយ ។ ម្នាលមាណព ដូចជាងកោរកាត់ក្តី កូនសិស្សរបស់ជាងកោរកាត់ក្តី ដែលជាអ្នកឈ្លាសវៃ រោយរាយនូវលំអិតសម្រាប់ងូត ក្នុងភាជន៍សំរឹទ្ធិ ហើយស្រោច ប្រស់ព្រំដោយទឹក ឯដុំលំអិតសម្រាប់ងូតនោះក៏រលាយទៅដោយទឹក ជ្រួតជ្រាបទៅក្នុងទឹក ប្រឡូកប្រឡំទៅដោយទឹកទាំងខាងក្នុងខាងក្រៅ មិនបានខ្ចាត់ខ្ចាយពីគ្នាឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុបានសម្រេចបឋមជ្ឈានក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុស្ងាត់ចាកកាមទាំងឡាយហើយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ កើតអំពីសេចក្តីស្ងាត់ សម្រាន្តឥរិយាបថនៅ ភិក្ខុនោះតែងញុំាងករជកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់មិនមានឡើយ ដោយអំពើណា ។ អំពើនេះឯង ជាសមាធិរបស់ភិក្ខុនោះ ។

សុភសុត្តេ ឈានកថា ឈានូបមា

[១២៨] បុន ចបរំ មាណវ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិ-ភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កា-យំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយ-ស្ស សមាធិជេន បីតិសុខេន ន អប្ផុតំ ហោតិ ។ សេយ្យថាបិ មាណវ ឧទករហទោ គម្ភីរោ ឧព្ភិតោ-ទកោ តស្ស នេវស្ស បុរត្ថិមាយ ទិសាយ ឧទកស្ស អាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្ស អា-យមុខំ ន បច្ឆិមាយ ទិសាយ ន ឧត្តរាយ ទិសាយ ឧទកស្ស អាយមុខំ ទេវោ បន កាលេន កាលំ សម្មាធារំ អនុប្បវេច្ឆេយ្យ អថខោ តម្ហា ច ឧទក-រហទា សីតា វារិធារា ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស

សុភសូត្រ ការពោលអំពីឈាន សេចក្តីឧបមានៃឈាន

[១២៨] ម្នាលមាណព មួយវិញទៀត ភិក្ខុបានរម្ងាប់វិតក្កៈ វិចារៈ ហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាធម្មជាតជាក់ច្បាស់ក្នុងខ្លួន ប្រកប ដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈ វិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន សម្រាន្តឥរិយា-បថនៅ ។ ភិក្ខុនោះតែងញ៉ាំងករជកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយ ទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបាន ផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិមិនមានឡើយ ។ ម្នាល មាណព ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង ប្រឡាយជាទីហូរនៃ ទឹកក្នុងទិសខាងកើតនៃអន្លង់ទឹកនោះ ក៏មិនមានឡើយ ប្រឡាយជាទី ហូរនៃទឹកក្នុងទិសខាងត្បូង ក៏មិនមាន ប្រឡាយជាទីហូរនៃទឹកក្នុងទិស ខាងលិចក៏មិនមាន ប្រឡាយជាទីហូរនៃទឹក ក្នុងទិសខាងជើង ក៏មិន មាន បើមានភ្លៀងបង្អុរចុះនូវធារទឹក ដោយប្រពៃសព្វ ៗ កាល ធារទឹក ត្រជាក់ ក៏ស្រាប់តែជោរឡើងអំពីអន្លង់ទឹកនោះ ហើយញ៉ាំងអន្លង់ទឹក នោះឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ នេះឯង ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកទាំងអស់នោះ ឈ្មោះថាមិនបាន

សីតេន ភាវិតា អប្ផុតំ អស្ស ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុតំ ហោតិ ។ ឥទម្បិស្ស ហោតិ សមាធិស្មឹ ។

[១២៩] បុន ចបរំ មាណវ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ

ផ្សព្វផ្សាយដោយទឹកត្រជាក់មិនមានឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានទុតិយជ្ឈាន ក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុបាន រម្ងាប់វិតក្កៈនិងវិចារៈហើយ ។ បេ ។ បានដល់នូវទុតិយជ្ឈាន សម្រាន្តឥរិយាបថនៅ ភិក្ខុនោះតែងញ៉ាំងករជកាយនេះ ឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយ ទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិមិនមានឡើយ ដោយអំពើណា ។ អំពើនេះឯង ជាសមាធិរបស់ភិក្ខុនោះដែរ ។

[១២៩] ម្នាលមាណព មួយវិញទៀត ភិក្ខុនឿយណាយចាកបីតិហើយប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈ ទាំងឡាយតែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈានថា បុគ្គលដែលបាននូវតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខាមានស្មារតី នៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញ៉ាំងករជកាយនេះឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យ

១៨១



បរិប្ផុរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិ-កេន សុខេន អប្ផុតំ ហោតិ ។ សេយ្យថាបិ មាណវ ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ-តានិ អន្តោ និមុគ្គបោសីនិ តានិ យាវ ច អគ្គានិ យាវ ច មូលានិ សីតេន វារិនា អភិសន្នានិ បរិ-សន្នានិ បរិបូរានិ បរិប្ផុតានិ នាស្ស កិញ្ចិ សព្វាវតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា សីតេន វារិ-នា អប្ផុតំ អស្ស ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិ-កេន សុខេន អប្ផុតំ ហោតិ ។ ឥទម្បិស្ស ហោតិ សមាធិស្មឹ ។

ផ្សព្វផ្សាយដោយសុខៈដែលប្រាសចាកបីតិ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខៈ ដែលប្រាសចាកបីតិ មិនមានឡើយ ។ ម្នាលមាណព ដូចជាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងត្រពាំង ព្រលិតក្តី ក្នុងត្រពាំង ឈូកក្រហមក្តី ក្នុងត្រពាំង ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចទៅក្នុងទឹក ឯជលជាតិទាំងអស់នោះ តែងជ្រួតជ្រាប ឆ្អែតស្កប់ស្កល់បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ រហូតដល់ចុង រហូតដល់គល់ អវយវៈបន្តិចបន្តួចនៃជលជាតិទាំងអស់ គឺព្រលិតក្តី ឈូកក្រ-ហមក្តី ឈូកសក្តី ឈ្មោះថាមិនបានផ្សព្វផ្សាយ ដោយទឹកត្រជាក់មិនមានឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានតតិយជ្ឈាន ក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុនឿយណាយចាកបីតិហើយ ។ បេ ។ ក៏បានដល់នូវតតិយជ្ឈាន សម្រាន្តឥរិយាបថនៅ ភិក្ខុនោះញុំាងករជកាយនេះឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយសុខៈដែលប្រាសចាកបីតិ ប្រទេសបន្តិចបន្តួចនៃកាយ ទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយ ដោយសុខៈដែលប្រាសចាកបីតិមិនមានឡើយ ដោយអំពើណា ។ អំពើនេះ ជាសមាធិរបស់ភិក្ខុនោះឯងដែរ ។

[១៣០] បុន ចបរំ មាណវ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេ វ សោមនស្ស-ទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិ-បារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុតំ ហោតិ ។ សេយ្យថាបិ មាណវ បុរិសោ ឱទាតេន វត្ថេន សសីសំ បារុបិត្វា និសិន្នោ អស្ស នាស្ស កិញ្ចិ សព្វាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុតំ ហោតិ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុតំ ហោតិ ។ ឥទម្បិស្ស ហោតិ សមាធិស្មឹ ។ អយំ ខោ សោ មាណវ អរិយោ

[១៣០] ម្នាលមាណព មួយវិញទៀត ព្រោះលះបង់នូវសុខ ព្រោះលះបង់នូវទុក្ខ ព្រោះរំលត់នូវសោមនស្សនិងទោមនស្ស ក្នុងកាលមុនហើយ ភិក្ខុក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍ មិនជាទុក្ខមិនជាសុខ គឺជាឧបេក្ខា មានសតិបរិសុទ្ធ ដែលកើតអំពីឧបេក្ខា សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញុំាងករជកាយនេះ ឲ្យផ្សព្វផ្សាយដោយចិត្តបរិសុទ្ធផូរផង់អង្គុយនៅ ឯប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ មិនមានឡើយ ។ ម្នាលមាណព ដូចបុរសយកសំពត់សស្អាត ដណ្ដប់កាយព្រមទាំងក្បាល អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់បុរសនោះឯង ឈ្មោះថាមិនបានផ្សព្វផ្សាយដោយសំពត់សស្អាត មិនមានឡើយ ដូចម្ដេចមិញ ម្នាលមាណព ភិក្ខុ ។ បេ ។ ម្នាលមាណព ភិក្ខុ ព្រោះលះបង់នូវសុខៈ ។ បេ ។ ក៏បានដល់នូវចតុត្ថជ្ឈាន សម្រាន្តឥរិយាបថនៅ ភិក្ខុនោះតែងញុំាងករជ-កាយនេះ ឲ្យផ្សព្វផ្សាយដោយចិត្ត ដ៏បរិសុទ្ធផូរផង់អង្គុយនៅ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ មិនមានឡើយ ដូច្នោះឯង ដោយអំពើណា ។ អំពើនេះឯង ជាសមាធិរបស់ភិក្ខុនោះ ។ ម្នាលមាណព នេះឯងជាអរិយ-

១៨៣

សុភសុត្តេ សុភមាណវស្ស អានន្ទត្ថេរប្បសំសា

សមាធិក្ខន្ធោ យស្ស សោ ភគវា វណ្ណវាទី អហោសិ ឯត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសិ អត្ថិ ចេវេត្ថ ឧត្តរឹ ករណីយន្តិ ។ អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ សោ ចាយំ ភោ អានន្ទ អរិយោ សមាធិក្ខន្ធោ បរិបុណ្ណោ នោ អបរិបុណ្ណោ ឯវំ បរិបុណ្ណញ្ចាហំ ភោ អានន្ទ អរិយំ សមាធិក្ខន្ធំ ឥតោ ពហិទ្ធា អញ្ញេសុ សមណព្រាហ្មណេសុ ន សមនុបស្សាមិ ឯវំ បរិបុណ្ណញ្ច ភោ អានន្ទ អរិយំ សមាធិក្ខន្ធំ ឥតោ ពហិទ្ធា អញ្ញេ សមណព្រាហ្មណា អត្តនិ សមនុបស្សេយ្យុំ តេ តាវតកេនេវ អត្តមនា អស្សុ អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ ។ អថ ច បន ភវំ អានន្ទោ ឯវមាហ អត្ថិ ចេវេត្ថ ឧត្តរឹ ករណីយន្តិ ។

សមាធិក្ខន្ធនោះ ដែលសម្តេចព្រះមានព្រះភាគ ទ្រង់បានពោលសរសើរហើយ ទាំងទ្រង់ណែនាំប្រជុំជននេះឲ្យប្រតិបត្តិ ឲ្យតាំងនៅ ឲ្យប្រតិស្ឋានឯកិច្ចដែលគួរធ្វើតទៅ ក្នុងសាសនានេះ នៅមានទៀត ។ សុភមាណពពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះមិនធ្លាប់មានបែរជាមានបាន បពិត្រព្រះអានន្ទដ៏ចម្រើន ក៏អរិយសមាធិក្ខន្ធនោះបរិបូណ៌ហើយ មិនមែនមិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណា មិនដែលឃើញនូវអរិយ-សមាធិក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងពួកសមណព្រាហ្មណ៍ដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះឡើយ បពិត្រព្រះអានន្ទដ៏ចម្រើន ឯពួកសមណព្រាហ្មណ៍ដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះ គង់បានឃើញអរិយសមាធិក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងខ្លួនដែរ តែសមណ-ព្រាហ្មណ៍ទាំងនោះឯង ពេញចិត្តដោយគុណ ត្រឹមតែសមាធិក្ខន្ធប៉ុណ្ណោះថា ល្មមហើយដោយគុណមានប្រមាណប៉ុណ្ណោះ សម្រេចហើយដោយគុណមានប្រមាណប៉ុណ្ណោះ ប្រយោជន៍នៃសាមញ្ញគុណ យើងបានដល់ហើយដោយលំដាប់ កិច្ចនីមួយដែលយើងទាំងឡាយគប្បីធ្វើតទៅ មិនមានឡើយ ។ ចំណែកព្រះអានន្ទដ៏ចម្រើន ពោលយ៉ាងនេះថា កិច្ចដែលគួរធ្វើតទៅ ក្នុងសាសនានេះនៅមានទៀត ។

[១៣១] កតមោ បន សោ ភោ អានន្ទ អរិយោ បញ្ញាក្ខន្ធោ យស្ស សោ ភវំ គោតមោ វណ្ណវាទី អហោសិ យត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសីតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឯវំ បជានាតិ អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសុបចយោ និច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ[១] ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ សិតំ ឯត្ថ បដិពទ្ធន្តិ ។ សេយ្យថាបិ មាណវ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រស្ស សុត្តំ អាវុតំ

១ ឱ. ម. អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ ។

[១៣១] មាណពសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយបញ្ញាខន្ធ ដែលព្រះគោតមដ៏ចម្រើន ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន នោះតើដូចម្តេច ។ ព្រះអានន្ទតបថា កាលបើចិត្ត តាំងខ្ជាប់ខ្ជួនបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនោកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះរមែងផ្ចង់តម្រង់បង្អោនចិត្តទៅដើម្បីញាណទស្សនៈ[១] ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូប ៤ កើតមកអំពីមាតាបិតា មានសេចក្តីចម្រើន ដោយជាតិបាយនិងនំ មានការលាបដុសខាត់បំបាត់ក្លិនអាក្រក់ និងការគក់ច្របាច់ជានិច្ច និងការបែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ក៏វិញ្ញាណរបស់អាត្មាអញនេះអាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ ។ ម្នាលមាណព ដូចកែវពៃទូរ្យដ៏ល្អ មានជាតិដ៏បរិសុទ្ធ មានជ្រុង ៨ ដែលជាងបានច្នៃល្អហើយ មានសម្បុរភ្លឺថ្លា ជ្រះថ្លាដោយវិសេស បរិបូណ៌ដោយអាការទាំងពួង (មានដុសលាងជាដើម) ប្រសិនបើគេដោតអំបោះទៅក្នុងកែវនោះ

១ ក្នុងអដ្ឋកថា ថា មគ្គញ្ញាណក្តី ផលញ្ញាណក្តី សព្វញ្ញុតញ្ញាណក្តី បច្ចវេក្ខណញ្ញាណក្តី វិបស្សនាញាណក្តី លោកហៅថាញាណទស្សនៈ តែក្នុងទីនេះ ព្រះថេរៈសំដែងសំដៅវិបស្សនាញាណតែម្យ៉ាង ។

១៨៤



នីលំ វា បីតំ វា លោហិតំ វា ឱទាតំ វា បណ្ឌុសុត្តំ វា តមេតំ ចក្ខុមា បុរិសោ ហត្ថេ ករិត្វា បច្ចវេក្ខេយ្យ អយំ ខោ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រិទំ សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតំ វា ឱទាតំ វា បណ្ឌុសុត្តំ វាតិ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ឯវំ បជានាតិ អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសុបចយោ និច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ សិតំ ឯត្ថ បដិពទ្ធន្តិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

សុភសូត្រ ការពោលអំពីបញ្ញា សេចក្ដីឧបមានៃបញ្ញា

ជាអំបោះមានពណ៌ខៀវក្ដី លឿងក្ដី ក្រហមក្ដី សសុទ្ធក្ដី សស្រទន់ក្ដី បុរសដែលមានភ្នែកភ្លឺ គប្បីយកកែវនោះមកដាក់លើដៃហើយ ពិចារណាមើលថា នេះជាកែវពៃទូរ្យដ៏ល្អ មានជាតិដ៏បរិសុទ្ធ មានជ្រុង ៨ ដែលជាងបានច្នៃល្អហើយ មានសម្បុរភ្លឺថ្លា ជ្រះថ្លាដោយវិសេស បរិបូណ៌ដោយអាការទាំងពួង អំបោះដែលគេដោតក្នុងកែវនោះ ជាអំបោះមានពណ៌ខៀវក្ដី លឿងក្ដី ក្រហមក្ដី សសុទ្ធក្ដី សស្រទន់ក្ដី យ៉ាងណាមិញ ម្នាលមាណពភិក្ខុដែលបានញាណទស្សនៈ ក៏យ៉ាងនោះឯង ។ បេ ។ ម្នាលមាណពភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តម្រង់ផ្ចង់បង្អោនចិត្តទៅដើម្បីញាណទស្សនៈគឺវិបស្សនាញាណ ភិក្ខុក៏ដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូប ៤ កើតអំពីមាតាបិតា មានសេចក្ដីចម្រើនដោយជាតិបាយនិងនំ មានការលាបដុសខាត់បំបាត់ក្លិនអាក្រក់ និងការគក់ច្របាច់ជានិច្ច និងការបែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ក៏ឯវិញ្ញាណរបស់អាត្មាអញនេះ អាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ ដោយអំពើណា ។ អំពើនេះឯងជាបញ្ញារបស់ភិក្ខុនោះ ។

[១៣២] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ មនោមយំ អភិនិម្មិនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥមម្ហា កាយា អញ្ញំ កាយំ អភិនិន្នាមេតិ រូបឹ មនោមយំ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ ។ សេយ្យថាបិ មាណវ បុរិសោ មុញ្ជម្ហា ឥសិកំ បវាហេយ្យ តស្ស ឯវមស្ស អយំ មុញ្ជោ អយំ ឥសិកា អញ្ញោ មុញ្ជោ អញ្ញា ឥសិកា មុញ្ជម្ហា ត្វេវ ឥសិកា បវាឡ្ហាតិ ។ សេយ្យថាបិ មាណវ បុរិសោ អសឹ កោសិយា បវាហេយ្យ តស្ស ឯវមស្ស អយំ អសិ អយំ កោសិ អញ្ញោ អសិ អញ្ញា កោសិ កោសិយា ត្វេវ អសិ បវាឡ្ហាតិ ។ សេយ្យថាបិ មាណវ បុរិសោ អហឹ ករណ្ឌា ឧទ្ធរេយ្យ តស្ស ឯវមស្ស អយំ អហិ អយំ ករណ្ឌោ អញ្ញោ អហិ អញ្ញោ ករណ្ឌោ ករណ្ឌា ត្វេវ អហិ ឧទ្ធរិតោតិ ឯវមេវ

[១៣២] ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅដើម្បីនិម្មិតនូវកាយ ដែលសម្រេចអំពីចិត្ត ។ ភិក្ខុនោះក៏និម្មិតនូវកាយដទៃ ចេញអំពីកាយនេះ មានរូបសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ។ ម្នាលមាណព ដូចជាបុរសដកបណ្តូលចេញអំពីស្មៅយាប្លង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាស្មៅយាប្លង នេះជាបណ្តូល ឯស្មៅយាប្លងដទៃ បណ្តូលដទៃ តែថាបណ្តូលដែលអាត្មាអញ ដកចេញមកគឺដកចេញអំពីស្មៅយាប្លងហ្នឹងឯង ។ ម្នាលមាណព មួយទៀត ដូចបុរសហូតដាវចេញអំពីស្រោម បុរសនោះរមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាដាវ នេះជាស្រោម ឯដាវដទៃ ស្រោមដទៃ តែថាដាវដែលអាត្មាអញហូតចេញ គឺហូតចេញអំពីស្រោមហ្នឹងឯង ។ ម្នាលមាណព ពុំនោះសោត ដូចបុរសទាញយកពស់ចេញអំពីស្រោម បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាពស់ នេះជាស្រោម ឯពស់ដទៃ ស្រោមដទៃ តែថាពស់ដែលអាត្មាអញ ទាញចេញពីស្រោមហ្នឹងឯង ដូចម្តេចមិញ

ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ មនោមយំ អភិនិម្មិនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ បេ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៣] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ឥទ្ធិវិធាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ ។ សោ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ

ម្នាលមាណព ភិក្ខុដែលបានញាណទស្សនៈក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីនិម្មិតនូវកាយដែលសម្រេចមកអំពីចិត្ត ដោយអំពើណា ។ បេ ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៣] ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅដើម្បីតាក់តែងឫទ្ធិ ។ ភិក្ខុនោះរមែងបាននូវការតាក់តែងឫទ្ធិជាច្រើនប្រការ គឺថាមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែងនិងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ។ ភិក្ខុនោះធ្វើនូវការងើបឡើង ឬមុជចុះក្នុងផែនដី ដូចជាងើបឡើងឬមុជចុះក្នុងទឹកក៏បាន ដើរលើទឹកក៏មិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ទៅឯអា-កាសទាំងភ្នែនដូចជាសត្វសកុណជាតិ ដែលមានស្លាបក៏បាន យកដៃ

ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ សេយ្យថាបិ មាណវ ទក្ខោ កុម្ភការោ វា កុម្ភការន្តេវាសី វា សុបរិកម្មកតាយ មត្តិកាយ យំ យទេវ ភាជនវិកតឹ អាកង្ខេយ្យ តន្តទេវ[១] ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថាបិ វា បន មាណវ ទក្ខោ ទន្តការោ វា ទន្តការន្តេវាសី វា សុបរិកម្មកតស្មឹ ទន្តស្មឹ យំ យទេវ ទន្តវិកតឹ អាកង្ខេយ្យ តន្តទេវ[២] ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថាបិ វា បន មាណវ ទក្ខោ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា សុបរិកម្មកតស្មឹ សុវណ្ណស្មឹ យំ យទេវ សុវណ្ណវិកតឹ អាកង្ខេយ្យ តន្តទេវ[៣] ករេយ្យ អភិនិប្ផាទេយ្យ ឯវមេវ ខោ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ

១-២-៣ ម. តំ តទេវ ។

ទៅស្ទាបអង្អែល ចាប់ពាល់ព្រះចន្ទ្រនិងព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលមាណព មួយទៀតដូចជាស្មូនឆ្នាំងក្តី កូនសិស្សរបស់ស្មូនឆ្នាំងក្តី ដែលឈ្លាសវៃ កាលបើដីស្អិតដែលគេធ្វើបរិកម្មល្អហើយ បើប្រាថ្នានឹងធ្វើភាជន៍ដ៏ប្លែកណា ៗ ក៏គប្បីធ្វើឲ្យសម្រេចនូវភាជន៍នោះ ៗ បាន ម្នាលមាណព ពុំនោះសោតដូចជាងភ្លុកក្តី កូនសិស្សរបស់ជាងភ្លុកក្តី ដែលឈ្លាសវៃ កាលបើភ្លុកដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃភ្លុកដ៏ប្លែកណា ៗ គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃភ្លុកដ៏ប្លែកនោះ ៗ បាន ម្នាលមាណព ពុំនោះសោតដូចជាជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តី ដែលឈ្លាសវៃ កាលបើមាសដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើគ្រឿងប្រើប្រាស់ ជាវិការៈនៃមាសដ៏ប្លែកណា ៗ ក៏គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃមាសដ៏ប្លែកនោះ ៗ បាន ដូចម្តេចមិញ ម្នាលមាណព ភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់

កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ឥទ្ធិវិធាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៤] សោ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ ទិព្វាយ សោតធាតុយា ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ សេយ្យថាបិ មាណវ បុរិសោ អទ្ធានមគ្គប្បដិបន្នោ សោ សុណេយ្យ[១] ភេរិសទ្ទំបិ មុទិង្គសទ្ទំបិ[២] សំខសទ្ទំបិ បណវសទ្ទំបិ ទេណ្ឌិមសទ្ទំបិ តស្ស ឯវមស្ស ភេរិសទ្ទោ ឥតិបិ មុទិង្គសទ្ទោ ឥតិបិ សំខសទ្ទោ ឥតិបិ បណវសទ្ទោ ឥតិបិ ទេណ្ឌិមសទ្ទោ ឥតិបិ ឯវមេវ ខោ

១ ម. សុណាតិ ។ ២ ម. ឥតោ បរំ សំខបណវទិណ្ឌិមសទ្ទំបិ តស្ស ឯវមស្ស ភេរិសទ្ទោ ឥតិបិ មុទិង្គសទ្ទោ ឥតិបិ សំខបណវទិណ្ឌិមសទ្ទោ ឥតិបិ ល្បទិសោ បាឋោ ទិស្សតិ ។

គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីតាក់តែងឫទ្ធិបាន ភិក្ខុនោះរមែងបាននូវការតាក់តែងឫទ្ធិ ជាច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។ បេ ។ ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៤] ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីទិព្វ-សោតធាតុ (ត្រចៀកទិព្វ) ។ ភិក្ខុនោះរមែងឮនូវសំឡេងពីរយ៉ាងបាន គឺសំឡេងជាទិព្វ ១ សំឡេងជារបស់មនុស្សធម្មតា ១ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដោយទិព្វសោតធាតុដ៏បរិសុទ្ធស្អាត កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតា ។ ម្នាលមាណព ដូចបុរសអ្នកដើរទៅកាន់ផ្លូវឆ្ងាយ បុរសនោះឮនូវសំឡេងស្គរធំក្តី សំឡេងសំភោរក្តី សំឡេងស័ង្ខក្តី សំ-ឡេងស្គរជ័យក្តី សំឡេងស្គរតូចក្តី បុរសនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា សំឡេងស្គរធំដូច្នេះក្តី សំឡេងសំភោដូច្នេះក្តី សំឡេងស័ង្ខដូច្នេះក្តី សំឡេងស្គរជ័យដូច្នេះក្តី សំឡេងស្គរតូចដូច្នេះក្តី ដូចម្តេចមិញ

មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ ឋិត្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោបិ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៤] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ចេតោបរិយញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ

ម្នាលមាណព ភិក្ខុដែលបានទិព្វសោតធាតុក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងឮសំឡេងពីរយ៉ាងបាន គឺសំឡេងជាទិព្វ ១ សំឡេងជារបស់មនុស្សធម្មតា ១ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដោយទិព្វសោតធាតុ ដ៏បរិសុទ្ធស្អាត កន្លងបង់នូវសោតធាតុ ជារបស់មនុស្សធម្មតា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៥] ភិក្ខុនោះ កាលបើតាំងចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏តម្រង់ផ្ទង់បង្អោនចិត្តទៅ ដើម្បីចេតោបរិយញ្ញាណ គឺការកំណត់ដឹងនូវចិត្តនៃសត្វដទៃ ។ ភិក្ខុនោះក៏កំណត់ដឹងនូវចិត្ត របស់ពួកសត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្ត

វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សំខិត្តំ វា ចិត្តំ សំខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ សេយ្យថាបិ មាណវ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនជាតិកោ អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកមុខនិមិត្តំ[១] បច្ចវេក្ខមានោ សកណិកំ វា

---

១ ម. សកំ មុខនិមិត្តំ ។

ប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលរួញថយក្តី ក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈគឺចិត្តដល់នូវភាវៈជាធំ បានខាងរូបាវចរនិងអរូបាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ គឺកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈគឺកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈគឺជារូបាវចរនិងអរូបាវចរៈក្តី ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងខ្ជាប់ខ្ជួនក្តី ក៏ដឹងច្បាស់ថា ចិត្តតាំងខ្ជាប់ខ្ជួន ចិត្តដែលមិនទាន់បានតាំងខ្ជាប់ខ្ជួនក្តី[១] ក៏ដឹងច្បាស់ថា ចិត្តមិនទាន់បានតាំងខ្ជាប់ខ្ជួន ចិត្តដែលរួចស្រឡះ (ចាកកិលេស) ហើយក្តី ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ ម្នាលមាណព ដូចស្ត្រីក្តី បុរសក្តី ដែលនៅក្មេង ជាក្រមុំកំលោះ នៅកំពុងចូលចិត្តនឹងគ្រឿងប្រដាប់ តាក់តែងរាងកាយ កាលឆ្លុះមើលស្រមោលមុខរបស់ខ្លួន នៅក្នុងកញ្ចក់ដ៏ស្អាតផូរផង់ក្តី ក្នុងភាជន៍ដ៏ពេញដោយទឹកថ្លាក្តី បើស្រមោលមុខរបស់ខ្លួន ប្រកបដោយទោស មានមុន (ជាដើម) ក្តី

---

១ ចិត្តជាអប្បនាសមាធិ ឬ ឧបចារសមាធិ ។

សកណិកាន្តិ បជានេយ្យ អកណិកំ វា អកណិកាន្តិ បជានេយ្យ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ ចេតោបរិយញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ ។ បេ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៦] សោ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិសតសហស្សំបិ

ក៏ដឹងថា ប្រកបដោយទោស បើស្រមោលមុខរបស់ខ្លួន មិនប្រកបដោយទោសក្តី ក៏ដឹងថាមិនប្រកបដោយទោស ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានចេតោបរិយញ្ញាណ ក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីចេតោបរិយញ្ញាណ ។ ភិក្ខុនោះក៏កំណត់ដឹងនូវចិត្តរបស់ពួកសត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។ បេ ។ ចិត្តមិនទាន់បានរួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់បានរួចស្រឡះ ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៦] ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះក៏រលឹកនូវខន្ធ ដែលសត្វអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ រលឹកខន្ធដូចម្តេច គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន

អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាសឹ(១) តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថាបិ មាណវ បុរិសោ សកម្ហាបិ(២) គាមា អញ្ញំ គាមំ គច្ឆេយ្យ តម្ហាបិ គាមា អញ្ញំបិ(៣) គាមំ គច្ឆេយ្យ សោ តម្ហា គាមា សកំយេវ គាមំ បច្ចាគច្ឆេយ្យ តស្ស ឯវមស្ស អហំ ខោ សកម្ហា គាមា អមុំ គាមំ អគច្ឆឹ តត្ថាបិ(៤) ឯវំ អដ្ឋាសឹ

---

១ ម. ឧទបាទឹ ។ ២ ម. សកម្ហា ។ ៣ ម. អញ្ញំ ។ ៤ ម. តត្រ ។

រលឹកនូវសំវដ្តកប្បជាច្រើនក៏បាន វិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្បជាច្រើនក៏បានថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើត ក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ។ ភិក្ខុនោះរលឹកបាននូវខន្ធ ដែលខ្លួនអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រយ៉ាងនេះ ។ ម្នាលមាណព ដូចបុរសចេញអំពីស្រុករបស់ខ្លួន ហើយទៅកាន់ស្រុកដទៃ ចេញអំពីស្រុកនោះ ហើយទៅកាន់ស្រុកដទៃទៀត បុរសនោះឯងក៏ត្រឡប់មកស្រុកនោះ មកកាន់ស្រុករបស់ខ្លួនវិញ ហើយបុរសនោះ ក៏នឹករលឹកឃើញយ៉ាងនេះថា អាត្មាអញបានចេញ អំពីស្រុករបស់ខ្លួនហើយ ទៅកាន់ស្រុកឯណោះ ដែលទៅកាន់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ

ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ សោ តម្ហា[១] ការា អមុំ គាមំ អគច្ឆឹ តត្រាបិ ឯវំ អដ្ឋាសឹ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ សោម្ហិ តម្ហា គាមា សកំយេវ គាមំ បច្ចាគតោតិ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនីហរតិ អភិ-និន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៧] សោ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ

---

១. តម្ហាបិ ។

បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ លុះអាត្មាអញ ចេញអំពីស្រុកនោះ ហើយទៅកាន់ស្រុកឯណោះ ដែលទៅដល់ស្រុកនោះ អាត្មាអញ បានឈរយ៉ាងនេះ បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ ឥឡូវនេះអាត្មាអញត្រឡប់មកពីស្រុកនោះ មកកាន់ស្រុករបស់ខ្លួនវិញហើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានបុព្វេនិវាសានុស្សតិញ្ញាណ ក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះ ក៏រលឹកនូវបុព្វេនិវាសជាច្រើនប្រការ រលឹកបានដូចម្តេច គឺរលឹកបាន ១ ជាតិ ២ ជាតិ ។ បេ ។ ភិក្ខុនោះរលឹកបាននូវបុព្វេនិវាស ជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៧] ភិក្ខុនោះ កាលបើ ចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីសត្តានំចុតូបបាតញ្ញាណ គឺសេចក្តីដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត

១៩៤

សុភសុត្តេ ចុតូបបាតញាណំ

ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុ-គតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមា-ទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នា-គតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវា-ទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-មានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ

ជាសត្វទាបថោក ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចី-ទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកជេរលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់អំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះរំលាងកាយទៅ បន្ទាប់អំពីមរណៈ ក៏ទៅក្នុងអបាយ[១] ទុគ្គតិ[២] វិនិបាត[៣] នរក[៤] មួយសោត អើហ្ន៎ សត្វទាំងអម្បាលនេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលនូវព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះលុះដល់រំលាងកាយទៅ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងលោកគឺមនុស្សសុគតិនិងសួគ៌ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វទាបថោក ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់

---

១ កំណើតសត្វតិរច្ឆាន ។ ២ បេតវិស័យ ។ ៣ អសុរកាយដែលមានមហិទ្ធិឫទ្ធិដូចរាហូអសុរិន្ទជាដើម ។ ៤ នរក គឺលោកដែលគ្មានសេចក្តីចម្រើន មានច្រើនប្រការ មានអវីចិនរកជាដើម ។

យថាកម្មូបគេ សត្តេ បជានាតិ ។ សេយ្យថាបិ មាណវ មជ្ឈេ សឹឃាដកេ ចាសាទោ តត្ថ ចក្ខុមា បុរិសោ ឋិតោ បស្សេយ្យ មនុស្សេ គេហំ បវិសន្តេបិ និក្ខមន្តេបិ រថិយាយ វីថី សញ្ចរន្តេបិ មជ្ឈេ សឹឃាដកេ និសិន្នេបិ តស្ស ឯវមស្ស ឯតេ មនុស្សា គេហំ បវិសន្តិ ឯតេ និក្ខមន្តិ ឯតេ រថិយាយបិ វីថឹ សញ្ចរន្តិ ឯតេ មជ្ឈេ សឹឃាដកេ និសិន្នាតិ ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ សត្តានំ ចុតូបចាតញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

ដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះឯង ។ ម្នាលមាណព ដូចជាប្រាសាទដែលតាំងនៅក្បែរផ្លូវត្រឡែងកែង នាកណ្តាលក្រុង បុរសមានភ្នែកភ្លឺឈរលើប្រាសាទនោះ គប្បីឃើញនូវមនុស្សទាំងឡាយ ដែលចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី ត្រាច់សញ្ចរអំពីច្រកផ្លូវទៅកាន់ថ្នល់ក្តី ដែលអង្គុយក្បែរផ្លូវត្រឡែងកែង នាកណ្តាលក្រុងក្តី បុរសនោះ ក៏ដឹងច្បាស់យ៉ាងនេះថា មនុស្សទាំងនុ៎ះ ដើរចូលទៅកាន់ផ្ទះ មនុស្សទាំងនុ៎ះ ចេញមកអំពីផ្ទះ មនុស្សទាំងនុ៎ះសញ្ចរអំពីច្រកផ្លូវទៅកាន់ថ្នល់ មនុស្សទាំងនុ៎ះ អង្គុយនៅក្បែរផ្លូវត្រឡែងកែង នាកណ្តាលក្រុង ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានសត្តានំចុតូបបាតញ្ញាណក៏ដូច្នោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីសត្តានំចុតូបបាតញ្ញាណ ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វទាបថោក ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

សុភសុត្តេ អាសវក្ខយញ្ញាណំ

[១៣៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញា-ណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថា-ភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវ-និរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមីតិ[១] ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សេយ្យថាបិ មាណវ

១ ម. វិមុត្តម្ហីតិ ។

សុភសូត្រ អាសវក្ខយញ្ញាណ

[១៣៨] ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់ បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺសេចក្ដីដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ។ ភិក្ខុនោះ ក៏ដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងតាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងតាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងតាមពិតថា នេះជាសេចក្ដីរលត់អាសវៈ ដឹងតាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្ដីរលត់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាលបើចិត្តផុតស្រឡះហើយ សេចក្ដីដឹងក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ ករណីយកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលមាណព

បព្វតសំខេបឧទករហទោ[១] អច្ឆោ វិប្បសន្នោ អនាវិលោ តត្ថ ចក្ខុមា បុរិសោ តីរេ ឋិតោ បស្សេយ្យ សិប្បិកសម្ពុកំបិ សក្ខរកឋលំបិ[២] មច្ឆគុម្ពំបិ ចរន្តំបិ តិដ្ឋន្តំបិ តស្ស ឯវមស្ស អយំ ខោ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្រិមេ សិប្បិកសម្ពុកាបិ សក្ខរកឋលាបិ មច្ឆគុម្ពាបិ ចរន្តាបិ តិដ្ឋន្តាបិ[៣] ឯវមេវ ខោ មាណវ ភិក្ខុ ។ បេ ។ យំបិ មាណវ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ ។ បេ ។ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ

---

១ ម. បព្វតសង្ខេបេ ឧទករហទោ ។ ២ សក្ខរកថលំបីតិបិ ។ ៣ ម. តិដ្ឋន្តាបីតិ ។

ដូចជាអន្លង់ទឹកលើកំពូលភ្នំ ដែលថ្លាឈ្វេង ឥតមានកករល្អក់ បុរសដែលមានភ្នែកភ្លឺ ឈរទៀបមាត់នៃអន្លង់ទឹកនោះ គប្បីឃើញនូវខ្យងនិងគ្រំក្តី ដុំក្រួសនិងបំណែកក្តី ហ្វូងត្រីដែលហែលទៅមកឬឋិតនៅក្តី បុរសនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អន្លង់ទឹកនេះឯងថ្លាឈ្វេង ឥតមានកករល្អក់ ខ្យងនិងគ្រំទាំងឡាយនេះក្តី ដុំក្រួសនិងបំណែកទាំងឡាយនេះក្តី ហ្វូងត្រីទាំងឡាយនេះ ដែលកំពុងហែលទៅមកឬកំពុងឋិតនៅក្តី ក្នុងអន្លង់ទឹកនោះ យ៉ាងណាមិញ ម្នាលមាណព ភិក្ខុដែលបានអាសវក្ខយ-ញ្ញាណ ក៏យ៉ាងនោះឯង ។ បេ ។ ម្នាលមាណព ភិក្ខុ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។ បេ ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ទង់បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ ភិក្ខុនោះក៏ដឹងតាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងតាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្តីរលត់អាសវៈ ។ ភិក្ខុនោះ កាលបើដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាលបើ ចិត្តផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតនៃអាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្ត

កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។

[១៣៩] អយំ ខោ សោ មាណវ អរិយោ បញ្ញាខន្ធោ យស្ស សោ ភគវា វណ្ណវាទី អហោសិ ឯត្ថ ច ឥមំ ជនតំ សមាទបេសិ និវេសេសិ បតិដ្ឋាបេសិ នត្ថិ ចេវេត្ថ ឧត្តរឹ ករណីយន្តិ ។ អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ សោវាយំ ភោ អានន្ទ អរិយោ បញ្ញាខន្ធោ បរិបុណ្ណោ នោ អបរិបុណ្ណោ ឯវំ បរិបុណ្ណញ្ចាហំ ភោ អានន្ទ អរិយំ បញ្ញាខន្ធំ ឥតោ ពហិទ្ធា អញ្ញេសុ សមណព្រាហ្មណេសុ ន សមនុបស្សាមិ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ ។ អភិក្កន្តំ ភោ អានន្ទ អភិក្កន្តំ ភោ អានន្ទ សេយ្យថាបិ ភោ អានន្ទ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ

គ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញ ក៏បានធ្វើស្រេចហើយ ករណីយកិច្ចដទៃនៃអាត្មាអញ ដែលប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ ទៀតមិនមានឡើយដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[១៣៩] ម្នាលមាណព នេះឯងជាអរិយបញ្ញាខន្ធ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន កិច្ចដែលគួរធ្វើតទៅទៀតក្នុងសាសនានេះ មិនមានឡើយ ។ សុភមាណព ពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះមិនធ្លាប់មានបែរជាមានបាន បពិត្រព្រះអានន្ទដ៏ចម្រើន អរិយបញ្ញាខន្ធនោះបរិបូណ៌ហើយ មិនមែន មិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាមិនដែលឃើញនូវអរិយបញ្ញាខន្ធ ដែលបរិបូណ៌យ៉ាងនេះ ក្នុងសមណព្រាហ្មណ៌ទាំងឡាយដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះឡើយ កិច្ចនីមួយដែលយើងទាំងឡាយ គប្បីធ្វើតទៅទៀតមិនមានឡើយ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលលោកម្ចាស់ សំដែងហើយដោយអនេកបរិយាយ យ៉ាងនេះ (ក្លីច្បាស់ណាស់) ដូចជាគេផ្ងារនូវ

បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ខោ ភោតា អានន្ទេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភោ អានន្ទ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុ-សង្ឃញ្ច ឧបាសកំ មំ ភវំ អានន្ទោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

សុភសុត្តំ ទសមំ និដ្ឋិតំ ។

ភាជន៍ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាគេបំភ្លឺប្រទីប ក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុ (ភ្នែក) នឹងមើលឃើញរូបទាំងឡាយ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះអានន្ទដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ។

ចប់ សុភសូត្រ ទី ១០ ។

# កេវដ្ដសុត្តំ ឯកាទសមំ

[៨៤០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ណាលន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ អថខោ កេវដ្ដោ[១] គហបតិបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កេវដ្ដោ គហបតិបុត្តោ ភគវន្តំ ឯតទវោច អយំ ភន្តេ ណាលន្ទា ឥទ្ធា ចេវ ផីតា ច ពហុជនា អាកិណ្ណមនុស្សា ភគវតិ អភិប្បសន្នា សាធុ ភន្តេ ភគវា ឯកំ ភិក្ខុំ សមាទិសតុ យោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ ឯវាយំ ណាលន្ទា ភិយ្យោសោមត្តាយ ភគវតិ អភិប្បសីទិស្សតីតិ ។ ឯវំ វុត្តេ ភគវា កេវដ្ដំ គហបតិបុត្តំ ឯតទវោច ន ខោ អហំ កេវដ្ដ ភិក្ខូនំ ឯវំ ធម្មំ ទេសេមិ ឯថ តុម្ហេ ភិក្ខវេ គិហី-នំ ឱទាតវសនានំ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ

---

១ ឱ. កេវទ្ធោ ។ ម. កេវឌ្ឍោ ។

# កេវដ្តសូត្រ ទី ១១

[១៤០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់គង់នៅ ក្នុងបាវារិកម្ពវ័ន ជិតស្រុកនាលន្ទា ។ គ្រានោះ គហបតីបុត្រឈ្មោះកេវដ្តៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះកេវដ្តគហបតីបុត្រអង្គុយ ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទានេះ ជាស្រុកស្តុកស្តម្ភបរិបូណ៌ (ដោយទ្រព្យរបស់ផ្សេង ៗ) មានជនច្រើន មានមនុស្សកុះករ មានមនុស្សជ្រះថ្លាក្រាស់ក្រៃល ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាអាចនឹងធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌ គឺកុសលកម្ម ១០ សូមព្រះមានព្រះភាគ បង្គាប់ភិក្ខុនោះ ១ រូប (ឲ្យធ្វើ) កាលបើយ៉ាងនេះ អ្នកស្រុកនាលន្ទានេះ ក៏នឹងរឹងរឹតតែជ្រះថ្លាឡើង ក្នុងព្រះមានព្រះភាគ ។ កាលកេវដ្តគហតីបុត្រ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងកេវដ្តគហបតីបុត្រថា ម្នាលកេ-វដ្តៈ តថាគតមិនសំដែងធម៌ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចូរមកធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌

កាហេថាតិ ។ ទុតិយម្បិ ខោ កេវឌ្ឍោ គហបតិបុត្តោ ភគវន្តំ ឯតទវោច ធាហំ ភន្តេ ភគវន្តំ បធំសេមិ[1] អបិច ឯវំ វទាមិ អយំ ភន្តេ នាលន្ទា ឥទ្ធា ចេវ ផីតា ច ពហុជនា អាកិណ្ណមនុស្សា ភគវតិ អភិប្បសន្នា សាធុ ភន្តេ ភគវា ឯកំ ភិក្ខុំ សមាទិសតុ យោ ឧត្តរិមនុស្ស-ធម្មា ឥទ្ធិប្បាដិហារិយំ ករិស្សតិ ឯវាយំ នាលន្ទា ភិយ្យោសោ មត្តាយ ភគវតិ អភិប្បសីទិស្សតីតិ ។ តតិយម្បិ ។ បេ ។

[១៤១] តីណិ ខោ ឥមានិ កេវឌ្ឍ បាដិហារិ-យានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ កតមានិ តីណិ ឥទ្ធិប្បាដិហារិយំ អាទេសនាបាដិ-ហារិយំ អនុសាសនីបាដិហារិយំ ។ កតមញ្ច កេវឌ្ឍ ឥទ្ធិប្បាដិហារិយំ ឥធ កេវឌ្ឍ ភិក្ខុ អនេកវិហិតំ

១ ឱ. ម. ធំសេមិ ។

ដល់ពួកគ្រហស្ថអ្នកស្លៀកពាក់ដូច្នេះឡើយ ។ កេវដ្តគហបតីបុត្របាន ក្រាបបង្គំទូលសេចក្ដីនេះ នឹងព្រះមានព្រះភាគជាគម្រប់ ២ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានតាំងព្រះមានព្រះភាគ (ឲ្យសំដែង) ទេ ខ្ញុំព្រះអង្គគ្រាន់តែក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទានេះ ជាស្រុកស្តុកស្តម្ភបរិបូណ៌ (ដោយទ្រព្យរបស់ផ្សេងៗ) មានជនច្រើន មានមនុស្សកុះករ មានមនុស្សជ្រះថ្លាក្រាស់ក្រែល ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាអាចនឹងធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌បាន សូមព្រះមានព្រះភាគបង្គាប់ភិក្ខុនោះ ១ រូប (ឲ្យធ្វើ) កាលបើយ៉ាងនេះ អ្នកស្រុកនាលន្ទានេះនឹងរឹងរឹតតែជ្រះថ្លាឡើង ក្នុងព្រះមានព្រះភាគ ។ (កេវដ្តគហបតីបុត្រក្រាបបង្គំទូលនូវសេចក្ដីនេះទៀត) ជាគម្រប់ ៣ ដងផង ។ បេ ។

[១៤១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ បាដិហារ្យ ៣ យ៉ាងនេះ ដែលតថាគតគប្បីធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងហើយ អាចនឹងសំដែងបាន បាដិហារ្យ ៣ យ៉ាង តើដូចម្ដេច គឺឥទ្ធិបាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលកេវដ្ដៈ ចុះឥទ្ធិបាដិហារ្យ តើដូចម្ដេច ម្នាលកេវដ្ដៈ ភិក្ខុក្នុងសាសនានេះ

កេវឌ្ឍសុត្តេ តីណិ បាដិហារិយានិ ឥទ្ធិវិធកថា

ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយា ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ[១] គច្ឆតិ សេយ្យថាបិ បឋវិយា អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេ-តិ ។ តមេនំ អញ្ញតរោ សទ្ធោ បសន្នោ បស្សតិ តំ ភិក្ខុំ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តំ ឯកោបិ ហុត្វា ពហុធា ហោន្តំ ពហុធាបិ ហុត្វា ឯកោ ហោន្តំ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានំ គច្ឆន្តំ សេយ្យថាបិ អាកាសេ បឋវិយា ឧម្មុជ្ជនិម្មុជ្ជំ ករោន្តំ សេយ្យថាបិ ឧទកេ ឧទកេបិ

១ ឱ. ម. អភិជ្ជមានោ ។

បាននូវឥទ្ធិវិធិគឺការតាក់តែងឫទ្ធិបានជាច្រើនប្រការ មនុស្សម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែងនិងទីខាងក្រៅភ្នំ ដូចជាទៅ ក្នុង អាកាសក៏បាន ងើបឡើងទាំងមុជចុះក្នុងផែនដី ដូចជាងើបមុជ ក្នុងទឹកក៏បាន ដើរទៅក្នុងទឹក ក៏មិនបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន ទៅក្នុងអាកាសទាំងភ្នែន ដូចជាសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែល ចាប់ពាល់នូវព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ កុលបុត្រឯណានីមួយ ជាអ្នកមានសទ្ធាជ្រះថ្លា ឃើញភិក្ខុនោះ ដែលបាននូវឥទ្ធិវិធិជាច្រើនប្រការគឺ មនុស្សម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែងនិងខាងក្រៅភ្នំ ដូចជាដើរទៅ ក្នុងអាកាសក៏បាន ងើបឡើងទាំងមុជចុះ ក្នុងផែនដី ហាក់ដូចជាងើបមុជក្នុងទឹកក៏បាន ដើរទៅក្នុងទឹក

អភិជ្ជមានេ គច្ឆន្តំ សេយ្យថាបិ បឋវិយា អាកាសេបិ បល្លង្កេន កមន្តំ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសន្តំ បរិមជ្ជន្តំ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេន្តំ ។ តមេនំ សោ សទ្ធោ បសន្នោ អញ្ញតរស្ស អស្សទ្ធស្ស អប្បសន្នស្ស អារោចេតិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស មហិទ្ធិកតា មហានុភាវតា អមាហំ ភិក្ខុំ អទ្ទសំ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តំ ឯកោបិ ហុត្វា ពហុធា ហោន្តំ ពហុធាបិ ហុត្វា ឯកោ ហោន្តំ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេន្តន្តិ ។ តមេនំ សោ អស្សទ្ធោ អប្បសន្នោ តំ សទ្ធំ បសន្នំ ឯវំ វទេយ្យ អត្ថិ ខោ ភោ គន្ធារិ នាម វិជ្ជា តាយ សោ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ។ បេ ។

ក៏មិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ទៅក្នុងអាកាសទាំងភ្នែន ដូចជាសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់នូវព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ កុលបុត្រដែលមានសទ្ធាជ្រះថ្លានោះក៏ប្រាប់នូវដំណើរភិក្ខុនោះ ដល់អ្នកដទៃ ដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្ដីជ្រះថ្លាថា ឱហ្ន៎ ហេតុនេះជាអស្ចារ្យពេក ឱហ្ន៎ ហេតុនេះមិនធ្លាប់មាន បែរជាមានបាន ភាវៈនៃសមណៈជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះខ្ញុំបានឃើញភិក្ខុឯណោះ ដែលបាននូវឥទ្ធិវិធិជាច្រើនប្រការគឺ ធ្វើមនុស្សម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់វិញក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ ជនដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្ដីជ្រះថ្លានោះ គប្បីនិយាយប្រាប់ដំណើរភិក្ខុនោះ ទៅនឹងកុលបុត្រដែលមានសទ្ធាជ្រះថ្លានោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើនមានវិជ្ជាមួយយ៉ាង ឈ្មោះគន្ធារិ គឺវិជ្ជាដែលឫសីឈ្មោះគន្ធារៈ តាក់តែងទុកមក ភិក្ខុនោះបាននូវឥទ្ធិវិធិជាច្រើនប្រការ ដោយវិជ្ជានោះ ។ បេ ។

យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតីតិ ។ តំ កិំ មញ្ញសិ កេវដ្ដ អបិ នុ សោ អស្សទ្ធោ អប្បសន្នោ តំ សទ្ធំ បសន្នំ ឯវំ វទេយ្យាតិ ។ វទេយ្យ ភន្តេតិ ។ ឥមំ ខោ អហំ កេវដ្ដ ឥទ្ធិប្បាដិហារិយេ អាទីនវំ សម្បស្សមានោ ឥទ្ធិប្បាដិហារិយេន អដ្ដិយាមិ ហរាយាមិ ជិគុច្ឆាមិ ។

[១៤២] កតមញ្ច កេវដ្ដ អាទេសនាបាដិហារិយំ ។ ឥធ កេវដ្ដ ភិក្ខុ បរសត្តានំ បរបុគ្គលានំ ចិត្តម្បិ អាទិសតិ ចេតសិកម្បិ អាទិសតិ វិតក្កិតម្បិ អាទិសតិ វិចារិតម្បិ អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ[១] តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ តមេនំ អញ្ញតរោ សទ្ធោ បសន្នោ បស្សតិ តំ ភិក្ខុំ បរសត្តានំ បរបុគ្គលានំ ចិត្តម្បិ អាទិសន្តំ ចេតសិកម្បិ អាទិសន្តំ វិតក្កិតម្បិ អាទិសន្តំ វិចារិតម្បិ អាទិសន្តំ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ

១ ម. សព្វត្ថ ចិត្តំបិ អាទិសតិ ចេតសិកំបិ អាទិសតិ វិតក្កិតំបិ អាទិសតិ វិចារិតំបិ អាទិសតិ ឯវំបិ តេ មនោ ឥត្ថំបីតិ ទិស្សតិ ។

ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលកេវដ្ដៈ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច ជនដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្ដីជ្រះថ្លានោះ នឹងគប្បីនិយាយពាក្យយ៉ាងនេះ ទៅនឹងកុលបុត្រ ដែលមានសទ្ធាជ្រះថ្លានោះដែរឬ ។ កេវដ្ដគហបតីបុត្រក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ជននោះគប្បីនិយាយដែរ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ តថាគត ពិចារណាឃើញច្បាស់នូវទោសក្នុងឥទ្ធិបាដិហារ្យនេះហើយ ទើបនឿយណាយធុញទ្រាន់ ខ្ពើមរអើមចាកឥទ្ធិបាដិហារ្យ ។

[១៨២] ម្នាលកេវដ្ដៈ ចុះអាទេសនាបាដិហារ្យ តើដូចម្ដេច ។ ម្នាលកេវដ្ដៈ ភិក្ខុក្នុងសាសនានេះ ទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ[១] ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ កុលបុត្រឯណានីមួយ ដែលមានសទ្ធាជ្រះថ្លាឃើញភិក្ខុនោះ ដែលទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ

១ អដ្ឋកថា លោកសំដៅយកសោមនស្សចេតសិកនិងទោមនស្សចេតសិក ។

១០៦



ឥតិបិ តេ ចិត្តន្តិ ។ តមេនំ សោ សទ្ធោ បសន្នោ អញ្ញតរស្ស អស្សទ្ធស្ស អប្បសន្នស្ស អារោចេតិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស មហិទ្ធិកតា មហានុភាវតា អមាហំ ភិក្ខុំ អទ្ទសំ បរសត្តានំ បរបុគ្គលានំ ចិត្តម្បិ អាទិសន្តំ ចេតសិកម្បិ អាទិសន្តំ វិតក្កិតម្បិ អាទិសន្តំ វិចារិតម្បិ អាទិសន្តំ ឯវំបិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ តមេនំ សោ អស្សទ្ធោ អប្បសន្នោ តំ សទ្ធំ បសន្នំ ឯវំ វទេយ្យ អត្ថិ ខោ ភោ មណិកា នាម វិជ្ជា តាយ សោ ភិក្ខុ បរសត្តានំ បរបុគ្គលានំ ចិត្តម្បិ អាទិសតិ ចេតសិកម្បិ អាទិសតិ វិតក្កិតម្បិ អាទិសតិ វិចារិតម្បិ អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ តំ កឹ មញ្ញសិ កេវដ្ឌ អបិ នុ សោ អស្សទ្ធោ អប្បសន្នោ

ចិត្តរបស់អ្នកដូច្នេះខ្លះ ។ កុលបុត្រដែលមានសទ្ធាជ្រះថ្លានោះ ក៏ប្រាប់នូវដំណើរភិក្ខុនោះ ដល់ជនដទៃដែលជាអ្នកមិនទាន់មានសទ្ធា មិនទាន់មានសេចក្តីជ្រះថ្លាថា ឱហ្ន៎ ហេតុនេះជាអស្ចារ្យណាស់ ឱហ្ន៎ ហេតុនេះមិនធ្លាប់មាន បែរជាមានបាន ភាវៈនៃសមណៈជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះខ្ញុំបានឃើញភិក្ខុឯណោះដែលទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ជនដែលមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លានោះ គប្បីនិយាយប្រាប់ដំណើរភិក្ខុនោះ ទៅនឹងកុលបុត្រដែលមានសទ្ធាជ្រះថ្លានោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន មានវិជ្ជាមួយយ៉ាងឈ្មោះមណិកា[១] ជាវិជ្ជាសម្រាប់ដឹងចិត្តបុគ្គលដទៃ ភិក្ខុនោះទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃ ដោយវិជ្ជានោះថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ម្នាលកេវដ្ដៈ អ្នកសំគាល់នូវហេតុនោះដូចម្ដេច ជនដែលមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លា

---

១ អដ្ឋកថា ប្រាប់វិជ្ជាឈ្មោះចិន្តាមណី ។

តំ សទ្ធំ បសន្នំ ឯវំ វទេយ្យាតិ ។ វទេយ្យ ភន្តេតិ ។ ឥមំ ខោ អហំ កេវដ្ដ អាទេសនាបាដិហារិយេ អាទីនវំ សម្បស្សមានោ អាទេសនាបាដិហារិយេន អដ្ដិយាមិ ហរាយាមិ ជិគុច្ឆាមិ ។

[១៨៣] កតមញ្ច កេវដ្ដ អនុសាសនីបាដិហារិយំ ។ ឥធ កេវដ្ដ ភិក្ខុ ឯវមនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសិករោថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ។ ឥទំ វុច្ចតិ កេវដ្ដ អនុសាសនីបាដិហារិយំ ។

[១៨៤] បុន ចបរំ កេវដ្ដ ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ[១] ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឥទំបិ វុច្ចតិ កេវដ្ដ អនុសាសនីបាដិហារិយំ[២] ។ ទុតិយំ ឈានំ ។

---

១ ម. សាមញ្ញផលំ ។ ២ ម. ឯវំ ខោ កេវដ្ដ ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំបិ វុច្ចតិ កេវដ្ដ អនុសាសនីបាដិហារិយំ ។

នឹងគប្បីនិយាយពាក្យយ៉ាងនេះ ទៅនឹងកុលបុត្រ ដែលមានសទ្ធា មានសេចក្ដីជ្រះថ្លានោះដែរឬ ។ គហបតីបុត្រក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ជននោះគប្បីនិយាយដែរ ។ ម្នាលកេវដ្ដៈ តថាគតកាលពិចារណាឃើញច្បាស់នូវទោស ក្នុងអាទេសនាបាដិហារ្យនេះឯង ទើបនឿយណាយធុញទ្រាន់ ខ្ពើមរអើមចាកអាទេសនាបាដិហារ្យ ។

[១៨៣] ម្នាលកេវដ្ដៈ ចុះអនុសាសនីបាដិហារ្យ តើដូចម្ដេច ។ ម្នាលកេវដ្ដៈ ភិក្ខុក្នុងសាសនានេះ តែងប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះចុះ កុំត្រិះរិះយ៉ាងនេះឡើយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តយ៉ាងនេះចុះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ អ្នកទាំង-ឡាយ ចូរលះបង់នូវតម្រេកក្នុងបញ្ចកាមគុណនេះ អ្នកទាំងឡាយ ចូរដល់នូវលោកុត្តរធម៌នេះ ហើយសម្រេចឥរិយាបថនៅ ។ ម្នាលកេវដ្ដៈ នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។

[១៨៤] ម្នាលកេវដ្ដៈ មួយវិញទៀត ព្រះតថាគត កើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ។ បេ ។ (អ្នកប្រាជ្ញគប្បីសំដែងឲ្យពិស្ដារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលកេវដ្ដៈ នេះត-ថាគតហៅថា អនុសាសនីបាដិហារ្យ ។ ភិក្ខុបានដល់នូវទុតិយជ្ឈាន ។

តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ កេវឌ្ឍ អនុសាសនីបាដិហារិយំ ។ បេ ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ ឥទំ វុច្ចតិ កេវឌ្ឍ អនុសាសនីបាដិហារិយំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ឥទំ វុច្ចតិ កេវឌ្ឍ អនុសាសនីបាដិហារិយំ ។ ឥមានិ ខោ កេវឌ្ឍ តីណិ បាដិហារិយានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។

[១៨៥] ភូតបុព្វំ កេវឌ្ឍ ឥមស្មឹយេវ ភិក្ខុសង្ឃេ អញ្ញតរស្ស ភិក្ខុនោ ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កត្ថ នុ ខោ[១] ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ អថខោ[២] កេវឌ្ឍ ភិក្ខុ តថារូបំ សមាធឹ សមាបជ្ជិ យថា សមាហិតេ ចិត្តេ ទេវយានិយោ

១ កត្ថន្នុ ខោ ។ ២ ឱ. ម. សោតិ បទំ ទិស្សតិ ។

តតិយជ្ឈាន ។ ចតុត្ថជ្ឈានហើយសម្រាន្តឥរិយាបថនៅ ។ ម្នាលកេវដ្ដៈ នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។ បេ ។ ភិក្ខុតម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ ។ ម្នាលកេវដ្ដៈ នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។ បេ ។ ភិក្ខុដឹងច្បាស់ថា កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលកេវដ្ដៈ នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។ ម្នាលកេវដ្ដៈ បាដិហារ្យទាំង ៣ យ៉ាងនេះឯង ដែលតថាគតធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយអាចសំដែងបាន ។

[១៨៥] ម្នាលកេវដ្ដៈ រឿងធ្លាប់មានមកថា ភិក្ខុមួយរូបក្នុងភិក្ខុសង្ឃនេះឯង កើតមានសេចក្ដីត្រិះរិះក្នុងចិត្តយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុចូលកាន់សមាធិ តាមបែបផែននៃចិត្តរបស់យោគី ដែលតាំងខ្ជាប់ដោយសមាធិ

២០៩



មគ្គោ ចាតុរហោសិ ។ អថខោ សោ កេវដ្ដ ភិក្ខុ យេន ចាតុម្មហារាជិកា ទេវា តេនុបសង្កមិ ឧបសង្កមិត្វា ចាតុម្មហារាជិកេ ទេវេ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ ចាតុម្មហារាជិកា ទេវា តំ ភិក្ខុំ ឯតទវោចុំ មយំបិ ខោ ភិក្ខុ ន ជានាម យត្ថិមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ ចត្តារោ មហារាជានោ អម្ហេហិ អភិក្កន្តតរា ច បណីតតរា ច តេ ខោ ឯវំ ជានេយ្យុំ យត្ថិមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ អថខោ សោ កេវដ្ដ ភិក្ខុ យេន ចត្តារោ មហារាជានោ តេនុបសង្កមិ ឧបសង្កមិត្វា

ផ្លូវជាទីទៅកាន់ទេវលោក ក៏កើតប្រាកដឡើង ។ ម្នាលកេវដ្ដៈ គ្រានោះ ភិក្ខុនោះចូលទៅរកពួកទេវតា ដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា លុះចូលទៅដល់ហើយ បានសួរសេចក្ដីនេះនឹងពួកទេវតាដែលឋិតនៅក្នុងឋានចាតុម្មហារាជិកាថា ម្នាលអាវុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ពួកទេវតាដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា បានឆ្លើយតបសេចក្ដីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងទាំងឡាយនេះឯង មិនដឹងថា មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាទេ បពិត្រភិក្ខុ តែមានមហារាជ ៤ ព្រះអង្គ ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ មហារាជទាំង ៤ នោះ គប្បីដឹងយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាដូច្នេះ (មិនខាន) ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុក៏ចូលទៅរកមហារាជទាំង ៤ ព្រះអង្គ លុះចូលទៅដល់ហើយ

ចត្តារោ មហាភូតា[១] ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ ចត្តារោ មហាភូតា តំ ភិក្ខុំ ឯតទវោចុំ មយំបិ ខោ ភិក្ខុ ន ជានាម យត្ថិមេ ។ បេ ។ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ តាវត្តឹសា នាម ទេវា អម្ហេហិ អភិក្កន្តតរា ច បណីតតរា ច តេ ខោ ឯវំ ជានេយ្យុំ យត្ថិមេ ចត្តារោ ។ បេ ។ វាយោធាតូតិ ។ អថខោ សោ កេវដ្ដ ភិក្ខុ យេន តាវត្តឹសា ទេវា តេនុបសង្កមិ ឧបសង្កមិត្វា តាវត្តឹសេ ទេវេ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ តាវត្តឹសា ទេវា តំ ភិក្ខុំ ឯតទវោចុំ មយំបិ ខោ ភិក្ខុ ន ជានាម យត្ថិមេ ។ បេ ។ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ

១ ឱ. ម. មហារាជេ ។

ក៏សួរសេចក្តីនេះនឹងមហារាជទាំង ៤ ថា ម្នាលអាវុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ មហារាជទាំង ៤ ព្រះអង្គឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ សូម្បីយើងទាំងឡាយក៏មិនដឹងសេចក្តីនេះដែរ ។ បេ ។ បពិត្រភិក្ខុ មានតែទេវតាទាំងឡាយ ដែលឋិតនៅក្នុងឋានតាវត្តិង្ស ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ ពួកទេវតាទាំងនោះឯង គប្បីដឹងសេចក្តីយ៉ាងនេះ ។ បេ ។ ម្នាលកេវដ្ដៈ គ្រានោះ ភិក្ខុក៏ចូលទៅរកពួកទេវតាដែលឋិតនៅក្នុងឋានតាវត្តិង្ស លុះចូលទៅដល់ហើយ ក៏បានសួរសេចក្តីនេះនឹងពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្សថា ម្នាលអាវុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ពួកទេវតាដែលឋិតនៅក្នុងឋានតាវត្តិង្ស ឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងទាំងឡាយ ក៏មិនដឹងសេចក្តីនេះដែរ ។ បេ ។ បពិត្រភិក្ខុ តែមាន

២១១

កេវដ្ដសុត្តំ មហាភូតបរិយេសកភិក្ខុវត្ថុ

សក្កោ ទេវានមិន្ទោ អម្ហេហិ អភិក្កន្តតរោ ច បណីតតរោ ច សោ ខោ ឯវំ ជានេយ្យ យត្ថិមេ ចត្តារោ ។ បេ ។ វាយោធាតូតិ ។ អថខោ សោ កេវដ្ដ ភិក្ខុ យេន សក្កោ ទេវានមិន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា សក្កំ ទេវានមិន្ទំ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ សក្កោ ទេវានមិន្ទោ តំ ភិក្ខុំ ឯតទវោច អហំបិ ខោ ភិក្ខុ ន ជានាមិ យត្ថិមេ ចត្តារោ ។ បេ ។ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ យាមា នាម ទេវា ។ បេ ។ សុយាមោ នាម ទេវបុត្តោ ។ បេ ។ តុសិតា នាម ទេវា ។ បេ ។ សន្តុសិតោ នាម ទេវបុត្តោ ។ បេ ។ និម្មានរតី នាម ទេវា ។ បេ ។ សុនិម្មិតោ នាម ទេវបុត្តោ ។ បេ ។ បរនិម្មិតវសវត្តី នាម ទេវា ។ បេ ។ បរនិម្មិតវសវត្តី នាម ទេវបុត្តោ

ទេវរាជឈ្មោះសក្កៈជាធំជាងទេវតាទាំងឡាយ ឧត្តមថ្លៃថ្លាជាងយើងទាំង-ឡាយ សក្កទេវរាជនោះឯង គប្បីដឹងសេចក្តីយ៉ាងនេះ ។ បេ ។ ម្នាលកេវដ្តៈ ភិក្ខុនោះក៏ចូលទៅរកសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ លុះចូលទៅដល់ហើយ ក៏សួរនូវសេចក្តីនេះនឹងសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ដែលរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្តៈ កាលបើភិក្ខុនោះសួរយ៉ាងនេះហើយ សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ បានឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំព្រះករុណា ក៏មិនដឹងសេចក្តីនេះដែរ ។ បេ ។ បពិត្រភិក្ខុ តែមានទេវតាឈ្មោះយាមៈ (ទេវតាឋិតនៅក្នុងឋានយាមៈ) ។ បេ ។ ទេវបុត្រឈ្មោះសុយាមៈ ។ បេ ។ ទេវបុត្រឈ្មោះតុសិតៈ (ទេ-វតាឋិតនៅក្នុងឋានតុសិត) ។ បេ ។ ទេវបុត្តឈ្មោះសន្តុសិតៈ ។ បេ ។ ទេវតាឈ្មោះនិម្មានរតី (ទេវតាឋិតនៅក្នុងឋាននិម្មានរតី) ។ បេ ។ ទេវបុត្រឈ្មោះសុនិម្មិតៈ ។ បេ ។ ទេវតាឈ្មោះបរនិម្មិតវសវត្តី (ទេវតាឋិតនៅក្នុងឋានបរនិម្មិតវសវត្តី) ។ បេ ។ ទេវបុត្រឈ្មោះបរនិម្មិតវសវត្តី

អម្ហេហិ អភិក្កន្តតរោ ច បណីតតរោ ច សោ ខោ ឯវំ ជានេយ្យ យត្ថិមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។

[១៨៦] អថខោ សោ កេវដ្ដ ភិក្ខុ យេន វសវត្តី ទេវបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា វសវត្តី ទេវបុត្តំ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ វសវត្តី ទេវបុត្តោ តំ ភិក្ខុំ ឯតទវោច អហំបិ ខោ ភិក្ខុ ន ជានាមិ យត្ថិមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ ព្រហ្មកាយិកា នាម ទេវា អម្ហេហិ អភិក្កន្តតរា ច បណីតតរា ច តេ ខោ ឯវំ ជានេយ្យុំ

ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ ទេវបុត្រឈ្មោះ បរនិម្មិតវសវត្តីនោះ គប្បីដឹងយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណា (មិនខាន) ។

[១៤៦] ម្នាលកេវដ្ដៈ លំដាប់នោះឯង ភិក្ខុនោះ ចូលទៅរកទេវបុត្រឈ្មោះ វសវត្តី លុះចូលទៅដល់ហើយ ក៏បានសួរសេចក្ដីនេះនឹងទេវបុត្រឈ្មោះ វសវត្តីថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ទេវបុត្រឈ្មោះ វសវត្តី ក៏បានឆ្លើយតបសេចក្ដីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំព្រះករុណាក៏មិនដឹងថា មហាភូតរូបទាំង ៤ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាដែរ ។ បពិត្រភិក្ខុ តែមានពួកទេវតាឈ្មោះ ព្រហ្មកាយិកៈ (ទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម) ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ ពួកទេវតានោះគប្បីដឹងសេចក្ដីយ៉ាងនេះ

យត្ថិមេ ចត្តារោ ។ បេ ។ វាយោធាតូតិ ។ អថខោ សោ កេវដ្ដ ភិក្ខុ តថារូបំ សមាធឹ សមាបជ្ជិ យថា សមាហិតេ ចិត្តេ ព្រហ្មយានិយោ មគ្គោ បាតុរហោសិ ។

[១៤៧] អថខោ សោ កេវដ្ដ ភិក្ខុ យេន ព្រហ្មកាយិកា ទេវា តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មកាយិកេ ទេវេ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ ។ បេ ។ វាយោធាតូតិ ។ ឯវំ វុត្តេ កេវដ្ដ ព្រហ្មកាយិកា ទេវា តំ ភិក្ខុំ ឯតទវោចុំ មយំបិ ខោ ភិក្ខុ ន ជានាម យត្ថិមេ ។ បេ ។ វាយោធាតូតិ អត្ថិ ខោ ភិក្ខុ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ អម្ហេហិ អភិក្កន្តតរោ ច បណីតតរោ ច សោ ខោ ឯវំ ជានេយ្យ យត្ថិមេ

(មិនខាន) ។ បេ ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុនោះក៏ចូលកាន់សមាធិ តាមបែបផែននៃចិត្តរបស់យោគី ដែលតាំងខ្ជាប់ដោយសមាធិ ផ្លូវជាទីទៅកាន់ព្រហ្មលោកក៏កើតប្រាកដឡើង ។

[១៨៧] ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះ ក៏ចូលទៅរកពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម លុះចូលទៅដល់ហើយ ក៏បានសួរសេចក្ដីនេះនឹងទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មថា ម្នាលអាវុសោទាំងឡាយ មហាភូតរូប ៤ នេះ ។ បេ ។ វាយោធាតុ ១ រលត់ ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះ សួរយ៉ាងនេះហើយ ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម បានឆ្លើយតបសេចក្ដីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងក៏មិនដឹងសេចក្ដីនេះដែរ ។ បេ ។ បពិត្រភិក្ខុ តែមានព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែង[១]សត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្ទៃ ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ មហាព្រហ្មនោះឯង គប្បីដឹងសេចក្ដីយ៉ាងនេះថា

១ ជាអ្នកចែកសត្វលោកឲ្យទៅជាក្សត្រ ជាព្រាហ្មណ៍ជាដើម (ពាក្យនេះជាសេចក្ដីយល់របស់ពួកព្រហ្មខ្លះ ។) ។

ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ការណំ បនាវុសោ ឯតរហិ សោ មហាព្រហ្មាតិ ។ មយំបិ ខោ ភិក្ខុ ន ជានាម យត្ថ វា ព្រហ្មា យេន វា ព្រហ្មា អបិច ភិក្ខុ យថា និមិត្តា ទិស្សន្តិ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភវតិ ព្រហ្មា បាតុភវិស្សតិ ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ បាតុភាវាយ យទិទំ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភ-វតីតិ ។ អថខោ សោ កេវដ្ដ មហាព្រហ្មា ន ចិ-រស្សេវ បាតុរហោសិ ។

[១៤៨] អថខោ សោ កេវដ្ដ ភិក្ខុ យេន មហាព្រហ្មា[(១)] តេនុបសង្កមិ ឧបសង្កមិត្វា តំ មហា-ព្រហ្មានំ ឯតទវោច កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។

១ ឱ. សោ មហាព្រហ្មា ។

មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណា (មិនខាន) ។ ភិក្ខុនោះសួរថា ម្នាលអាវុសោ ចុះឥឡូវនេះ មហាព្រហ្មនោះនៅ ក្នុងទីណា ។ ពួកទេវតានោះឆ្លើយតបថា បពិត្រភិក្ខុ យើងទាំងឡាយក៏មិនដឹងថា ព្រហ្មនៅ ក្នុងទីណា ឬនៅ ក្នុងទីចំណែកនៃទិសណាដែរ បពិត្រភិក្ខុ ប៉ុន្តែនិមិត្តទាំងឡាយតែងប្រាកដ ពន្លឺតែងកើតច្បាស់ រស្មីតែងកើតប្រាកដក្នុងទីណា ព្រហ្មនឹងមានប្រាកដក្នុងទីនោះ នេះជាបុព្វនិមិត្ត ដើម្បីមានប្រាកដនៃព្រហ្ម គឺពន្លឺក៏កើតច្បាស់ រស្មីមានប្រាកដ ។ ម្នាលកេវដ្ដៈ លំដាប់នោះ មិនយូរប៉ុន្មានឡើយ មហាព្រហ្មនោះក៏មានរូបប្រាកដឡើង ។

[១៤៨] ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះចូលទៅរកមហាព្រហ្ម លុះចូលទៅដល់ហើយ បានសួរសេចក្ដីនេះនឹងមហាព្រហ្មនោះថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាហ្ន៎ ។

២១៤

កេវដ្ដសុត្តេ មហាភូតបរិយេសកភិក្ខុវត្ថុ

ឯវំ វុត្តេ កេវដ្ដ សោ មហាព្រហ្មា តំ ភិក្ខុំ ឯតទវោច អហមស្មិ ភិក្ខុ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានន្តិ ។ ទុតិយម្បិ ខោ កេវដ្ដ សោ ភិក្ខុ តំ មហាព្រហ្មានំ ឯតទវោច ន ខោ អហំ តំ អាវុសោ ឯវំ បុច្ឆាមិ ត្វមសិ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ[1] ឯវញ្ច ខោ អហន្តំ អាវុសោ ឯវំ បុច្ឆាមិ កត្ថ នុ ខោ អាវុសោ ឥមេ ចត្តារោ មហាភូតា

១ ឱ. ភូតភវ្យានន្តិ ។ ម. ភូតភព្យានន្តិ ។

ម្នាលកេវដ្ដៈ កាលបើភិក្ខុសួរយ៉ាងនេះហើយ មហាព្រហ្មនោះក៏ឆ្លើយតបសេចក្ដីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្មឈ្មោះ មហាព្រហ្មគ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វ-លោក ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតមកហើយ និងសត្វនៅក្នុងផ្ទៃ ។ ម្នាលកេវដ្ដៈ ភិក្ខុនោះបានសួរនូវសេចក្ដីនេះនឹងមហាព្រហ្មនោះ ជាគម្រប់២ ដងទៀតថា ម្នាលអាវុសោ អាត្មាមិនមែនសួរអ្នកយ៉ាងនេះថា អ្នកជាព្រហ្មឈ្មោះ មហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងឡាយ ឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វ ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្ទៃដូច្នេះទេ ម្នាលអាវុសោ ឯអាត្មាសួរយ៉ាងនេះថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺ

អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ទុតិយម្បិ ខោ កេវដ្ដ សោ មហាព្រហ្មា តំ ភិក្ខុំ ឯតទវោច អហមស្មិ ភិក្ខុ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញ-ទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានន្តិ ។ តតិយម្បិ ខោ កេវដ្ដ សោ ភិក្ខុ តំ មហាព្រហ្មានំ ឯតទវោច ន ខោ អហន្តំ អាវុសោ ឯវំ បុច្ឆាមិ តុម្ហសិ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ ឯវញ្ច ខោ អហន្តំ អាវុសោ ឯវំ បុច្ឆាមិ កត្ថ នុ ខោ អាវុសោ

បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះទេតើ ។ ម្នាលកេវដ្ដៈ មហាព្រហ្មនោះបានឆ្លើយតបសេចក្ដីនេះនឹងភិក្ខុនោះជាគម្រប់២ ដងទៀតថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្ទៃ ។ ម្នាលកេវដ្ដៈ ភិក្ខុនោះបានសួរនូវសេចក្ដីនេះនឹងមហាព្រហ្មជាគម្រប់ ៣ ដងទៀតថា ម្នាលអាវុសោ អាត្មាមិនមែនសួរយ៉ាងនេះថា អ្នកជាព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃសត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្ទៃដូច្នេះទេ ម្នាលអាវុសោ ឯអាត្មាសួរអ្នកយ៉ាងនេះថា ម្នាលអាវុសោ

ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។

[១៤៩] អថខោ កេវដ្ដ សោ[១] មហាព្រហ្មា តំ ភិក្ខុំ ពាហាយំ គហេត្វា ឯកមន្តំ អបនេត្វា តំ ភិក្ខុំ ឯតទវោច ឥមេ ខោ មំ ភិក្ខុ ព្រហ្មកាយិកា ទេវា ឯវំ ជានន្តិ នត្ថិ កិញ្ចិ ព្រហ្មុនោ អញ្ញាតំ នត្ថិ កិញ្ចិ ព្រហ្មុនោ អទិដ្ឋំ នត្ថិ កិញ្ចិ ព្រហ្មុនោ អវិទិតំ នត្ថិ កិញ្ចិ ព្រហ្មុនោ អសច្ឆិកតន្តិ តស្មា អហំ តេសំ សម្មុខា ន ព្យាកាសឹ អហំបិ ខោ ភិក្ខុ ន ជានាមិ យត្ថិមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ តស្មា តិហ ភិក្ខុ តុម្ហេវេតំ ទុក្កដំ[២] តុម្ហេវេតំ អបរទ្ធំ យំ ត្វំ ភគវន្តំ អតិធាវិត្វា[៣] ពហិទ្ធា បរិយេដ្ឋឹ អាបជ្ជសិ ឥមស្ស បញ្ហស្ស វេយ្យាករណាយ

---

១ ឱ. ម. អថខោ សោ កេវដ្ដ ។ ២ ឱ. ទុក្កតំ ។ ៣ ឱ. អតិសិត្វា ។ ម. អតិធាវិត្វា ។

មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះទេតើ ។

[១៤៩] ម្នាលកេវដ្ដៈ គ្រានោះ មហាព្រហ្មនោះចាប់ដើមដៃភិក្ខុនោះហើយនាំចៀសចេញទៅ ក្នុងទីដ៏សមគួរ ហើយនិយាយសេចក្ដីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មទាំងនេះឯង តែងស្គាល់នូវខ្ញុំយ៉ាងនេះថា ហេតុអ្វីនីមួយឈ្មោះថា ព្រហ្ម មិនដឹង មិនឃើញ មិនស្គាល់ មិនធ្វើឲ្យច្បាស់នោះមិនមានឡើយ ព្រោះហេតុនោះ ទើបខ្ញុំមិនព្យាករ ក្នុងទីចំពោះមុខនៃទេវតាទាំងនុ៎ះ បពិត្រភិក្ខុ ខ្ញុំសោតក៏មិនដឹងថា មហាភូតរូប ៤ ទាំងនេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ ក្នុងទីណាដែរ បពិត្រភិក្ខុ លោកម្ចាស់លះបង់ចោលព្រះមានព្រះភាគហើយ ដល់នូវការស្វែងរក (បុគ្គល) ខាងក្រៅវិញ ដើម្បីព្យាករណ៍នូវប្រស្នានេះ ដោយអំពើណា អំពើនោះ លោកម្ចាស់ធ្វើមិនល្អទេ អំពើនោះលោកម្ចាស់ធ្វើខុសហើយ បពិត្រភិក្ខុ ព្រោះហេតុ

គច្ឆ ត្វំ ភិក្ខុ តមេវ ភគវន្តំ ឧបសង្កមិត្វា ឥមំ បញ្ហំ បុច្ឆ យថា តេ ភគវា ព្យាករោតិ តថា នំ ធារេយ្យាសីតិ ។

[១៨០] អថខោ កេវឌ្ឍ សោ ភិក្ខុ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មម បុរតោ បាតុរហោសិ ។ អថខោ សោ កេវឌ្ឍ ភិក្ខុ មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កេវឌ្ឍ សោ ភិក្ខុ មំ ឯតទវោច កត្ថ នុ ខោ ភន្តេ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវំ វុត្តេ អហំ កេវឌ្ឍ តំ ភិក្ខុំ ឯតទវោចំ ភូតបុព្វំ ភិក្ខុ សាមុទ្ទិកា វាណិជា តីរទស្សឹ សកុណំ គហេត្វា នាវាយ[១] អជ្ឈោគាហន្តិ តេ អតីរទស្សិនិយា នាវាយ តីរទស្សឹ សកុណំ មុញ្ចន្តិ សោ គច្ឆតិ បុរត្ថិមំ ទិសំ គច្ឆតិ ទក្ខិណំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ គច្ឆតិ ឧត្តរំ ទិសំ គច្ឆតិ

១ ឱ. ម. នាវាយ សមុទ្ទំ ។

នោះ លោកម្ចាស់ចូរទៅគាល់ព្រះមានព្រះភាគអង្គនោះហើយ សួរនូវប្រស្នានេះចុះ បើព្រះមានព្រះភាគទ្រង់ព្យាករ ដល់លោកម្ចាស់យ៉ាងណា លោកម្ចាស់គប្បីចាំទុកនូវសេចក្តីនោះយ៉ាងនោះចុះ ។

[១៩០] ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះក៏បាត់អំពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះមុខតថាគត (រហ័ស) ប្រៀបដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះ ថ្វាយបង្គំតថាគតរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលកេវដ្ដៈ លុះភិក្ខុនោះអង្គុយ ក្នុងទីដ៏សមគួរហើយ ក៏បានសួរនូវសេចក្តីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន មហាភូតរូបទាំង ៤ នេះគឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ តថាគតក៏បានសំដែងសេចក្តីនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ រឿងធ្លាប់មានមកហើយថា មានពួកឈ្មួញសមុទ្រ បាននាំយកសត្វស្ទាបដែលជាសត្វមើលឃើញត្រើយសមុទ្រ ហើយចុះទៅកាន់សមុទ្រដោយសំពៅ ពួកឈ្មួញទាំងនោះកាលបើសំពៅដែលបើកទៅ មើលមិនឃើញត្រើយសមុទ្រ ក៏លែងសត្វបក្សីដែលមើលឃើញត្រើយសមុទ្រ សត្វបក្សីនោះក៏ហើរទៅកាន់ទិសខាងកើត ទៅកាន់ទិសខាងត្បូង ទៅកាន់ទិសខាងលិច ទៅកាន់ទិសខាងជើង

ឧទ្ធំ ទិសំ គច្ឆតិ អនុទិសំ សចេ សោ សមុទ្ទា តីរំ បស្សតិ តថាបក្កន្តោ[១] វ ហោតិ សចេ បន សោ សមុទ្ទា តីរំ ន បស្សតិ តមេវ នាវំ បច្ចាគច្ឆតិ ឯវមេវ ខោ ត្វំ ភិក្ខុ យតោ យាវ ព្រហ្មលោកា[២] បរិយេសមានោ ឥមស្ស បញ្ហស្ស វេយ្យាករណេន អជ្ឈគមា អថខោ មយ្ហមេវ[៣] សន្តិកេ បច្ចាគតោ ន ខោ ឯសោ ភិក្ខុ បញ្ហោ ឯវំ បុច្ឆិតព្វោ កត្ថ នុ ខោ ភន្តេ ឥមេ ចត្តារោ មហាភូតា អបរិសេសា និរុជ្ឈន្តិ សេយ្យថីទំ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឯវញ្ច ខោ សោ ភិក្ខុ បញ្ហោ បុច្ឆិតព្វោ ។

[១៨១] កត្ថ អាបោ ច បឋវី ច
តេជោ វាយោ ន គាធតិ
កត្ថ ទីឃញ្ច រស្សញ្ច
អណុំ ថូលំ សុភាសុភំ
កត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតីតិ ។

---

១ ឱ. ម. តថា គតកោ វ ។ ២ ឱ. យាវ យតោ យាវ ព្រហ្មលោកា ។ ៣ ឱ. វេយ្យាករណំ នាជ្ឈគា អថ មមំយេវ ។ ម. វេយ្យាករណំ អជ្ឈគា អថ មមញ្ញេវ ។

ទៅកាន់ទិសខាងលើ ទៅកាន់ទិសតូច បើសត្វបក្សីនោះ មើលឃើញត្រើយសមុទ្រជុំវិញ ក៏ហើរបាត់ទៅតែម្តង ប្រសិនបើ សត្វបក្សីនោះ មើលមិនឃើញត្រើយសមុទ្រជុំវិញទេ ក៏ហើរត្រឡប់មករកសំពៅនោះវិញ ម្នាលភិក្ខុ ខ្លួនអ្នកបានដើរស្វែងរក (បុគ្គល) ដើម្បីព្យាករណ៍នូវប្រស្នានេះរហូតដល់ព្រហ្មលោក ក៏ត្រឡប់មកកាន់សំណាក់នៃតថាគតវិញដូច្នោះឯង ម្នាលភិក្ខុ ប្រស្នានេះមិនត្រូវសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះឡើយ ។ ម្នាលភិក្ខុ ប្រស្នានោះអ្នកត្រូវសួរយ៉ាងនេះថា ។

[១៩១] អាបោធាតុក្តី បឋវីធាតុក្តី តេជោធាតុក្តី វាយោ-
ធាតុក្តី មិនតាំងនៅក្នុងទីណា (ឧបាទាយរូប) ដែលមាន
សណ្ឋានវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អ អាក្រក់ក្តី រលត់
ក្នុងទីណា នាមនិងរូបរលត់ឥតមានសេសសល់ក្នុងទីណា ។

តត្រ វេយ្យាករណំ ភវតិ ។

[១៥២] វិញ្ញាណំ អនិទស្សនំ
អនន្តំ សព្វតោ បភំ
ឯត្ថ អាបោ ច បថវី ច
តេជោ វាយោ ន គាធតិ
ឯត្ថ ទីឃញ្ច រស្សញ្ច
អណុំ ថូលំ សុភាសុភំ
ឯត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតិ
វិញ្ញាណស្ស និរោធេន
ឯត្ថេតំ ឧបរុជ្ឈតីតិ ។

ឥទមវោច ភគវា ។ អត្តមនោ កេវដ្ដោ គហប-តិបុត្តោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

កេវដ្ដសុត្តំ ឯកាទសមំ និដ្ឋិតំ ។

សេចក្តីដោះស្រាយ ក្នុងប្រស្នានោះដូច្នេះ ។

[១៩២] វិញ្ញាណគឺព្រះនិព្វាន មិនមែនជាទីសម្រាប់ឃើញ (ដោយចក្ខុបាន) ទេ ជាធម្មជាតគ្មានទីបំផុត មានពន្លឺ (កម្មដ្ឋាន) ដោយជុំវិញ អាបោធាតុក្តី បឋវីធាតុក្តី តេជោធាតុក្តី វាយោ-ធាតុក្តី មិនតាំងនៅក្នុងព្រះនិព្វាន នុ៎ះឡើយ (ឧបាទាយរូប) ដែលមានសណ្ឋានវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អ អាក្រក់ក្តី តែងរលត់ ក្នុងព្រះនិព្វាននុ៎ះ នាមនិងរូប តែងរលត់ឥត មានសេសសល់ក្នុងព្រះនិព្វាននុ៎ះ នាមនិងរូបនេះ តែងរលត់ ក្នុងព្រះនិព្វាននុ៎ះ ព្រោះរលត់ទៅនៃវិញ្ញាណ ។

ព្រះមានព្រះភាគ បានសំដែងព្រះសូត្រនេះចប់ហើយ ។ កេវដ្ដ-គហបតីបុត្រ ក៏មានចិត្តរីករាយ ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ កេវដ្តសូត្រ ទី ១១ ។

# លោហិច្ចសុត្តំ ទ្វាទសមំ

[១៨៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន សាលវតិកា តទវសរិ ។ តេន ខោ បន សមយេន លោហិច្ចោ ព្រាហ្មណោ សាលវតិកំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា បសេនទិកោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។

[១៨៤] តេន ខោ បន សមយេន លោហិច្ចស្ស ព្រាហ្មណស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ឥធ សមណោ វា ព្រាហ្មណោ វា កុសលំ ធម្មំ អធិគច្ឆេយ្យ កុសលំ ធម្មំ អធិគន្ត្វា ន បរស្ស អារោចេយ្យ កិញ្ហិ បរោ បរស្ស ករិស្សតិ សេយ្យថាបិ នាម បុរាណំ ពន្ធនំ ឆិន្ទិត្វា អញ្ញំ នវំ ពន្ធនំ ករេយ្យ

# លោហិច្ចសូត្រ ទី ១២

[១៥៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ព្រះដំណើរទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយពួកភិក្ខុច្រើន ប្រមាណ ៥០០ រូប ក៏បានទៅដល់ស្រុកឈ្មោះ សាលវតិកា[១] ។ ក៏សម័យនោះឯង ព្រាហ្មណ៍ឈ្មោះលោហិច្ច នៅអាស្រ័យក្នុងស្រុកសាលវតិកា ដែលជាស្រុកកុះករដោយសត្វ គឺមនុស្សនិងតិរច្ឆានមានដំរីសេះជាដើម បរិបូណ៌ដោយស្មៅឧសនិងទឹក បរិបូណ៌ដោយស្រូវអង្ករ ជាព្រះរាជទ្រព្យដែលព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជទាន ជាព្រះរាជអំណោយ ជារង្វាន់ដ៏ប្រសើរ ។

[១៥៤] ជួនសម័យនោះឯង ទិដ្ឋិអាក្រក់ មានសភាពដូច្នោះ ក៏កើតឡើងដល់លោហិច្ចព្រាហ្មណ៍ថា សមណៈឬព្រាហ្មណ៍ ក្នុងលោកនេះ គប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះថា អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ ចងចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះ

---

១ ក្នុងអដ្ឋកថា ថា ស្រុកនោះគេដាំដើមឈើព័ទ្ធជុំវិញ ហាក់ដូចជារបង ហេតុនោះបានជាឈ្មោះថា សាលវតិកា ។

ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ អស្សោសិ ខោ លោហិច្ចោ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សាលវតិកំ អនុប្បត្តោ តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា ។ បេ ។ ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

ក៏យ៉ាងនោះដែរ អាត្មាអញ (យល់) ថា លោកធម៌ ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ។ តមក លោហិច្ចព្រាហ្មណ៍ បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្តចេញចាកសក្យត្រកូលទៅបួស ហើយទ្រង់ព្រះដំណើរទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើនប្រមាណ ៥០០ រូប បានដល់មកស្រុក សាលវតិកាហើយ កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលមកកាន់ភពថ្មីទៀត ទ្រង់បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ទ្រង់សំដែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ កិរិយាដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃណាស់ ។

## លោហិច្ចសុត្តេ សុត្តនិទានំ អប្បាពាធាទិបុច្ឆនំ

[១៨៩] អថខោ លោហិច្ចោ ព្រាហ្មណោ ភេសិកំ[១] នហាបិតំ អាមន្តេសិ ឯហិ ត្វំ សម្ម ភេសិកេ យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ គោតមំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ លោហិច្ចោ ភោ គោតម ព្រាហ្មណោ ភវន្តំ គោតមំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ អធិវាសេតុ កិរ ភវំ គោតមោ លោហិច្ចស្ស ព្រាហ្មណស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ឯវំ ភន្តេតិ ខោ ភេសិកោ នហាបិតោ លោហិច្ចស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភេសិកោ នហាបិតោ ភគវន្តំ ឯតទវោច

---

១ ឱ. រោសិកំ ។

[១៥៥] លំដាប់នោះឯង លោហិច្ចព្រាហ្មណ៍ បាននិយាយនឹងអ្នកផ្លូតទឹកឈ្មោះរោសិកៈថា ម្នាលរោសិកៈជាសំឡាញ់ អ្នកចូរមកអាយ អ្នកចូរទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះសមណគោតម តាមពាក្យរបស់យើងថា បពិត្រព្រះគោតមដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ (ផ្តាំឲ្យ) ទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយនិងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះគោតមដ៏ចម្រើន រួចហើយចូរទូលយ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើនព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់លោហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។ អ្នកផ្លូតទឹកឈ្មោះរោសិកៈ ទទួលពាក្យរបស់លោហិច្ចព្រាហ្មណ៍ថា បាទ អ្នកម្ចាស់ ហើយក៏ដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអ្នកផ្លូតទឹកឈ្មោះរោសិកៈអង្គុយក្នុងទីដ៏សមគួរស៊ប់ហើយ ក៏បានយកសេចក្តីនេះ ក្រាបបង្គំទូលព្រះមានព្រះភាគថា

លោហិច្ចោ ភន្តេ ព្រាហ្មណោ ភគវន្តំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភន្តេ ភគវា លោហិច្ចស្ស ព្រាហ្មណស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេន-ាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

[១៨៦] អថខោ រោសិកោ នហាបិតោ[១] ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន លោហិច្ចោ ព្រាហ្មណោ តេនុបសង្កមិ ឧបសង្កមិត្វា លោហិច្ចំ ព្រាហ្មណំ ឯតទវោច អវោចុម្ហា ខោ មយំ ភោតោ វចនេន[២] តំ ភគវន្តំ លោហិច្ចោ ភន្តេ ព្រាហ្មណោ ភគវន្តំ អប្បា-ពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ

១ ឱ. ភេសីកោ ។ ២ ឱ. អវោចុម្ហ ភោ មយំ ភន្តេ តវ វចនេន ។ ម. អវោ-ចុម្ហា មយំ ភន្តេ តវ វចនេន ។

បពិត្រព្រះអង្គដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ (ផ្តាំឲ្យ) ទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយនិងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះមានព្រះភាគ ហើយឲ្យទូលនិមន្តព្រះអង្គ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់លោហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។

[១៥៦] លំដាប់នោះ អ្នកផ្ងូតទឹកឈ្មោះរោសិកៈ ដឹងច្បាស់ថា ព្រះមានព្រះភាគ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយ ដើរចូលទៅរកលោ-ហិច្ចព្រាហ្មណ៍ លុះចូលទៅដល់ហើយ បាននិយាយប្រាប់សេចក្តីនុ៎ះចំពោះលោហិច្ចព្រាហ្មណ៍ថា ខ្ញុំបានទូលព្រះមានព្រះភាគនោះ តាមពាក្យរបស់អ្នកម្ចាស់ហើយថា បពិត្រព្រះអង្គដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ឲ្យទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយនិងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះ

ឯវញ្ច វទេតិ អធិវាសេតុ កិរ ភន្តេ ភគវា លោហិច្ចស្ស ព្រាហ្មណស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ អធិវុដ្ឋញ្ច[១] បន តេន ភគវតាតិ ។ អថខោ លោហិច្ចោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទេត្វា រោសិកំ នហាបិតំ អាមន្តេសិ ឯហិ ត្វំ សម្ម រោសិក យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា សមណស្ស គោតមស្ស កាលំ អារោចេហិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ ឯវំ ភោតិ ខោ រោសិកោ នហាបិតោ លោហិច្ចស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រោសិកោ នហាបិតោ ភគវតោ កាលំ អារោចេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។

១ ឱ. អធិវត្ថញ្ច ។

មានព្រះភាគ ហើយឲ្យនិមន្តព្រះអង្គ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់លោ-ហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ឯឥឡូវ ព្រះមានព្រះភាគនោះក៏ទ្រង់បានទទួលនិមន្តស្រេចហើយ ។ លុះកន្លងរាត្រីនោះហើយ លោ-ហិច្ចព្រាហ្មណ៍ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ក្នុងផ្ទះរបស់ខ្លួន រួចហើយហៅអ្នកផ្ងូតទឹកឈ្មោះរោសិកៈមកនិយាយថា ម្នាលរោសិកៈជាសំឡាញ់ អ្នកចូរមកអាយ អ្នកចូរទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរក្រាបទូលភត្តកាល ចំពោះព្រះសមណគោតមថា បពិត្រព្រះគោតមដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ អ្នកផ្ងូតទឹកឈ្មោះរោសិកៈ ទទួលពាក្យរបស់លោហិច្ចព្រាហ្មណ៍ថា បាទ អ្នកដ៏ចម្រើន ហើយក៏ដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយឈរក្នុងទីដ៏សមគួរ ។ លុះអ្នកផ្ងូតទឹកឈ្មោះរោសិកៈ ឈរក្នុងទីដ៏សមគួរហើយក៏ក្រាបបង្គំទូលនូវភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។

[១៨៧] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សាលវតិកា តេនុបសង្កមិ ។ តេន ខោ បន សមយេន រោសិកោ នហាបិតោ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ ហោតិ ។ អថខោ រោសិកោ នហាបិតោ ភគវន្តំ ឯតទវោច លោហិច្ចស្ស ភន្តេ[១] ព្រាហ្មណស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ[២] ឥធ សមណោ វា ព្រាហ្មណោ វា កុសលំ ធម្មំ អធិគច្ឆេយ្យ កុសលំ ធម្មំ អធិគន្ត្វា ន បរស្ស អារោចេយ្យ កិញ្ហិ បរោ បរស្ស ករិស្សតិ សេយ្យថាបិ នាម បុរាណំ ពន្ធនំ ឆិន្ទិត្វា អញ្ញំ នវំ ពន្ធនំ ករេយ្យ ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ សាធុ ភន្តេ ភគវា លោហិច្ចំ ព្រាហ្មណំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតូតិ ។ អប្បេវនាម សិយា រោសិកេ អប្បេវនាម សិយា រោសិកេតិ ។ អថខោ ភគវា យេន លោហិច្ចស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា

---

១ ឱ. ភន្តេតិ ន ទិស្សតិ ។ ២ ឱ. ម. ហោតីតិ ន ទិស្សតិ ។

[១៩៧] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅក្នុងស្រុកឈ្មោះសាលវតិកានោះព្រមដោយភិក្ខុសង្ឃ ។ សម័យនោះឯង អ្នកផ្ងូតទឹកឈ្មោះរោសិកៈ ក៏ដើរតាមក្រោយ ៗ នៃព្រះមានព្រះភាគ ។ វេលានោះ អ្នកផ្ងូតទឹកឈ្មោះរោសិកៈ បានយកសេចក្តីនេះ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះ កើតឡើងដល់លោហិច្ចព្រាហ្មណ៍ថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះថា អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ហើយ ចងចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះយ៉ាងនោះដែរ អាត្មាអញ (យល់)ថា លោភធម៌ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ជួយដោះលោហិច្ចព្រាហ្មណ៍ ឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះចេញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលរោសិកៈ កិច្ចប៉ុណ្ណោះ មិនមែនជាភារៈនៃតថាគតទេ ម្នាលរោសិកៈ កិច្ចប៉ុណ្ណោះ មិនសមគួរដល់តថាគតទេ ។ រួចព្រះមានព្រះភាគទ្រង់ព្រះដំណើរទៅកាន់លំនៅលោហិច្ចព្រាហ្មណ៍នោះ លុះចូលទៅដល់ហើយ

បញ្ញត្តេ អាសនេ និសីទិ ។ អថខោ លោហិច្ចោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។

[១៥៨] អថខោ លោហិច្ចោ ព្រាហ្មណោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ លោហិច្ចំ ព្រាហ្មណំ ភគវា ឯតទវោច សច្ចំ កិរ លោហិច្ច តេ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ឥធ សមណោ វា ព្រាហ្មណោ វា កុសលំ ធម្មំ អធិគច្ឆេយ្យ កុសលំ ធម្មំ អធិគន្ត្វា ន បរស្ស អារោចេយ្យ កិញ្ហិ បរោ បរស្ស ករិស្សតិ សេយ្យថាបិ នាម បុរាណំ ពន្ធនំ ឆិន្ទិត្វា អញ្ញំ នវំ ពន្ធនំ ករេយ្យ ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។

ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ គ្រានោះឯង លោហិច្ចព្រាហ្មណ៍ បានអង្គាសថ្វាយខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសា ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែហាមឃាត់ ។

[១៥៨] លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ លោហិច្ចព្រាហ្មណ៍ក៏កាន់យកអាសនៈមួយដ៏ទាបហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគទ្រង់សួរសេចក្តីនុ៎ះ ចំពោះលោហិច្ចព្រាហ្មណ៍ ដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលលោហិច្ច បានឮថា ទិដ្ឋិអាក្រក់នេះ កើតឡើងដល់អ្នកថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះអ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបានដូចជាបុគ្គលកាត់ចំណងចាស់ចោលចេញហើយ ចងនូវចំណងថ្មីដទៃវិញយ៉ាងណាមិញ សេចក្តីនេះក៏យ៉ាងនោះដែរ អាត្មាអញ (យល់) ថា លោភធម៌ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបានដូច្នេះ ពិតមែនឬ ។

ឯវំ ភោ គោតម ។ តំ កឹ មញ្ញសិ លោហិច្ច ននុ ត្វំ សាលវតិកំ អជ្ឈាវសសីតិ ។ ឯវំ ភោ គោតម ។ យោ នុ ខោ លោហិច្ច ឯវំ វទេយ្យ លោហិច្ចោ ព្រាហ្មណោ សាលវតិកំ អជ្ឈាវសតិ យា សាលវតិកាយ សមុទ-យំ សញ្ជាតិ លោហិច្ចោ វ តំ ព្រាហ្មណោ ឯកកោ បរិភុញ្ជេយ្យ ន អញ្ញេសំ ទទេយ្យាតិ ឯវំវាទី សោ យេ តំ ឧបជីវន្តិ តេសំ អន្តរាយករោ វា ហោតិ នោ វាតិ ។ អន្តរាយករោ ភោ គោតម ។ អន្តរាយករោ សមានោ[១] ហិតានុកម្បី វា តេសំ ហោតិ អហិតា-នុកម្បី វាតិ ។ អហិតានុកម្បី ភោ គោតម ។ អហិ-តានុកម្បិស្ស មេត្តំ វា តេសុ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ

១ ឱ. សមានោ លោហិច្ច ។

លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះមែន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលលោហិច្ច អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកអាស្រ័យនៅក្នុងស្រុកសាលវតិកា មិនមែនឬ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះមែន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលលោហិច្ច ជនណានិយាយយ៉ាងនេះថា លោហិច្ចព្រាហ្មណ៍ គ្រប់គ្រងស្រុកសាលវតិកា សួយណាដែលកើតឡើងក្នុងស្រុកសាលវតិកា លោហិច្ចព្រាហ្មណ៍ ត្រូវបរិភោគសួយនោះតែម្នាក់ឯង មិនត្រូវឲ្យអ្នកដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះតើ ឈ្មោះថា អ្នកធ្វើសេចក្តីអន្តរាយដល់ពួកញាតិមិត្តនិងកម្មករដែលរស់នៅ ព្រោះអាស្រ័យនឹងអ្នក ឬក៏មិនមែនទេ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ឈ្មោះថា អ្នកធ្វើសេចក្តីអន្តរាយមែន ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា (បើ) ជននោះឈ្មោះថា អ្នកធ្វើសេចក្តីអន្តរាយ តើជននោះនឹងហៅថា អ្នកអនុគ្រោះដោយប្រយោជន៍ ដល់ពួកញាតិមិត្តទាំងនោះ ឬមិនអនុគ្រោះ ដោយប្រយោជន៍ទេ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថា អ្នកមិនអនុគ្រោះដោយប្រយោជន៍ទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា (បើ) ជននោះមិនអនុគ្រោះ ដោយប្រយោជន៍ហើយ នឹងហៅថា អ្នកតាំងចិត្តមេត្តា

លោហិច្ចសុត្តេ ភគវតោ លោហិច្ចអនុយោគកថា

សបត្តិកំ វាតិ ។ សបត្តិកំ ភោ គោតម ។ សបត្តិ-
កេ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆាទិដ្ឋី វា ហោតិ សម្មាទិដ្ឋី
វាតិ ។ មិច្ឆាទិដ្ឋី ភោ គោតម ។ មិច្ឆាទិដ្ឋិស្ស
ខោ អហំ លោហិច្ច ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ
វទាមិ និរយំ វា តិរច្ឆានយោនឹ វា ។

[១៨៩] តំ កឹ មញ្ញសិ លោហិច្ច ននុ រាជា
បសេនទិកោសលោ កាសិកោសលំ អជ្ឈាវសតីតិ ។
ឯវំ ភោ គោតម ។ យោ នុ ខោ លោហិច្ច ឯវំ
វទេយ្យ រាជា បសេនទិកោសលោ កាសិកោសលំ
អជ្ឈាវសតិ យា កាសិកោសលេ សមុទយំ សញ្ជា-
តិ រាជា វ តំ បសេនទិកោសលោ ឯកកោ
បរិភុញ្ជេយ្យ ន អញ្ញេសំ ទទេយ្យាតិ ឯវំវាទី សោ

ទៅរកញាតិមិត្តទាំងនោះ ឬហៅថាជាសឹកសត្រូវ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថា សឹកសត្រូវ ។ ព្រះអង្គទ្រង់ត្រាស់ថា កាលបើចិត្តជាសឹកសត្រូវ តាំងឡើងហើយ នឹងហៅថា ជននោះជាមិច្ឆាទិដ្ឋិឬជាសម្មាទិដ្ឋិ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថាជាមិច្ឆាទិដ្ឋិ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលលោហិច្ច តថាគតតែងពោលនូវគតិ ២ យ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៩៩] ព្រះមានព្រះភាគ ត្រាស់សួរថា ម្នាលលោហិច្ច អ្នកសំគាល់សេចក្តីនោះដូចម្តេច ក្រែងព្រះបាទបសេនទិកោសល គ្រប់គ្រងដែនកាសីនិងកោសលឬ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពិតមែន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលលោហិច្ច ជនណានិយាយយ៉ាងនេះថា ព្រះបាទបសេនទិកោសល គ្រប់គ្រងដែនកាសីនិងដែនកោសល សួយណាកើតឡើង ក្នុងដែនកាសីនិងកោសល ព្រះបាទបសេនទិកោសល ត្រូវបរិភោគសួយនោះតែមួយព្រះអង្គឯង មិនត្រូវប្រទានដល់ពួកជនដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះ

យេ រាជានំ បសេនទិកោសលំ ឧបជីវន្តិ តុម្ហេ ចេវ អញ្ញេ ច តេសំ អន្តរាយករោ វា ហោតិ នោ វាតិ ។ អន្តរាយករោ ភោ គោតម ។ អន្តរា-យករោ សមានោ ហិតានុកម្បី វា តេសំ ហោតិ អហិតានុកម្បី វាតិ ។ អហិតានុកម្បី ភោ គោ-តម ។ អហិតានុកម្បិស្ស មេត្តំ វា តេសុ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ សបត្តកំ វាតិ ។ សបត្តកំ ភោ គោតម ។ សបត្តកេ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆាទិដ្ឋិ វា ហោតិ សម្មាទិដ្ឋិ វាតិ ។ មិច្ឆាទិដ្ឋិ ភោ គោតម ។ មិច្ឆាទិដ្ឋិស្ស ខោ អហំ លោហិច្ច ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វា ។

[១៦០] ឥតិ កិរ លោហិច្ច យោ ឯវំ វទេយ្យ លោហិច្ចោ ព្រាហ្មណោ សាលវតិកំ អជ្ឈាវសតិ យា

តើនឹងចាត់ជាអ្នកធ្វើសេចក្តីអន្តរាយ ដល់អ្នកទាំងឡាយ និងពួកជនដទៃដែលរស់នៅដោយសារព្រះបាទបសេនទិកោសលនោះ ឬមិនមែនទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ជាអ្នកធ្វើសេចក្តីអន្តរាយ ។ (បើ) ចាត់ជាអ្នកធ្វើសេចក្តីអន្តរាយហើយ តើនឹងចាត់ជាអ្នកអនុគ្រោះ ដោយប្រយោជន៍ដល់ពួកជនទាំងនោះ ឬមិនចាត់ជាអ្នកអនុគ្រោះ ដោយប្រយោជន៍ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនចាត់ជាអ្នកអនុគ្រោះដោយប្រយោជន៍ទេ ។ (បើ) មិនចាត់ជននោះ ថាជាអ្នកអនុគ្រោះ ដោយប្រយោជន៍ទេ តើនឹងចាត់ថាជាអ្នកតាំងមេត្តាចិត្តទៅរកញាតិមិត្តទាំងនោះ ឬចាត់ថាជាសឹកសត្រូវ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ថាជាសឹកសត្រូវ ។ កាលបើចិត្តជាសឹកសត្រូវកើតឡើងហើយ តើនឹងចាត់ជននោះជាមិច្ឆាទិដ្ឋិ ឬជាសម្មាទិដ្ឋិ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច តថាគតតែងសំដែងនូវគតិពីរយ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៦០] ម្នាលលោហិច្ច បានឮមកថា ជនណាមួយនិយាយយ៉ាងនេះថា លោហិច្ចព្រាហ្មណ៍ នៅគ្រប់គ្រងស្រុកសាលវតិកា សួយណា

### លោហិច្ចសុត្តេ លោហិច្ចស្ស មិច្ឆាទិដ្ឋិវិវេចនកថា

សាលវតិកាយ សមុទយំ សញ្ញាតិ លោហិច្ចោ វ តំ ព្រាហ្មណោ ឯកកោ បរិភុញ្ជេយ្យ ន អញ្ញេសំ ទទេយ្យាតិ ឯវំភាវី សោ យេ តំ ឧបជីវន្តិ តេសំ អន្តរាយករោ ហោតិ អន្តរាយករោ សមានោ អហិតានុកម្បី ហោតិ អហិតានុកម្បិស្ស សបត្តិកំ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ សបត្តិកោ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆាទិដ្ឋិ ហោតិ ។ ឯវមេវ ខោ លោហិច្ច យោ ឯវំ វទេយ្យ ឥធ សមណោ វា ព្រាហ្មណោ វា កុសលំ ធម្មំ អធិគច្ឆេយ្យ កុសលំ ធម្មំ អធិគន្ត្វា ន បរស្ស អារោចេយ្យ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ សេយ្យ-ថាបិ នាម បុរាណំ ពន្ធនំ ។ បេ ។ ករិស្សតីតិ ។ ឯវំភាវី សោ យេ តេ កុលបុត្តា តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆន្តិ

ដែលកើតឡើង ក្នុងស្រុកសាលវតិកា លោហិច្ចព្រាហ្មណ៍ត្រូវបរិភោគសួយនោះតែម្នាក់ឯង មិនត្រូវឲ្យដល់ពួកជនដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះ ឈ្មោះថាជាអ្នកធ្វើសេចក្តីអន្តរាយ ដល់ពួកញាតិមិត្តនិងកម្មករដែលនៅដោយសារអ្នក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថាជាអ្នកមិនអនុគ្រោះ ដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ហើយ ចិត្តជាសឹកសត្រូវក៏កើតប្រាកដឡើង កាលបើចិត្តជាសឹកសត្រូវ កើតប្រាកដឡើងហើយ បុគ្គលនោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច យ៉ាងហ្នឹងហើយ (បើ) ជនណាមួយនិយាយយ៉ាងនេះថា សមណព្រាហ្មណ៍ ក្នុងលោកនេះ គប្បីបានសម្រេចកុសលធម៌ លុះបានសម្រេចកុសលធម៌ហើយ មិនគប្បីប្រាប់ដល់បុគ្គលដទៃទេ ព្រោះថា បុគ្គលដទៃនឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ។ ដូចបុគ្គលកាត់ចំណងចាស់ចោលចេញ ។ បេ ។ នឹងធ្វើ ។ ជនដែលនិយាយយ៉ាងនេះ នោះឈ្មោះថាជាអ្នកធ្វើសេចក្តីអន្តរាយ ដល់ពួកកុលបុត្តអ្នកអាស្រ័យនូវធម្មវិន័យ ដែលតថាគត បានប្រកាសស្រេចហើយ បានសម្រេចគុណវិសេសដ៏លើសលុបមានសភាពយ៉ាងនោះ ទាំងធ្វើឲ្យជាក់ច្បាស់នូវ

សោតាបត្តិផលំបិ សច្ឆិករោន្តិ សកទាគាមិផលំបិ សច្ឆិករោន្តិ អនាគាមិផលំបិ សច្ឆិករោន្តិ អរហត្តំបិ សច្ឆិករោន្តិ យេ ចិមេ[1] ទិព្វា គព្ភា បរិបាចេន្តិ ទិព្វានំ ភវានំ អភិនិព្វត្តិយា តេសំ អន្តរាយករោ ហោតិ អន្តរាយករោ សមានោ អហិតានុកម្បី ហោតិ អហិតានុកម្បិស្ស សបត្តកំ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ សបត្តកេ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆាទិដ្ឋី ហោតិ ។ មិច្ឆាទិដ្ឋិស្ស ខោ អហំ លោហិច្ច ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វា ។

[១៦១] ឥតិ កិរ លោហិច្ច យោ ឯវំ វទេយ្យ រាជា បសេនទិកោសលោ កាសិកោសលំ អជ្ឈាវសតិ យា កាសិកោសលេ សមុទយំ សញ្ជាតិ រាជា វ តំ បសេនទិកោសលោ ឯកកោ បរិភុញ្ជេយ្យ ន

---

[1] ឱ. យេ កេចិមេ ។

សោតាបត្តិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលខ្លះ ទាំងដល់ពួកកុលបុត្រ (ដែលស្តាប់ធម្មទេសនារបស់ព្រះតថាគតហើយ តែមិនទាន់បានលុះអរិយភូមិនៅឡើយ) គ្រាន់តែបង្អោនចិត្តទៅកាន់ទេវលោក ដើម្បីកើតក្នុងទេវលោក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថាជាអ្នកមិនអនុគ្រោះដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ហើយ ចិត្តជាសត្រូវក៏កើតប្រាកដឡើង កាលបើចិត្តជាសត្រូវកើតប្រាកដហើយ ជននោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ចតថាគតតែងពោលនូវគតិ ២ យ៉ាងគឺ នរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៦១] ម្នាលលោហិច្ច បានឮមកថា ជនណាមួយ និយាយយ៉ាងនេះថា ព្រះបាទបសេនទិកោសល នៅគ្រប់គ្រងដែនកាសីនិងកោសល សួយណាដែលកើតឡើង ក្នុងដែនកាសីនិងកោសល ព្រះបាទបសេនទិកោសល ត្រូវសោយសួយនោះតែមួយព្រះអង្គឯង មិនត្រូវ

លោហិច្ចសុត្តេ លោហិច្ចស្ស មិច្ឆាទិដ្ឋិវិវេចនកថា

អញ្ញេសំ ឧទេយ្យាតិ ឯវំភាជី សោ យេ ភាជានំ បសេ-
ឧនិគោសលំ ឧបជីវន្តិ តុម្ហេ ចេវ អញ្ញេ ច តេសំ
អន្តរាយករោ ហោតិ អន្តរាយករោ សមានោ អហិ-
តានុកម្បី ហោតិ អហិតានុកម្បិស្ស សបត្តិកំ ចិត្តំ
បច្ចុបដ្ឋិតំ ហោតិ សបត្តិកេ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆា-
ទិដ្ឋិ ហោតិ ។ ឯវមេវ ខោ លោហិច្ច យោ ឯវំ
វទេយ្យ ឥធ សមណោ វា ព្រាហ្មណោ វា កុសលំ
ធម្មំ អធិគច្ឆេយ្យ កុសលំ ធម្មំ អធិគន្ត្វា ន បរស្ស
អារោចេយ្យ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ សេយ្យ-
ថាបិ នាម បុរាណំ ពន្ធនំ ឆិន្ទិត្វា អញ្ញំ នវំ ពន្ធនំ
ករេយ្យ ឯវំ សម្បទមិទំ ចាបកម្មំ លោភធម្មំ វទាមិ
កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ ឯវំភាជី សោ យេ
តេ កុលបុត្តា តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម

ប្រទានដល់ពួកជនឯទៀតទេ ជនដែលនិយាយយ៉ាងនេះ នោះឈ្មោះថា ជាអ្នកធ្វើសេចក្តីអន្តរាយ ដល់រាជបរិពារ គឺពួកអ្នករាល់គ្នា និងពួកជនឯទៀតដែលរស់នៅដោយសារព្រះបាទបសេនទិកោសល កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថាជាអ្នកមិនអនុគ្រោះ ដោយប្រយោជន៍ កាលបើមិនអនុគ្រោះ ដោយប្រយោជន៍ហើយ ចិត្តជាសឹកសត្រូវឈ្មោះថា កើតប្រាកដឡើង កាលបើចិត្តជាសឹកសត្រូវ កើតប្រាកដហើយ ជននោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច យ៉ាងហ្នឹងហើយ (បើ) ជនណាមួយ និយាយយ៉ាងនេះថា សមណៈឬព្រាហ្មណ៍ក្នុងលោកនេះ គប្បីបានសម្រេចកុសលធម៌ លុះបានសម្រេចកុសលធម៌ហើយ មិនគប្បីប្រាប់បុគ្គលឯទៀតទេ ព្រោះថា បុគ្គលឯទៀត នឹងធ្វើអ្វីឲ្យបុគ្គលឯទៀតបាន ។ ដូចជាបុគ្គលកាត់ចំណងចាស់ចោលចេញហើយ ចងចំណងថ្មីដទៃទៀតឡើងវិញដូច្នេះឯង ខ្ញុំយល់ថា លោភធម៌ជាអំពើដ៏លាមក ព្រោះហេតុថាបុគ្គលឯទៀតនឹងធ្វើអ្វីឲ្យបុគ្គលឯទៀតកើត ។ ជនដែលនិយាយយ៉ាងនេះនោះ ឈ្មោះថាជាអ្នកធ្វើសេចក្តីអន្តរាយ ដល់ពួកកុលបុត្រដែលអាស្រ័យ

ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆន្តិ សោតាបត្តិផលំបិ សច្ឆិករោន្តិ សកទាគាមិផលំបិ សច្ឆិករោន្តិ អនាគាមិផលំបិ សច្ឆិករោន្តិ អរហត្តំបិ សច្ឆិករោន្តិ យេ ចិមេ ទិព្វា គព្ភា បរិបាចេន្តិ ទិព្វានំ ភវានំ អភិនិព្វត្តិយា តេសំ អន្តរាយករោ ហោតិ អន្តរាយករោ សមានោ អហិតានុកម្បី ហោតិ អហិតានុកម្បិស្ស សបត្តកំ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ សបត្តកេ ចិត្តេ បច្ចុបដ្ឋិតេ មិច្ឆាទិដ្ឋិ ហោតិ ។ មិច្ឆាទិដ្ឋិស្ស ខោ អហំ លោហិច្ច ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វា ។

[១៦២] តយោ ខោមេ លោហិច្ច សត្ថារោ យេ លោកេ ចោទនារហា យោ ច បនេវរូបេ សត្ថារេ ចោទេតិ សា ចោទនា ភូតា តច្ឆា ធម្មិកា អនវជ្ជា កតមេ តយោ ឥធ លោហិច្ច ឯកច្ចោ សត្ថា យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ

នូវធម្មវិន័យដែលតថាគតសំដែងហើយ បានសម្រេចគុណវិសេសដ៏លើស លុបមានសភាពយ៉ាងនេះ ហើយធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលខ្លះ ទាំងដល់ពួកកុលបុត្រ (ដែល បានស្តាប់ធម្មទេសនា របស់តថាគតហើយ តែមិនទាន់បានលុះអរិយភូមិ នៅឡើយ) គ្រាន់តែបង្អោនចិត្តទៅ កាន់ទេវលោក ដើម្បីកើតក្នុង ទេវលោក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថាជាអ្នកមិន អនុគ្រោះ ដោយប្រយោជន៍ កាលបើមិនអនុគ្រោះ ដោយប្រយោជន៍ ចិត្តជាសឹកសត្រូវឈ្មោះថា កើតប្រាកដឡើង កាលបើចិត្តជាសឹកសត្រូវ កើតឡើងហើយ ជននោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច តថាគត តែងពោលនូវគតិ ២ យ៉ាងគឺ នរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៦២] ម្នាលលោហិច្ច គ្រូទាំង ៣ ពួកនេះ ដែលគួរដល់ ការចោទប្រកាន់បានក្នុងលោក មួយទៀត ជនណា ចោទប្រកាន់ពួក គ្រូដែលមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ ឥតទោសទេ គ្រូទាំង ៣ ពួកនោះ តើដូចម្តេចខ្លះ ម្នាល លោហិច្ច គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស

ស្វាស្ស សាមញ្ញត្ថោ អននុប្បត្តោ ហោតិ ។ សោ តំ សាមញ្ញត្ថំ អននុបាបុណិត្វា សាវកានំ ធម្មំ ទេសេតិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស សាវកា ន សុស្សូន្តិ[១] ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ ។ សោ ឯវមស្ស ចោទេតព្វោ អាយស្មា ខោ យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ សោ តេ សាមញ្ញត្ថោ អននុប្បត្តោ តំ ត្វំ សាមញ្ញត្ថំ អននុបា-បុណិត្វា សាវកានំ ធម្មំ ទេសេសិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស តេ សាវកា ន សុស្សូន្តិ ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ សេយ្យថាបិ នាម ឱសក្កន្តិយា វា ឧសក្កេយ្យ[២] បរម្មុខឹ វា អាលិង្គេយ្យ

១ ឱ. តស្ស តេ សាវកា នេ សុស្សូសន្តិ ។ ២ ឱ. ឧស្សុក្កេយ្យ ។ ម. ឧស្សក្កេយ្យ ។

ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ គ្រូនោះមិនបានសម្រេចឡើយ ។ គ្រូនោះមិនបានសម្រេចប្រយោជន៍នៃសាមញ្ញគុណនោះ ហើយសំដែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ ដល់អ្នកទាំងឡាយ ។ ពួកសាវ័ករបស់គ្រូនោះ រមែងមិនស្ដាប់ មិនផ្ទៀងត្រចៀកស្ដាប់ មិនតាំងចិត្តប្រុងស្ដាប់ ដើម្បីឲ្យដឹងច្បាស់ឡើយ មានតែនាំគ្នា ប្រព្រឹត្តគេចចេញចាកពាក្យប្រដៅរបស់គ្រូ ។ គ្រូនោះអ្នកផងគួរចោទប្រកាន់ យ៉ាងនេះថា លោកមានអាយុ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា (បើ) ប្រយោជន៍នៃសាមញ្ញគុណនោះ លោកមិនទាន់បានសម្រេចទេ លោកមិនទាន់បានសម្រេចប្រយោជន៍ នៃសាមញ្ញគុណនោះ ហើយសំ-ដែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅ ដើម្បីសេចក្ដីសុខដល់អ្នកទាំងឡាយ ។ សាវ័កទាំងនោះរបស់លោក រមែងមិនស្ដាប់ មិនផ្ទៀងត្រចៀកស្ដាប់ មិនតាំងចិត្តប្រុងស្ដាប់ ដើម្បីឲ្យដឹងច្បាស់ មានតែនាំគ្នាប្រព្រឹត្តគេចចេញចាកពាក្យប្រដៅរបស់គ្រូ បុរសចូលទៅរកស្ត្រីដែលមិនស្ម័គ្រ គឺស្ត្រីដែលមិនប្រាថ្នារួមសំវាសជាមួយ ឬចូលទៅឱបស្ត្រីពីខាងក្រោយ សេចក្ដីនេះ

ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ អយំ ខោ[១] លោហិច្ច បឋមោ សត្ថា យោ លោកេ ចោទនារហោ យោ ច បនេវរូបំ សត្ថារំ ចោទេតិ សា ចោទនា ភូតា តច្ឆា ធម្មិកា អនវជ្ជា ។

[១៦៣] បុន ចបរំ លោហិច្ច ឥធេកច្ចោ សត្ថា យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ ស្វាស្ស សាមញ្ញត្ថោ អននុប្បត្តោ ហោតិ ។ សោ តំ សាមញ្ញត្ថំ អននុបាបុណិត្វា សាវកានំ ធម្មំ ទេសេតិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស តេ សាវកា សុស្សន្តិ សោតំ ឱទហន្តិ អញ្ញា-ចិត្តំ ឧបដ្ឋបេន្តិ ន ច វោក្កម្ម សត្ថុ សាសនា វត្តន្តិ ។

១ ឱ. ខោសទ្ធោ ន ទិស្សតិ ។

ឧបមាយ៉ាងណា បុគ្គលដែលនិយាយថា ខ្ញុំ(យល់)ថា លោភធម៌ ជាធម៌លាមក បុគ្គលដទៃដូចម្តេច នឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ច នេះឯងជាគ្រូទី ១ ដែលគួរដល់ការចោទប្រកាន់បានក្នុងលោក បើអ្នកណាចោទប្រកាន់គ្រូមានសភាពដូច្នោះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ ឥតទោសទេ ។

[១៦៣] ម្នាលលោហិច្ច សេចក្តីតទៅទៀតថា គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ គ្រូនោះមិនទាន់បានសម្រេចនៅឡើយ ។ គ្រូនោះមិនទាន់បានសម្រេចប្រយោជន៍នៃសាមញ្ញគុណនោះហើយ សំដែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយដូច្នេះ ។ សាវ័កទាំងនោះរបស់គ្រូនោះ ក៏ស្តាប់ ផ្ទៀងត្រចៀកស្តាប់ តាំងចិត្តប្រុងស្តាប់ ដើម្បីដឹងច្បាស់ មិននាំគ្នាប្រព្រឹត្តគេចវេះចេញ ចាកពាក្យប្រដៅរបស់គ្រូទេ ។

លោហិច្ចសុត្តេ ទុតិយោ ចោទនារហោ សត្ថា

សោ ឯវមស្ស ចោទេតព្វោ អាយស្មា ខោ យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ តេ សាមញ្ញត្ថោ អននុប្បត្តោ តំ ត្វំ សាមញ្ញត្ថំ អននុបាបុណិត្វា សាវកានំ ធម្មំ ទេសេសិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស តេ សាវកា សុស្សូន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ន ច វោក្កម្ម សត្ថុ សាសនា វត្តន្តិ សេយ្យថាបិ នាម សកំ ខេត្តំ ឱហាយ បរក្ខេត្តំ និទ្ធាយិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ អយំ ខោ លោហិច្ច ទុតិយោ សត្ថា យោ លោកេ ចោទនារហោ យោ ច បនេវរូបំ សត្ថារំ ចោទេតិ សា ចោទនា ភូតា តច្ឆា ធម្មិកា អនវជ្ជា ។

លោហិច្ចសូត្រ គ្រូទី ២ ដែលគួរដល់ការចោទប្រកាន់

គ្រូនោះអ្នកផងគួរចោទប្រកាន់យ៉ាងនេះថា លោកមានអាយុចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ លោកមិនទាន់បានសម្រេច លោកមិនទាន់បានសម្រេចប្រយោជន៍នៃសាមញ្ញគុណនោះទេ ហើយសំដែងធម៌ ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយដូច្នេះ ។ សាវ័កទាំងនោះរបស់គ្រូនោះ ក៏ស្តាប់ ផ្ទៀងត្រចៀកស្តាប់ តាំងចិត្តប្រុងស្តាប់ ដើម្បីដឹងច្បាស់ មិននាំគ្នាប្រព្រឹត្តគេចវេះចេញចាក ពាក្យប្រដៅរបស់គ្រូទេ បុគ្គលលះបង់ស្រែរបស់ខ្លួនចេញហើយ ទៅសំគាល់ស្រែរបស់បុគ្គលដទៃថាគួរជំរះ (ស្មៅ) សេចក្តីនេះមានឧបមាយ៉ាងណា បុគ្គលដែលនិយាយថាខ្ញុំយល់ថា លោភធម៌ ជាធម៌លាមក បុគ្គលដទៃនឹងធ្វើអ្វីឲ្យបុគ្គលដទៃបានក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ច នេះជាគ្រូទី ២ ដែលគួរដល់ការចោទប្រកាន់ក្នុងលោក បើបុគ្គលណា ចោទប្រកាន់គ្រូ មានសភាពយ៉ាងនេះ ការចោទប្រកាន់នោះជាការពិតប្រាកដ ប្រកបដោយធម៌ឥតទោសទេ ។

[២៦៤] បុន ចបរំ លោហិច្ច ឥធេកច្ចោ សត្ថា យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ ហោតិ ស្វាស្ស សាមញ្ញត្ថោ អននុប្បត្តោ ហោតិ ។ សោ តំ សាមញ្ញត្ថំ អននុបាបុណិត្វា សាវកានំ ធម្មំ ទេសេតិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស សាវកា ន សុស្សន្តិ[១] ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ ។ សោ ឯវមស្ស ចោទេតព្វោ អាយស្មា ខោ យស្សត្ថាយ អគារស្មា អនគារិយំ បព្វជិតោ សោ តេ សាមញ្ញត្ថោ អននុប្បត្តោ តំ ត្វំ សាមញ្ញត្ថំ អននុបាបុណិត្វា សាវកានំ ធម្មំ ទេសេសិ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស តេ សាវកា ន សុស្សន្តិ

១ ឱ. តស្ស តេ សាវកា ន សុស្សូសន្តិ ។

[១៦៤] ម្នាលលោហិច្ច សេចក្តីតទៅទៀតថា គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ គ្រូនោះមិនទាន់បានសម្រេចនៅឡើយ ។ គ្រូនោះមិនទាន់បានសម្រេចសាមញ្ញគុណនោះ ហើយសំដែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយដូច្នេះ ។ សាវ័កទាំងនោះរបស់គ្រូនោះ ក៏មិនស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ទេ មានតែនាំគ្នាប្រព្រឹត្តគេចវេះចេញចាកពាក្យប្រដៅរបស់គ្រូ គ្រូនោះគួរឲ្យអ្នកផងចោទប្រកាន់យ៉ាងនេះថា លោកមានអាយុ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់សាមញ្ញគុណណា ប្រយោជន៍ នៃសាមញ្ញគុណនោះ លោកមិនបានសម្រេចនៅឡើយ លោកមិនទាន់បានសម្រេចសាមញ្ញគុណនោះ ហើយសំដែងធម៌ ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយដូច្នេះ ។ សាវ័កទាំងនោះរបស់គ្រូនោះ ក៏មិនស្តាប់

លោហិច្ចសុត្តេ តតិយោ ចោទនារហោ សត្ថា

ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ សេយ្យថាបិ នាម បុរាណំ ពន្ធនំ ឆិន្ទិត្វា អញ្ញំ នវំ ពន្ធនំ ករេយ្យ ឯវំ សម្បទមិទំ បាបកំ លោភធម្មំ វទាមិ កិញ្ហិ បរោ បរស្ស ករិស្សតីតិ ។ អយំ ខោ លោហិច្ច តតិយោ សត្ថា យោ លោកេ ចោទនារហោ យោ ច បនេវរូបំ សត្ថារំ ចោទេតិ សា ចោទនា ភូតា តច្ឆា ធម្មិកា អនវជ្ជា ។ ឥមេ ខោ លោហិច្ច តយោ សត្ថារោ យេ លោកេ ចោទនារហា យោ ច បនេវរូបេ សត្ថារោ ចោទេតិ សា ចោទនា ភូតា តច្ឆា ធម្មិកា អនវជ្ជាតិ ។

[១៦៤] ឯវំ វុត្តេ លោហិច្ចោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អត្ថិ បន ភោ គោតម កោចិ សត្ថា យោ លោកេ ន ចោទនារហោតិ ។ អត្ថិ ខោ លោហិច្ច

មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ទេ មានតែប្រព្រឹត្តគេចវេះចេញចាកពាក្យប្រដៅរបស់គ្រូ បុគ្គលកាត់ចំណងចាស់ចេញហើយ ចងចំណងថ្មីដទៃឡើងវិញ សេចក្តីនេះមានឧបមាយ៉ាងណា បុគ្គលដែលនិយាយថា ខ្ញុំយល់ថា លោភធម៌ជាធម៌លាមក បុគ្គលដទៃនឹងជួយធ្វើអ្វីដល់បុគ្គលដទៃបាន ក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ច នេះជាគ្រូទី ៣ ដែលគួរដល់ការចោទប្រកាន់ក្នុងលោកបាន បើអ្នកណា ចោទប្រកាន់គ្រូមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដប្រកបដោយធម៌ ឥតទោសទេ ។ ម្នាលលោហិច្ច គ្រូទាំង ៣ ពួកនេះឯង ដែលគួរដល់ការចោទប្រកាន់ក្នុងលោកបាន បើអ្នកណាចោទប្រកាន់គ្រូទាំងឡាយមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ ឥតទោសទេ ។

[១៦៥] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រូណាមួយដែលមិនគួរដល់ការចោទប្រកាន់ ក្នុងលោកតើមានឬទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលលោហិច្ច គ្រូដែលមិន

សត្ថា យោ លោកេ ន ចោទនារហោតិ ។ កតមោ បន ភោ[១] គោតម សត្ថា យោ លោកេ ន ចោទនារហោតិ ។ ឥធ លោហិច្ច តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឯវំ ខោ លោហិច្ច ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ ខោ លោហិច្ច សត្ថរិ សាវកោ ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆតិ ។ អយំ ខោ[២] លោហិច្ច សត្ថា យោ លោកេ ន ចោទនារហោ យោ[៣] បនេវរូបំ សត្ថារំ ចោទេតិ សា ចោទនា អភូតា អតច្ឆា អធម្មិកា សាវជ្ជា ។ បេ ។ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ ខោ លោហិច្ច សត្ថរិ សាវកោ ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆតិ ។ អយំបិ ខោ លោហិច្ច សត្ថា យោ លោកេ ន ចោទនារហោ យោ ច បនេវរូបំ សត្ថារំ ចោទេតិ

---

១ ឱ. ម. កតមោ បន សោ ភោ ។ ២ ឱ. ម. អយំ បិ ខោ ។ ៣ ឱ. ម. យោ ច ។

គួរដល់ការចោទប្រកាន់ក្នុងលោកមានដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះគ្រូដូចម្តេច ដែលមិនគួរដល់ការចោទប្រកាន់ ក្នុងលោក ។ ម្នាលលោហិច្ច ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។ បេ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលលោហិច្ច ភិក្ខុជាអ្នកបរិបូណ៌ ដោយសីលយ៉ាងនេះឯង ។ បេ ។ បានដល់នូវបឋមជ្ឈាន ។ ម្នាលលោហិច្ច សាវ័ក រមែងសម្រេចនូវគុណវិសេសដ៏លើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ ម្នាលលោហិច្ច សាស្តានេះឯងមិនគួរដល់ការចោទប្រ-កាន់ក្នុងលោកឡើយ បើអ្នកណាចោទប្រកាន់សាស្តា មានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការមិនពិតប្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។ បេ ។ ភិក្ខុបានដល់នូវទុតិយជ្ឈាន ។ នូវតតិ-យជ្ឈាន ។ នូវចតុត្ថជ្ឈាន ។ ម្នាលលោហិច្ច សាវ័កដែលសម្រេចនូវគុណវិសេសលើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ ម្នាលលោហិច្ច សាស្តានេះឯងមិនគួរដល់ការចោទប្រកាន់ក្នុងលោកឡើយ បើបុគ្គលណា ចោទប្រកាន់សាស្តា មានសភាពយ៉ាងនេះ

សា ចោទនា អភូតា អតច្ឆា អធម្មិកា សាវជ្ជា ។ បេ ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ យស្មឹ ខោ លោហិច្ច សត្ថរិ សាវកោ ឯវរូបំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យស្មឹ ខោ លោហិច្ច សត្ថរិ សាវកោ ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆតិ ។ អយំ ខោ លោហិច្ច សត្ថា យោ លោកេ ន ចោទនារហោ យោ ច បនេវរូបំ សត្ថារំ ចោទេតិ សា ចោទនា អភូតា អតច្ឆា អធម្មិកា សាវជ្ជាតិ ។

[១៦៦] ឯវំ វុត្តេ លោហិច្ចោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សេយ្យថាបិ ភោ គោតម បុរិសោ បុរិសំ នរកប្បបាតំ បបតន្តំ កេសេសុ គហេត្វា ឧទ្ធរិត្វា

ការចោទប្រកាន់នោះជាការមិនពិតប្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។ បេ ។ ភិក្ខុតម្រង់ផ្គង់បង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ ។ ម្នាលលោហិច្ច សាវ័កដែលសម្រេច នូវគុណវិសេសដ៏លើសលុបយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃក្រៅពីនេះទៅទៀតមិនមានឡើយ ។ ម្នាលលោហិច្ច សាវ័កដែលសម្រេចនូវគុណវិសេស ដ៏លើសលុបយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ ម្នាលលោហិច្ច សាស្តានេះឯងដែលមិនគួរ ដល់ការចោទប្រកាន់ ក្នុងលោកឡើយ បើបុគ្គលណា ចោទប្រកាន់សាស្តាមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការមិនពិតប្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។

[១៦៦] លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន បុរសចាប់សក់បុរសផងគ្នា ដែលធ្លាក់ទៅក្នុងជ្រោះជ្រៅ ទាញ

ថលេ បតិដ្ឋាបេយ្យ ឯវមេវាហំ[១] ភោតា គោតមេន នរកប្បបាតំ បបតន្តោ ឧទ្ធរិត្វា ថលេ បតិដ្ឋាបិតោ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ បេ ។

លោហិច្ចសុត្តំ ទ្វាទសមំ និដ្ឋិតំ ។

១ ឱ. ឯវមេវំ ។ ម. ឯវមេវ ។

ឡើងលើគោកបានយ៉ាងណា ព្រះគោតមដ៏ចម្រើន ក៏ស្រង់ខ្ញុំព្រះអង្គ ដែលធ្លាក់ទៅក្នុងជ្រោះជ្រៅគឺអបាយភូមិ យកមកដាក់លើគោក គឺឋាន សួគ៌បានយ៉ាងនោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រ ព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាគេ ផ្ងារវត្ថុដែលផ្កាប់ ឬដូចជាបើកនូវវត្ថុដែលកំបាំង ពុំនោះសោតដូចជាគេ ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវដូច្នោះឯង ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ជាសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។ បេ ។

ចប់ លោហិច្ចសូត្រទី ១២ ។

# តេវិជ្ជសុត្តំ តេរសមំ

[១៦៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន មនសាកដំ នាម កោសលានំ ព្រាហ្មណគាមោ តទវសរិ ។ តត្រ សុទំ ភគវា មនសាកដេ វិហរតិ ឧត្តរេន មនសាកដស្ស អចិរវតិយា នទិយា តីរេ អម្ពវនេ ។

[១៦៨] តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា មនសាកដេ បដិវសន្តិ សេយ្យថីទំ វង្កី[១] ព្រាហ្មណោ តារុក្ខោ ព្រាហ្មណោ បោក្ខរសាតិ ព្រាហ្មណោ ជាណុស្សោណិ ព្រាហ្មណោ តោទេយ្យព្រាហ្មណោ អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា ។

---

១ ឱ. ចង្កី ។

# តេវិជ្ជសូត្រ ទី ១៣

[១៦៧] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរ ទៅកាន់ចារិក ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើនប្រមាណ ៥០០ រូប បានដល់ទៅស្រុកព្រាហ្មណ៍ឈ្មោះមនសាកត របស់កោសលជនបទ ។ ឮថា ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងអម្ពវ័ន ជិតឆ្នេរស្ទឹងអចិរវតី ក្នុងទិសខាងជើងនៃមនសាកតគ្រាមជិតស្រុកមនសាកតនោះ ។

[១៦៨] សម័យនោះ ពួកព្រាហ្មណមហាសាល ដែលមានឈ្មោះល្បីល្បាញច្រើននាក់ មកស្នាក់នៅក្នុងស្រុកមនសាកត ព្រាហ្មណ៍ទាំងនោះឈ្មោះអ្វីខ្លះ គឺឈ្មោះវង្កីព្រាហ្មណ៍[១] តារុក្ខព្រាហ្មណ៍[២] បោក្ខរសាតិព្រាហ្មណ៍[៣] ជាណុសោនិព្រាហ្មណ៍[៤] តោទេយ្យព្រាហ្មណ៍[៥] និងពួកព្រាហ្មណមហាសាលឯទៀត ដែលមានឈ្មោះល្បីល្បាញ ។

---

១ អដ្ឋកថា ថា នៅក្នុងក្រុងឈ្មោះឱបសាទ ។ ២ នៅក្នុងក្រុងឈ្មោះឥច្ឆានង្គល ។ ៣ នៅក្នុងក្រុងឈ្មោះឧក្កដ្ឋ ។ ៤ នៅក្នុងក្រុងឈ្មោះសាវត្ថី ។ ៥ នៅក្នុងក្រុងតុទិគ្រាម ។

អថខោ វាសេដ្ឋភារទ្វាជានំ មាណវានំ ជង្ឃវិហារំ[1] អនុចង្កមន្តានំ អនុវិចរន្តានំ មគ្គាមគ្គេ កថា ឧទបាទិ ។ វាសេដ្ឋោ មាណវោ ឯវមាហ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ[2] និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ[3] អក្ខាតោ ព្រាហ្មណេន បោក្ខរសាតិនាតិ ។ ភារទ្វាជោបិ[4] មាណវោ ឯវមាហ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ អក្ខាតោ ព្រាហ្មណេន តារុក្ខេនាតិ ។ នេវ ខោ អសក្ខិ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ សញ្ញាបេតុំ ន បន អសក្ខិ ភារទ្វាជោ មាណវោ វាសេដ្ឋំ មាណវំ សញ្ញាបេតុំ ។

១ ឱ. វាសេដ្ឋភារទ្វាជានំ ជង្ឃាវិហារំ ។ ២ ឱ. អយំ អញ្ជសាយនោ ។ ៣ ឱ. ស្វាយំ ។ ៤ ឱ. ភារទ្វាជោ ។

គ្រានោះ ពួកមាណពជាវាសេដ្ឋគោត្រនិងភារទ្វាជគោត្រ កំពុងនាំគ្នាដើរត្រសងចុះឡើងឲ្យស្រួលជើង (ដើម្បីបន្ទោបង់សេចក្តីរួយស្រពន់) ក៏កើតពាក្យជជែកគ្នាអំពីផ្លូវនិងមិនមែនផ្លូវឡើង ។ វាសេដ្ឋមាណពបាននិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបានផ្លូវនេះឯងដែលបោក្ខរសាតិព្រាហ្មណ៍ បានសំដែងប្រាប់ ។ ចំណែកខាងភារទ្វាជមាណព បាននិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិ តាមផ្លូវនោះឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលតារុក្ខព្រាហ្មណ៍ បានសំដែងប្រាប់ ។ វាសេដ្ឋមាណពមិនអាច ដើម្បីញ៉ាំងភារទ្វាជមាណពឲ្យចូលចិត្តបាន ចំណែកភារទ្វាជមាណព ក៏មិនអាច ដើម្បីញ៉ាំងវាសេ-ដ្ឋមាណព ឲ្យចូលចិត្តបានដែរ ។

[១៦៩] អថខោ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ អាមន្តេសិ អយំ ខោ បន ភារទ្វាជ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ មន-សាកតេ វិហរតិ ឧត្តរេន មនសាកតស្ស អចិរវតិយា នទិយា តីរេ អម្ពវនេ តំ ខោ បន ភវន្តំ គោតមំ ឯវំ-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ ភគវាតិ អាយាម[១] ភារទ្វាជ យេន សមណោ គោតមោ តេនុបសង្កមិស្សា-ម ឧបសង្កមិត្វា ឯតមត្ថំ សមណំ គោតមំ បុច្ឆិស្សាម យថា នោ សមណោ គោតមោ ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ ។ ឯវំ ភោតិ ខោ ភារទ្វាជោ មា-ណវោ វាសេដ្ឋស្ស មាណវស្ស បច្ចស្សោសិ ។

---

១ ឱ. អាយាម ភោ ។

[១៦៩] គ្រានោះ វាសេដ្ឋមាណពបានប្រឹក្សានឹងភារទ្វាជៈថា ម្នាលភារទ្វាជៈ ព្រះសមណគោតមនេះឯងជាសក្យបុត្រ ចេញចាកសក្យត្រកូលមកទ្រង់ព្រះផ្នួស ឥឡូវនេះគង់នៅក្នុងអម្ពវ័ន ជិតឆ្នេរស្ទឹងអចិរវតី ទិសខាងជើងនៃមនសាកតគ្រាម ក្បែរស្រុកមនសាកត កិត្តិសព្ទសរសើរព្រះសមណគោតមដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយ សុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មង គ្រប់យ៉ាងត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ។ បេ ។ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភារទ្វាជៈ មក យើងទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ យើងនឹងសួរសេចក្តីនុ៎ះ ចំពោះព្រះសមណគោតម (បើ) ព្រះសមណគោតម ទ្រង់ដោះស្រាយដល់ពួកយើងយ៉ាងណា យើងនឹងចាំនូវសេចក្តីនោះយ៉ាងនោះ ។ ភារទ្វាជមាណព បានទទួលស្តាប់ពាក្យរបស់វាសេដ្ឋមាណពថា ម្នាលអ្នកដ៏ចម្រើន យ៉ាងហ្នឹងហើយ ។

[១៧០] អថខោ វាសេដ្ឋភារទ្វាជា មាណវា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ វាសេដ្ឋោ មាណវោ ភគវន្តំ ឯតទវោច ឥធ ភោ គោតម អម្ហាកំ ជង្ឃវិហារំ[១] អនុចង្កមន្តានំ អនុវិចរន្តានំ មគ្គាមគ្គេ កថា ឧទបាទិ អហំ ឯវំ វទាមិ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ អក្ខាតោ ព្រាហ្មណេន ពោក្ខរសាតិនាតិ ភារទ្វាជោ មាណវោ ឯវមាហ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ អក្ខាតោ ព្រាហ្មណេន តារុក្ខេនាតិ ឯត្ថ ភោ គោតម

១ ឱ. ជង្ឃាវិហារំ ។

[១៧០] គ្រានោះ វាសេដ្ឋមាណពនិងភារទ្វាជមាណព ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវាសេដ្ឋ-មាណព អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន កាលដែលយើងខ្ញុំ កំពុងនាំគ្នា ដើរត្រសងចុះឡើងឲ្យស្រួលជើង ក៏កើតសំដីជជែកគ្នា អំពីផ្លូវនិងមិនមែនផ្លូវ ក្នុងទីហ្នឹង ខ្ញុំព្រះអង្គពោលយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯង ដែលបោក្ខរសាតិ-ព្រាហ្មណ៍ បានសំដែងប្រាប់ ចំណែកខាងភារទ្វាជមាណព បាននិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រាហ្មណ៍ ផ្លូវនេះឯង ដែលតារុក្ខព្រាហ្មណ៍ បានសំដែងប្រាប់ បពិត្រ

អត្ថេវ វិគ្គហោ អត្ថិ វិវាទោ អត្ថិ នានាវាទោតិ ។ ឥតិ កិរ វាសេដ្ឋ ត្វំ ឯវំ វទេសិ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ អក្ខាតោ ព្រាហ្មណេន ចោក្ខរសាតិនាតិ ភារទ្វាជោ មាណវោ ឯវមាហ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយ យ្វាយំ អក្ខាតោ ព្រាហ្មណេន តារុក្ខេនាតិ អថ កិស្មឹ បន វោ វាសេដ្ឋ វិគ្គហោ កិស្មឹ វិវាទោ កិស្មឹ នានាវាទោតិ ។ មគ្គាមគ្គេ ភោ គោតម កិញ្ចាបិ ភោ គោតម ព្រាហ្មណា នានាមគ្គេ បញ្ញបេន្តិ អទ្ធរិយា ព្រាហ្មណា តិត្តិរិយា ព្រាហ្មណា ឆន្ទោកា ព្រាហ្មណា ពវ្ហារិជា ព្រាហ្មណា[១]

---

១ ឱ. ឆន្ទាវា ព្រាហ្មណា ព្រហ្មចរិយា ព្រាហ្មណាតិ ទិស្សតិ ។ ម. ពវ្ហារិជ្ឈា ព្រាហ្មណាតិ ទិស្សតិ ។

តេវិជ្ជសូត្រ ពោលអំពីវាសេដ្ឋមាណពនិងភារទ្វាជមាណព មានសេចក្តីប្រកាន់ខុសគ្នា

ព្រះគោតមដ៏ចម្រើន ការប្រកាន់ខុសគ្នាក៏មាន ការជជែកគ្នាក៏មាន ការពោលផ្សេងគ្នាក៏មាន អំពីផ្លូវនិងមិនមែនផ្លូវនេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋ បានឮថា អ្នកនិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលបោក្ខរសាតិព្រាហ្មណ៍ បានសំដែងប្រាប់ ឯភារទ្វាជមាណព ពោលយ៉ាងនេះថា នេះជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯង ដែលតារុក្ខព្រាហ្មណ៍ បានសំដែងប្រាប់ ម្នាលវាសេដ្ឋ កាលបើដូច្នោះ អ្នកទាំងឡាយ ប្រកាន់ខុសគ្នាព្រោះហេតុដូចម្តេច ជជែកគ្នា ព្រោះហេតុដូចម្តេច ពោលពាក្យផ្សេងគ្នា ព្រោះហេតុដូចម្តេច ។ វាសេដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន (យើងខ្ញុំព្រះអង្គជជែកគ្នា) ព្រោះផ្លូវនិងមិនមែនផ្លូវ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ គឺពួកអទ្ធរិយព្រាហ្មណ៍ ពួកតិត្តិរិយព្រាហ្មណ៍ ពួកឆន្ទោកព្រាហ្មណ៍ ពួកពវ្ហរិធព្រាហ្មណ៍ បញ្ញត្តផ្លូវទាំងឡាយផ្សេង ៗ គ្នា ក៏ពិតមែនហើយ

អថខោ សព្ពានិ តានិ និយ្យានិកានិ និយ្យន្តិ តក្ករស្ស ព្រហ្មសហព្យតាយ សេយ្យថាបិ ភោ គោតម គាមស្ស វា និគមស្ស វា អវិទូរេ ពហូនិ ចេបិ នានាមគ្គានិ ភវន្តិ អថខោ សព្ពានិ តានិ គាមសមោសរណានិ ភវន្តិ ឯវមេវ ខោ ភោ គោតម កិញ្ចាបិ ព្រាហ្មណា នានាមគ្គេ បញ្ញបេន្តិ អទ្ធរិយា ព្រាហ្មណា តិត្តិរិយា ព្រាហ្មណា ឆន្ទោកា ព្រាហ្មណា ពវ្ហរិជា ព្រាហ្មណា អថខោ សព្ពានិ តានិ និយ្យានិកានិ និយ្យន្តិ តក្ករស្ស ព្រហ្មសហព្យតាយាតិ ។ និយ្យន្តីតិ វាសេដ្ឋ វទេសិ ។ និយ្យន្តីតិ ភោ គោតម វទាមិ ។ និយ្យន្តីតិ វាសេដ្ឋ វទេសិ ។ និយ្យន្តីតិ ភោ គោតម វទាមិ ។ និយ្យន្តីតិ វាសេដ្ឋ វទេសិ ។ និយ្យន្តីតិ ភោ គោតម វទាមីតិ ។

តែថា ផ្លូវទាំងអស់នោះ សុទ្ធតែស្រោចស្រង់សត្វ នាំអ្នកប្រតិបត្តិតាម ផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបាន បពិត្រព្រះគោតមដ៏ចម្រើន ដូចផ្លូវដ៏ច្រើន ជិតស្រុកឬជិតនិគម ទោះបីជាផ្លូវផ្សេង ៗ គ្នាមែន ប៉ុន្តែ ផ្លូវនោះ សុទ្ធតែមូលមករកស្រុកទាំងអស់ ដូចម្តេចមិញ បពិត្រព្រះ គោតមដ៏ចម្រើន ពួកព្រាហ្មណ៍ទាំងឡាយ គឺពួកអទ្ធរិយព្រាហ្មណ៍ ពួក តិត្តិរិយព្រាហ្មណ៍ ពួកឆន្ទោកព្រាហ្មណ៍ ពួកពវ្ហរិជព្រាហ្មណ៍ បញ្ញត្ត ផ្លូវទាំងឡាយផ្សេង ៗ គ្នាក៏ពិតមែនហើយ តែផ្លូវទាំងអស់នោះសុទ្ធតែជាទី ស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយ នឹងពួកព្រហ្ម ដូច្នោះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ អ្នកនិយាយថា ផ្លូវរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែង ស្រោចស្រង់សត្វបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយ ថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបាន ។ ម្នាលវាសេដ្ឋៈ អ្នក និយាយថា ផ្លូវរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែងស្រោចស្រង់សត្វ បានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបាន ។ ម្នាលវាសេដ្ឋៈ អ្នកនិយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ និយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបាន ។

តេវិជ្ជសុត្តេ ភគវតោ វាសេដ្ឋានុយោគកថា

[១៧១] កឹ បន វាសេដ្ឋ អត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ អត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ ឯកាចរិយោបិ យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ អត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ អាចរិយបាចរិយោបិ[១] យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ អត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ

---

១ ឱ. ម. ឯកាចរិយបាចរិយោបិ ។

តេវិជ្ជសូត្រ ពោលអំពីព្រះមានព្រះភាគ ទ្រង់សាកសួរវាសេដ្ឋមាណព

[១៧១] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋ ចុះបណ្តាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ ទោះបីព្រាហ្មណ៍ម្នាក់ក្តី ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ វាសេដ្ឋមាណព ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនោះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យម្នាក់ ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្តាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យជាប្រធានលើអាចារ្យ ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្តាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ

យាវ សត្តមាចរិយមហាយុគា យេន ព្រហ្មា សក្ខិ ទិដ្ឋោ-តិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ អត្ថិ យេ តេ[១] តេវិជ្ជានំ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ តេវិជ្ជា ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមីហិតំ តទ-នុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុ-វាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សា-មិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្ស-បោ ភគុ តេបិ នំ[១] ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម យត្ថ វា ព្រហ្មា យេន វា ព្រហ្មា យហឹ វា ព្រហ្មាតិ ។ នោ ហិទំ ភោ គោតម ។

---

១ ឱ. តេតិ បទំ ន ទិស្សតិ ។ ២ ឱ. នន្តិ បទំ ន ទិស្សតិ ។

តាំងអំពីតំណនៃអាចារ្យជាគម្រប់ ៧ មក ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះពួកឫសីជាន់មុន ៗ ជាអ្នកតែងមន្ត អ្នកវាយមន្ត ដល់ពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា ក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាមបទមន្តបែបបុរាណនេះ ដែលពួកឫសី ធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្តដែលឫសីទាំងឡាយ ពោលមកហើយ តែងបង្រៀនតាមបទមន្តដែលឫសីទាំងឡាយ បង្រៀនមកហើយ ឫសីទាំងនោះឈ្មោះអ្វីខ្លះ គឺឫសីឈ្មោះ អដ្ឋកៈ ១ វាមកៈ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គិរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សប ១ ភគុ ១ ឫសីទាំងនោះតើមាន (ឫសីណាមួយ) ពោលពាក្យនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅត្រង់កន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយ ឃើញព្រហ្មនុ៎ះ ដូច្នេះដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការស្គាល់និងការឃើញនុ៎ះ មិនមានទេ ។

តេវិជ្ជសុត្តេ ភគវតោ វាសេដ្ឋានុយោគកថា

[១៧២] ឥតិ កិរ វាសេដ្ឋ នត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ(១) នត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ ឯកាចរិយោបិ យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ នត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ អាចរិយបាចរិយោបិ យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ នត្ថិ កោចិ តេវិជ្ជានំ ព្រាហ្មណានំ យាវ សត្តមាចរិយមហាយុគា យេន ព្រហ្មា សក្ខិ ទិដ្ឋោតិ ។

---

១ ឱ. ម. នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋាតិ បាឋោ សព្វត្ថ ន ទិស្សតិ ។

តេវិជ្ជសូត្រ ពោលអំពីព្រះមានព្រះភាគ ទ្រង់សាកសួរវាសេដ្ឋមាណព

[១៧២] ព្រះមានព្រះភាគ ត្រាស់សួរថា ម្នាលវាសេដ្ឋ បណ្ដាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើបានឮថា មាននរណាមួយ សូម្បីតែព្រាហ្មណ៍ម្នាក់ ដែលឃើញព្រហ្មផ្ទាល់ នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ វាសេដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះ មិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្ដាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យម្នាក់ ដែលឃើញព្រហ្មនេះផ្ទាល់ នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្ដាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យជាប្រធានលើអាចារ្យ ដែលឃើញនូវព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្ដាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ តាំងអំពីតំណអាចារ្យជាជីតារបស់អាចារ្យជាគម្រប់ ៧ ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ។

នោ ហិទំ ភោ គោតម ។ កឹ បន វាសេដ្ឋ យេបិ តេ[១] តេវិជ្ជានំ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ តេវិជ្ជា ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមីហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតម- នុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ នំ ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម យត្ថ វា ព្រហ្មា យេន វា ព្រហ្មា យហឹ វា ព្រហ្មាតិ ។ តេ វ[២] តេវិជ្ជា ព្រាហ្មណា ឯវមា- ហំសុ មយំ[៣] ន ជានាម មយំ[៤] ន បស្សាម

---

១ ឱ. តេតិ បទំ ន ទិស្សតិ ។ ២ ឱ. វត ។ ៣-៤ ឱ. យំ ។

បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាល វាសេដ្ឋៈ ចុះពួកឫសីជាន់មុន ៗ ដែលជាអ្នកតែងមន្ត ជាអ្នករាយមន្ត ដល់ពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា ពួកព្រាហ្មណ៍ដែលបាន សម្រេចត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាមបទមន្តបុរាណនេះ មកហើយ ដែលពួកឫសីធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលមក តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយ ពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងឡាយបង្រៀន មកហើយ ឫសីទាំងនោះឈ្មោះអ្វីខ្លះ គឺឫសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វា-សេដ្ឋៈ ១ កស្សប ១ ភគុ ១ ឫសីទាំងនោះតើមាន (ឫសីណាមួយ) ពោល យ៉ាងនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយ ឃើញព្រហ្មនុ៎ះ ដូច្នេះដែរឬទេ ។ ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃ-វិជ្ជានោះឯង តែងនិយាយយ៉ាងនេះថា យើងមិនស្គាល់ យើងមិនឃើញទេ

តស្ស សហព្យតាយ មគ្គំ ទេសេម អយមេវ ឧជុ-
មគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ
តក្ករស្ស ព្រហ្មសហព្យតាយាតិ ។

[១៧៣] តំ កឹ មញ្ញសិ វាសេដ្ឋ ឯវំ សន្តេ
តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ
សម្បជ្ជតីតិ ។ អទ្ធា ខោ ភោ គោតម ឯវំ សន្តេ
តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ
សម្បជ្ជតីតិ ។ សាធុ[១] វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យំ
ន ជានន្តិ យំ ន បស្សន្តិ តស្ស សហព្យតាយ
មគ្គំ ទេសិស្សន្តិ[២] អយមេវ ឧជុមគ្គោ អយមញ្ជ-
សាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្ម-
សហព្យតាយាតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ
វាសេដ្ឋ អន្ធវេណីបរំបរសំសត្តា[៣] បុរិមោបិ ន បស្សតិ

១ ឱ. តេ វត ។ ២ ឱ. ទេសេស្សន្តិ ។ ៣ ឱ. អន្ធវេណិបរម្បរា សំសត្តា ។

តែយើងទាំងឡាយសំដែងផ្លូវ ដើម្បីកើតជាមួយនឹងព្រហ្មនោះបានថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ។

[១៧៣] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនបានសេចក្តីអស្ចារ្យទេឬ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន កាលបើដូច្នេះ តាមដោយនូវពិត ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនមានសេចក្តីអស្ចារ្យទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាមិនស្គាល់ព្រហ្មណា មិនឃើញព្រហ្មណាទេ តែសំដែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មបាន ហេតុនុ៎ះនឹងយកជាការមិនបានទេ ។ ម្នាលវាសេដ្ឋ ដូចមនុស្សមានភ្នែកខ្វាក់ ដើរជាជួរតោងគ្នានិងគ្នា អ្នកដើរមុន ក៏មើលមិនឃើញ

មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតិ ឯវមេវ ខោ វាសេដ្ឋ អន្ធវេណូបមំ មញ្ញេ តេវិជ្ជានំ ព្រាហ្មណានំ ភាសិតំ បុរិមោបិ ន បស្សតិ មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតិ តេសមិទំ តេវិជ្ជានំ ព្រាហ្មណានំ ភាសិតំ ហស្សកំយេវ សម្បជ្ជតិ នាមកំយេវ សម្បជ្ជតិ រិត្តកំយេវ សម្បជ្ជតិ តុច្ឆកំយេវ សម្បជ្ជតិ ។ តំ កឹ មញ្ញសិ វាសេដ្ឋ បស្សន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយេ អញ្ញេ វាបិ ពហូ ជនា[១] យតោ ច ចន្ទិមសុរិយា ឧគ្គច្ឆន្តិ យត្ថ ច ឱគច្ឆន្តិ អាយាចន្តិ ថោមយន្តិ បញ្ជលិកា នមស្សមានា អនុបរិវត្តន្តីតិ ។ ឯវំ ភោ គោតម បស្សន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយេ អញ្ញេ វាបិ ពហូ ជនា យតោ ច ចន្ទិមសុរិយា ឧគ្គច្ឆន្តិ យត្ថ ច ឱគច្ឆន្តិ អាយាចន្តិ ថោមយន្តិ បញ្ជលិកា នមស្សមានា អនុបរិវត្តន្តីតិ ។

---

១ ម. អញ្ញេ ចាបិ ពហូ ជនា ។

អ្នកដើរកណ្តាល ក៏មើលមិនឃើញ អ្នកដើរក្រោយ ក៏មើលមិនឃើញ ដូចម្តេចមិញ ម្នាលវាសេដ្ឋៈ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មានទំនងឧបមេយ្យ ដូចជាមនុស្សខ្វាក់ដើរជាជួរ អ្នកដើរមុនក៏មើលមិនឃើញ អ្នកដើរកណ្តាលក៏មើលមិនឃើញ អ្នកដើរក្រោយក៏មើលមិនឃើញដូច្នោះឯង ភាសិតនេះរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ ជាពាក្យគួរឲ្យអ្នកផងសើចចំអកបាន ជាភាសិតឱនថយ (លាមក) ជាភាសិតទទេ ជាភាសិតសោះសូន្យ មែនពិត ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់ហេតុនោះដូចម្តេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា រមែងឃើញព្រះចន្ទ្រនិងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រនិងព្រះអាទិត្យ រះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរករសរសើរ ប្រណម្យអញ្ជលី នមស្ការដើរក្រឡឹង ។ បពិត្រព្រះគោ-តមដ៏ចម្រើន ដូច្នោះមែនហើយ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រនិងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រនិងព្រះអាទិត្យ រះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរករសរសើរ ប្រណម្យអញ្ជលី នមស្ការដើរក្រឡឹង ។

[១៧៤] តំ កឹ មញ្ញសិ វាសេដ្ឋ យំ បស្សន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយេ អញ្ញេ ចាបិ ពហូ ជនា យតោ ច[១] ចន្ទិមសុរិយា ឧគ្គច្ឆន្តិ យត្ថ ច ឱគច្ឆន្តិ អាយាចន្តិ ថោមយន្តិ បញ្ជលិកា នមស្សមានា អនុបរិវត្តន្តីតិ តេសម្បិ បហោន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយានំ[២] សហព្យតាយ មគ្គំ ទេសេតុំ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ចន្ទិមសុរិយានំ សហព្យតាយាតិ ។ នោ ហិទំ ភោ គោតម ។ ឥតិ កិរ វាសេដ្ឋ យំ បស្សន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយេ អញ្ញេ ចាបិ ពហូ ជនា យតោ ច ចន្ទិមសុរិយា ឧគ្គច្ឆន្តិ យត្ថ ច ឱគច្ឆន្តិ អាយាចន្តិ ថោមយន្តិ បញ្ជលិកា នមស្សមានា អនុបរិវត្តន្តិ តេសំបិ ន បហោន្តិ ចន្ទិមសុរិយានំ សហព្យតាយ មគ្គំ ទេសេតុំ អយមេវ ឧជុមគ្គោ

---

១ ឱ. ចសទ្ទោ នត្ថិ ។ ២ ឱ. អនុបរិវត្តន្តិ បហោន្តិ ចន្ទិមសុរិយានំ ។ ម. អនុបរិវត្តន្តិ បហោន្តិ តេវិជ្ជា ព្រាហ្មណា ចន្ទិមសុរិយានំ ។

តេវិជ្ជសូត្រ ពោលអំពីព្រះមានព្រះភាគ ទ្រង់សាកសួរវាសេដ្ឋមាណព

[១៧២] ម្នាលវាសេដ្ឋៈ អ្នកសំគាល់ហេតុនោះដូចម្ដេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រនិងព្រះអាទិត្យ សូម្បីតែពួកជនឯទៀតច្រើននាក់ក៏ឃើញព្រះចន្ទ្រនិងព្រះអាទិត្យដែរ ព្រះចន្ទ្រនិងព្រះអាទិត្យរះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរករ សរសើរ ប្រណម្យអញ្ជលី នមស្ការដើរក្រឡឹង ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ល្មមសំដែងផ្លូវដើម្បីកើតជាមួយនឹងព្រះចន្ទ្រព្រះអាទិត្យទាំងនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រះចន្ទ្រព្រះអាទិត្យ ដូច្នេះមានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានទេ ។ ម្នាលវាសេដ្ឋៈ បានឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រនិងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រនិងព្រះអាទិត្យរះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរករ សរសើរ ប្រណម្យអញ្ជលី នមស្ការដើរក្រឡឹង ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនល្មមនឹងសំដែងផ្លូវដើម្បីកើតជាមួយនឹងព្រះចន្ទ្រព្រះអាទិត្យទាំងនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជា

អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ចន្ទិមសុរិយានំ សហព្យតាយាតិ កឹ បន ន កិរ តេវិជ្ជេហិ ព្រាហ្មណេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ អាចរិយេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ អាចរិយបាចរិយេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ យាវ សត្តមាចរិយមហាយុគេហិ ព្រហ្មា សក្ខិ ទិដ្ឋោ យេបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ តេវិជ្ជា ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមីហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ

ផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រះចន្ទ្រព្រះអាទិត្យបានឡើយ ឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនដែលបានឃើញព្រហ្មណ៍ផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថា អាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថា ពួកអាចារ្យ ជាប្រធានលើអាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថា ពួកបុព្វាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តាំងអំពីតំណនៃអាចារ្យ ជាជីតារបស់អាចារ្យជាគំរប់ ៧ ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកឫសីជាន់មុន ៗ ដែលជាអ្នកតែងមន្ត ជាអ្នករាយមន្ត ដល់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាមបទមន្តនេះ ជារបស់ចាស់ដែលពួកឫសី ធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងឡាយ

សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គី អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ នំ ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម យត្ថ វា ព្រហ្មា យេន វា ព្រហ្មា យហឹ វា ព្រហ្មាតិ ។ តេ វ តេវិជ្ជា ព្រាហ្មណា ឯវមាហំសុ យំ ន ជានាម យំ ន បស្សាម តស្ស សហព្យតាយ មគ្គំ ទេសេម អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតា-យាតិ ។

[១៧៨] តំ កឹ មញ្ញសិ វាសេដ្ឋ ននុ ឯវំ សន្តេ តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ[១] ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ[២] ភោ គោតម ឯវំ សន្តេ តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ សាធុ វាសេដ្ឋ តេ ច[៣] វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យំ ន ជានន្តិ យំ ន បស្សន្តិ

---

១ ឱ. ម. អប្បាដិហិរកតំ ។ ២ ឱ. ខោសទ្ទោ នត្ថិ ។ ៣ ឱ. វត ។

បង្រៀនមកហើយ ឫសីណាខ្លះ គឺឫសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឫសីទាំងនោះ បានពោលយ៉ាងនេះនឹងអ្នកថា ព្រហ្ម នៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងស្គាល់ទីនុ៎ះ យើងឃើញព្រហ្មនុ៎ះ ដូច្នេះដែរឬ ។ ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជាទាំងនោះ ក៏ពោលយ៉ាងនេះថា យើងមិនដែលស្គាល់ព្រហ្ម ណា មិនដែលឃើញព្រហ្មណាទេ ប៉ុន្តែយើងសំដែងផ្លូវ ដើម្បីកើតជា មួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀតទាត់ ជាទី ស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយ នឹងព្រហ្មបាន ។

[១៧៥] ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនបានការទេ មិនមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើ ដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនបានការណ៍ទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃ-វិជ្ជាទាំងនោះ មិនដែលស្គាល់ព្រហ្មណា មិនដែលឃើញព្រហ្មណាទេ

តស្ស សហាព្យតាយ មគ្គំ ទេសេស្សន្តិ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហាព្យតាយាតិ នេតំ ឋានំ វិជ្ជតិ ។

[១៧៦] សេយ្យថាបិ វាសេដ្ឋ បុរិសោ ឯវំ វទេយ្យ អហំ[១] យា ឥមស្មិំ ជនបទេ ជនបទកល្យាណី តំ ឥច្ឆាមិ តំ កាមេមីតិ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ តំ ជនបទកល្យាណំ ខត្តិយឹ វា ព្រាហ្មណឹ វា វេស្សឹ វា សុទ្ទឹ វាតិ[២] ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ឯវំនាមា វា ឯវំគោត្តា វា ទីឃា វា រស្សា វា មជ្ឈិមា វា[៣] កាឡិកា វា សាមា វា

១ ម. ឯត្តន្តរេ ខោសទ្ទោ ទិស្សតិ ។ ២ ឱ. ម. ខត្តិយី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតិ ។ ៣ ឱ. មជ្ឈិមា វាតិ បាឋោ ន ទិស្សតិ ។

ប៉ុន្តែហ៊ានសំដែងផ្លូវ ដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មនោះបាន ហេតុនេះនឹងយកជាការណ៍ពុំបានឡើយ ។

[១៧៦] ម្នាលវាសេដ្ឋៈ ដូចជាបុរសពោលយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននូវស្ត្រីដែលមានរូបល្អក្នុងជនបទនេះ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន ស្ត្រីមានរូបល្អ ក្នុងជនបទដែលអ្នកប្រាថ្នាចង់បាន តើអ្នកស្គាល់ស្ត្រីមានរូបល្អ ក្នុងជនបទនោះ ថាជានាងខត្តិយានី ឬនាងព្រាហ្មណី ជានាងវេស្សី ឬជានាងសុទ្ទីដែរឬ ។ បុរសនោះកាលគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន ស្ត្រីមានរូបល្អ ក្នុងជនបទដែលអ្នកប្រាថ្នាចង់បាន តើអ្នកស្គាល់ស្ត្រីមានរូបល្អ ក្នុងជនបទនោះថា មានឈ្មោះយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ ខ្ពស់ ឬទាប ឬយ៉ាងកណ្តាល ខ្មៅ ឬស្រអែម

មត្ថុវច្ឆវិ វាតិ អមុកស្មឹ កាមេ វា និគមេ វា នគរេ វាតិ ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តំ ត្វំ ឥច្ឆសិ កាមេសីតិ ។ ឥតិ បុដ្ឋោ អាមាតិ[១] វទេយ្យ ។ តំ កឹ មញ្ញសិ វាសេដ្ឋ ននុ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភោ គោតម ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ វាសេដ្ឋ ន កិរ តេវិជ្ជេហិ ព្រាហ្មណេហិ ព្រហ្មា សក្ខិ ទិដ្ឋោ ។ បេ ។

[១៧៧] សេយ្យថាបិ វាសេដ្ឋ បុរិសោ ចាតុម្មហាបថេ[២] និស្សេណឹ ករេយ្យ បាសាទស្ស អារោហណាយ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ[៣] ត្វំ បាសាទស្ស អារោហណាយ និស្សេណឹ ករោសិ ជានាសិ តំ បាសាទំ បុរត្ថិមាយ វា[៤] ទិសាយ ទក្ខិណាយ វា[៥]

១ ឱ. អាមោតិ ។ ២ ម. ចាតុមហាបថេ ។ ៣ ឱ. យស្ស ។ ៤-៥ ឱ. វាសទ្ទោ ន ទិស្សតិ ។

ឬសម្បុរខ្មៅស្រស់ស្អាតថា នៅក្នុងស្រុកឯណោះ និគមឯណោះ ឬនគរឯណោះដែរឬ ។ បុរសនោះកាលគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកមិនស្គាល់ មិនឃើញស្រ្តីណា អ្នកប្រាថ្នាចង់បានស្រ្តីនោះឬ ។ បុរសនោះដែលគេសួរដូច្នេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ ភាសិតរបស់បុរសនោះ ជាភាសិតមិនបានការណ៍មិនមែនទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើយ៉ាងនេះ ភាសិតរបស់បុរសនោះ ជាភាសិតមិនបានការណ៍ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ បានឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ ។ បេ ។

[១៧៧] ម្នាលវាសេដ្ឋៈ ដូចជាបុរសធ្វើជណ្តើរ បម្រុងឡើងប្រាសាទត្រង់ផ្លូវធំបែកជា ៤ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរ បម្រុងឡើងប្រាសាទណា ចុះអ្នកស្គាល់ប្រាសាទនោះថា (នៅ) ក្នុងទិសខាងកើត ឬទិសខាងត្បូង

ទិសាយ បច្ឆិមាយ វា[១] ទិសាយ ឧត្តរាយ វា[២] ទិសាយ ឧទ្ធំ វា អធោ វា មជ្ឈោ[៣] វាតិ ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តស្ស ត្វំ ចាសាទស្ស អារោហណាយ និស្សេណឹ ករោសីតិ ។ ឥតិ បុដ្ឋោ អាមាតិ វទេយ្យ ។ តំ កឹ មញ្ញសិ វាសេដ្ឋ ននុ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភោ គោតម ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ វាសេដ្ឋ ន កិរ តេវិជ្ជេហិ ព្រាហ្មណេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ អាចរិយេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ

១-២ ឱ. វាសទ្ទោ ន ទិស្សតិ ។ ៣ ម. មជ្ឈិមោ ។

ឬទិសខាងលិច ឬទិសខាងជើង ប្រាសាទនោះខ្ពស់ ឬទាប ឬយ៉ាង កណ្តាលដែរឬ ។ បុរសនោះកាលគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនដឹង ទេ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកមិន ដឹង មិនឃើញប្រាសាទណាទេ តែធ្វើជណ្តើរបម្រុងឡើងប្រាសាទនោះ ឬ ។ បុរសនោះ កាលគេសួរដូច្នេះហើយ ក៏ឆ្លើយថា បាទ ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់ហេតុនោះ ដូចម្តេច កាលបើដូច្នោះ សំដីនៃបុរសនោះ មិនបានការណ៍មិនមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើយ៉ាងនេះ សំដីរបស់បុរសនោះមិនបានការណ៍ទេ ។ ម្នាលវាសេដ្ឋៈ មែនហើយ បានឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនដែលឃើញព្រហ្ម ផ្ទាល់នឹងភ្នែករបស់ខ្លួន បានឮថា ពួកអាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃ-វិជ្ជា ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួក

តេវិជ្ជានំ ព្រាហ្មណានំ អាចរិយបាចរិយេហិ ព្រហ្មា សក្ខិ ទិដ្ឋោ នបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ យាវ សត្តមាចរិយមហយុគា ព្រហ្មា សក្ខិ ទិដ្ឋោ យេបិ កិរ តេវិជ្ជានំ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ តេវិជ្ជា ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមីហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ នំ ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម យត្ថ វា ព្រហ្មា យេន វា ព្រហ្មា យហឹ វា ព្រហ្មាតិ ។ តេ វ[១] តេវិជ្ជា ព្រាហ្មណា ឯវមាហំសុ

១ ឱ. វត ។

អាចារ្យជាប្រធានលើអាចារ្យ របស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកបុព្វាចារ្យរបស់ពួកព្រាហ្មណ៍ តាំងពីតំណនៃអាចារ្យ ជាជីតារបស់អាចារ្យជាគម្រប់ ៧ ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែលរបស់ខ្លួនដែរ បានឮថា ពួកឫសីជាន់មុន ៗ ដែលជាអ្នកតែងមន្ត ជាអ្នករាយមន្ត ដល់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតែបទមន្តបុរាណនេះដែលពួកឫសី ធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយពោលមកហើយ តែងបង្រៀនតាមបទមន្តដែលឫសីទាំងឡាយបង្រៀនមកហើយ ឫសីណាខ្លះ គឺឫសីឈ្មោះ អដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ សូម្បីឫសីទាំងនោះ ក៏មិនពោលយ៉ាងនេះថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នេះដែរឬទេ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ក៏ពោលយ៉ាងនេះថា

យំ ន ជានាម យំ ន បស្សាម តស្ស សហព្យតាយ មគ្គំ ទេសេម អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយាតិ ។ តំ កឹ មញ្ញសិ វាសេដ្ឋ ននុ ឯវំ សន្តេ តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភោ គោតម ឯវំ សន្តេ តេវិជ្ជានំ ព្រាហ្មណានំ អប្បាដិហិរិកតំ ភាសិតំ សម្បជ្ជតីតិ ។ សាធុ វាសេដ្ឋ តេ ច វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យំ ន ជានន្តិ យំ ន បស្សន្តិ តស្ស សហព្យតាយ មគ្គំ ទេសេស្សន្តិ អយមេវ ឧជុមគ្គោ អយមញ្ជសាយនោ និយ្យានិកោ និយ្យាតិ តក្ករស្ស ព្រហ្មសហព្យតាយាតិ នេតំ ឋានំ វិជ្ជតិ ។

យើងមិនស្គាល់ព្រហ្មណា យើងមិនឃើញព្រហ្មណាទេ ប៉ុន្តែយើងសំដែងផ្លូវ ដើម្បីទៅកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះឲ្យទៅកើតជាមួយនឹងព្រហ្មបាន ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ សំដីរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាសំដីមិនបានការណ៍ឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ពិតមែនហើយ កាលបើយ៉ាងនោះ សំដីរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាសំដីមិនបានការណ៍ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះមិនស្គាល់ព្រហ្មណា មិនឃើញព្រហ្មណាទេ ប៉ុន្តែហ៊ានសំដែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្ម ហេតុនេះយកជាការណ៍ពុំបានទេ ។

តេវិជ្ជសុត្តេ មគ្គាមគ្គកថា អចិរវតីនទីឧបមា

[១៧៨] សេយ្យថាបិ វាសេដ្ឋ អយំ អចិរវតី នទី បូរា ឧទកស្ស សមតិត្តិកា កាកបេយ្យា អថខោ[១] បុរិសោ អាគច្ឆេយ្យ ចារត្ថិកោ ចារគវេសី ចារគាមី[២] ចារំ តរិតុកាមោ សោ ឱរិមេ តីរេ ឋិតោ ចារិមន្តីរំ អវ្ហេយ្យ ឯហិ ចាភចារំ ឯហិ ចាភចារន្តិ ។ តំ កឹ មញ្ញសិ វាសេដ្ឋ អបិ នុ តស្ស បុរិសស្ស អវ្ហាយន-ហេតុ វា អាយាចនហេតុ វា បត្ថនហេតុ វា អភិនន្ទ-នហេតុ វា អចិរវតិយា នទិយា ចារិមន្តីរំ ឱរិមន្តីរំ អាគច្ឆេយ្យាតិ ។ នោ ហិទំ ភោ គោតម ។ ឯវមេវ ខោ វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យេ ធម្មា ព្រាហ្មណ-ការកា តេ ធម្មេ បហាយ វត្តមានា យេ ធម្មា អព្រាហ្មណការកា តេ ធម្មេ សមាទាយ វត្តមានា ឯវមាហំសុ ឥន្ទំ អវ្ហយាម សោមំ អវ្ហយាម វរុណំ អវ្ហយាម ឦសានំ អវ្ហយាម បជាបតឹ អវ្ហយាម

១ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។ ២ ម. បារគាមី បារគវេសី ។

[១៧៨] ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹកល្មមក្អែកទំមាត់ច្រាំងឱនផឹកបាន គ្រានោះ មានបុរសអ្នកត្រូវការត្រើយខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកនឹងទៅត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បុរសនោះបានមកដល់ ក៏ឈរនៅត្រើយខាងអាយ ហើយស្រែកហៅត្រើយខាងនាយថា ម្នាលត្រើយខាងនាយ អ្នកចូរមករកត្រើយខាងអាយ ម្នាលត្រើយខាងនាយ អ្នកចូរមករកត្រើយខាងអាយ ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច ត្រើយខាងនាយនៃស្ទឹងអចិរវតី (នោះ) មុខជានឹងមករកត្រើយខាងអាយ ព្រោះហេតុនៃបុរសនោះស្រែកហៅ ឬព្រោះហេតុនៃបុរសនោះអង្វរ ព្រោះហេតុសេចក្តីប្រាថ្នា ឬព្រោះហេតុសេចក្តីត្រេកអរបានដែរឬ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាក៏ដូច្នោះដែរ គេប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ចេញហើយ ប្រព្រឹត្តសមាទានធម៌ ដែលមិនមែនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ ហើយពោលយ៉ាងនេះថា យើងហៅព្រះឥន្ទ្រ ហៅព្រះចន្ទ ហៅព្រះវរុណ ហៅព្រះឦសាន ហៅព្រះបជាបតិ

ព្រហ្មានំ អវ្ហយាម មហិន្ទំ អវ្ហយាមាតិ ។ តេ ច វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យេ ធម្មា ព្រាហ្មណករណា តេ ធម្មេ បហាយ វត្តមានា យេ ធម្មា អព្រាហ្មណករណា តេ ធម្មេ សមាទាយ វត្តមានា អវ្ហាយនហេតុ វា អាយាចនហេតុ វា បត្ថនហេតុ វា អភិនន្ទនហេតុ វា កាយស្ស ភេទា បរម្មរណា ព្រហ្មានំ សហព្យូបគា ភវិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

[១៧៩] សេយ្យថាបិ វាសេដ្ឋ អយំ អចិរវតី នទី បូរា ឧទកស្ស សមតិត្ថិកា កាកបេយ្យា អថ បុរិសោ អាគច្ឆេយ្យ បារត្ថិកោ បារគវេសី បារគាមី បារំ តរិតុកាមោ សោ ឱរិមេ តីរេ ទឡ្ហាយ អន្ទុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពទ្ធោ តំ កឹ មញ្ញសិ វាសេដ្ឋ ននុ[១] សោ បុរិសោ អចិរវតិយា នទិយា ឱរិមា តីរា[២] បារិមន្តីរំ គច្ឆេយ្យាតិ ។ នោ ហិទំ ភោ គោតម ។

---

១ ឱ. អបិ នុ ។ ម. អបិ នុ ខោ ។ ២ ឱ. ឱរិមតីរា ។

ហៅព្រះព្រហ្ម ហៅព្រះមហិន្ទ្រ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ ហើយ ប្រព្រឹត្តសមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ លុះបែកធ្លាយកាយ បន្ទាប់អំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ព្រោះហេតុស្រែកហៅ ឬព្រោះហេតុសេចក្តីអង្វរ ព្រោះហេតុសេចក្តីប្រាថ្នា ឬព្រោះហេតុសេចក្តីត្រេកអរ ហេតុដូច្នេះនេះ មិនដែលមានឡើយ ។

[១៧៩] ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹក ល្មមតែក្អែកទំមាត់ច្រាំងឱនផឹកបាន គ្រានោះ មានបុរសអ្នកត្រូវការត្រើយខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកទៅត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បានមកដល់ (ស្ទឹងនោះ) ក៏យកខ្សែដ៏មាំ មកចងដើមដៃទៅខាងក្រោយ (ចងស្លាបសេក) យ៉ាងខ្ជាប់ទុកនៅត្រើយខាងអាយ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះ នឹងចេញពីត្រើយខាងអាយ នៃស្ទឹងអចិរវតី ទៅត្រើយខាងនាយ តើបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនបានទេ ។

ឯវមេវ ខោ វាសេដ្ឋ បញ្ចិមេ កាមគុណា អរិយស្ស វិនយេ អន្ទុន្តិបិ វុច្ចន្តិ ពន្ធនន្តិបិ វុច្ចន្តិ កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ។ ជិវ្ហាវិញ្ញេយ្យា រសា ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយាតិ ។ ឥមេ ខោ វាសេដ្ឋ បញ្ច កាមគុណា អរិយស្ស វិនយេ អន្ទុន្តិបិ វុច្ចន្តិ ពន្ធនន្តិបិ វុច្ចន្តិ ឥមេ ខោ វាសេដ្ឋ បញ្ច កាមគុណេ តេវិជ្ជា ព្រាហ្មណា គធិតា មុច្ឆិតា អជ្ឈោសន្នា អនាទីនវទស្សាវិនោ[១] អនិស្សរណបញ្ញា បរិភុញ្ជន្តិ ។ តេ ច វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យេ ធម្មា ព្រាហ្មណការណា តេ ធម្មេ បហាយ វត្តមានា យេ ធម្មា អព្រាហ្មណការណា តេ ធម្មេ សមាទាយ វត្តមានា

---

១ ឱ. អជ្ឈាបន្នា អនាទីនវទស្សាវី ។ ម. អជ្ឈោបន្នា អនាទីនវទស្សាវិនោ ។

តេវិជ្ជសូត្រ មគ្គាមគ្គកថា កាមគុណទាំង ៥

ម្នាលវាសេដ្ឋៈ ដូច្នោះមែនហើយ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅកាមគុណទាំង ៥ នេះថា ខ្នោះក៏មាន ថា ចំណងក៏មាន កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូប ដែលគួរដឹងបានដោយចក្ខុ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ សំឡេង ដែលគួរដឹងបានដោយត្រចៀក ។ បេ ។ ក្លិន ដែលគួរដឹងបានដោយច្រមុះ ។ រស ដែលគួរដឹងបានដោយអណ្តាត ។ ផោដ្ឋព្វៈ ដែលគួរដឹងបានដោយកាយ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ ។ ម្នាលវាសេដ្ឋៈ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅកាមគុណ ៥ នេះឯង ថា ខ្នោះ ក៏មាន ថា ចំណងក៏មាន ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាប់ជក់នៅ ជ្រប់នៅ លិចលង់នៅ ឃើញថាមិនមានទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន តែងបរិភោគកាមគុណទាំង៥ នេះឯង ។ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ ប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ចេញ ហើយប្រព្រឹត្ត សមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ

បញ្ច កាមគុណេ គធិតា មុច្ឆិតា អជ្ឈោសន្នា អនាទីនវទស្សាវិនោ អនិស្សរណបញ្ញា បរិភុញ្ជន្តិ កាមច្ឆន្ទពទ្ធា កាយស្ស ភេទា បរម្មរណា ព្រហ្មានំ សហព្យូបគា ភវិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

[១៨០] សេយ្យថាបិ វាសេដ្ឋ អយំ អចិរវតី នទី បូរា ឧទកស្ស សមតិត្តិកា កាកបេយ្យា អថ ខោ បុរិសោ អាគច្ឆេយ្យ បារត្ថិកោ បារគវេសី បារគាមី បារំ តរិតុកាមោ សោ ឱរិមេ តីរេ សសីសំ បារុបិត្វា និបជ្ជេយ្យ ។ តំ កឹ មញ្ញសិ វាសេដ្ឋ អបិ នុ ខោ សោ បុរិសោ អចិរវតិយា នទិយា ឱរិមា តីរា បារិមន្តីរំ គច្ឆេយ្យាតិ ។ នោ ហិទំ ភោ គោតម ។ ឯវមេវ ខោ វាសេដ្ឋ បញ្ចិមេ នីវរណា អរិយស្ស វិនយេ អាវរណា-

ជាប់ជក់នៅ លិចលង់នៅ ឃើញថា មិនមានទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន តែងបរិភោគកាមគុណទាំង ៥ ជាអ្នកមានកាមច្ឆន្ទៈជាចំណង លុះបែកធ្លាយកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ហេតុនេះមិនគួរមានឡើយ ។

[១៨០] ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹក ល្មមក្អែកទំមាត់ច្រាំងឱនផឹកបាន វេលានោះ មានបុរសអ្នកត្រូវការត្រើយខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកទៅកាន់ត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បានមកដល់ បុរសនោះ ក៏ទទូរអស់ទាំងក្បាល ហើយដេកទៀបត្រើយខាងនាយ ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះគួរចេញអំពីត្រើយខាងអាយនៃស្ទឹងអចិរវតី ទៅឯត្រើយខាងនាយបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនេះពុំគួរទៅបានទេ ។ ម្នាលវាសេដ្ឋៈ ក៏ដូច្នោះដែរ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅនីវរណធម៌ ៥ ប្រការនេះថា អាវរណៈ

តិបិ វុច្ចន្តិ នីវរណាតិបិ វុច្ចន្តិ ឱនាហនាតិបិ(១) វុច្ចន្តិ បរិយោហនាតិបិ(២) វុច្ចន្តិ កតមេ បញ្ច កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ឥមេ ខោ វាសេដ្ឋ បញ្ច នីវរណា អរិយស្ស វិនយេ អាវរណាតិបិ វុច្ចន្តិ នីវរណាតិបិ វុច្ចន្តិ ឱនាហនាតិបិ វុច្ចន្តិ បរិយោហនាតិបិ វុច្ចន្តិ ។

[១៨១] ឥមេហិ ខោ វាសេដ្ឋ បញ្ចហិ នីវរណេហិ តេវិជ្ជា ព្រាហ្មណា អាវុដា និវុដា ឱផុដា បរិយោនទ្ធា ។ តេ ច វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា យេ ធម្មា ព្រាហ្មណការណា តេ ធម្មេ បហាយ វត្តមានា យេ ធម្មា អព្រាហ្មណការណា តេ ធម្មេ សមាទាយ វត្តមានា បញ្ចហិ នីវរណេហិ អាវុដា និវុដា ឱផុដា បរិយោនទ្ធា តេ(៣) កាយស្ស ភេទា បរម្មរណា ព្រហ្មសហព្យូបគា(៤) ភវិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

---

១ ឱ. ឱនហាតិបិ បាហោ ។ ២ ឱ. បរិយោនហាតិបិ បាហោ ។ ម. បរិយោនាហនាតិបិ បាហោ ។ ៣ ឱ. តេតិ បទំ ន ទិស្សតិ ។ ៤ ឱ. ព្រហ្មានំ សហវ្យូបគា ។ ម. ព្រហ្មានំ សហព្យូបគា ។

(គ្រឿងទប់) ក៏បាន ហៅថា នីវរណៈ (គ្រឿងរាំង) ក៏បាន ហៅ ថា ឱនាហនៈ (គ្រឿងទាញយិត) ក៏បាន ហៅថា បរិយោហនៈ (គ្រឿងរួបរឹត) ក៏បាន នីវរណៈទាំង ៥ ប្រការ តើដូចម្តេចខ្លះ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ម្នាលវាសេដ្ឋៈ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅ នីវរណៈ ទាំង ៥ ប្រការនេះឯង ថា អាវរណៈ ក៏បាន ហៅថា នីវរណៈ ក៏បាន ហៅថា ឱនាហនៈ ក៏បាន ហៅថា បរិយោហនៈ ក៏បាន ។

[១៨១] ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកបានត្រៃវិជ្ជា ត្រូវ នីវរណៈទាំង ៥ នេះដោតក្រង ចងរឹត ចងក្រៀក ចាក់ស្រេះហើយ ។ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គល ឲ្យទៅជាព្រាហ្មណ៍ចេញ ហើយប្រព្រឹត្តសមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ ព្រាហ្មណ៍ទាំងនោះ ត្រូវ នីវរណៈ ទាំង ៥ ដោតក្រង ចងរឹត ចងក្រៀក ចាក់ស្រែះហើយ លុះ បែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួក ព្រហ្ម ហេតុនេះមិនមានសោះឡើយ ។

[១៨២] តំ កឹ មញ្ញសិ វាសេដ្ឋ កិន្តិ[១] តេ សុតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ សបរិគ្គហោ វា ព្រហ្មា អបរិគ្គហោ វាតិ ។ អបរិគ្គហោ ភោ គោតម ។ សវេរចិត្តោ វា អវេរចិត្តោ វាតិ ។ អវេរចិត្តោ ភោ គោតម ។ សព្យាបជ្ឈចិត្តោ វា អព្យាបជ្ឈចិត្តោ វាតិ ។ អព្យាបជ្ឈចិត្តោ ភោ គោតម ។ សំកិលិដ្ឋចិត្តោ វា អសំកិលិដ្ឋចិត្តោ វាតិ ។ អសំកិលិដ្ឋចិត្តោ ភោ គោតម ។ វសវត្តិ វា អវសវត្តិ វាតិ ។ វសវត្តិ ភោ គោតម ។ តំ កឹ មញ្ញសិ វាសេដ្ឋ សបរិគ្គហា វា តេវិជ្ជា ព្រាហ្មណា

១ ឱ. កិញ្ចិ ។

[១៨២] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកធ្លាប់បានឮពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យទាំងឡាយ និយាយថា ព្រហ្មមានស្ត្រីជាគ្រឿងជាប់ចំពាក់ ឬមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ទេ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ទេ ។ ព្រហ្មមានចិត្តចងពៀរ ឬមិនបានចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានចិត្តចងពៀរទេ ។ ព្រហ្មមានចិត្តប្រកបដោយព្យាបាទ ឬមិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានចិត្តប្រកបដោយព្យាបាទទេ ។ ព្រហ្មមានចិត្តសៅហ្មង ឬមិនមានចិត្តសៅហ្មងទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានចិត្តសៅហ្មងទេ[១] ។ ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ឬប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន[២] ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានស្ត្រីជាគ្រឿងជាប់

---

១ អដ្ឋកថា ពន្យល់ថា ព្រហ្មមិនមានចិត្តសៅហ្មង ព្រោះមិនមាន ឧទ្ធច្ចកុក្កុច្ចៈ ។ ២ ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ព្រោះមិនមានវិចិកិច្ឆា ។

អបរិគ្គហា ភោតិ ។ សបរិគ្គហា ភោ គោតម ។ សវេរចិត្តា វា អវេរចិត្តា វាតិ ។ សវេរចិត្តា ភោ គោតម ។ សព្យាបជ្ឈចិត្តា វា អព្យាបជ្ឈចិត្តា វាតិ ។ សព្យាបជ្ឈចិត្តា ភោ គោតម ។ សំកិលិដ្ឋចិត្តា វា អសំកិលិដ្ឋចិត្តា វាតិ ។ សំកិលិដ្ឋចិត្តា ភោ គោតម ។ វសវត្តី វា អវសវត្តី វាតិ ។ អវសវត្តី ភោ គោតម ។

[១៨៣] ឥតិ កិរ[១] តេ វាសេដ្ឋ សបរិគ្គហា តេវិជ្ជា ព្រាហ្មណា អបរិគ្គហោ ព្រហ្មា អបិ នុ ខោ សបរិគ្គហានំ តេវិជ្ជានំ ព្រាហ្មណានំ អបរិគ្គហេន ព្រហ្មុនា សទ្ធឹ សំសន្ទតិ សមេតីតិ ។ នោ ហេតំ ភោ

១ ឱ. តេតិ បទំ ន ទិស្សតិ ។

ចំពាក់ ឬមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានស្ត្រីជាគ្រឿងជាប់ចំពាក់ (គ្រប់គ្រងស្រីដែរ) ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តចងពៀរ ឬមិនមានចិត្តចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តចងពៀរ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តប្រកបដោយព្យាបាទ ឬ មិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា មានចិត្តប្រកបដោយព្យាបាទ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ឬមានចិត្តមិនសៅហ្មងទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តបាន ឬប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។

[១៨៣] ម្នាលវាសេដ្ឋៈ អើ បើថា ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ មានស្ត្រីជាគ្រឿងជាប់ចំពាក់ដូច្នេះ ឯព្រហ្មជាអ្នកមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ទេ ចុះបណ្តាពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ដែលមានស្ត្រីជាគ្រឿងជាប់ចំពាក់ តើប្រៀបផ្ទឹមនឹងព្រហ្មដែលមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់សមគ្នាដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនុ៎ះប្រៀប

គោតម ។ សាធុ វាសេដ្ឋ តេ ច[១] វាសេដ្ឋ សបរិគ្គ-
ហា តេវិជ្ជា ព្រាហ្មណា កាយស្ស ភេទា បរម្មរណា
អបរិគ្គហស្ស ព្រហ្មុនោ សហព្យូបគា ភវិស្សន្តីតិ នេតំ
ឋានំ វិជ្ជតិ ។ ឥតិ កិរ តេ វាសេដ្ឋ សវេរចិត្តា តេវិជ្ជា
ព្រាហ្មណា អវេរចិត្តោ ព្រហ្មា អបិ នុ ខោ សវេរចិត្តានំ
តេវិជ្ជានំ ព្រាហ្មណានំ អវេរចិត្តេន ព្រហ្មុនា សទ្ធឹ
សំសន្ទតិ សមេតីតិ ។ នោ ហេតំ ភោ គោតម ។
ឥតិ កិរ តេ វាសេដ្ឋ សព្យាបជ្ឈចិត្តា តេវិជ្ជា ព្រាហ្ម-
ណា អព្យាបជ្ឈចិត្តោ ព្រហ្មា សំកិលិដ្ឋចិត្តា តេវិជ្ជា
ព្រាហ្មណា អសំកិលិដ្ឋចិត្តោ ព្រហ្មា អវសវត្តី តេវិជ្ជា
ព្រាហ្មណា វសវត្តិ ព្រហ្មា អបិ នុ ខោ អវសវត្តីនំ
តេវិជ្ជានំ ព្រាហ្មណានំ វសវត្តិនា ព្រហ្មុនា សទ្ធឹ សំ-

១ ឱ. វត ។

ធៀបមិនសមគ្នាទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលមានស្ត្រីជាគ្រឿងជាប់ចំពាក់ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏ទៅកើតជាមួយនឹងព្រហ្ម ដែលមិនមានស្ត្រីជាគ្រឿងជាប់ចំ-ពាក់ ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលវាសេដ្ឋៈ បានឮដូច្នេះថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ មានចិត្តចងពៀរ ចំណែកខាងព្រហ្មមិនមានចិត្តចងពៀរទេ ប្រៀបធៀបពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលមានចិត្តចងពៀរ ជាមួយនឹងព្រហ្មដែលមិនមានចិត្តចងពៀរ តើសមគ្នាដែរឬ ។ ប-ពិត្រព្រះគោតមដ៏ចម្រើន ដំណើរនុ៎ះប្រៀបធៀបមិនបានទេ ។ ម្នាលវាសេដ្ឋៈ បានឮដូច្នេះថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ មានចិត្តប្រកបដោយព្យា-បាទ ព្រហ្មមិនមានចិត្តប្រកបដោយព្យាបាទ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ព្រហ្មមិនមានចិត្តសៅហ្មងទេ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ចុះបើប្រៀបធៀបពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលប្រព្រឹត្តទៅតាមអំណាចចិត្តមិនបាន ជាមួយនឹងព្រហ្ម ដែលព្រឹត្តទៅតាមអំណាចចិត្ត

សន្ធតិ សមេតីតិ ។ នោ ហេតំ ភោ គោតម ។ សាធុ វាសេដ្ឋ តេ ច វាសេដ្ឋ អវសវត្តី តេវិជ្ជា ព្រាហ្មណា កាយស្ស ភេទា បរម្មរណា វសវត្តិស្ស ព្រហ្មុនោ សហព្យូបគា ភវិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។ ឥធ ខោ បន តេ[១] វាសេដ្ឋ តេវិជ្ជា ព្រាហ្មណា អាសីទិត្វា សំសីទន្តិ សំសីទិត្វា វិសត្តំ[២] ចាបុណន្តិ សុខតរំ មញ្ញេ តរន្តិ[៣] តស្មា ឥទំ តេវិជ្ជានំ ព្រាហ្មណានំ តេវិជ្ជាឥរិណន្តិបិ វុច្ចតិ តេវិជ្ជាវិវនន្តិបិ វុច្ចតិ តេវិជ្ជាព្យសនន្តិបិ វុច្ចតីតិ ។

[១៨៤] ឯវំ វុត្តេ វាសេដ្ឋោ មាណវោ ភគវន្តំ ឯតទវោច សុតំ មេតំ ភោ គោតម សមណោ គោតមោ ព្រហ្មានំ សហព្យតាយ មគ្គំ ជានាតីតិ ។ តំ កឹ មញ្ញសិ វាសេដ្ឋ អាសន្នេ ឥតោ មនសាកតំ

---

១ ឱ. តេតិ បទំ ន ទិស្សតិ ។ ២ ឱ. វិសាទំ វា ។ ម. វិសារំ ។ ៣ ឱ. បតរន្តិ ។

បាន តើសមគ្នាដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនុ៎ះប្រៀបធៀបមិនបានទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទាំងនោះ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្ដីស្លាប់ នឹងទៅកើតជាមួយនឹងព្រហ្ម ដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជា ទាំងនោះចូលទៅ (កាន់ទីមិនមែនផ្លូវដោយសំគាល់ថាផ្លូវ) ក្នុងផ្លូវជាទីទៅកាន់ព្រហ្មលោក (ដូចជា) ចុះទៅ (កាន់ទីមានភក់ដោយសំគាល់ថាទីរាបស្មើ) លុះចុះទៅហើយ ក៏ដល់នូវសេចក្ដីបាក់បែក (នៃអវយវៈតូចធំ) សំគាល់នូវការឆ្លងថាស្រួលហើយ ក៏ឆ្លងទៅ ព្រោះហេតុនោះ ត្រៃវិជ្ជារបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានេះ អ្នកប្រាជ្ញ តែងហៅថា ព្រៃធំ គឺត្រៃវិជ្ជាខ្លះ ហៅថា ព្រៃដែលគ្មានទឹក គឺត្រៃវិជ្ជា ខ្លះ ហៅថា សេចក្ដីវិនាស គឺត្រៃវិជ្ជា ខ្លះ ។

[១៨៤] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណព ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថាព្រះសមណគោតមស្គាល់ផ្លូវ ដើម្បីទៅកើតជាមួយនឹងព្រហ្មមែនឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច មនសាកតគ្រាម នៅក្នុងទីជិតនឹងទីនេះ

ន ឥតោ ទូរេ មនសាកតន្តិ ។ ឯវំ ភោ គោតម អាសន្នេ ឥតោ មនសាកតំ ន ឥតោ ទូរេ មនសាកតន្តិ ។ តំ កឹ មញ្ញសិ វាសេដ្ឋ ឥធ[១] បុរិសោ មនសាកតេ ជាតសំវឌ្ឍោ[២] តមេនំ មនសាកតា[៣] តាវទេវ អវសតំ មនសាកតស្ស មគ្គំ បុច្ឆេយ្យុំ សិយា នុ ខោ វាសេដ្ឋ តស្ស បុរិសស្ស មនសាកតេ ជាតសំវឌ្ឍស្ស មនសាកតស្ស មគ្គំ បុដ្ឋស្ស ទន្ធាយិតត្តំ វា វិត្ថាយិតត្តំ វាតិ ។ នោ ហិទំ ភោ គោតម ។ តំ កិស្ស ហេតុ ។ អមុកោ ហិ ភោ គោតម បុរិសោ មនសាកតេ ជាតសំវឌ្ឍោ តស្ស សព្វានេវ មនសាកតស្ស មគ្គានិ សុវិទិតានីតិ ។ សិយា ខោ វាសេដ្ឋ តស្ស បុរិសស្ស មនសាកតេ ជាតសំវឌ្ឍស្ស មនសាកតស្ស មគ្គំ បុដ្ឋស្ស

---

១ ឱ. ម. ឥធស្ស ។ ២ ឱ. ជាតោ សំវទ្ធោ ។ ៣ ឱ. ម. មនសាកដតោ ។

មនសាកតគ្រាម មិនមែននៅក្នុងទីឆ្ងាយអំពីទីនេះទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះហើយ មនសាកតគ្រាមនៅក្នុងទីជិតនឹងទីនេះ មនសាកតគ្រាម មិននៅក្នុងទីឆ្ងាយអំពីទីនេះទេ ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច បុរសដែលកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាមនេះ មានអ្នកផង សួររកផ្លូវនៃមនសាកតគ្រាម ចំពោះបុរសនោះដែលចេញទៅ អំពីមនសាកតគ្រាមក្នុងខណៈនោះ ម្នាលវាសេដ្ឋៈ បុរសដែលកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាមនោះ កាលបើគេសួររកផ្លូវនៃមនសាកតគ្រាម សំដីយឺតយូរនិងអឹមអៀម តើមានខ្លះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន សំដីនេះមិនយឺតយូរ មិនអឹមអៀមទេ ។ សេចក្ដីនោះព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះបុរសឯណោះកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាម បានជាបុរសនោះស្គាល់ផ្លូវទាំងអស់ ដែលទៅកាន់មនសាកតគ្រាម ដោយច្បាស់លាស់ ។ ម្នាលវាសេដ្ឋៈ បុរសដែលកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាមនោះ កាលបើ មានអ្នកផង សួររកផ្លូវនៃមនសាកតគ្រាម គង់មាន

ឆន្ទាយិតត្តំ វា វិត្ថាយិតត្តំ វា[១] ឆ ត្វេវ តថាគ-
តស្ស ព្រហ្មលោកេ វា ព្រហ្មលោកគាមិនិយា វា
បដិបទាយ បុដ្ឋស្ស ឆន្ទាយិតត្តំ វា វិត្ថាយិតត្តំ វា
ព្រហ្មាឆញ្ចាហំ[២] វាសេដ្ឋ បជាឆាមិ ព្រហ្មលោកញ្ច
ព្រហ្មលោកគាមិនិញ្ច បដិបទំ យថាបដិបន្នោ ច
ព្រហ្មា[៣] ព្រហ្មលោកំ ឧបបន្នោ តញ្ច បជាឆាមីតិ ។

[១៨៤] ឯវំ វុត្តេ វាសេដ្ឋោ មាណវោ ភគវន្តំ
ឯតទវោច សុតំ មេតំ ភោ គោតម សមណោ
គោតមោ ព្រហ្មានំ សហាព្យតាយ មគ្គំ ទេសេតីតិ
សាធុ នោ ភវំ គោតមោ ព្រហ្មានំ សហាព្យតាយ
មគ្គំ ទេសេតុ ឧល្លុម្បតុ ភវំ គោតមោ ព្រាហ្ម-
ណិំ បជន្តិ ។ តេនហិ វាសេដ្ឋ សុណាហិ
សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ
ខោ វាសេដ្ឋោ មាណវោ ភគវតោ បច្ចស្សោសិ ។

១ ឱ. នោ ។ ២ ឱ. ព្រហ្មានំ បហំ ។ ៣ ឱ. ម. ព្រហ្មាតិ បទំ ន ទិស្សតិ ។

សំដីយឺតយូរ និងអឹមអៀមខ្វះ ឯតថាគតកាលបើអ្នកផង សួររកផ្លូវទៅកាន់ព្រហ្មលោក ឬបដិបទាជាទីទៅកាន់ព្រហ្មលោក មិនមានការប្រព្រឹត្ត យឺតយូរនិងការអឹមអៀមឡើយ ម្នាលវាសេដ្ឋៈ តថាគត ស្គាល់ទាំងព្រហ្មស្គាល់ទាំងព្រហ្មលោក ស្គាល់ទាំងបដិបទា ជាទីទៅកាន់ព្រហ្មលោក មិនតែប៉ុណ្ណោះសោត ព្រហ្មប្រតិបត្តិយ៉ាងណា ទើបបានទៅកើតក្នុងព្រហ្មលោក តថាគតក៏ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះ ។

[១៨៥] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណព ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោ-តមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះសមណគោតមសំដែងផ្លូវ ដើម្បីទៅកើតជាមួយនឹងព្រហ្មបាន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះគោតមដ៏ចម្រើន សំដែងផ្លូវ ដើម្បីទៅកើត ជាមួយនឹងព្រហ្ម សូមព្រះគោតមដ៏ចម្រើន ស្រោចស្រង់ព្រាហ្មណ៍និងពពួកសត្វផងចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ បើដូច្នោះចូរអ្នកប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសំដែងប្រាប់ ។ វាសេដ្ឋមាណព បានទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច ឥធ វាសេដ្ឋ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលំ ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឯវំ ខោ វាសេដ្ឋ ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ តស្សិមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុ-បស្សតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជា-យតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកា-យោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វា-វន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សេយ្យថាបិ វាសេដ្ឋ ពលវា សំខធមោ អប្បកសិរេនេវ ចតុទ្ទិសា វិញ្ញាបេយ្យ

ព្រះមានព្រះភាគត្រាស់ថា ម្នាលវាសេដ្ឋៈ ព្រះតថាគត កើតឡើងក្នុងលោកនេះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។ បេ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលវាសេដ្ឋៈ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។ បេ ។ កាលភិក្ខុនោះបានពិចារណាឃើញច្បាស់នូវនីវរណៈ ៥ នេះក្នុងខ្លួន ដែលខ្លួនលះបង់ហើយ បាមោជ្ជៈ គឺសេចក្តីត្រេកអរយ៉ាងល្មម ក៏កើតឡើង កាលបើបាមោជ្ជៈ កើតឡើងហើយ បីតិក៏កើតឡើង កាលចិត្តប្រកបដោយបីតិ កើតឡើងហើយ កាយក៏រមែងស្ងប់រម្ងាប់ កាលបើមានកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលបានសេចក្តីសុខហើយ ក៏រមែងតាំងនៅមាំ ។ ភិក្ខុនោះមានចិត្តប្រកបដោយមេត្តា រមែងផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ទាំងទិសខាងលើ ទិសខាងក្រោមនិងទិសទទឹងបានដូចគ្នា មានចិត្តប្រកបដោយមេត្តា ដ៏ទូលាយធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងពួងគ្រប់ទិសគ្រប់ដំបន់ ។ ម្នាលវាសេដ្ឋៈ មនុស្សមានកម្លាំង ផ្លុំស័ង្ខអាចញុំាងបុគ្គលឲ្យដឹងបានគ្រប់ទិសទាំង ៤ ដោយមិនលំបាកយ៉ាងណា

តេវិជ្ជសុត្តេ អប្បមញ្ញាចេតោវិមុត្តិកថា

ឯវមេវ ខោ វាសេដ្ឋ ឯវំ ភាវិតាយ មេត្តាយ ចេតោ-វិមុត្តិយា យំ បមាណកតំ កម្មំ ន តំ តត្រាវសិ-ស្សតិ ន តំ តត្រាវតិដ្ឋតិ ។ អយំបិ ខោ វាសេដ្ឋ ព្រហ្មានំ សហព្យតាយ មគ្គោ ។

[១៨៦] បុន ចបរំ វាសេដ្ឋ ភិក្ខុ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ។ បេ ។ ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្ត-តាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យា-បជ្ជេន ផរិត្វា វិហរតិ ។ សេយ្យថាបិ វាសេដ្ឋ ពល-វា សំខធមោ អប្បកសិរេនេវ ចតុទ្ទិសា វិញ្ញាបេយ្យ

ម្នាលវាសេដ្ឋៈ កម្មជាកាមាវចរណា ក្នុងមេត្តាចេតោវិមុត្តិ ដែលបុគ្គលបានចម្រើនយ៉ាងនេះ កម្មជាកាមាវចរនោះ មិនបានកៀចគ្រាញនៅក្នុងរូបាវចរនិងអរូបាវចរនោះ គឺកម្មជាកាមាវចរនោះ មិនបានឋិតនៅក្នុងរូបាវចរនិងអរូបាវចរនោះឡើយ ក៏យ៉ាងនោះឯង ។ ម្នាលវាសេដ្ឋៈ នេះឯងហៅថា ផ្លូវ ដើម្បីទៅកើតជាមួយនឹងព្រហ្ម ។

[១៨៦] ម្នាលវាសេដ្ឋៈ សេចក្តីតទៅទៀតថា ភិក្ខុមានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ទាំងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងបានដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ទូលាយធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ គ្រប់ទិសគ្រប់ដំបន់ ។ ម្នាលវាសេដ្ឋៈ មនុស្សដែលមានកម្លាំងផ្លុំស័ង្ខ អាចញ៉ាំងបុគ្គលឲ្យដឹងគ្រប់

ឯវមេវ ខោ វាសេដ្ឋ ឯវំ ភាវិតាយ ឧបេក្ខាយ ចេ-តោវិមុត្តិយា យំ បមាណកតំ កម្មំ ន តំ តត្រាវ-សិស្សតិ ន តំ តត្រាវតិដ្ឋតិ ។ អយំ[១] ខោ វាសេដ្ឋ ព្រហ្មានំ សហាព្យតាយ មគ្គោ ។ តំ កឹ មញ្ញសិ វាសេដ្ឋ ឯវំវិហារី ភិក្ខុ សបរិគ្គហោ វា អបរិគ្គហោ វាតិ ។ អបរិគ្គហោ ភោ គោតម ។ សវេរចិត្តោ វា អវេរចិត្តោ វាតិ ។ អវេរចិត្តោ ភោ គោតម ។ សព្យាបជ្ឈចិត្តោ វា អព្យាបជ្ឈចិត្តោ វាតិ ។ អព្យាបជ្ឈចិត្តោ ភោ គោតម ។ សំកិលិដ្ឋចិត្តោ វា អសំកិលិដ្ឋចិត្តោ វាតិ ។ អសំកិលិដ្ឋចិត្តោ ភោ គោតម ។ វសវត្តិ វា អវសវត្តិ វាតិ ។

១ ឱ. ម. អយម្បិ ខោ ។

ទិសទាំង ៤ បាន ដោយមិនលំបាក យ៉ាងណា ម្នាលវាសេដ្ឋៈ កម្មជាកាមាវចរណា ក្នុងឧបេក្ខាចេតោវិមុត្តិ ដែលបុគ្គលបានចម្រើនយ៉ាងនេះ កម្មជាកាមាវចរនោះ មិនបានកៀចក្រាញនៅ ក្នុងរូបាវចរនិអរូបាវចរនោះ គឺកម្មជាកាមាវចរនោះ មិនបានឋិតនៅក្នុងរូបាវចរនិងអរូបាវចរនោះឡើយ ក៏យ៉ាងនោះឯង ។ ម្នាលវាសេដ្ឋៈ នេះឯងជាផ្លូវដើម្បីកើតជាមួយនឹងពួកព្រហ្ម ។ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច ភិក្ខុមានមេត្តាព្រហ្មវិហារយ៉ាងនេះ ជាអ្នកមានស្រ្តីជាគ្រឿងជាប់ចំពាក់ ឬមិនមានស្រ្តីជាគ្រឿងជាប់ចំពាក់ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានស្រ្តីជាគ្រឿងជាប់ចំពាក់ទេ ។ ភិក្ខុនោះមានចិត្តចងពៀរ ឬមិនមានចិត្តចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានចិត្តចងពៀរទេ ។ ភិក្ខុនោះមានចិត្តប្រកបដោយព្យាបាទ ឬមិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានចិត្តប្រកបដោយព្យាបាទទេ ។ ភិក្ខុនោះមានចិត្តសៅហ្មង ឬមានចិត្តមិនសៅហ្មងទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានចិត្តសៅហ្មងទេ ។ ភិក្ខុនោះប្រព្រឹត្តទៅតាមអំណាចចិត្តបាន ឬមិនប្រព្រឹត្តទៅ តាមអំណាចចិត្តបានទេ ។

## ២៧៧

តេវិជ្ជសុត្តេ អប្បមញ្ញាចេតោវិមុត្តិកថា

វេរវត្តិ ភោ គោតម ។ ឥតិ កិរ វាសេដ្ឋ អបរិគ្គហោ ភិក្ខុ អបរិគ្គហោ ព្រហ្មា អបិ នុ ខោ អបរិគ្គហស្ស ភិក្ខុនោ អបរិគ្គហេន ព្រហ្មុនា សទ្ធឹ សំសន្ទតិ សមេតីតិ ។ ឯវំ ភោ គោតម ។ សាធុ វាសេដ្ឋ សោ ច[១] វាសេដ្ឋ អបរិគ្គហោ ភិក្ខុ កាយស្ស ភេទា បរម្មរណា អបរិគ្គហស្ស ព្រហ្មុនោ សហព្យូបគោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ ។ ឥតិ កិរ វាសេដ្ឋ អវេរ-ចិត្តោ ភិក្ខុ អវេរចិត្តោ ព្រហ្មា ។ បេ ។ អព្យាបជ្ឈចិត្តោ ភិក្ខុ អព្យាបជ្ឈចិត្តោ ព្រហ្មា ។ អសំកិលិដ្ឋចិត្តោ ភិក្ខុ អសំកិលិដ្ឋចិត្តោ ព្រហ្មា ។ វសវត្តិ ភិក្ខុ វសវត្តិ ព្រហ្មា អបិ នុ ខោ វសវត្តិស្ស ភិក្ខុនោ វសវត្តិនា ព្រហ្មុនា សទ្ធឹ សំសន្ទតិ សមេតីតិ ។ ឯវំ ភោ គោតម ។

១ ឱ. ម. វេត ។

បពិត្រព្រះគោតមដ៏ចម្រើន ប្រព្រឹត្តទៅតាមអំណាចចិត្តបាន ។ ម្នាលវាសេដ្ឋៈ អើ បើថា ភិក្ខុជាអ្នកមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ ព្រហ្មក៏ជាអ្នកមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ហើយ តើប្រៀបធៀបភិក្ខុដែលមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់នឹងព្រហ្ម ដែលមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់សមគ្នាដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបធៀបសមគ្នាហើយ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ភិក្ខុដែលមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ នឹងទៅកើតជាមួយនឹងព្រហ្មដែលមិនមានស្ត្រីជាគ្រឿងជាប់ចំពាក់ ហេតុដូច្នេះនេះ តែងមានជាប្រាកដ ។ ម្នាលវាសេដ្ឋៈ បានឮដូច្នេះថា ភិក្ខុមិនមានចិត្តចងពៀរ ព្រហ្មក៏មិនមានចិត្តចងពៀរដែរ ។ បេ ។ ភិក្ខុមិនមានចិត្តប្រកបដោយព្យាបាទ ព្រហ្មក៏មិនមានចិត្តប្រកបដោយព្យាបាទដែរ ។ ភិក្ខុមានចិត្តមិនសៅហ្មង ព្រហ្មក៏មានចិត្តមិនសៅហ្មងដែរ ។ ភិក្ខុប្រព្រឹត្តទៅតាមអំណាចចិត្តបាន ព្រហ្មក៏ប្រព្រឹត្តទៅតាមអំណាចចិត្តបានដែរ ប្រៀបធៀបភិក្ខុដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន នឹងព្រហ្មដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន តើសមដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបធៀបសមគ្នាហើយ ។

សាធុ វាសេដ្ឋ សោ ច វាសេដ្ឋ វសវត្តិ ភិក្ខុ កាយស្ស ភេទា បរម្មរណា វសវត្តិស្ស ព្រហ្មុនោ សហព្យូបគោ ភវិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

[១៨៧] ឯវំ វុត្តេ វាសេដ្ឋភារទ្វាជា មាណវា ភគ-វន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ខោ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ

ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ភិក្ខុប្រព្រឹត្តទៅតាមអំណាចចិត្តបាននោះ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ នឹងទៅកើតជាមួយនឹងព្រហ្ម ដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន ហេតុដូច្នេះនេះ តែងមានជាប្រាកដ ។

[១៨៧] លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណពនិងភារទ្វាជមាណព ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ពីរោះណាស់ ធម៌ដែលព្រះអង្គទ្រង់សំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) បពិត្រព្រះគោតមដ៏ចម្រើន គួរនោដូចជាមនុស្ស ចាប់របស់ដែលផ្កាប់ចុះឲ្យផ្ងារឡើងបាន ពុំនោះដូចជាមនុស្ស បើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្ស ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬក៏ដូចជាមនុស្ស កាន់ប្រទីប ទ្រោលបំភ្លឺ ក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុ មើលឃើញ នូវរូបទាំងឡាយបាន

២៧៩

តេវិជ្ជសុត្តេ ឧបាសកត្តទេសនា តស្សុទ្ទានំ

ឯតេ មយំ ភគវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតេតិ ។

តេវិជ្ជសុត្តំ តេរសមំ និដ្ឋិតំ ។

តស្សុទ្ទានំ

ព្រហ្មា សាមញ្ញអម្ពដ្ឋ-

សោណកូដមហាលិ ជាលិនី

សីហបោដ្ឋបាទសុភោ កេវដ្ដោ

លោហិច្ចតេវិជ្ជា តេរសាតិ ។

សីលក្ខន្ធវគ្គោ និដ្ឋិតោ ។

យើងទាំងឡាយនោះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងជាទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយ ថាជាឧបាសក ដល់សរណគមន៍ ស្មើដោយជីវិត ។

ចប់ តេវិជ្ជសូត្រ ទី ១៣ ។

បញ្ជីនៃសីលក្ខន្ធវគ្គនោះ មានសូត្រ ១៣ គឺ

ព្រហ្មជាលសូត្រ ១ សាមញ្ញផលសូត្រ ១ អម្ពដ្ឋសូត្រ ១

សោណទណ្ឌសូត្រ ១ កូដទន្តសូត្រ ១ មហាលិសូត្រ ១

ជាលិយសូត្រ ១ មហាសីហនាទសូត្រ ១ បោដ្ឋបាទសូត្រ ១

សុភសូត្រ ១ កេវដ្តសូត្រ ១ លោហិច្ចសូត្រ ១ តេវិជ្ជសូត្រ ១ ។

ចប់ សីលក្ខន្ធវគ្គ ។

មាតិកាបត្តានិ

# សុត្តន្តបិដកេ ទីឃនិកាយស្ស

# ទុតិយោ ភាគោ

# សីលក្ខន្ធវគ្គោ

## កូដទន្តសុត្តំ បញ្ចមំ


| | | |
|---|---|---|
| | | អង្កេ |
| កូដទន្តសុត្តេ | កូដទន្តព្រាហ្មណវត្ថុ | ៣ |
| | កូដទន្តព្រាហ្មណគុណកថា | ៧ |
| | ពុទ្ធគុណកថា | ១១ |
| | តិវិធា យញ្ញសម្បទា សោឡសបរិក្ខារា | ១៧ |
| | មហាវិជិតរាជកថា | ១៩ |
| | មហាវិជិតរាជមហាយញ្ញកថា | ២១ |
| | កូដទន្តព្រាហ្មណបរិវិតក្កោ | ៤៣ |
| | ពុទ្ធយញ្ញកថា និច្ចទានំ | ៤៥ |
| | សរណាគមនំ | ៤៧ |
| | តថាគតស្ស ឧប្បាទោ | ៤៩ |

# សន្លឹកចង្អុលប្រាប់មាតិកា

## សុត្តន្តបិដក ទីឃនិកាយ

## ទុតិយភាគ

## សីលក្ខន្ធវគ្គ

### *កូដទន្តសូត្រ ទី ៥*

លេខទំព័រ


| | | |
|---|---|---|
| កូដទន្តសូត្រ | រឿងកូដទន្តព្រាហ្មណ៍ ........................................................ | ៣ |
| | ពោលអំពីគុណ នៃកូដទន្តព្រាហ្មណ៍........................................ | ៧ |
| | ពុទ្ធគុណកថា.......................................................................... | ១១ |
| | យញ្ញសម្បទា ៣ ប្រការ មានបរិក្ខារ ១៦.................................. | ១៧ |
| | ការពោលអំពីព្រះបាទមហាវិជិតរាជ ....................................... | ១៩ |
| | ការពោលអំពីមហាយ័ញ្ញ របស់ព្រះបាទមហាវិជិតរាជ ............. | ២១ |
| | សេចក្តីត្រិះរិះ របស់កូដទន្តព្រាហ្មណ៍........................................ | ៤៣ |
| | ពុទ្ធយញ្ញកថា និច្ចភត្តទាន...................................................... | ៤៥ |
| | សរណាគមន៍ ..................................................... | ៤៧ |
| | ការកើតឡើងនៃព្រះតថាគត............................... | ៤៩ |

# មាតិកាបត្តានិ


អង្គេ

| | | |
|---|---|---|
| កូដទន្តសុត្តេ | កូដទន្តព្រាហ្មណស្ស ឧបាសកត្តទេសនា................................ | ៥១ |
| | យញ្ញវាតុបសង្កមនំ................................ | ៥៣ |


## មហាលិសុត្តំ ឆដ្ឋំ


| | | |
|---|---|---|
| មហាលិសុត្តេ | សុត្តនិទានំ.................................................................... | ៥៧ |
| | ឯកំសភាវិតសមាធិ ទិព្វរូបទស្សនំ ....................................... | ៦១ |
| | ទិព្វសទ្ទស្សវនំ....................................... | ៦៣ |
| | ឧភយំសភាវិតសមាធិ ទិព្វរូបទស្សនាទិ ................................ | ៦៥ |
| | សមាធិភាវនានំ សច្ឆិកិរិយាហេតុចរណំ................................... | ៦៧ |
| | ចេតោវិមុត្តិបញ្ញាវិមុត្តិសច្ឆិករណាទិ ......................................... | ៦៩ |
| | ពុទ្ធគុណកថា សីលសម្បទា ឈានំ......................................... | ៧១ |
| | ភគវតោ ភាសិតំ អភិនន្ទនំ...................................................... | ៧៣ |

# សង្ខេបចង្កូលប្រាប់មាតិកា


| | | លេខទំព័រ |
|---|---|---|
| កូដទន្តសូត្រ | ការសំដែងខ្លួនជាឧបាសកនៃកូដទន្តព្រាហ្មណ៍......................... | ៥១ |
| | ការយាងចូលទៅកាន់រោងយញ្ញពិធី របស់កូដទន្តព្រាហ្មណ៍.... | ៥៣ |

## មហាលិសូត្រ ទី ៦

| | | |
|---|---|---|
| មហាលិសូត្រ | សុត្តនិទាន........................................................................ | ៥៧ |
| | សមាធិដែលភិក្ខុចម្រើនដោយចំណែកមួយ ការឃើញនូវរូបទិព្វ. | ៦១ |
| | សមាធិដែលភិក្ខុចម្រើនដោយចំណែកមួយ ការស្តាប់ឮ សំឡេងទិព្វ ....................................................................... | ៦៣ |
| | សមាធិដែលភិក្ខុចម្រើនទាំងពីរចំណែក ការឃើញរូបទិព្វជាដើម. | ៦៥ |
| | ការប្រព្រឹត្តដែលជាហេតុធ្វើឲ្យជាក់ច្បាស់នូវសមាធិភាវនា......... | ៦៧ |
| | ការធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិជាដើម ........... | ៦៩ |
| | ពុទ្ធគុណកថា សីលសម្បទា ឈាន ....................................... | ៧១ |
| | ការត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ..................... | ៧៣ |

# មាតិកាបត្តានិ

អង្កេ

## ជាលិយសុត្តំ សត្តមំ

ជាលិយសុត្តេ សីលសម្បទា ឈានំ........................................................ ៧៥
ភគវតោ ភាសិតំ អភិនន្ទនំ................................................... ៧៧

## មហាសីហនាទសុត្តំ អដ្ឋមំ

មហាសីហនាទសុត្តេ សព្វន្តបគរហោទិកំ...................................................... ៧៩
អកុសលប្បហានកថា........................................................... ៨១
កុសលសមាទានកថា ........................................................... ៨៣
អចេលកស្សបស្ស តបោបក្កមកថា ......................................... ៨៧
តិវិធា សម្បទា.......................................................................... ៩១
សាមញ្ញព្រហ្មញ្ញកថា............................................................. ៩៣
មេត្តចិត្តភាវនាកថា................................................................. ៩៧
តិវិធា សម្បទា.......................................................................... ១០១
បរិសាសុ សីហនាទោ............................................................ ១០៣
តិត្ថិយបរិវាសោ អចេលកស្សបស្ស
បព្វជ្ជូបសម្បទា................................................ ១០៧

# សង្ខេបចង្អុលប្រាប់មាតិកា

## ជាលិយសូត្រ ទី ៧

លេខទំព័រ


ជាលិយសូត្រ សីលសម្បទា ឈាន .......... ៧៥

ការត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ .......... ៧៧


## *មហាសីហនាទសូត្រទី ៨*


មហាសីហនាទសូត្រ ការតិះដៀលតបៈទាំងពួងជាដើម .......... ៧៩

ពោលអំពីការលះអកុសលធម៌ .......... ៨១

ពោលអំពីការសមាទានកុសលធម៌ .......... ៨៣

ពោលអំពីផ្តើមនូវតបៈរបស់អចេលកស្សប .......... ៨៧

សម្បទា ៣ ប្រការ .......... ៩១

ពោលអំពីសាមញ្ញគុណ និងព្រហ្មញ្ញគុណ .......... ៩៣

ពោលអំពីការចម្រើនមេត្តាចិត្ត .......... ៩៧

សម្បទា ៣ យ៉ាង .......... ១០១

សីហនាទក្នុងបរិសទ្យទាំងឡាយ .......... ១០៣

តិត្ថិយបរិវាស និងបព្វជ្ជាឧបសម្បទានៃអចេលកស្សប .......... ១០៧

# មាតិកាបត្តានិ

អង្កេ

## ពោដ្ឋបាទសុត្តំ នវមំ


| | | |
|---|---|---|
| បោដ្ឋបាទសុត្តេ | ភគវតោ បោដ្ឋបាទុបសង្កមនំ | ១១១ |
| | អភិសញ្ញានិរោធកថា | ១១៣ |
| | តតិយជ្ឈានំ ចតុត្ថជ្ឈានំ | ១១៧ |
| | វិញ្ញាណញ្ចាយតនជ្ឈានាទីនិ | ១១៩ |
| | អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ | ១២១ |
| | សញ្ញាញាណកថា | ១២៣ |
| | សញ្ញាអត្តកថា | ១២៥ |
| | អព្យាកតប្បញ្ហា | ១២៧ |
| | ព្យាកតប្បញ្ហា អព្យាកតប្បញ្ហា | ១២៩ |
| | ចិត្តហត្ថិសារីបុត្តបោដ្ឋបាទបរិព្វាជកា | ១៣១ |
| | ឯកំសិកាបិ អនេកំសិកាបិ ធម្មា | ១៣៣ |
| | ឯកំសិកោ ធម្មោ | ១៣៥ |
| | សមណព្រាហ្មណានំ ទិដ្ឋិកថា | ១៣៧ |

# សង្ខឹកចង្អុលប្រាប់មាតិកា

## បោដ្ឋបាទសូត្រ ទី ៩

លេខទំព័រ


| | | |
|---|---|---|
| បោដ្ឋបាទសូត្រ | ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរចូលទៅរកបោដ្ឋបាទបរិព្វាជក | ១១១ |
| | ការពោលអំពីអភិសញ្ញានិរោធ........................................... | ១១៣ |
| | តតិយជ្ឈាន និងចតុត្ថជ្ឈាន ............................................ | ១១៧ |
| | អរូបជ្ឈានមានវិញ្ញាណញ្ចាយតនជ្ឈានជាដើម......................... | ១១៩ |
| | អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ............................. | ១២១ |
| | ការពោលអំពីសញ្ញានិងញាណ........................................... | ១២៣ |
| | ការពោលអំពីសញ្ញានិងខ្លួន ............................................... | ១២៥ |
| | ប្រស្នាដែលតថាគតមិនបានព្យាករ ..................................... | ១២៧ |
| | ប្រស្នាដែលព្រះមានព្រះភាគទ្រង់ព្យាករនិងប្រស្នាដែលមិនទ្រង់ព្យាករ............................................................ | ១២៩ |
| | ចិត្តហត្ថិសារីបុត្តនិងបោដ្ឋបាទបរិព្វាជក ................................. | ១៣១ |
| | ធម៌ប្រព្រឹត្តទៅដោយចំណែកមួយក៏មាន មិនមែនដោយចំណែក-មួយក៏មាន ................................................... | ១៣៣ |
| | ធម៌ដែលប្រព្រឹត្តទៅដោយចំណែកមួយ.................................. | ១៣៥ |
| | ការពោលអំពីទិដ្ឋិរបស់សមណព្រាហ្មណ៍................................ | ១៣៧ |

# មាតិកាបត្តានិ


| | | អង្កេ |
|---|---|---|
| បោដ្ឋបាទសុត្តេ | ឱឡារិកោ អត្តប្បដិលាភោ.................................................. | ១៩៥ |
| | អរូបោ អត្តប្បដិលាភោ......................................................... | ១៩៧ |
| | ឱឡារិកាទិកោ អត្តប្បដិលាភោ............................................. | ១៥១ |
| | ចិត្តហត្ថិសារីបុត្តស្ស ព្យាករណំ............................................. | ១៥៣ |
| | ឱឡារិកាទិកោ អត្តប្បដិលាភោ............................................. | ១៥៧ |
| | អាយស្មា ហត្ថិសារីបុត្តោ អរហត្តប្បត្តោ................................ | ១៥៩ |


## សុភសុត្តំ ឧសមំ


| | | |
|---|---|---|
| សុភសុត្តេ | មាណវកស្ស អានន្ទត្ថេរស្ស សន្តិកុបសង្កមនំ | ១៦១ |
| | អានន្ទត្ថេរស្ស សុភមាណវនិវេសនុបសង្កមនំ | ១៦៣ |
| | តថាគតសទ្ធាបដិលាភោ......................................................... | ១៦៥ |
| | តិរច្ឆានវិជ្ជាយ មិច្ឆាជីវោ...................................................... | ១៦៧ |
| | សីលសម្បទា ....................................................................... | ១៦៩ |
| | សតិសម្បជញ្ញំ ..................................................................... | ១៧១ |
| | បញ្ចនីវរណេហិ ចិត្តំ បរិសោធនំ............................................ | ១៧៣ |

# សង្ខឹកចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | |
|---|---|---|
| បោដ្ឋបាទសូត្រ | ការបាននូវឱឡារិកអត្តភាព | ១៤៥ |
| | ការបាននូវអរូបអត្តភាព | ១៤៧ |
| | ការបាននូវអត្តភាពមានឱឡារិកអត្តភាពជាដើម | ១៥១ |
| | សេចក្តីដោះស្រាយរបស់ចិត្តហត្ថិសារីបុត្ត | ១៥៣ |
| | ការបាននូវអត្តភាពមានឱឡារិកអត្តភាពជាដើម | ១៥៧ |
| | ព្រះចិត្តហត្ថិសារីបុត្តមានអាយុបានសម្រេចព្រះអរហត្ត | ១៥៩ |

## សុភសូត្រ ទី ១០

| | | |
|---|---|---|
| សុភសូត្រ | មាណពចូលទៅកាន់សំណាក់នៃព្រះអានន្ទត្ថេរ | ១៦១ |
| | ព្រះអានន្ទត្ថេរចូលទៅកាន់លំនៅរបស់សុភមាណព | ១៦៣ |
| | ការបាននូវសទ្ធាក្នុងព្រះតថាគត | ១៦៥ |
| | ការចិញ្ចឹមជីវិតខុស ព្រោះតិរច្ឆានវិជ្ជា | ១៦៧ |
| | សីលសម្បទា | ១៦៩ |
| | សតិសម្បជញ្ញៈ | ១៧១ |
| | ការជម្រះចិត្តឲ្យស្អាតចាកនីវរណធម៌ទាំង ៥ | ១៧៣ |

# មាតិកាបត្តានិ


| | | អង្កេ |
|---|---|---|
| សុភសុត្តេ | បញ្ចនីវរណូបមា.................................................................. | ១៧៥ |
| | ឈានកថា ឈានូបមា.......................................................... | ១៧៧ |
| | សុភមាណវស្ស អានន្ទត្ថេរប្បសំសោ..................................... | ១៨៣ |
| | បញ្ញាកថា បញ្ញូបមា............................................................. | ១៨៥ |
| | ទិព្វសោតធាតុ................................................. | ១៨៩ |
| | ចេតោបរិយញ្ញាណំ........................................... | ១៩១ |
| | បុព្វេនិវាសានុស្សតិញ្ញាណំ...................................................... | ១៩៣ |
| | ចុតូបបាតញ្ញាណំ.................................................................... | ១៩៥ |
| | អាសវក្ខយញ្ញាណំ................................................................. | ១៩៧ |
| | សុភស្ស អានន្ទត្ថេរប្បសំសោ ឧបាសកត្តទេសនា.................. | ១៩៩ |


## កេវដ្ដសុត្តំ ឯកាទសមំ


| | | |
|---|---|---|
| កេវដ្ដសុត្តេ | តីណិ បាដិហារិយានិ ឥទ្ធិវិធិកថា............................................ | ២០៣ |
| | អាទេសនាបាដិហារិយកថា .................................................. | ២០៥ |
| | អនុសាសនីបាដិហារិយកថា.................................................. | ២០៧ |

# សង្ខេបសេចក្ដីក្នុងច្រាប់មាតិកា


| | | លេខទំព័រ |
|---|---|---|
| សុភសូត្រ | សេចក្ដីឧបមានៃនីវរណធម៌ទាំង ៥...................................... | ១៧៥ |
| | ការពោលអំពីឈាន សេចក្ដីឧបមានៃឈាន.......................... | ១៧៧ |
| | ការពោលសរសើរព្រះអានន្ទត្ថេរ នៃសុភមាណព.................... | ១៨៣ |
| | ការពោលអំពីបញ្ញា សេចក្ដីឧបមានៃបញ្ញា............................ | ១៨៥ |
| | សោតធាតុជាទិព្វ............................................ | ១៨៩ |
| | ចេតោបរិយញ្ញាណ.......................................... | ១៩១ |
| | បុព្វេនិវាសានុស្សតិញ្ញាណ.................................................... | ១៩៣ |
| | ចុតូបបាតញ្ញាណ ................................................................. | ១៩៥ |
| | អាសវក្ខយញ្ញាណ ............................................................... | ១៩៧ |
| | សុភមាណពសរសើរព្រះអានន្ទត្ថេរ ការសំដែងខ្លួនជាឧបាសក... | ១៩៩ |


## *កេវដ្តសូត្រ ទី ១០*


| | | |
|---|---|---|
| កេវដ្តសូត្រ | បាដិហារ្យ ៣ យ៉ាង ការពោលអំពីឥទ្ធិវិធិ................................ | ២០៣ |
| | ការពោលអំពីអាទេសនាបាដិហារ្យ ....................................... | ២០៥ |
| | ការពោលអំពីអនុសាសនីបាដិហារ្យ....................................... | ២០៧ |

# មាតិកាបត្តានិ


អង្កេ

| | | |
|---|---|---|
| កេវដ្ដសុត្តេ | មហាសុភូតបរិយេសកភិក្ខុវត្ថុ................................................ | ២០៩ |
| | មហាភូតប្បញ្ហាវេយ្យាករណំ ................................................ | ២១៩ |

## លោហិច្ចសុត្តំ ទ្វាទសមំ

| | | |
|---|---|---|
| លោហិច្ចសុត្តេ | សុត្តនិទានំ អប្បាពាធាទិបុច្ឆនំ ................................................ | ២២៣ |
| | ភគវតោ កាលស្ស អារោចនំ ................................................ | ២២៥ |
| | លោហិច្ចអនុយោគកថា................................................ | ២២៧ |
| | លោហិច្ចស្ស មិច្ឆាទិដ្ឋិវិវេចនកថា................................................ | ២៣១ |
| | តយោ ចោទនារហា សត្ថារោ................................................ | ២៣៥ |
| | ទុតិយោ ចោទនារហោ សត្ថា................................................ | ២៣៧ |
| | តតិយោ ចោទនារហោ សត្ថា................................................ | ២៣៩ |
| | អចោទនារហោ សត្ថា លោហិច្ចស្ស ឧបាសកត្ត-ទេសនា................................................ | ២៤១ |

## តេវិជ្ជសុត្តំ តេរសមំ

| | | |
|---|---|---|
| តេវិជ្ជសុត្តេ | វាសេដ្ឋភារទ្វាជានំ មន្តនំ ពុទ្ធគុណកថា................................................ | ២៤៥ |
| | វិគ្គាហិកកថា................................................ | ២៤៧ |

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

តេវជ្ជសូត្រ	រឿងភិក្ខុអ្នកស្វែងរកមហាភូតរូប........................................... ២០៩

សេចក្តីព្យាករប្រស្នាអំពីមហាភូតរូប....................................... ២១៩

*លោហិច្ចសូត្រទី ១២*

លោហិច្ចសូត្រ	សុត្តនិទាន ការទូលសួរអំពីមិនមានអាពាធជាដើម (ចំពោះព្រះមានព្រះភាគ) ......................................... ២២៣

ការក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគ................. ២២៥

ពោលអំពីព្រះមានព្រះភាគ ទ្រង់សាកសួរលោហិច្ចព្រាហ្មណ៍ ២២៧

ពោលអំពីការទ្រង់ដោះទិដ្ឋិខុស របស់លោហិច្ចព្រាហ្មណ៍.......... ២៣១

គ្រូដែលគួរដល់ការចោទប្រកាន់មាន ៣ ពួក............................ ២៣៥

គ្រូទី ២ ដែលគួរដល់ការចោទប្រកាន់..................................... ២៣៧

គ្រូទី ៣ ដែលគួរដល់ការចោទប្រកាន់..................................... ២៣៩

សាស្តាមិនគួរដល់ការចោទប្រកាន់ ការសំដែងខ្លួនជាឧបាសក នៃលោហិច្ចព្រាហ្មណ៍................................ ២៤១

*តេវិជ្ជសូត្រទី ១០*

តេវិជ្ជសូត្រ	ការប្រឹក្សាគ្នានៃវាសេដ្ឋមាណពនិងភារទ្វាជមាណព ពុទ្ធគុណកថា.................................................................. ២៤៥

ពោលអំពីវាសេដ្ឋមាណពនិងភារទ្វាជមាណព មានសេចក្តីប្រកាន់ខុសគ្នា.................................................... ២៤៧

# មាតិកាបត្តាជិ


| | | អង្កេ |
|---|---|---|
| តេវិជ្ជសុត្តេ | ភគវតោ វាសេដ្ឋានុយោគកថា................................................ | ២៤៩ |
| | មគ្គាមគ្គកថា បុព្វកឥសយោ................................................... | ២៥៧ |
| | និស្សេណីឧបមា...................................................................... | ២៥៩ |
| | បុព្វកឥសយោ......................................................................... | ២៦១ |
| | អចិរវតីនទី ឧបមា.................................................................. | ២៦៣ |
| | បញ្ច កាមគុណា....................................................................... | ២៦៥ |
| | បញ្ច នីវរណានិ........................................................................ | ២៦៧ |
| | វាសេដ្ឋានុយោគោ.................................................................. | ២៦៩ |
| | ព្រហ្មលោកគាមិនី បដិបទា...................................................... | ២៧១ |
| | អប្បមញ្ញាចេតោវិមុត្តិកថា........................................................... | ២៧៥ |
| | ឧបាសកត្តទេសនា តស្សុទ្ទានំ..................................................... | ២៧៩ |

# សង្ខឹកាចង្អុលច្រាប់មាតិកា

លេខទំព័រ

តេវិជ្ជសូត្រ ពោលអំពីព្រះមានព្រះភាគទ្រង់សាកសួរវាសេដ្ឋមាណព.......... ២៥៩
មគ្គាមគ្គកថា ពួកឫសីជាបុព្វបុរស ......................................... ២៥៧
សេចក្តីឧបមាដោយជណ្តើរ............................... ២៥៩
ពួកឫសីជាបុព្វបុរស.......................................... ២៦១
សេចក្តីឧបមា ដោយស្ទឹងអចិរវតី......................... ២៦៣
កាមគុណទាំង ៥.............................................. ២៦៥
នីវរណធម៌ ៥ ប្រការ........................................... ២៦៧
ការទ្រង់សាកសួរវាសេដ្ឋមាណព......................... ២៦៩
បដិបទាជាគ្រឿងញ៉ាំងសត្វឲ្យទៅកាន់ព្រហ្មលោក..................... ២៧១
ការពោលអំពីចេតោវិមុត្តិ មានកំណត់ប្រមាណមិនបាន............. ២៧៥
ការសំដែងខ្លួនជាឧបាសក និងបញ្ជីរឿងនៃសីលក្ខន្ធវគ្គនោះ....... ២៧៩